INSTITUT
DE CIVILISATION
INDIENNE
N° 2627

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ៧

ខែ ៧, ៨, ៩, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER
933

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៨

គ. ស. ១៩៣៥

1935

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME-ORIENT

# បញ្ជីរឿង


១ — បុណ្យសម្ពោធផ្ទាំងព្រះពុទ្ធរូបសិលា នៅទីក្រុងនគរធំ ។ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ រៀបរៀង . . . . . . ៩

២ — រឿងស្ដេចឧទយន ដកយកពីសេចក្ដីល្បង អំពីគុណាពវ្យនឹងព្រឹហត្កថា របស់លោក ហ្វេលិក្ស៍ឡាកូត, ព្រម្ពារ ជុំ-ម៉ៅ ប្រែពីភាសាបារាំងមកជាភាសាខ្មែរ . . . . . . . . . . . . . . . . . . ២៩

៣ — សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ រៀបរៀង (ត) . . . . . . . . . . . . . . . . . . . ៤៧

៤ — រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយ :

១ — អំពីក្បួនដែលទេវតាសែកសោយ . . . . . . . . . . . . ៧១

២ — អំពីប៉ុស្តកំពង់ធំ . . . . . . . . . . . . . . . . . ៨១

៣ — អំពីខ្មោចចូលដិប . . . . . . . . . . . . . . . . . ៨៣


## រូបថត


ព្រះរូបព្រះករុណា នឹងស្ដេចលាវ . . . . . . . . . . . . . . . . ៧

# TABLE DES MATIÈRES

I Inauguration à Ang-Kor de la statue du Bouddha du Bayon........................................ 9

II. La légende d'Udayana extraite de l'Essai sur Gunadhya et la Brhatkatha par Félix Lacôte, traduit du Français en Cambodgien par Kromokar Choum-Mau........... 29

III. Sasanapravatti ou l'Histoire des religions, par Préas Maha Pitou Krasém pandit à la Bibliothèque Royale (suite). 47

IV. Contes populaires Cambodgiens inédits:

I. L'influence des différents dieux qui interviennent pour protéger la même étoile sous laquelle ont lieu les naissances........................................ 71

II. Le poste de Kompong-Thom........................ 81

III. Le diable dans la bouteille........................ 83

## ILLUSTRATION.

Sa Majesté et les Princes Laostiens................. 7

# បុណ្យសម្ពោធឆ្លងព្រះពុទ្ធរូបសិលា

## នៅទីក្រុងនគរធំ

នៅថ្ងៃពេញបូណ៌មី ខែពិសាខ ឆ្នាំកុរសប្តស័ក ព.ស. ២៤៧៨

(១៧ ម៉ែ ១៩៣៥)

ព្រះមហាពិទូរ ក្រសេម រៀបរៀង



ព្រះបរមរូបព្រះករុណា នឹងព្រះរូបព្រះអង្គម្ចាស់សាវាង
នឹងព្រះអណុជពីរអង្គ

## បុណ្យសម្ពោធព្រះពុទ្ធរូបសិលា នៅទីក្រុងនគរធំ

ពីថ្ងៃមុនមក រាជការកុងសេវ៉ាទ័រ ដែលជាអ្នកត្រួតត្រាថែរក្សាប្រាសាទបូរាណនៅទីក្រុងនគរធំ បានជីកគាស់កកាយនៅទីត្រង់កណ្ដាលប្រាសាទបាយ័ន ដែលជាប្រាសាទសំខាន់សឹងតាំងនៅត្រង់រវាងស្នូលកណ្ដាលក្រុងនគរធំ ប្រទះឃើញព្រះពុទ្ធរូបធ្វើអំពីថ្ម មានរូបនាគប្រក់ ទំហំទទឹងព្រះភ្នែនប្រមាណ ១ ម៉ែត្រ ៤០ សង្ទីម៉ែត្រ កប់នៅក្នុងកណ្ដាលប្រាសាទនោះជំរៅ ១៣ ម៉ែត្រ ។ ព្រះពុទ្ធរូបនេះហើយ គឺព្រះមហាក្សត្ររបស់ខ្មែរយើង ទ្រង់ឲ្យសាងឡើងក្នុងរវាងពុទ្ធសករាជ ១៧៥០ ។

ព្រះពុទ្ធរូបអង្គនេះ បើនឹងនិយាយតាមក្បួនខ្នាតព្រះពុទ្ធរូប នឹងលក្ខណទ្រង់ទ្រាយគ្រប់ប្រការហើយ ឃើញថាហ្មត់ចត់ត្រឹមត្រូវតាមក្បួនលក្ខណគ្រប់យ៉ាងទាំងអស់ ឥតមានខ្វស់ទាស់ផ្គងត្រង់ណា គឺព្រះភក្ត្រទ្រង់សក្តិសមជាព្រះពុទ្ធដែលជាព្រះធម្មរាជា ព្រះភ្រូមោសោតក៏ទ្រង់ទ្រទ្រួយកោងស្រួលសមគ្នានឹងព្រះនេត្រ ព្រះឱស្ឋ ក៏ទ្រង់ញញឹមសំដែងឲ្យឃើញ

ភាពជាបុគ្គលគ្មានទុក្ខ រាប់ថា ជាព្រះពុទ្ធរូបជាន់ឯកលេខ ១ នឹងរកព្រះពុទ្ធរូបឯទៀតមកប្រៀបផ្ទឹមឲ្យត្រឹមស្មើបានដោយក្រ គួរទុកជាគំរូយ៉ាងរបស់ជាងអ្នកសាងព្រះពុទ្ធរូបតទៅបាន ។

ដោយហេតុនេះ កាលព្រះករុណាជាអំម្ចាស់ជីវិតលើត្បូង បានទ្រង់ជ្រាបពណ៌មាននេះហើយ មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លាមហិមា ប្រាថ្នាចង់ឲ្យព្រះពុទ្ធរូបអង្គនោះស្ថិតនៅអស់កាលជ័យូរ នឹងបានជាទីបូជាគោរពរបស់មហាជនរាល់ ៗ គ្នា ទាំងជាគ្រឿងប្រដាប់ព្រះពុទ្ធសាសនា នឹងនគរកម្ពុជាឲ្យរុងរឿងឡើងផង ដោយមានព្រះពុទ្ធរូបអង្គនេះដែលជាកេរ្តិ៍ដំណែលរបស់បុព្វបុរសយើង លោកបានកសាងទុកមក ទើបត្រាស់ឲ្យក្រុងសេវ៉ាទ័រ ដឹកលំព្រះពុទ្ធរូបនោះទុកមួយអន្លើសិន, ហើយត្រាស់ឲ្យសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈ បេញសង្ឃដីកាឃោសនាអ្នកនគរ ៗ ក៏មានសទ្ធាជ្រះថ្លាបួលព្រះរាជកុសលផង ទាំងបព្ជិតទាំងគ្រហស្ថគ្រប់ថ្នាក់គ្រប់ជាន់បុគ្គល ។ កាលប្រមូលបានប្រាក់មកហើយ

ត្រាស់ឲ្យប្រគល់ឲ្យក្រុងសៅរ៉ាទ័រអង្គរ ជាមេការបាត់បែងធ្វើព្រះពុទ្ធមន្ទីរ ។

ក្រុងសៅរ៉ាទ័រ ក៏ទទួលព្រះរាជឱង្ការ នឹងទទួលប្រាក់ទៅធ្វើជាពុទ្ធមន្ទីរ ដោយរួសរាន់ទាន់តាមព្រះរាជហឫទ័យបំណង ដោយអស់អញពេញចិត្តរបស់ខ្លួន គឺធ្វើជាវិហារមុខ ៤ យ៉ាងតូប ១ នៅត្រង់កន្លែងព្រះវិហារចាស់ ១ សង់តាំងនៅខាងមុខព្រះលានក្រុងនគរធំ បានធ្វើហើយស្រេចនូវវេលាដើមខែពិសាខ ឆ្នាំកុរសប្តស័ក (ខែមេ ១៩៣៥) នេះ ។

ក្រោយនោះមានព្រះរាជកំណត់បេញថា នៅថ្ងៃ ១៥ កើតខែពិសាខ (១៧ មេ ១៩៣៥) នឹងធ្វើបុណ្យសម្ពោធ (អភិសេក) ព្រះពុទ្ធរូបនោះនៅទីដ្ឋបពោលហើយ ។ គ្រានោះលោកឡឺរេស៊ីដង់ត៍ លោកចៅហ្វាយខេត្ត ចៅហ្វាយស្រុក នឹងមេឃុំសៀមរាប ជាមេការបាត់ឲ្យរៀបសំអាតទីកន្លែង នឹងធ្វើរោងផ្សេងៗ សម្រាប់ក្នុងការបុណ្យនោះគឺ:

ខាងមុខពុទ្ធមន្ទីរ ខាងក្នុងកំផែង មានរោង ១ ធំវែងជាទីសម្រាប់ធ្វើបុណ្យបំរើនព្រះបរិត្ត វេរភត្តថ្វាយព្រះសង្ឃឆាន់

នឹងសម្រាប់ទទួលព្រះសង្ឃដែលមានសមណសក្តិ នឹងកូនសិស្សសាលាបាលីជាន់ខ្ពស់ចំនួន ១០០ អង្គ មានសម្តេចព្រះមង្គលទេពាចារ្យ សង្ឃនាយកគណធម្មយុត្តិក៍ នឹងលោក.... ជំណាងសម្តេចព្រះធម្មលិខិត សង្ឃនាយកគណមហានិកាយ នឹងលោកគ្រូព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ជាដើម ។

ខាងត្បូងរោងនេះផ្ទាប់ តែក្រៅកំផែង មានរោង ២ ធំវែងសម្រាប់ទទួលព្រះសង្ឃ ៩០០ អង្គ ដែលនិមន្តយកក្នុងខេត្តសៀមរាបនោះ សំណាក់អាស្រ័យនៅ (រួមចំនួនព្រះសង្ឃទាំងដែលនិមន្តពីភ្នំពេញផង ជា ១០០០ អង្គ ។

ខាងមុខព្រះពុទ្ធមន្ទីរត្រង់ តែខាងក្រៅកំផែង មានព្រះពន្លាភាក់ ១ ខ្នង ជាទីសម្រាប់ព្រះករុណាទ្រង់ភាក់ម្តង ៗ នឹងសម្រាប់ល្ខោនព្រះរាជទ្រព្យរាំ ឲ្យរាស្ត្រអ្នកស្រុកមើល ។

ខាងកើតនឹងខាងត្បូងព្រះពន្លាភាក់ មានរោងជាច្រើនខ្នងសម្រាប់ស្ត្រីខ្ញុំរាជការ នឹងពួកល្ខោនព្រះរាជទ្រព្យ នឹងអ្នករាជការប្រុស ៗ ក្នុងព្រះបរមរាជវាំង អាស្រ័យនៅ នឹង

មានរោងសម្រាប់ធ្វើបង្ហាន់ព្រះសង្ឃនឹងធ្វើអាហារលៀងខ្ញុំរាជការប្រុស-ស្រីដែលតាមហែ ។

ខាងត្បូងព្រះពុទ្ធមន្ទីរ តែក្រៅកំផែង មានរោង ១ យ៉ាងវែង ខាន់ជាល្វែង ៗ ចំនួនប្រមាណ ២៥ ល្វែង សម្រាប់រាស្ត្រអ្នកស្រុកជួលដាក់ត្បែងលក់ទំនិញផ្សេង ៗ នឹងលក់កាហ្វេ តែរ លីមូណាត់ សុរា បាយ នំ ចំណីផ្សេង ៗ ឲ្យអ្នកដែលទៅក្នុងការបុណ្យនោះទិញបរិភោគ តាមត្រូវការ ។

នៅខាងលិចព្រះពុទ្ធមន្ទីរ ក្រៅកំផែង មានរោងល្បែង ៣ រោង គឺរោងណាំងស្បែក ១ រោងណាំងតាលុង ១ រោងភ្លេងប្រៀងឡូក ដែលអ្នកស្រុកនោះហៅថា ភ្លេងអាយ៉ៃ ១ ។

ថ្ងៃ ១៥ កើត ខែពិសាខ ត្រូវនឹងថ្ងៃ ១៧ ម៉េ ១៩៣៥ វេលាព្រឹកព្រះករុណាស្ដេចយាងចេញពីក្រុងភ្នំពេញ ដោយព្រះទីនាំងរថយន្តជាមួយនឹងលោកឡឺរេស៊ីដង់ស៊ុបេរីយើរ (រឹសូម) ព្រមទាំងព្រះរាជវង្សានុវង្សនូវអស់លោកសេនាបតីដែលត្រូវតាមហែ មានព្រះអង្គម្ចាស់អធិបតី នឹងសម្ដេចចៅហ៊្វាវាំង វរៈវៀងជ័យ អធិបតី ជាដើម ។ វេលាម៉ោង ១១ កន្លះព្រឹក

ព្រះករុណាស្តេចដល់សៀមរាប ទ្រង់ចៀងចូលផ្ទះលោករេស៊ីដង់ត៍សិន តាមកំណត់ក្នុងប្រក្រាម គ្រានោះអ្នករាជការខេត្តសៀមរាបទាំងបារាំងទាំងខ្មែរ គឺ លោករេស៊ីដង់ត៍ កុងសេវ៉ាទ័រអង្គរ លោកចៅហ្វាយខេត្ត ចៅហ្វាយស្រុកគ្រប់ស្រុកក្នុងខេត្តនោះនឹងពួកតុលាការសាលាដំបូង នឹងអ្នករាជការខ្លះដែលទៅពីក្រុងភ្នំពេញ នឹងព្រះសង្ឃចៅអធិការវត្តធំ ៗ ក្នុងស្រុកសៀមរាប ប្រមាណ ១០ អង្គ ចាំទទួលព្រះករុណានៅក្នុងផ្ទះលោករេស៊ីដង់ត៍ ។ មានទាហានក្រុមរក្សាស្រុក ១ ក្រុម នឹងក្រុមភ្លេងបារាំងព្រះរាជទ្រព្យ ចាំទទួលថ្វាយគំនាប់នឹងលេងថ្វាយជ័យតាមទំនៀម នៅទីសួនខាងមុខផ្ទះលោករេស៊ីដង់ត៍ ។ កាលព្រះករុណាស្តេចយាងចូលទៅក្នុងបន្ទប់ធំក្នុងផ្ទះលោករេស៊ីដង់ត៍ ជាមួយនឹងលោកឡូរេស៊ីដង់ត៍សុប៉េរិយើរ ពួកអ្នករាជការបារាំងខ្មែរក៏ថ្វាយគំនាប់ នឹងថ្វាយបង្គំព្រមគ្នា រួចលោករេស៊ីដង់ត៍ក៏ក្រាបបង្គំទូលរាយឈ្មោះនឹងដំណែងអ្នករាជការធំ ៗ ទាំងបារាំងទាំងខ្មែរ ព្រះករុណាទ្រង់បដិសណ្ឋារនឹងអ្នករាជការទាំង

នោះតាមសមគួរហើយ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានគ្រឿងឥស្សរិយយសអស្សរិទ្ធិកម្ពុជា ( ស៊េវ៉ាលីយេ ) ដល់មោនសៀរទ្រវេរ ក្នុងសេវ៉ាទ័រអង្គរ ជាបំណាច់ដែលបានចាត់ការឲ្យជីកឃើញព្រះពុទ្ធរូបនាគប្រក់ ដូចពោលមកហើយខាងដើម ។ ស្រេចហើយព្រះករុណាស្ដេចយាងទៅគង់នៅបុង្គាឡូមុខប្រាសាទនគរវត្ត ។

ក្នុងឱកាសស្ដេចយាងទៅនេះ មានអ្នករាជការទាំងបារាំងទាំងខ្មែរតាមស្ដេចជាច្រើនក្រុម ច្រើនក្រសួងផងគ្នា ក្រសួងព្រះបរមរាជវាំង គឺក្រុមព្រះអាលក្ខណ៍ ក្រុមព្រះរាជយុត្តកក្រុមដម្រួត ក្រុមមហាទ្បឹក ក្រុមវាំង ក្រុមល្ហោនព្រះរាជទ្រព្យ ក្រុមស្ត្រីខ្ញុំរាជការ ក្រុមបារគូ ក្រុមហោរ ក្រុមទាហានរក្សាព្រះអង្គ ក្រុមភ្លេងពិណពាទ្យ ក្រុមភ្លេងបារាំងព្រះរាជទ្រព្យ ។ ក្រសួងយុត្តិធម៌ខ្លះ ក្រសួងសេនាបតីជើងទឹកខ្លះនឹងក្រសួងប៉ូលិស ក្រសួងស៊ើបការសម្ងាត់ ពេទ្យជាដើម ទៅបម្រុងការតាមមុខក្រសួងរៀងខ្លួន ។

## ចូលបុណ្យ

ថ្ងៃសុក្រ ១៥ កើត វេលាម៉ោង ៦ ល្ងាច (ដែលត្រូវនឹងថ្ងៃដែលព្រះសម្ពុទ្ធ ទ្រង់ប្រសូតិ-ត្រាស់ដឹង-បរិនិព្វាន ហើយត្រូវនឹងថ្ងៃដែលសម្ពោធឆ្លងពុទ្ធសាសនបណ្ឌិត្យ ក្នុងប្រទេសកម្ពុជានេះផង) ជាវេលាផ្ដើមធ្វើពិធីសម្ពោធព្រះពុទ្ធរូប ។ ពៅភ្នាក់ងាររៀបតែងតាំងក្រាលកន្ទេល ព្រំ នឹងតាំងព្រះទីតាំងកោប្ដិ (កៅអី) នឹងកៅអីសម្រាប់អ្នករាជការទាំងពួង នឹងរៀបគ្រឿងពលីការថ្វាយទេវតាតាមទំនៀម នៅទីព្រះលានខាងមុខព្រះពុទ្ធមន្ទីរដែលសាងថ្មីនោះ គឺ បាយសី ៩ ថ្នាក់ ១ គូ, បាយសី ៧ ថ្នាក់ ១ គូ, បាយសី ៥ ថ្នាក់ ១ គូ, បាយសី ៣ ថ្នាក់ ១ គូ, ផ្កាឈាជ ៥, ទៀន ៥, ធូប ៥, នឹងណាំតៅមាស ១ ពានព្រះស្រីជីប ១ គូ, ព្រះតៅ ១ គូ, ព្រះលម ១ គូ, ពានព្រះឈុត ១ គូ, ព្រះស្រោប ១ គូ, ពានព្រះស្រីស្នង ១ គូ, កាទឹក ១ គូ, តុកប្រាក់បំអាប ១ គូ, តុកប្រាក់បង្អែម ១ គូ, ជានបាយ ១ គូ, ផ្លែឈើ ៨ តោក, ក្បាលជ្រូកស្ងោរ ៤, មាន់ស្ងោរ ៤, ទាស្ងោរ ៤, ទៀនធំ ៤ ។

ដល់ម៉ោង ៦ តាមកំណត់ខាងលើ ព្រះករុណាស្តេចយាងទៅបួងសួងផ្តើមការបុណ្យ ជាមួយនឹងលោកឡឺរេស៊ីដង់សុប៉េរីយើរ ជួបជុំដោយព្រះរាជវង្សានុវង្ស នឹងសេនាបតី មន្ត្រីធំ-តូច ទាំងបារាំង ទាំងខ្មែរ នឹងព្រះអង្គម្ចាស់សាវ៉ាង ជាព្រះរាជបុត្រព្រះបៅក្រុងហ្លួងព្រះបាងនឹងព្រះអនុជ ២ អង្គ នៅទីព្រះពុទ្ធមន្ទីរនោះ ។ គ្រានោះមានមហាជន គឺព្រះសង្ឃបំនួន ១០០០ អង្គ គហស្ថអ្នកស្រុកក្នុងខេត្តសៀមរាបនឹងដែលទៅពីខេត្តផ្សេង គឺខេត្តកណ្តាល-ពោធិសត្វ-បាត់ដំបង ។ល។ ទៅជួបជុំមីដេរដាសពាសពេញនៅទីនោះ ដើម្បីនឹងទស្សនាការបុណ្យបារមី ព្រះករុណាជាអំម្ចាស់ជីវិតលើត្បូងរបស់ខ្លួន ហើយនឹងមើលបុណ្យដែលព្រះមហាក្សត្រទ្រង់ធ្វើ ។

ព្រះករុណាទ្រង់ក្រាបថ្វាយបង្គំព្រះពុទ្ធរូបដោយគោរព ហើយទ្រង់គង់លើព្រះទីនាំងកៅអី ព្រាហ្មណ៍ផ្លុំស័ង្ខថ្វាយជ័យបីបទ, លំដាប់នោះឧកញ្ញាហោរាធិបតី សូត្រប្រកាសអញ្ជើញទេវតា នឹងរំលឹកព្រះគុណព្រះមហាក្សត្រាធិរាជដែលទិវង្គតកន្លងទៅហើយ ដើម្បីឲ្យមកជួយឧបត្ថម្ភគាំពារទំនុកបម្រុងដល់ព្រះ

ករុណាជាអម្ចាស់ជីវិតលើត្បូង និងលោកឡឺគូវែរណើរយេណេរ៉ាលនិងលោកឡឺរេស៊ីដង់ត៍ស៊ុប៉េរិយើរនគរកម្ពុជា នូវព្រះរាជវង្សានុវង្សនិងចៅចម-ម៉ម-ម្នាង ព្រមទាំងអ្នកដែលចូលប្រាក់ក្នុងការស្ថាបនានេះ កាលសូត្រចប់ហើយ ភ្លេងព្រះរាជទ្រព្យក៏ផ្ដើមរាំបួងសួងថ្វាយទេវតា ។

ក្នុងខណៈនោះប្រាកដឃើញជាការអស្ចារ្យ ១ យ៉ាងដែលគួរនាំមកថ្លែងទុកក្នុងទីនេះ ដើម្បីឲ្យបណ្ដាអ្នកដែលមិនបានទៅក្នុងការបុណ្យនោះជ្រាបហេតុនោះផង គឺមានពួកសត្វរៃកណ្ដឹងដែលនៅទីដើមឈើជិត ៗ ទីនោះបន្លឺនូវសូរសព្ទរងំ ព្រមគ្នាក្នុងខណៈដែលភ្លេងរាំ ហើយនឹងលេងភ្លេងំ មានអាការហាក់ដូចជាសត្វរៃកណ្ដឹងអំបាលនោះមានសេចក្ដីសាទរផង ឬពុំនោះសោតក៏ជាទូតរបស់ទេពនិករ ៗ ឲ្យមកជួយស្រែកអនុមោទនាក្នុងការកុសលនេះ កាលភ្លេងបួងសួងចប់ហើយ រៃក៏ឈប់យំដែរ ខនេះធ្វើឲ្យមនុស្សទាំងពួងដែលទៅប្រជុំក្នុងទីនោះកើតពិផលធ្ងល់សង្កាតែរាល់គ្នា ហើយចោទជណ្ដឹងគ្នាលាន់ថា ជាការណ៍អស្ចារ្យណាស់ ។

កាលបួងសួងចប់ហើយ ដល់ពេលបំរើនព្រះបរិត្ត ព្រះករុណាក៏ស្តេចយាងចូលរោងធំនៅក្នុងកំផែងនោះ ព្រះសង្ឃ១០០អង្គមានសម្តេចព្រះមង្គលទេព្វាចារ្យជាប្រធាន បំរើនព្រះបរិត្តថ្វាយព្រះរាជកុសល ចប់ហើយ ព្រះករុណាស្តេចយាងទៅស្ថិតនៅទីមុខរោងបុណ្យ ទតមើលមហាជនប្រុសស្រីក្មេងចាស់ដែលប្រជុំចាំមើលព្រះអង្គ សឹងអង្គុយបៀតសៀតមីដេរដាសពាសពេញទាំងខាងក្នុងកំផែងទាំងខាងក្រៅកំផែង ប្រមាណចំនួនប្រហែលជា ៦-៧ ពាន់នាក់ សង្កេតមើលអាការកិរិយាអ្នកស្រុកអំពាលនោះមានសេចក្តីខ្វល់ខ្វាយចង់ឃើញអង្គព្រះករុណាពន់ពេកណាស់ ទោះបីចង្អៀតហើយក្តៅស្អុះយ៉ាងណា ក៏ឧស្សាហ៍ប្រៀតបៀតគ្នាចូលទៅអង្គុយ ប្រណម្យដៃយ៉ាងស្ងប់ស្ងៀម ហើយភ្នែកក៏រំពៃគន់មើលព្រះភូមីស្ទើរតែពុំប្រិចភ្នែក ។ ខណៈនោះព្រះករុណាជាអម្ចាស់ត្រាស់សួរសីហនាទបំពោះទៅកាន់មហាជនអំពាលនោះថា "យើងសូមចែកចំណែកកុសលផលបុណ្យដែលយើងធ្វើក្នុងគ្រានេះ ដល់អ្នកទាំងឡាយដែល

មកប្រជុំក្នុងទីនេះ សុំឲ្យបានសេចក្ដីសុខសេចក្ដីចំរើនក្នុងបច្ចុប្បន្នកាលឥឡូវនេះ និងសូមឲ្យសម្រេចត្រៃពិធសម្បត្តិ គឺសម្បត្តិក្នុងមនុស្សលោក ទេវលោក និងព្រះនិព្វានជាទីបំផុត" កាលផុតព្រះសូរសៀងហើយ មហាជនទាំងនោះក៏ទទួល សាធុ ៣ ដងព្រមគ្នា ឮសូរសព្ទទ្រហឹងទៅ ។ ត្រង់នេះ សង្កេតមើលអាណាប្រជារាស្ត្រ មានសេចក្ដីរីករាយសប្បាយចិត្តណាស់ ដែលព្រះករុណាជាអំម្ចាស់ទ្រង់ស្ថិតឲ្យឃើញព្រះអង្គយូរ ហើយត្រាស់ប្រារព្ធមកនឹងខ្ទង ។ ស្រេចហើយស្ដេចយាងទៅប្រថាប់ទីដើមវិញ ។

ម៉ោង៩កន្លះដល់ម៉ោង១១យប់ ល្ខោនព្រះរាជទ្រព្យរាំរឿងព្រះថោង គឺរឿងក្សត្រខ្មែរ១អង្គក្នុងជាន់ដើម ដូចមានសេចក្ដីស្រង់មកដោយសង្ខេបដូច្នេះ

១ ពុទ្ធសករាជ ២៦៦ មុនគ្រិស្តសករាជ ២៧៨ ឆ្នាំ ព្រះថោងដែលព្រះបាទអាទិត្យវង្ស ជាព្រះបិតាសោយរាជ្យនៅក្រុងឥន្ទបថ (ប្រទេសឥណ្ឌា) បំបរបង់ដោយទោសក្បត់ ទ្រង់លាព្រះអនុជចុះពោងពាយ មានមហាជនតាមស្ដេចជាច្រើននាក់

ពោងពាយរសាត់មកជាប់នៅជើងភ្នំជង់រែកក្រុងកម្ពុជា ហើយឲ្យធ្វើព្រះពន្លាគង់នៅទីនោះសឹងជាស្រុករបស់ព្រះបាទអស្ស-បៃយស្តេចចាមទី៥ ដែលព្រះអយ្យកោមកលិចសំពៅនៅទីនោះកាល ព.ស.១៣៤ មុនគ្រិស្តសករាជ៤១០ឆ្នាំ ។

២ រាជទូតព្រះបាទអស្សបៃយទៅសួរព្រះថោងៗ ក៏ថ្លែងតាមដំណើរសព្វគ្រប់ហើយសុំភាក់នៅទីឆ្នេរសមុទ្រនោះ ។

៣ ព្រះថោងគង់នៅយូរក៏មានអំណាចពាសពេញក្នុងទីនោះ ស្តេចចាមក៏លើកទ័ពទៅបណ្តេញព្រះថោង ក៏កើតច្បាំងគ្នានឹងព្រះថោង តែព្រះបាទអស្សបៃយបាញ់ក៏រត់ទៅនៅស្រុកបម្ប៉ាជាស្រុកលាវ(១) ។

៤ ព្រះថោងគង់នៅស្រុកនោះ តាមដើមហៅថា គោកធ្លកហើយស្តេចយាងទៅឆ្នេរសមុទ្រ ដើម្បីនឹងរកទីជយភូមិតាំងក្រុងដល់ទៅឆ្នេរខ្សាច់ ១ កន្លែងសឹងមានដើមធ្លក ១ ដុះនៅទីនោះក៏ទ្រង់អាស្រ័យប្រថាប់នៅទីនោះ ។ យប់នោះមាននាគធីតា

(១) ស្រុកចម្ប៉ា គឺស្រុកហាណូយសព្វថ្ងៃនេះជាស្រុករបស់ចាមពីដើមមកមិនមែនជាស្រុកលាវទេ ។

ឈ្មោះ ធារាវតី មកលេងតាមឆ្នេរខ្សាច់ជួបនឹងព្រះថោងក៏មានសេចក្ដីប្រតិព័ទ្ធនឹងគ្នា ។

៥ នាងធារាវតីត្រឡប់ទៅនាគពិភពទូលមាតាបិតាថា ព្រះថោងសុំផ្ញើអាពាហ៍ពិពាហ៍នឹងនាង មាតាបិតាក៏អនុម័តិតាម ។

៦ ស្ដេចនាគបិតានាងធារាវតីក៏លើកសេនាទាហានពីក្នុងសមុទ្រឡើងមកនិម្មិតជាប្រាសាទវាំង ហើយអភិសេកសមរសព្រះធីតានឹងព្រះថោង ហើយថ្វាយព្រះនាមព្រះថោងជាព្រះបាទកុមេរាជ ឲ្យគ្រប់គ្រងក្រុងកម្ពុជាធិបតី ហើយស្ដេចនាគត្រឡប់ទៅវិញ ឲ្យព្រះថោងចាប់ជាយស្បៃនាងធារាវតី បុះទឹកតាមស្ដេចនាគទៅមើលនគរនាគ ។

ខ្មែរនេះយើងកាន់ជាប់ជាទំនៀមដល់សព្វថ្ងៃនេះ គឺវេលារៀបការគេឲ្យលេងភ្លេងព្រះថោងនាងនាគ ឲ្យកូនប្រុសកាន់ជាយស្បៃកូនស្រីចូលទៅស្ទៃក្នុង ក្នុងវេលាដែលផ្ទឹមហើយ (តែរឿងនេះនៅមានសេចក្ដីកំបាំងដែលត្រូវពិចារណាតទៅទៀត) ។

ពេញ្ញា៖ ធារាវតី មកលេងតាមឆ្នេរខ្សាច់ជួបនឹងព្រះថោងក៏មាន សេចក្តីប្រតិព័ទ្ធនឹងគ្នា ។

៥ នាងធារាវតីត្រឡប់ទៅនាគពិភពទូលមាតាបិតាថា ព្រះថោងសុំផ្ញើអាពាហ៍ពិពាហ៍នឹងនាង មាតាបិតាក៏អនុម័តតាម ។

៦ ស្តេចនាគបិតានាងធារាវតីក៏លើកសេនាទាហានពីក្នុងសមុទ្រឡើងមកនិម្មិតជាប្រាសាទវាំង ហើយអភិសេកសមរសព្រះធីតានឹងព្រះថោង ហើយថ្វាយព្រះនាមព្រះថោងជាព្រះបាទកុមេរាជ ឲ្យគ្រប់គ្រងក្រុងកម្ពុជាធិបតី ហើយស្តេចនាគត្រឡប់ទៅវិញ ឲ្យព្រះថោងចាប់ជាយស្បៃនាងធារាវតី បុះទឹកតាមស្តេចនាគទៅមើលនគរនាគ ។

៧នេះខ្មែរយើងកាន់ជាប់ជាទំនៀមដល់សព្វថ្ងៃនេះ គឺវេលារៀបការគេឲ្យលេងភ្លេងព្រះថោងនាងនាគ ឲ្យកូនប្រុសកាន់ជាយស្បៃកូនស្រីចូលទៅស្លៃក្នុង ក្នុងវេលាដែលផ្ទឹមហើយ (តែរឿងនេះនៅមានសេចក្តីកំបាំងដែលត្រូវពិចារណាតទៅទៀត) ។

ក្នុងយប់ថ្ងៃសុក្រនេះ ក្រោយវេលាដែលបំរើនព្រះបរិត្ត ហើយ មានទេសនា ២ កណ្ឌ គឺលោកគ្រូ ព្រះសាសនសោ-ភ័ណ ណាត ចាងហ្វាងវង់សាលាបាឡី ទេសនារឿងពុទ្ធ-ប្បវត្តិ ពណ៌នាសេចក្ដីតាំងអំពីព្រះសិទ្ធត្ថកុមារមកបង្កើតក្នុងត្រកូលក្សត្រសក្យរាជរហូតដល់បេញទ្រង់ផ្នួស បានត្រាស់ជាសម្មាសម្ពុទ្ធ ។ ល ។ ចប់ ។ លោកគ្រូព្រះមហាព្រហ្មមុនី អ៊ូ អធិបតីរង ក្រុមជំនុំប្រែព្រះត្រៃបិដក ទេសនារឿងធម្មគោរព គឺ សំដែងអំពីសភាវៈដែលឈ្មោះថា ព្រះធម៌ ហើយសំដែងអំពីអានិសង្សនៃការស្ដាប់ធម៌ដោយគោរពថា មានផលប្រសើរវិសេសដូច្នេះដូច្នោះ ។

ទេសនារួចហើយហៅភ្នាក់ងារក្រុមរាជបណ្ឌិត និងក្រុមរាជនិមន្តរៀបធ្វើពិធីអភិសេកសម្ពោធព្រះពុទ្ធរូបសិលាដែលរកឃើញថ្មីនោះ និមន្តព្រះសង្ឃ ២ រូបសូត្រពុទ្ធាភិសេក និងសូត្រធម៌យោគផ្ចាញ់មាររហូតដល់ភ្លឺ ដោយរបៀបតាមដែលធ្លាប់ធ្វើរៀងរាបមកហើយ ។ មានឧបាសកឧបាសិកាមកស្ដាប់ទេសនានិងស្ដាប់ធម៌ពុទ្ធាភិសេកនោះបង្អៀតគ្នា ។

១ ទៀតក្នុងយប់នោះ វេលាម៉ោង៩ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានលៀងលោកគូវេរណើរក្លូសាំងរ៉ឹន លោកឡឺរេស៊ីដង់ត៍សុប៉េរិយើរកម្ពុជានឹងលោកសេដេស ចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស (ហាណូយ) នឹងព្រះអង្គម្ចាស់សាវ៉ាងព្រមទាំងព្រះអនុជទាំងពីរអង្គនឹងអ្នករាជការឯទៀតទាំងបារាំងទាំងខ្មែរ ជាច្រើននាក់ផងគ្នានៅទីបុគ្គាឡ សៀមរាប មានភ្លេងបារាំងព្រះរាជទ្រព្យលេងជាកំសាន្តផង ។

កាលសោយរូបហើយ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានគ្រឿងឥស្សរិយយសដល់លោកគូវេរណើរ ក្លូសាំងរ៉ឹន ១ លោកសេដេស ១ នឹងព្រះរាជទានគ្រឿងវិរសេនា ដល់ព្រះអង្គម្ចាស់សាវ៉ាង ព្រះរាជទានគ្រឿងសេនាសុវត្ថិធារា ដល់ព្រះអង្គម្ចាស់ទាំផាន់ នឹងព្រះអង្គម្ចាស់សុពណរង្សី ។

ដល់ម៉ោង ១១ ល្ងាចរំលោងហើយ មានអុបកញ្ច្រប-រន្ទា-ភ្លើងធ្វាយទេវតា នៅទីមុខព្រះលានក្រុងនគរធំ មានប្រជារាស្ត្រ

គ្រប់សាសន៍ដែលនៅក្នុងនគរកម្ពុជា នាំគ្នាទៅរង់ចាំមើលមីដេរ ជាសពាសពេញវាលមុខព្រះលាន ហើយមានសេចក្ដីសរសើរ ថាល្អមើល ។

ថ្ងៃសៅរ៍ ១៨ មេ ១៩៣៥ វេលាម៉ោង ៩ ព្រឹក ដល់ម៉ោង ១១ និមន្តព្រះសង្ឃ ១០០ អង្គដែលបំរើនព្រះបរិត្តឆាន់ភោជនាហារ ដែលចៅភ្នាក់ងារក្រសួងព្រះបរមរាជវាំងទៅរៀបចំប្រគេនឆាន់ ។ ព្រះករុណាជាអំម្ចាស់ជីវិតលើត្បូងស្ដេចយាងទៅទ្រង់សីល នឹងអង្គាសព្រះសង្ឃឆាន់ មានអ្នករាជការដែលតាមហែ នឹងអ្នករាជការខេត្តសៀមរាប មកជួបជុំចាំក្រាបបង្គំគាល់នៅទីនោះស្រេចហើយព្រះករុណាស្ដេចយាងត្រឡប់ទីប្រថាប់វិញ ។

វេលារសៀលម៉ោង ៣ ដល់ម៉ោង ៥ មានទេសនាសង្កាយនា ៣ អង្គ គឺលោកគ្រូព្រះពោធិវាំង ចៅអធិការវត្តសារាវន ១ លោកគ្រូព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាឡីជាន់ខ្ពស់ ១ លោកគ្រូព្រះវិមលធម្ម ភ្លួង វត្តបទុមវតី ១ ។ ទេសនាផ្សាយកុសលដល់មហាជនបណ្ដាដែលបានចេញប្រាក់ជួយក្នុងការស្ថាបនាពុទ្ធមន្ទីរនោះ ទាំងដែលបានទៅប្រជុំក្នុងទីនោះក្ដី ទាំង

ដែលមិនបានទៅក្តី ។ ចប់ហើយប្រគេនទេយ្យធម្មវត្ថុដល់ព្រះសង្ឃដែលទេសនា និងហត្ថបាសទាំង ១០០០ អង្គ ។

ក្នុងឱកាសបុណ្យនេះមានបែកសៀវភៅពង្សាវតារ ព្រះបាទជ័យវរ្ម័ន ទី ៧ និងព្រះពុទ្ធរូបដែលសម្ពោធនោះ ដែលព្រះរាជ-បណ្ណាល័យចាត់ការបោះពុម្ព ដោយទឹកប្រាក់ដែលរៃមកក្នុងការស្ថាបនាពុទ្ធមន្ទីរ ឲ្យមហាជនប្រុសស្រីផង ។

វេលាយប់ម៉ោង ៩ កន្លះ ល្ខោនព្រះរាជទ្រព្យបេញរាំរឿងព្រះសង្ខ ឲ្យអ្នកស្រុកមើល ដូចមានសេចក្តីដែលស្រង់មកដោយសង្ខេបតទៅនេះ:

១ ព្រះបាទសាមលរាជនៅនគរសាមល គិតឧបាយកលយកទោសសម្លាប់ព្រះសង្ខឬហៅថា ងោះ ជាសុណិសាដែលក្លែងខ្លួនជាងោះរូបអាក្រក់ពន់ពេក ត្រាស់ប្រើងោះនឹងសុណិសាប្រុស ៦ អង្គឲ្យទៅរកត្រីថ្វាយ ដោយគិតថា ងោះគង់រកត្រីថ្វាយមិនបាន ។

២ ព្រះសង្ខងោះមានឫទ្ធិ ក្រឡាខ្លួនបេញពីរូបងោះជារូបល្អដូចដើមវិញ ទៅនៅក្រោមដើមជ្រៃធ្មើបណ្តាលមិនឲ្យបងថ្លៃ

ទាំង ៦ រកត្រីបាន ស្ដេចទាំង ៦ ឃើញព្រះស័ង្ខស្មានថា ជាទេវតា ក៏គោរពអង្វរសុំឲ្យរកត្រីបានខ្លះ ។

៣ ព្រះស័ង្ខក៏ឲ្យត្រីទៅស្ដេចទាំង ៦ បន្តិច ៗ ម្នាក់ តែសុំកាត់ចុងច្រមុះស្ដេចទាំង ៦ បន្តិច ៗ ជាសំគាល់ឲ្យស្ដេចសាមលជ្រាបហេតុនៅវេលាក្រោយ ។

៤ ដោះយកត្រីទៅថ្វាយព្រះបិតាក្មេកច្រើនជាអនេកមុនស្ដេចទាំង ៦ ទៅដល់ ព្រះបិតាក្មេកទ្រង់ខ្ញាល់នឹងសុណិសាទាំង ៦ ដែលយឺតយូរ លុះស្ដេចទាំង៦ទៅដល់ យកត្រីបន្តិច ៗ ម្នាក់ទៅថ្វាយ ព្រះបាទសាមលឃើញស្នាមដាចចុងច្រមុះផង ក៏ត្រាស់សួរពីហេតុដែលដាចច្រមុះ ស្ដេចទាំង ៦ ទូលថា ដាចដោយក្រពតប្រិបក្នុងការមុចទឹកចាប់ត្រី កាលស្ដេចទាំង ៦ ក្រឡេកទៅឃើញដោះបានត្រីច្រើន ក៏រករឿងព្រួតគ្នាឈ្លោះនឹងនាងរចនាជាភរិយាដោះ នាងរចនាទ្រាំមិនបានក៏ឲ្យដោះប្រែរូបល្អដូចដើម ហើយនាំគ្នាទៅទីលំនៅអាត្មាវិញហោង (ចប់) ។

រាំយប់នេះមានមហាជនទៅមើលច្រើនដូចយប់មុន ។

យប់ថ្ងៃសៅរនេះ វេលាម៉ោង៩ លោកឡឺរេស៊ីដង់ត៍សុប៉េ-រិយើរក្រាបទូលអញ្ជើញព្រះករុណាទៅសោយល្ងាចនៅបុគ្គាឡូ សៀមរាប មួយអន្លើដោយអ្នករាជការបារាំង-ខ្មែរដែលមានបណ្ដាស័ក្តិធំ ៗ ជាច្រើននាក់ និងព្រះអង្គម្ចាស់សារ៉ាំង ព្រមទាំងព្រះអនុជ ២ អង្គផង ។ មានភ្លេងបារាំងព្រះរាជទ្រព្យលេងជាកំសាន្តក្នុងឱកាសសោយ ។

ព្រឹកឡើងថ្ងៃអាទិត្យ ១៩ មេ វេលាម៉ោង៩ មានការថ្វាយបង្គាន់សង្ឃដូចថ្ងៃមុន ព្រះករុណាស្ដេចយាងទៅតែមួយរំពេចហើយស្ដេចត្រឡប់វិញ ត្រាស់ឲ្យព្រះអង្គម្ចាស់អធិបតីនៅអង្គាសបង្គាន់សង្ឃ ជំនួសព្រះអង្គ មានមន្ត្រីធំ-តូចទៅជួបជុំគាល់ដូចថ្ងៃមុន កាលព្រះសង្ឃឆាន់ហើយ ក៏ថ្វាយអនុមោទនា និងថ្វាយអតិរេក ថ្វាយព្រះពរលាតាមទំនៀម ។

ដាស្វរេចពិធីបុណ្យតែប៉ុណ្ណេះ ។

# រឿងស្តេចឧទយន

ដកយកពីសេចក្តីល្បង អំពី គុណាពវ្យ នឹងព្រឹហត្កថា

របស់លោកហ្វេលិក្សឡាកូត ក្រម្ការ ជុំ-មៅ

ប្រែពីភាសាបារាំងសែសមកជាភាសាខ្មែរ

## រឿងឧទយន

យើងមិនមានប្រទះឃើញហេតុការផ្សេង ៗ របស់ឧទយន រៀបគ្នាឲ្យបានស្រួលល្អដូចជាក្នុងរឿងរ៉ាវនៃប្រទ្យោត (បជ្ជោត) នេះឡើយ ។ ប៉ុន្តែក្រៅអំពី មូលសព្វាស្តិវាទវិនយ, នោះប្រទ្យោត ដូចជាមិនមែនជាតួបុគ្គលដែលមានឈ្មោះទាមក្នុងរឿងរ៉ាវ; ឯ បំណែកឧទយនវិញ ឃើញបេញជាតួបុគ្គលដែលល្បីល្បាញ ឈ្មោះនាមជាញឹកញយ ។ ដោយហេតុថា ស្តេចទាំងប៉ុន្មាន ដែលរស់នៅក្នុងសម័យពុទ្ធកាល ឃើញស្តេចឧទយននេះប្រកប ដោយព្រះកិត្តិនាមខ្ទរខ្ទាយ ព្រោះទំនងជាទ្រង់បានទទួលសេច ក្តីទូន្មានរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ មកត្រួតលើកិច្ចជាមហា-ក្សត្រម្ចាស់ផែនដី ។ រឿងនីតិសាស្ត្រគឺជារឿងដែលព្រះ សម្មាសម្ពុទ្ធទ្រង់ប្រារព្ធនឹងព្រះបាទឧទយន ។

ព្រះបាទឧទយនទ្រង់រំពឹងក្នុងទីស្ងាត់ គឺទ្រង់ចង់ជ្រាបអំពី កុសលនឹងអកុសលរបស់ស្តេចទាំងឡាយ ហើយទ្រង់ពិចារណា ថា: "ប្រសិនបើនៅក្នុងទីនេះមានសមណខ្លះ សមណោកនឹង ពន្យល់អញអំពីរឿងនេះមិនខាន" ពិចារណាដូច្នេះហើយទ្រង់

ទឹកដល់ព្រះសម្មាសម្ពុទ្ធបរមគ្រូ ដែលជាអ្នកត្រាស់ដឹងគ្រប់យ៉ាងទាំងអស់ ហើយក៏ទ្រង់យាងទៅរកព្រះសម្មាសម្ពុទ្ធ ធ្វើកិរិយានមស្សការហើយក៏ក្រាបទូលសួរ ។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងប្រាប់ អំពីទសពិធទាំង ១០ និងអទសពិធទាំង ១០ សម្រាប់ម្ចាស់ផែនដី, អំពីផ្លូវទាំង ៥ ដែលនឹងនាំព្រះរាជវង្សានុវង្សទៅកាន់សេចក្ដីវិនាស, អំពីលក្ខណៈ ៥ យ៉ាងដែលនាំឲ្យព្រះរាជវង្សានុវង្សបានសេចក្ដីចំរើន, ហើយក្នុងទីបំផុតអំពីបែបបទដែលត្រូវបំពេញដើម្បីឲ្យបាននូវលក្ខណៈទាំងនេះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់ថា បើប្រព្រឹត្តតាមទាំងប៉ុន្មានប្រការនេះ នឹងបានទទួលសេចក្ដីអនុគ្រោះអំពីព្រះពុទ្ធគ្រប់ព្រះអង្គ អំពីព្រះពោធិសត្វគ្រប់ព្រះអង្គ អំពីទេវតាគ្រប់អង្គ និងអំពីនាគទាំងឡាយគ្រប់អង្គ។ ក្នុងវេលានោះព្រះបាទឧទយន ក៏យល់ព្រមតាមគ្រប់ប្រការ ។

សេចក្ដីទាំងប៉ុន្មាននេះ គ្មានត្រង់ណាដែលខុសអំពីសេចក្ដីដែលគេប្រទះឃើញក្នុងសាសន៍ណាមួយទៀយ ទាំងក្នុងសេចក្ដីដែលបំពោះតែខាងព្រះពុទ្ធសាសនា ក៏ដូចគ្នា ព្រះសម្មាសម្ពុទ្ធទ្រង់ទទួលសម្ដែងតែពីរឿងបំពេញកិច្ចជាផ្លូវសាសនា ប៉ុន្តែ

សេចក្ដីដែលទ្រង់ប្រារព្ធសម្ដែងនេះ គ្រាន់តែជាឧបាយតែម្យ៉ាងប៉ុណ្ណោះ ។ រឿងនេះមិនធ្វើឲ្យយើងដឹងការអ្វីច្រើនឡើយ អំពីឧទយន; ប៉ុន្តែធ្វើឲ្យយើងដឹងថា ក្នុងស្រុកដែលកាន់ព្រះពុទ្ធសា-សនា នោះឈ្មោះឧទយនតែងប៉ះពាល់ដល់គំនិតរាល់គ្នាតែកាលណាប្រារព្ធដល់កិច្ចការជាកលឧបាយ : ដែលពោលថា ឧទយនបេះដឹងដោយការប្រដៅនៃព្រះសម្មាសម្ពុទ្ធ នោះជាការធម្មតាដូចជាជនជាតិក្រិកម្នាក់ពោលថា ឧលិស្ស បេះដឹងដោយការប្រដៅនៃប៉ាល្លាស អបេណេ ដូច្នោះដែរ ។

ក្រៅអំពីគម្ពីរ នីតិសាស្ត្រ មានសេចក្ដី ១ ទៀតក្នុងព្រះត្រៃបិដក បិនុយកឈ្មោះឧទយនទៅដាក់ជាបំណងជើងរឿង គឺរឿងឧទយន-វត្សរាជ-បរិប្បជ្ជា ដែលជារឿង ១ ដកយកចេញពីមាគន្ទិកាវទាន រឿងនេះយើងនឹងបានឃើញទៅមុខឯណោះ ។

មាននិទាន ១ វែងគ្រប់គ្រាន់ដែលសម្ដែងអំពីឧទយន គឺក្នុងទិវ្យាវទាន លេខ ៣៦ ដែលត្រូវគ្នានឹង មូលស៌ាស្តិវាទវិនយរបស់ចិន (បោះពុម្ពនៅក្រុងតូក្យូ) ; ប៉ុន្តែក្នុងអដ្ឋកថាព្រះធម្មបទឃើញមានពោលល្អិតល្អោចអំពីរឿងឧទយន ។ ឯចំណែក

ខាងគម្ពីរទិវ្យាវទានវិញ មិនឃើញមាននិយាយអំពីនាង វាស-
វទត្តា ទេ; តែសេចក្ដីនេះមិនបាច់សង្ស័យអ្វីឡើយ គឺជាសេច
ក្ដីដក ១ បទចេញមក, ហើយឯចំណែក មូលសវ៌ាស្តិវាទវិន័យ
វិញមានអធិប្បាយរឿងនាង វាសវទត្តា ដូចក្នុងរឿងប្រទ្យោត
(បជ្ជោត); ដែលយើងបានឃើញក្នុងខាងលើនោះដែរ, ព្រះ
ពុទ្ធឃោសាចារ្យ បានបញ្ចូលរឿងនេះទៅក្នុងរឿងឧទយន ។
ខ្ញុំយល់ឃើញថា សេចក្ដីនេះហាក់ដូចមានកង្វល់ខ្លះ ដែលនឹង
យកមកប្រមូលផ្ដុំជាហេតុការរបស់ឧទយន ។ ខ្ញុំឃើញមាន
ក្នុងសេចក្ដីអធិប្បាយមួយ ដែលជាការចាត់ចែងរបស់ព្រះពុទ្ធ-
ឃោសាចារ្យ ដែលស្រង់យកនិទានរឿងកំណើតរបស់ឧទយន
ទៅដាក់ជាខាងដើម គឺទំនងជាលោកមានសេចក្ដីប្រាថ្នានឹងត
រឿងរបាក្សត្រនៃស្ដេចពួកវត្ស ទេដឹង ។

រឿងនេះខ្ញុំចាប់ផ្ដើមអំពី អដ្ឋកថាព្រះធម្មបទ ដោយយក
សៀវភៅ ដែលលោកហ្វូស្បូល់បានផ្សាយ, ហើយឯកន្លែងត្រង់
ណាដែលលោកហ្វូស្បូល់កាត់ចោលចេញនោះ ខ្ញុំយកសៀវភៅ

អក្សរសីហឡ ដែលលោក គុណរតន បោះពុម្ពនៅកុឡុម្បូរពី ក្នុងឆ្នាំ ១៨៨៦ មកពិនិត្យបំពេញ ។

ព្រះបាទ បរន្តប ព្រះចៅក្រុងកោសម្ពី ទ្រង់គង់ក្រសាល ក្នុងទីព្រះលាន ដើម្បីយកកំដៅព្រះអាទិត្យពេលព្រឹក មួយអន្លើ ដោយព្រះអគ្គទេពីដែលកំពុងទ្រង់គភ៌ ។ ក្នុងវេលានោះព្រះអគ្គ-ទេវីយកឆ្លងព្រះអង្គពណ៌ក្រហមរបស់ព្រះស្វាមីទៅគ្រលុំ ហើយ ទ្រង់ប្រាស្រ័យសំណេះសំណាលទៅវិញទៅមកជាមួយនឹងព្រះ ភស្តារ ហើយព្រះនាងក៏ទ្រង់ដោះព្រះទំរង់ត្រាពីម្រាមព្រះហស្ត ព្រះស្វាមីយកមកពាក់លេងនៅម្រាមព្រះហស្តនាង, "ក្នុងវេ-លានោះ មានសត្វហត្ថលិង្គ ហើរតាមអាកាសមកដល់ក្នុងទី នោះ; លុះមើលពីចំងាយមកឃើញព្រះនាងទ្រង់គ្រលុំព្រះពស្ត្រ ក្រហម ក៏គិតស្មានថា ជាដុំសាច់ ១ ដុំ ហើយបក្សីក៏សម្ទបស្លាប បោះពួយបុះមក ។ ព្រះមហាក្សត្រលុះឮសន្ធឹកបក្សីបោះពួយបុះ ដូច្នោះក៏ស្លុតព្រះទ័យហើយស្ទុះរត់ចូលទៅក្នុងព្រះដំណាក់; ឯចំ-ណែកព្រះអគ្គទេវីដោយទ្រង់គភ៌ផង ដោយជាស្ត្រីស្មារតីតិចផង ក៏ស្ទុះរត់ចូលមិនទាន់ ។ ហត្ថលិង្គបោះពួយទៅលើព្រះនាង

ហើយឆាបឬ្សាមជាប់ក្នុងក្រញាំជើងហើរឡើងទៅអាកាសវិញទៅ ឯបក្សីដែលមានកំឡាំង « ស្មើនឹងដំរី ៥ នេះ » តែងតែប្សាមក្តោប បំណាំដោយក្រចកហើរយកទៅលើអាកាស ហើយបរិភោគ ។ ក្នុងវេលាដែលបក្សីកំពុងហើរព្រះនាងពិចារណាថា បើនឹងស្រែកទៅសត្វនេះច្បាស់ជាផ្អើលភ្ញាក់ ហើយនឹងលែងទំលាក់អញ បោលមិនខាន ព្រោះសត្វទាំងអស់តែងខ្លាចសំឡេងមនុស្ស បើដូច្នេះគួរបង្អង់បន្តិចមើលសិន ។ វេលានោះបក្សីក៏នាំយកទៅដល់កន្លែងមួយឆ្ងាយក្នុងភ្នំហិមវន្ត ចូលទៅក្នុងដើមព្រះជ្រៃមួយក៏ដាក់ចុះលើប្រគាប ។ ក្នុងវេលាដែលបក្សីកំពុងតែងាកចុះឡើងជុំវិញខ្លួនមុននឹងបរិភោគ ព្រះនាងក៏តាំងទះព្រះហស្តហើយស្រែកឡើង ហើយបក្សីភ័យខ្លាចក៏ស្ទុះហើរទៅ ។ ក្នុងយប់នោះមានផ្គររន្ទះផ្លៀងនឹងព្យុះជាខ្លាំងហើយព្រះនាងអស់ព្រះកាយពលណាស់ផងដោយមានទុក្ខជាទំងន់ផងក៏នៅភ្លឹះៗក្នុងរាត្រីនោះទៅ « លុះដល់ពេលដែលរាត្រីស្វាងឡើងដោយអំណាចពពករសាត់បេញអស់ទៅ ហើយពន្លឺព្រះអាទិត្យក៏លេចឡើងខាងទិសបូព៌ា ។ ដោយព្រះនាងប្រសូតិព្រះរាជបុត្រក្នុងពេលផ្គរផ្លៀងខ្យល់ព្យុះ, ពេលបែក

បបួសហើយនៅលើភ្នំ ព្រះនាងក៏ទ្រង់សន្មតិព្រះនាមព្រះរាជកុមារថា "ឧទេន" ។ នៅជិតទីនោះព្រះបាទអល្លកប្បទ្រង់មកបួសជាតាបសហើយតាំងអាស្រមនៅ ។ អល្លកប្បតាបសបានឃើញព្រះនាងហើយ ក៏មានសេចក្ដីអាសូរករុណា ដាក់បង្គោងឲ្យចុះពីដើមឈើមកទាំងមាតានឹងបុត្រ ដោយឥតឲ្យប៉ះពាល់ដល់កាយព្រះនាងឡើយ ហើយនាំយកមកនៅក្នុងអាស្រមឲ្យបរិភោគអាហារ ។ ព្រះនាងពិចារណាថា តាបសនេះអាចនឹងបោះបង់ព្រះនាងចោលក្នុងថ្ងៃណា ១ មិនខាន ហើយព្រះនាងក៏នឹងស្លាប់ជាមួយនឹងព្រះរាជឱរស ដោយមិនបានស្គាល់ផ្លូវដែលនឹងត្រឡប់ទៅនគរវិញឡើយ ។ នាងពិចារណាទៅក៏ឃើញមានតែផ្លូវម្យ៉ាងជាទីនាំឲ្យរួចទុក្ខ គឺថាធ្វើឲ្យតាបសស្រឡាញ់ គិតដូច្នោះហើយនាងក៏ធ្វើបានសម្រេចដូចសេចក្ដីប៉ុនប៉ង ហើយក៏តាំងនៅរួមជាមួយគ្នាជាស្រួលតមក ។

ក្នុងថ្ងៃ ១ តាបសពិនិត្យមើលផ្កាយលើមេឃហើយក៏ស្រែកថាៈ "ស្ដេចបរន្តបសុរិណ្ណគតហើយ" ។ ព្រះនាងក៏តាំងទ្រង់ព្រះកន្សែង តាបសទើបសួរថា ហេតុអ្វីក៏យំ ព្រះនាងឆ្លើយ

តាមត្រង់ ថាស្តេចបរន្តបជាព្រះស្វាមីនាង ។ ដើម្បីនឹងលួងព្រះនាងកុំឲ្យមានទុក្ខនោះតាបសពោលថា "ធម្មជាតិដែលកើតឡើងហើយតែងតែស្លាប់ទៅវិញជាធម្មតា" ។ ក្នុងវេលានោះព្រះនាងឆ្លើយតបថា "ដែលខ្ញុំយំនេះ គឺយំអាណិតកុមារជាកូនខ្ញុំទ្រោះនឹងមិនបានទទួលរាជសម្បត្តិតរាជវង្សទៅ ។ តាបសឆ្លើយឡើងថា "ខ្ញុំនឹងចាត់ការនេះឲ្យបានសម្រេច" ថាដូច្នេះហើយក៏ប្រគល់ពិន ១ ឲ្យព្រះរាជកុមារ ហើយបង្រៀនមន្ត ១ យ៉ាងដើម្បីហៅដំរីមកផង្ហាំង ។ លុះបង្ហាត់បាន ៣ ថ្ងៃក៏បានបេះចាំស្ទាត់ល្អមទុកចិត្តបាន ។ នៅថ្ងៃទី ៣ មេក្លោងដំរីមកលុតក្រាបនៅមុខព្រះកុមារ ។ ក្នុងវេលានោះតាបសបង្គាប់ព្រះនាងឲ្យ ។ ដំបូន្មានដល់ព្រះកុមារ ដើម្បីឲ្យចេញពីគុហាទៅទទួលយករាជសម្បត្តិតែម្តង ។ ព្រះនាងប្រាប់ឧទេនកុមារឲ្យដឹងថា ខ្លួនព្រះកុមារជារាជបុត្រស្តេចក្រុងកោសម្ពីទ្រង់ព្រះនាមបរន្តប ហើយប្រាប់ឈ្មោះសេនាបតីរបស់សម្តេចព្រះវររាជបិតា ហើយដើម្បីនឹងឲ្យគេជឿជាក់ឥតសង្ស័យនោះ ព្រះនាងបានប្រគល់ទូវព្រះភូសានឹងព្រះទម្រង់របស់ព្រះស្វាមី ។ ឧទេនកុមារទ្រង់ឡើងលើមែកឈើ

ទាប ១ ហើយតាំងរាយមន្តហៅដំរី ក្នុងវេលានោះមេក្មេងដំរីក៏ចូលមកក្រាបនៅចំពោះព្រះភក្ត្រ ព្រះកុមារទ្រង់ឡើងលើដំរីហើយឱនខ្សឹបដាក់ត្រចៀកប្រាប់អំពីសេចក្តីប្រាថ្នារបស់ព្រះអង្គ ។ មេក្មេងដំរីក៏បន្លឺនូវសម្រែកយ៉ាងខ្លាំង ដើម្បីប្រមូលផ្តុំដំរីទាំងអស់រាប់ពាន់ ។ ដំរីដែលជរានឹងក្មេងលោកក៏ឲ្យវិលត្រឡប់ទៅវិញទុកតែដំរីណាដែលមានកំឡាំងពលំល្មមធ្វើការសង្គ្រាមបាន ។ ឱទេនកុមារលុះផ្តុំដំរីបានច្រើនដូច្នេះហើយក៏សុំដៅឆ្ពោះព្រះនគរដើម្បីទារយករាជសម្បត្តិ ឬឲ្យបេញច្បាំង ។ ក្នុងវេលានោះពពួកអាណាប្រជានុរាស្ត្រឆ្លើយតបមកវិញថា "យើងមិនព្រមប្រគល់រាជសម្បត្តិ ហើយយើងមិនព្រមច្បាំង ព្រោះយើងមិនទាន់បានដឹងជាព្រះរាជទេវី ដែលសត្វហត្ថីលិង្គឆាបទៅកំពុងទ្រង់គភ៌នោះជាស្លាប់ឬរស់ ឱទេនកុមារតាំងរាប់ឈ្មោះសេនាបតីហើយបង្ហាញព្រះភូសានឹងព្រះទម្រង់ដែលជារបស់តាងឲ្យមើលហើយក្នុងវេលានោះគេក៏បើកទ្វារព្រះរាជវាំងថ្វាយ ហើយលើកឲ្យសោយរាជសម្បត្តិតព្រះរាជវង្សក្នុងវេលានោះ ។

រឿងដដែលនេះប្រទះឃើញមានក្នុងគម្ពីរ បបញ្ចសូទនី (មជ្ឈិមនិកាយអដ្ឋកថា) នឹងក្នុង ពោធិរាជកុមារសុត្ត ប៉ុន្តែជាសេចក្តីខ្លីៗណាស់ ។ រឿងនេះមានសេចក្តីកាត់យ៉ខ្លីៗពីរបីបន្ទាត់តទៅទៀត ត្រង់ដែលស្តេចបណ្ឌាបជ្ជោត ចាប់ព្រះបាទឧទេនបានទៅ នឹងត្រង់ដែលបង្រៀនមន្តដល់បុត្រីស្តេចបណ្ឌាបជ្ជោត នឹងអំពីនាំគ្នារត់បេញពីនគរ ។

ខ្ញុំមិនស្រង់រឿងឃោសកក្នុងជាតិទី ២ ដែលមានសម្តែងក្នុងគម្ពីរធម្មបទដ្ឋកថា មកសម្តែងទេ ព្រោះរឿងនេះឃើញមានក្នុងគម្ពីរមនោរថប្បូរណី (ទំព័រ ២៥១ បោះពុម្ពនៅក្លូឡុម្ប្បូរពីឆ្នាំ ១៨៩៣) រឿងនេះលោក អ. ហារឌី បានប្រែបេញពីភាសាបាឡី អំពីច្បាប់ទាំងពីរ ។ ក្នុងរឿងនោះព្រះបាទឧទេនមិនជាមានរឿងរ៉ាវអ្វីជាដុំកំភួនទេ គឺឃើញគ្រាន់តែប្រគល់នូវទ្រព្យសម្បត្តិទាំងប៉ុន្មានជារបស់អាពុកឃោសក ឲ្យដល់ឃោសកជាកូន ។

តពីនេះគេហួសទៅនិយាយរឿងនាងសាមាវតីវិញ ។ នាងនេះជាបុត្រីសេដ្ឋីម្នាក់ ឈ្មោះភទ្ទវតីដែលជាសម្លាញ់គ្នានឹងឃោ-

សិតសេដ្ឋី (គឺជាឃោសកក្នុងរឿងមុននេះឯង) នាងនេះបាន មកឯស្រុកកោសម្ពីជាមួយនឹងអាពុកម្ដាយ ដោយរត់ពីជំងឺឆ្លង ដែលកើតក្នុងស្រុកខ្លួន ទាំង ៣ នាក់មកតាមផ្លូវអត់បាយជាច្រើន ថ្ងៃ ហើយចូលមកសុំទាននៅមាត់ទ្វារក្រុង ឯអាពុកនឹងម្ដាយ ចូលទៅរកឃោសិតជាសម្លាញ់មិនទាន់ក៏ស្លាប់មុនទៅ ។ វេលា ដែលបានរងទុក្ខលំបាកជាច្រើនហើយ ទើបបានសេដ្ឋីចិត្តបុណ្យ នោះទទួលនាងសាមាវតីធ្វើជាបុត្រីចិញ្ចឹម ។ ក្នុងថ្ងៃ ១ ព្រះបាទ ឧទេនបានឃើញនាងហើយជាប់ព្រះទ័យស្នេហា ទើបបង្គាប់ដល់ ឃោសិតសេដ្ឋីឲ្យយកទៅថ្វាយ តែវេលានោះសេដ្ឋីមិនព្រម ថ្វាយតាមសេចក្ដីត្រូវការរបស់ព្រះមហាក្សត្រ, ព្រះបាទឧទេន ទ្រង់ព្រះក្រោធក៏បណ្ដេញឃោសិតចេញពីផ្ទះខ្លួន ។ ក្នុងវេលា នោះនាងសាមាវតីនិយាយអង្វរអាពុកចិញ្ចឹម ឲ្យថ្វាយនាងទៅ ស្ដេចតាមសព្វព្រះទ័យចុះ តែសូមឲ្យស្ដេចលើកដំកើងឲ្យមាន កិត្តិយស ហើយឲ្យមានបរិវារសម្រាប់បំរើ ។ ព្រះមហាក្សត្រទ្រង់ យល់ព្រម ហើយក៏នាងជារាជទេពីនាំយកទៅក្នុងព្រះបរម-

រាជវាំង តាំងឲ្យនៅក្នុងទីសម្រាប់រាជទេពីសក្តិខ្ពស់ មួយអន្លើដោយបរិវារទាំងឡាយជាច្រើន ។

ព្រះបាទឧទេន មានរាជទេពី ១ ទៀតឈ្មោះនាងវាសុលទត្តា; គឺជាបុត្រីព្រះបាទបណ្ឌបជ្ជោត ស្ដេចស្រុកឧជ្ជេនី ។ មហាក្សត្រនេះទ្រង់មានឥច្ឆានឹងព្រះបាទឧទេន, ទ្រង់តាំងធ្វើដំរីយន្តបញ្ឆោតចាប់យកព្រះបាទឧទេនបាន យកទៅឃុំក្នុងគុកហើយដោយទ្រង់មានសេចក្ដីរីករាយសប្បាយក្នុងព្រះទ័យណាស់ ក៏ទ្រង់បាត់ការធ្វើបុណ្យ ជប់លៀងកំណត់ ៣ ទិវា ។ ព្រះបាទឧទេនបានជ្រាបរឿងអំពីនាយគុកក៏ទ្រង់ព្រះក្រោធ ហើយប្ដេជ្ញាព្រះទ័យគុំស្ដេចបណ្ឌបជ្ជោតជាមាំមួន ។ ក្នុងវេលានោះស្ដេចបណ្ឌបជ្ជោតបង្គំឲ្យព្រះបាទឧទេន បង្រៀនមន្តជាទីសំងាត់ដើម្បីផ្សាំងដំរី ។ ព្រះបាទឧទេនទទួលបង្រៀន ប៉ុន្តែត្រូវឲ្យអ្នកដែលរៀននោះថ្វាយបង្គំគោរពជាមុនសិន ស្ដេចបណ្ឌបជ្ជោតមានសេចក្ដីមានះខ្លាំងមិនព្រមបុះវិន្ទាឡើយ តែទ្រង់ពិចារណាថានឹងឲ្យព្រះរាជបុត្រីមកធ្វើជាសិស្សព្រះបាទឧទេន ។ គិតដូច្នេះហើយទ្រង់មានព្រះបន្ទូលថា "ខ្ញុំមានស្រីគមម្នាក់ក្នុងទីនេះត្រូវឲ្យ

វានៅក្នុងរាំងនន ហើយខ្ទុនស្តេចនៅពីខាងក្រៅ ហើយស្តេចបង្រៀនវាពីខាងក្រៅ ។ ព្រះបាទឧទេនក៏ព្រម ។ តពីនោះស្តេចបណ្ឌបជ្ជោតមានព្រះបន្ទូលនឹងនាង វាសុលទត្តា ជាបុត្រីថាឲ្យទៅរៀនមន្តពីអំពីសំណាក់មនុស្សឃ្លង់ម្នាក់ ដែលពួននៅពីក្រៅរាំងនន ។ លុះតាំងបង្រៀនទៅ កូនសិស្សទន្ទេញក្រឰតទឹងហើយក៏ស្រែកជេរទៅថា "ខ្មោចមេគមរៀនអីក្របាំម្លេះ" ព្រះនាងខ្ញាល់ក៏ស្រែកជេរទៅវិញថា "អាគម្លង់" ។ ព្រះបាទឧទេនទ្រង់ព្រះក្រោធជាត់ជាយរាំងននឡើង ក៏ស្គល់គ្នាំងនៅធ្មឹងទាំងពីរនាក់ទៅ តពីនេះក៏ប្រាប់ហេតុទៅវិញទៅមកទាំងអស់ ។ ឧបាយកលរបស់ស្តេចបណ្ឌបជ្ជោត ដែលធ្វើមិនឲ្យឃើញគ្នាទៅវិញទៅមក ត្រឡប់ជារិតតែឲ្យស្រឡាញ់ស្និទ្ធស្នាលនឹងគ្នាទៅទៀត ។ លុះដូច្នេះហើយ ក្សត្រទាំងពីរក៏រិតតែធ្វើពេលបង្រៀនឲ្យរិតតែយូរទៅ ។ ព្រះបាទឧទេនបបួលព្រះនាង វាសុលទត្តារត់ទៅជាមួយសន្យានឹងដំកល់ធ្វើជាអគ្គមហេសី ហើយឲ្យនៅក្នុងប្រាសាទ១យ៉ាងធំទូលាយ ។ ប៉ុន្តែក្នុងគ្រានោះព្រះនាងក្រាបទូលព្រះវររាជបិតាថា ព្រះនាងបេះបាំស្ទាត់ហើយ ហើយសុំព្រះ

រាជានុញ្ញាតបានដើម្បីចេញក្នុងវេលាយប់តាមទ្វារណា ១ ហើយ ត្រឡប់ចូលមកវិញ តាមតែពេលណាក៏ដោយ ប្រយោជន៍នឹងដកយកស្មៅដែលមានឫទ្ធិ តាមដោយផ្កាយលើមេឃកំណត់ឲ្យ ហើយស្មៅនោះនឹងយកទៅធ្វើជាគ្រឿងរណ្ដាប់សំរាប់មន្តដែលរៀន ។ តាំងពីនោះមក គេធ្លាប់ឃើញព្រះនាងនឹងព្រះបាទឧទេន ចេញចូលតាមទ្វារជាមួយគ្នា ។ ស្ដេចបណ្ឌបជ្ជោតមានដំរីញី ១ ឈ្មោះភទ្ទវតីមានកំឡាំងដើរផ្លូវ ១ ថ្ងៃបាន ៥០ យោជន៍, មានសេនាម្នាក់ឈ្មោះកាកៈដើរផ្លូវ១ថ្ងៃបាន៦០យោជន៍, មានសេះ២ ឈ្មោះចេឡកណ្ឋិ ១ មុញ្ជកេសិ ១ ដើរផ្លូវ ១ ថ្ងៃបាន ១០០ យោជន៍ មានដំរីឈ្មោល ១ ឈ្មោះនាឡាគិរិ អាចដើរផ្លូវ ១ ថ្ងៃបាន ១២០ យោជន៍ - តពីត្រង់នេះទៅមាននិទានរឿងជាអតីតកាល ដែលមិនមានប្រយោជន៍ដល់យើងក្នុងវេលានេះឡើយ ។ ក្នុងថ្ងៃ ១ ស្ដេចបណ្ឌបជ្ជោតទ្រង់យាងទៅក្រសាលក្នុងឧទ្យាន ហើយព្រះបាទឧទេន ទ្រង់ជ្រាបដូច្នោះ ក៏ទ្រង់ពិចារណាថា ឱកាសនេះស្រួលល្អណាស់ ។ ទើបយកមាសដាក់ក្នុងថង់ជាច្រើន ហើយផ្ទុកលើខ្នងភទ្ទវតី ទ្រង់ឡើងជិះលើខ្នងជាមួយនឹង

ព្រះនាងវាសុលទត្តា ហើយបររត់ទៅ ។ ស្ដេចបណ្ដាបជ្រោតទ្រង់បានជ្រាបរឿងនេះ ដោយពួកទាហានចាំព្រះដំណាក់បានទូលហើយក៏ទ្រង់បាត់ឲ្យលើកកងទ័ពដេញតាម ។ វេលាដែលឃើញកងទ័ពដេញជិតទៅ ព្រះបាទឧទេនក៏ទ្រង់រះបង់មាស ទំលាក់រាយបុះតាមផ្លូវ ពួកទាហានដែលដេញតាមឃើញមាសដូច្នោះក៏នាំគ្នាឈប់រើស ។ ការដែលប្រើឧបាយនេះញយៗនាំឲ្យរត់រួចដល់ព្រៃនគរ ព្រះបាទឧទេនក៏យាងចូលទៅដល់ក្រុងកោសម្ពីយកព្រះនាងវាសុលទត្តាជាព្រះទេពី បញ្ចូលក្នុងពួកព្រះទេពីធំៗទាំងប៉ុន្មានអង្គ ។

ព្រះបាទឧទេន មានព្រះទេពី ១ ទៀតឈ្មោះនាង មាគន្ទិយា ។ រឿងរ៉ាវរបស់នាងនេះ ជាប់គ្នានឹងរឿងរ៉ាវរបស់នាងសាមាវតី ហើយរឿងនាងសាមាវតីនេះចេញមកអំពីរឿង ឃោសិតសេដ្ឋី ប៉ុន្តែរឿងទាំងពីរខាងលើនេះ ឥតមានទាក់ទិនអ្វីនឹងរឿងនាងវាសុលទត្តាឡើយ ។ ឯរឿងនាងវាសុលទត្តានេះនាំឲ្យជាប់រឿងទាំងពីរខានជាប់តគ្នា ព្រោះមកនៅជ្រែកជាកណ្ដាល ។

( មានតទៅទៀត )

# សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ធរបនបណ្ឌិត

នៅព្រះរាជបណ្ណាល័យរៀបរៀង

(ត)

ពួកអ្នកកាន់លទ្ធិព្រហ្មញ្ញ រមែងគោរពបូជាទេវតាដូចពោលហើយនឹងប្រព្រឹត្តប្រតិបត្តិតាមពាក្យប្រដៅក្នុងគម្ពីរត្រៃវេទ (ដែលយើងហៅត្រៃភេទ) នឹងវេទាង្គដ៏ជាគម្ពីរដើមរបស់គេ បែបយ៉ាងគម្ពីរព្រះត្រៃបិដករបស់ពួកយើង សឹងសំដែងអំពីកិច្ចសម្រាប់បួងសួងទេវតានឹងពិធីការបូជាយញ្ញ ព្រមទាំងមន្តសម្រាប់សែន ឯគម្ពីរត្រៃវេទនោះមាន ៣ គម្ពីរ គឺៈ –

១ គម្ពីរ សាមវេទ សំដែងអំពីពិធីអារក្ខាពលីកម្ម គឺ បួងសួងសូមឲ្យព្រះឥន្ទ្រនឹងព្រះពរុណជួយអភិបាលមនុស្សលោក ឲ្យភ្លៀងធ្លាក់ចុះមកស្រោចស្រង់លោកត្រូវតាមរដូវកាល ឲ្យធញ្ញជាតិនឹងបណ្ដាដំណាំទាំងពួងដុះលូតលាស់ល្អបរិបូណ៌ ឲ្យមនុស្សនឹងសត្វបានចិញ្ចឹមជីវិតមានកូនចៅចំរើនពូជពង្ស នឹងសូមឲ្យប្រាសចាកឧបទ្រពអន្តរាយដោយប្រការទាំងពួង ។

២ គម្ពីរ អស្សវេទ ឬហៅមួយយ៉ាងទៀតថា ឥរុវេទសំដែងអំពីពិធីតុស្តិ (ឬស្តុតី) សូមឲ្យព្រះវិស្សុកម្មនឹងព្រះមារុតព្រះព្រហ្មប្រសិទ្ធិប្រទានពរ ឲ្យសម្រេចកិច្ចក្នុងការហត្ថកម្មពានិជ-

កម្ម និងសូមឲ្យសម្រេចផលប្រយោជន៍ បានលុះលាភសក្ការ ផ្សេងៗតាមដែលត្រូវការ ។

៣ គម្ពីរ យជុរវេទ គឺយុជយុទ្ធ សំដែងអំពីធ្វើពិធីយុទ្ធ-ពលីកម្មដល់ព្រះឥសូរ ព្រះនារាយណ៍ ព្រះអាទិត្យ ព្រះអគ្គិនី សូមឲ្យមានឫទ្ធិតេជៈជោគជ័យ ឈ្នះអស់សឹកសត្រូវទាំងសម្ពាយ និងសូមឲ្យកំចាត់ឧបទ្រពអន្តរាយទាំងពួង ។

ក្នុងព្រះវេទ ៣ ប្រការនេះ ព្រះវេទមួយៗ លោកបំណែកចេញជា ២ ផ្នែក គឺហៅថា វេទ ឬព្រហ្ម ១ ផ្នែក មន្ត ១ ផ្នែក ។ ផ្នែកវេទ បាននិងពិធីកម្មរបៀបការដែលនឹងចាត់គ្រឿងសក្ការបូជាយព្រះជាម្ចាស់, ផ្នែកមន្ត បាននិងរបៀបពាក្យសារស្លោក សម្រាប់សូត្រស្លូតីអង្វរនិងសរសើរព្រះជាម្ចាស់ ដើម្បីនឹងឲ្យទ្រង់មេត្តាប្រោសប្រសិទ្ធិប្រទានពរឲ្យតាមដែលត្រូវការ ។ គម្ពីររបស់ព្រាហ្មណមិនមែនមានតែ ៣ ប៉ុណ្ណេះ នៅមានគម្ពីរឯទៀត ដែលអ្នកប្រាជ្ញបានរបនាតាក់តែងបំបែកអំពីគម្ពីរដើមទាំង ៣ តទៅទៀត និងតែងឡើងក្នុងជំនាន់ក្រោយជាច្រើន បែបអដ្ឋកថានិងដីការបស់ព្រះត្រៃបិដកដូច្នោះ ។

ព្រាហ្មណឫជាតិឯទៀតអ្នកដែលកំពុងរៀនព្រះវេទទាំង៣ នេះហៅថា"ព្រហ្មចារី" អ្នកបំពេញព្រហ្មគឺព្រះវេទ ។ អ្នករៀនចេះចប់ហើយហៅថា "វេទគូ" អ្នកដល់នូវទីបំផុតនៃព្រះវេទ, ឬហៅថា "បារគូ" អ្នកដល់នូវត្រើយនៃព្រះវេទ គឺស្រេចកិច្ចដែលជាហេតុតោងនៅក្នុងសំណាក់គ្រូហើយ ដូច្នេះបុគ្គលដែលហៅថា "ព្រាហ្មណ" គប្បីប្ចូលបិត្តថា មានជា ២ យ៉ាង គឺព្រាហ្មណដោយជាតិ ១ យ៉ាង ព្រាហ្មណដោយលុះគុណធម៌ គឺត្រៃវេទ ១ យ៉ាង ។ ព្រាហ្មណពួកក្រោយនេះចាត់ជាព្រាហ្មណជាន់ខ្ពស់បំផុត អ្នកដទៃមានក្សត្រិយ៍ជាដើមត្រូវគោរព ដូចយ៉ាងយើងគោរពព្រះសង្ឃសមណ ។

១ បដិបត្តិក្នុងលទ្ធិព្រហ្មញ្ញ

ពួកអ្នកកាន់លទ្ធិនេះមានសេចក្តីឃើញថា លោកជាតុនឹងវត្ថុជាតុទាំងពួងបណ្តាដែលមាននៅក្នុងពិភពនេះ ព្រះជាម្ចាស់ទ្រង់សាង ទ្រង់បង្កើតឡើងទាំងអស់ បណ្តាជាតុទាំងពួងមានទឹកដីភ្លើងខ្យល់អាកាសជាដើម សុទ្ធតែមានទេពប្រចាំនៅទាំង

អស់ ដូច្នេះកាលគេត្រូវការអ្វី ក៏ក្រាបសំពះបួងសួងបន់ស្រន់ព្រះជាម្ចាស់នឹងទេវតានោះ ៗ សុំឲ្យប្រសិទ្ធិប្រទានពរឲ្យខ្លួន ដោយមកសំគាល់ឃើញថា អ្នកនឹងបានសុខ ព្រោះព្រះជាម្ចាស់ប្រទានឲ្យ នឹងបានទុក្ខ ព្រោះព្រះជាម្ចាស់ដាក់ទំនាយ គឺទាយឲ្យវិនាសហិនហោចទៅ អ្វី ៗ ទាំងអស់ស្រេចនឹងព្រះជាម្ចាស់ប្រទានឲ្យ ព្រះជាម្ចាស់មានអំណាចអាចនឹងបណ្ដាលរបស់ទាំងពួងឲ្យប្រព្រឹត្តទៅតាមព្រះហឫទ័យបំណងបានគ្រប់យ៉ាង ដូច្នេះកាលបើអ្នកណាមួយប្រាថ្នាអ្វី គប្បីបំពេញកិច្ចក្នុងលទ្ធិនោះតាមដែលគេកំណត់ទុកដោយសារុបមាន ៣ យ៉ាង គឺ៖

ធ្វើទុក្ករកិច្ចទរមានរាងកាយ ហៅថា បំពេញតបៈ១

តាំងពិធីបួងសួងបូជាហៅថា បូជាអគ្គិឬបូជាយញ្ញ១

ធ្វើពិធីជំរះលាងបាបក្នុងគង្គា ហៅថា សិរិរាត្រី ១ ។

១ ពិធីបំពេញតបៈ

ឯពិធីបំពេញនោះគឺ ប្រព្រឹត្តទរមានរាងកាយយ៉ាងតឹងរឹងឲ្យបាននូវសេចក្ដីលំបាកទៀបស្លាប់ខ្លះ ដល់នូវសេចក្ដីស្លាប់ខ្លះ

ដូចយ៉ាងប្រព្រឹត្តដើរនឹងឈរជាវត្ត មិនដេកមិនអង្គុយ, រដូវក្តៅត្រូវអាំងភ្លើង ៥ គម្ពរ គឺដុតភ្លើងឡើងជុំវិញខ្លួន ៤ គម្ពរ លើក្បាល ១ គម្ពរទៀត គឺកំដៅព្រះអាទិត្យ, រដូវភ្លៀងត្រូវឈរហាលភ្លៀង, រដូវល្ហាត្រូវប្រើសំពត់ទទឹក, នឹងប្រព្រឹត្តស៊ីតែផ្លែឈើចិញ្ចឹមជីវិតតាងបាយតាងនំ ដោយបួលចិត្តថា តេជៈដែលប្រព្រឹត្តតបៈដូច្នោះ បណ្តាលឲ្យក្តៅដល់ព្រះជាម្ចាស់ ៗ ទតមកឃើញអំណាចកំលាំងព្យាយាម នឹងសេចក្តីភក្តីដ៏មុតមាំមិនរញ្ញរាដូច្នោះហើយ រមែងទ្រង់មេត្តាប្រោសប្រទានពរឲ្យតាមប្រាថ្នា, នឹងបួលចិត្តថា ជាបុណ្យកុសលយ៉ាងក្រៃពេក. ប្រសិនជាស្លាប់ទៅក្នុងវេលានោះ រមែងបានទៅកើតក្នុងឋានសួគ៌ មិនតោងចុតិប្រែប្រួលទៅកើតជាអ្វីទៀត ៗ អ្នកណាប្រព្រឹត្តមិនគប្បីនឹងព្រះជាម្ចាស់ ៗ រមែងដាក់បណ្តាសាឲ្យវិនាសទៅ ឬដាក់ទណ្ឌកម្មឲ្យទទួលទោសមានកំណត់ បើជាទោសធ្ងន់ត្រូវទៅសោយទុក្ខឯនរកដោយខ្លួនឯងផង ៗ

## ២ ពិធីបូជាព្រះអគ្រនី

តាមក្នុងដំណាលថា ព្រះអគ្រនីនោះជាបុត្រ តរស្ត្រ គឺវិសពកម៌ន ខ្លះថាជាបុត្រអាកាសនឹងផែនដី លក្ខណរូបឆោម សក់សំបុរមាស ខ្លួនក្រហម មុខ ២ អណ្តាត ៧ ដៃ ៧ ជើង ៣, រូបឆោមជាកំលោះជានិច្ចមិនចេះចាស់ ព្រោះកើតឡើងថ្មីរាល់ថ្ងៃ ទ្រង់ធនូជាអាវុធ របទ្រង់ទំមសេះក្រហម, ជាអ្នកទ្រង់នូវគម្ពីរសាស្ត្រទាំងពួង ស្ថិតនៅឯឋានសួគ៌នឹងផែនដី ក្នុងទឹក មានកិច្ចជាទូត ទៅមកក្នុងរវាងឋានសួគ៌នឹងឋានមនុស្ស ។ ព្រះអគ្រនីនេះ គេរាប់បួលក្នុងពួកព្រះអាទិត្យ ព្រោះជាអ្នកមានតេជៈដូចគ្នា ពួកទេវតា អ្នកដែលមានរស្មី ព្រោះព្រះអគ្រនីប្រទានឲ្យ ។ ពួកអ្នកកាន់សាសនាព្រាហ្មណ៍រមែងរាប់អាន ព្រះអគ្រ-នីនេះជាសំខាន់ ១ យ៉ាង រហូតដល់ទៅតែងតាំងរបៀបពិធីបូជាទុកយ៉ាងមាំមួន ដូចមានតទៅនេះ ។

ក្នុងគម្ពីរគោបថព្រាហ្មណ៍ម សំដែងអំពីពិធីបូជាភ្លើងតាមបទអថិវវេទ, ក្នុងគម្ពីរតលវការព្រាហ្មណ៍ម សំដែងអំពីយញ្ញវិធីតាមបទសាមវេទ បំណែកចេញជា ៤ យ៉ាងគឺ:

១ ប្រដៅព្រះវេទដល់សិស្សទាំងឡាយ ហៅថា បូជាព្រះវេទ

២ សែនដោយគ្រឿងសំណែនទាំងឡាយមានទំជាដើម ហៅថា បូជាបិតា

៣ ដុតរបស់ក្នុងគម្ពរភ្លើងថ្វាយទេវតា ហៅថា បូជាទេវតា

៤ ឲ្យអាហារជាទាន ហៅថា បូជាសត្វទាំងឡាយ ។

ក្នុងពិធីបូជាទាំង ៤ ខនេះ ខទី ១-២- និងទី ៤ សូម្បីសំដែងដោយសង្ខេបតែប៉ុណ្ណោះ អ្នកមើលអ្នកស្ដាប់ក៏ល្មមចូលចិត្តបាន មានអត្ថដ៏គួរសមនឹងអធិប្បាយតែក្នុងខទី ៣ ហេតុនោះក្នុងទីនេះនឹងអភិប្រាយបំពោះតែខនោះដោយល្មមសមគួរ ។ ពួកអ្នកកាន់សាសនាព្រាហ្មណយល់ថា ភ្លើងមានទេវតាដែលហៅថា ព្រះអគ្គនី (គឺព្រះអគ្គិ) នៅប្រចាំ ជាអ្នកមានឫទ្ធិតេជៈដ៏វិសេសមួយយ៉ាង ទើបនាំគ្នាបូជាដើម្បីឲ្យបានឫទ្ធិតេជៈដូច្នោះ ។ តាមរឿងដើមថា ជនជាតិកោឡារីរាប់អានសាសនានាគ ដល់មកក្នុងរជ្ជកាលព្រះចៅប្បុរាជ អាសិរពិសបឹកព្រះអង្គសុគតទៅ ព្រះរាជបុត្រក្រោធនឹងអាសិរពិសណាស់ត្រាស់ឲ្យយកភ្លើងទៅដុតសម្លាប់អាសិរពិសវិនាសទៅជាច្រើន

អំពីនោះមកក៏ទ្រង់លើកលែងរាប់អានសាសនានាគ បែមករាប់អានព្រះភ្លើងនេះវិញ ។ ពួកអរិយបាននាំលទ្ធិបូជាភ្លើងនេះមកកាន់ប្រទេសកាបុល គឺកប្បុរជាដំបូង សព្វថ្ងៃនេះមានជនជាតិឥរ៍ណានៅរាប់អានពិធីនេះនៅឡើយ ។

ឯរបៀបការបូជានោះ ត្រូវជីករណ្ដៅធំនៅក្នុងរាងផ្ទូវ ៤ ដំបន់ ហើយបង្កាត់ភ្លើងក្នុងរណ្ដៅនោះឲ្យឆេះសន្ធោឡើងមុននឹងបូជា ព្រាហ្មណាតោងស្វាធ្យាយមន្តបួងសួងប្រកាសទេវតាតាមបែបដែលសំដែងទុកក្នុងគម្ពីរព្រះវេទផ្នែកមន្តនោះស្រេចហើយនាំយករបស់ផ្សេង ៗដែលជាគ្រឿងសង្វេយទេវតាទៅបង់បុះក្នុងរណ្ដៅភ្លើងនោះ នឹងយកសត្វឬមនុស្សទៅសម្លាប់នៅទីនោះយកឈាមបូជា, អ្នកខ្លះមានសទ្ធាជ្រះថ្លាខ្លាំង អារសាច់ខ្លួនឯងបូជាក៏មាន, អ្នកខ្លះសម្លាប់ប្រពន្ធកូនឬខ្លួនឯងបូជាតែម្ដងក៏មាន របៀបនេះសមគួរដល់បុគ្គលគ្រប់ជាន់នឹងគប្បីធ្វើបាន ។ នៅមានរបៀបមួយយ៉ាងទៀតប្លែកអំពីនេះបន្តិចជាកិច្ចដែលក្សត្រិយ៍នឹងគប្បីបំពេញ មានប្រាកដក្នុងគម្ពីររបស់ព្រាហ្មណានឹងក្នុងគម្ពីរខាងព្រះពុទ្ធសាសនាថា ទំនៀមព្រះមហា-

ក្សត្រិយ៍អំពីបុរាណ អ្នកប្រាថ្នានឹងប្រកាសឥស្សរភាពនៃខ្លួនជាចក្រពត្តិ ត្រូវធ្វើពិធីបូជាយញ្ញ ដែលហៅក្នុងបក្រវត្តិវត្តថា អស្វមេធ(១) ប្រែថាឆ្លាសក្នុងការសម្លាប់សេះ ។ ដំបូងត្រូវលែងសេះសព្រះទីនាំង ១ ឲ្យដើរចូលទៅជាន់ដែនប្រទេសតូចធំជិតខាងទាំងប៉ុន្មានដែលមិនទាន់ចុះចូលជាស្រុកបំណុះ នឹងឲ្យសេនាទាហាន ១ កងទ័ពលើកតាមសេះនោះទៅផង កាលលើកទៅ បើមានប្រទេសណាមួយរឹងទទឹងមិនព្រមចុះចូលជាស្រុកបំណុះ ឬចាប់សេះសនោះទុក កងទ័ពដែលលើកតាមទៅត្រូវចាត់ការវាយឲ្យបាក់បបហើយលើកបង្ហួសទៅ បើប្រទេសណាខ្លាចអំណាចព្រមបំណុះអំពីដំបូងដៃ មិនចាប់តោងធ្វើជម្លោះស្រេចហើយលើកទ័ពត្រឡប់ព្រះនគរ នាំយកទាំងក្សត្រិយ៍ម្ចាស់ប្រទេសនោះៗមកផង ដល់ព្រះនគរហើយ យកសេះសនោះទៅសម្លាប់បូជាយញ្ញ ដូចពោលហើយ ថ្វាយជាពលីដល់ទេវតា ទាំងជាគ្រឿងប្រកាសឲ្យលោកជ្រាបថា ព្រះ

(១) កាលព្រះពុទ្ធអង្គឧប្បត្តិឡើងក្នុងលោក ទ្រង់កែ១នេះទៅជា សស្សមេធ ប្រែថា ឆ្លាសក្នុងការធ្វើស្រែស្រូវ បានសេចក្តីថា អ្នកជាមហាក្សត្រិយ៍ត្រូវឲ្យឆ្លាសក្នុងការបណ្តុះបណ្តាលរាស្ត្រឲ្យចេះធ្វើស្រែស្រូវឲ្យបានផលបរិបូណ៌ឡើងជាសម្បត្តិសម្រាប់ព្រះនគរ ។

មហាក្សត្រិយ៍អង្គនោះជាបក្រពត្តិរាជបានផ្សាយព្រះតេជានុភាព រហូតប្រថពីតលហើយ ។ របៀបនេះក្សត្រិយ៍ទាំងឡាយដែលមានព្រះតេជានុភាពធំៗមានព្រះហៅយុធិស្ឋិរ ព្រះហៅមហាវិជិតជាដើមបានទ្រង់ធ្វើមកហើយក្នុងអតីតកាល ។

៣ ពិធីសិវរាត្រិ

ពិធីសិវរាត្រីនេះ តាមប្រវេណីគេធ្លាប់ធ្វើក្នុងស្ទឹងព្រះគង្គាដ៍ មាននៅក្នុងប្រទេសឥណ្ឌៀឯណោះ ហេតុម្ដេចបានជាគេកំណត់ធ្វើតែក្នុងទីនោះ មានរឿងរ៉ាវមកដូចម្ដេច ក្នុងទីនេះឃើញសមគួរនឹងនាំយកប្រវត្តិព្រះគង្គាមកសំដែងទុកក្នុងរវាងនេះឲ្យជ្រាបមូលហេតុជាមុនសិន ហើយនឹងសំដែងពិធីសិវរាត្រីជាខាងក្រោយដូច្នេះ ។

គង្គាសព្ទនេះក្នុងភាសាមគធក្ដី ក្នុងភាសាសំស្ក្រឹតក្ដីលោកថា ជាឈ្មោះនៃទឹក ពួកយើងក៏ធ្លាប់ចូលចិត្តបានតែប៉ុណ្ណោះ តែក្នុងគតិព្រហ្មញ្ញចូលចិត្តហួសពីនោះទៅទៀតថា ព្រះគង្គាជាធីតារបស់ព្រះបាទហិមវ័ត គឺភ្នំហិមពាន្ត នឹងនាងមេនការួមជនកជននីគ្នានឹងព្រះឧមាមហេសីព្រះឥស្វរ ដើមឡើយ

នៅឯឋានសួគ៌ទាំងពីរ ។ លុះមកដល់រជ្ជកាលព្រះបាទសគរក្សត្រិយ៍សូរ្យវង្ស គ្រប់គ្រងនគរស្រីអយុធ្យា មុនព្រះរាមឡើងទៅជាច្រើនជំណាក្សត្រិយ៍មានឱរសប្រាំមួយម៉ឺនអង្គ ។ គ្រាមួយនោះទ្រង់ធ្វើពិធីអស្វមេធនៅទីចន្លោះភ្នំហិមពាន្តនឹងភ្នំវិន្ធ្យ ព្រះឥន្ទ្រឃើញធ្វើពិធីមាំទាំដូច្នោះ គិតក្រែងព្រះបាទសគរនឹងមានអំណាចលើសលប់ទៅ ទើបដំណែងអង្គជារក្សសោ (គឺអារក្សទឹក) ទៅលួចសេះដែលសម្រាប់សម្លាប់បូជានោះទៅ ព្រះចៅសគរទើបឲ្យឱរសទាំងប្រាំមួយម៉ឺនស្វែងរកសេះនោះ លើផែនដីសព្វកន្លែងហើយមិនឃើញ ព្យាយាមជីកផែនដីជម្រៅប្រាំមួយម៉ឺនយោជន៍ ទើបប្រទះសេះនឹងព្រះកបិល ដែលព្រះនារាយណ៍បែងភាគមកនៅជិតសេះនោះ សាគរកុមារទាំងឡាយសំដៅទៅនឹងប្រហារព្រះកបិលក៏សំដែងឫទ្ធិកើតជាភ្លើងឆេះស្លាប់ទាំង ៦០.០០០ អង្គ ។ ន័យថា លុះតែបានទឹកព្រះគង្គាមកស្រោចស្រង់អង្គារ (ធ្អឹង) ទើបនឹងជ្រះអស់បាប នឹងឡើងទៅកើតឯឋានសួគ៌បាន ព្រះចៅសគរមិនឃើញមានឧបាយដូចម្តេចដែលនឹងឲ្យទឹកគង្គាមកដល់អង្គារឱរសបានក៏ទ្រង់ស្ងៀមបុំណ្ណោះទៅ ។

អំណាំសលង់មកជាអង្វែងឆ្នាំ ក្នុងរជ្ជកាលព្រះបាទភគីរថក្នុងវង្សនោះស្ដេចចេញទ្រង់ផ្នួសជាឫសី បានបំពេញវត្តយ៉ាងតឹងរ៉ឹងមាំមួន ទាល់តែព្រះព្រហ្មកើតមេត្តាចុះមកប្រទានពរ ព្រះរាជឫសីភគីរថទូលសុំពរ ឲ្យបានព្រះគង្គាហូរចុះមកលាងជំរះអង្គារសាគរកុមារ ព្រះព្រហ្មក៏អំណោយតាមប្រាថ្នា តែត្រាស់ថា ឲ្យទូលសុំអំណាចព្រះឥសូរជួយទទួលព្រះគង្គាផង ព្រោះថាបើនឹងលែងឲ្យហូរចុះមកឃ្លងឃ្លាងតែម្ដង លោកនឹងដល់នូវវិនាសលិចលង់ស្លាប់អស់។ ព្រះឫសីតោងបែទៅតាំងព្យាយាមធ្វើពិធីសុំកំលាំងព្រះឥសូរមកជួយតទៅ ទាល់តែព្រះឥសូរទ្រង់មេត្តាប្រោសតាមបំណង ។ ខណៈព្រះគង្គាហូរចុះចាកឋានសួគ៌ ព្រះឥសូរក៏ទ្រង់ទទួលដោយព្រះសិរ (ដោយហេតុនេះ ព្រះឥសូរទើបមាននាមថា គង្គាធរ អ្នកទទួលព្រះគង្គា អំពីនោះមក) ព្រះគង្គាក្រោធខ្លាំងណាស់ ដែលត្រូវបន្ថយឋានន្តរចុះចាកឋានសួគ៌មកកាន់មនុស្សលោក ត្រូវព្រះឥសូរទមានឲ្យហូរវិលវល់នៅក្នុងរវាងព្រះកេសាលំដាប់នោះព្រះមុនីភគីរថទើបទូលសុំឲ្យលែងព្រះគង្គា ព្រះឥសូរក៏លែងឲ្យហូរបាញ់បែកជា ៧ ជ្រលង ព្រះឫសីភគីរថក៏បររថ

នាំផ្លូវព្រះគង្គាឲ្យហូរទៅឯអង្គារកុមារសាគរ ព្រះគង្គាក៏ហូរតាមស្នាមរថទៅ ដល់ទៅទី ១ ដែលជាទីតាំងមណ្ឌលពិធីរបស់ព្រះជហ្នុសិទ្ធាចារ្យ ព្រះយោគីភគិរថបររថកាត់ទីនោះទៅ ព្រះគង្គាហូរតាមទៅក៏លិចទីពិធីនោះអស់ ព្រះជហ្នុក្រោធ ក៏ហាមាត់បៀមព្រះគង្គាទុកក្នុងមាត់ទាំងអស់ ហូរទៅទៀតមិនបាន ទាល់តែពួកទេពនិករប្រជុំគ្នាមកអង្វរសុំ ព្រះជហ្នុទើបលែងឲ្យហូរតទៅ គឺឲ្យហូរចេញតាមរន្ធត្រចៀកហើយហូរតាមស្នាមរថទៅដូចអំពីដើមដរាបដល់អង្គារកុមារសាគរ ។ កាលព្រះគង្គាហូរស្រោចស្រប់អង្គារជំរះមន្ទិលហើយ វិញ្ញាណរបស់កុមារសាគរក៏បានឡើងទៅកើតឯឋានសួគ៌ទាំង ៦០.០០០ ព្រោះហេតុនេះ ព្រះគង្គាទើបបានមកនៅក្នុងមនុស្សលោកដរាបដល់សព្វថ្ងៃនេះ ។ កាលព្រះគង្គាចុះមកនៅក្នុងមនុស្សលោកនេះហើយ ឫសីជីព្រាហ្មណទាំងឡាយមានសេចក្ដីសោមនស្សសាទរពន់ប្រមាណ អ្នកដែលបានងូតទឹកនោះហើយ ក៏ជ្រះស្រឡះអស់បាបអំពីខ្លួន សូម្បីតែទេវតាដែលចុតិមកកើតក្នុងមនុស្សលោកព្រោះបាបកម្មឯណានីមួយ កាលបានងូតព្រះគង្គាហើយ

ក៏បានត្រឡប់ឡើងទៅកើតឯឋានសួគ៌វិញ ។ ព្រះគង្គាដែលបុះមកនៅក្នុងលោកនេះ គឺដើមទឹកហូរចេញ អំពីភ្នំហិមាល័យហូរបាក់មកខាងត្បូង តែបែកជាស្ទឹងពីរ ស្ទឹងខាងលិចឈ្មោះយមុនា ស្ទឹងខាងកើតឈ្មោះគង្គា ស្ទឹងគង្គារហូរកាត់មកត្រង់នគរសង្កស្ស នគរកន្យាកុញ្ជ រៀងមកដល់នគរមគធរវាងក្រុងរាជគ្រឹះហ និងក្រុងបាតលីបុត្រអំពីដើម តាមជងស្ទឹងនោះមានឈ្មោះហៅផ្សេង ៗ គឺត្រង់កន្លែងដែលព្រះគង្គាបុះអំពីឋានសួគ៌ហៅ គង្គោតរី ត្រង់កន្លែងដែលព្រះឫសីភគីរថបររថនាំព្រះគង្គាទៅឯអង្គារសាគរកុមារហៅ ភាគីរថី ។ សព្វថ្ងៃនេះត្រង់គង្គោតរី ដែលជាទីសក្តិសិទ្ធិមានទេវស្ថាន ១ គួបជំកល់រូបព្រះគង្គានិងរូបរាជឫសីភគីរថទុកជាសំគាល់ នៅតំបន់នេះគេបំណែកទីកំពង់សំរាប់ងូតលាងបាបជា ៣ អន្លើ ហៅថា កំពង់ព្រះព្រហ្ម ១ កំពង់ព្រះវិស្ណុ ១ កំពង់ព្រះឥស្សូរ ១ កំពង់ទាំង ៣ នេះមានគុណផ្សេងគ្នា អ្នកងូតប្រាថ្នាបង់ងូតកំពង់ណា ក៏បុះងូតក្នុងកំពង់នោះទៅ ។ ត្រង់ជ្រោយតំបន់ស្រុកអល្លាហាបាទមានកំពង់ ១ ហៅថា ប្រយាគ ជាទីសក្តិសិទ្ធិបំផុត មានប្រជុំជនទៅ

ងូតជំរះបាប រាប់ចំនួនដោយសែន ៗ ដោយសេចក្ដីជឿជាក់ក្នុងអានុភាពនៃព្រះគង្គា ។ បើបានទៅងូតជំរះកាយក្នុងវេលាទេសកាលក្នុងកំពង់អំបាលនេះ នឹងជ្រះអស់បាបកម្មអំពីសន្តានមានអ្នកខ្លះព្យាយាមដើរប្រទក្សិណស្ទឹងព្រះគង្គាអស់វេលា ២-៣ ឆ្នាំ ទើបចុះងូតក៏មាន ពួកផណ្ឌៀត្រិវការណាស់ វេលាទៀបនឹងស្លាប់សូមឲ្យបានទៅស្លាប់ ឬបានទៅដុតរំលាយសពនៅឆ្នេរព្រះគង្គា ស្រេចហើយរើសឆ្អឹងបណ្ដែតបោលក្នុងព្រះគង្គាទៅ ដោយអានុភាពនៃព្រះគង្គាជំរះបាប អ្នកនោះឯងនឹងបានឡើងទៅកើតឯឋានសួគ៌ ប្រសិនបើស្លាប់នៅទីឆ្ងាយ ពួកញាតិយកឆ្អឹងទៅគ្រវែងបោលក្នុងព្រះគង្គា ក៏បានឡើងទៅកើតឯឋានសួគ៌ដែរ ។ អ្នកដែលនៅឆ្ងាយបើបានឱកាសទៅងូត ច្រើនតែដងទឹកនោះយកមកផ្ញើញាតិមិត្រអ្នកដែលមិនបានទៅ អ្នកដែលជ្រះថ្លាខ្លាំងគ្រាន់តែបញ្ចេញឱទានថា "គង្គា គង្គា" ប៉ុណ្ណោះ សូម្បីនៅចម្ងាយទាំង ៣០ យោជន៍ ដោយអានុភាពនៃព្រះគង្គាក៏អាចជួយឲ្យរួចចាកបាបដែលខ្លួនធ្វើមកទាំង ៣ ជាតិហើយបាន ។

ដោយហេតុជឿជាក់ក្នុងអានុភាពនៃព្រះគង្គាដូច្នេះ ពួកព្រាហ្មណ៍ទើបបញ្ញត្តិពិធីសិវរាត្រីឡើង គឺជាពិធីដែលគេកំណត់ឲ្យធ្វើក្នុងវេលារាត្រី ក្នុង ១ ឆ្នាំធ្វើម្តង នេះពោលតាមដែលធ្លាប់ដឹងមកដោយច្រើន ។ ពិធីនេះដែលគេធ្វើក្នុងបច្ចុប្បន្ន ពួកព្រាហ្មណ៍នៅនគរពារាណសី វេលាយប់នាំគ្នាទៅឯវត្តព្រាហ្មណ៍ ឬហៅថា ទេវស្ថាន ធ្វើកិច្ចសូត្រមន្តភាវនានមស្សការទេវរូបនឹងសិវលិង្គ តាមប្រវេណីរបស់គេរហូតរាត្រីកាល លុះទៀបភ្លឺទើបនាំគ្នាកាន់យកនូវក្អមស្ពាន់ម្នាក់ ១ ទៅកាន់ស្ទឹងគង្គា អង្គុយចុះដងមកសូត្រសែក ខ្ពុរមាត់លុបមុខ ហើយទើបលោតចុះក្នុងទឹក មុជឲ្យលិចក្បាលអស់វារ ៣-ដង ហើយខ្វេះយកដីមកដុសខ្លួននឹងបរិកម្មថា គង្គា គង្គា ដូច្នេះរអ៊ូទៅ សក់ដែលជ្រុះក្នុងវេលានោះត្រូវរើសបណ្តែតទឹកទៅ ប៉ុណ្ណោះឈ្មោះថា បានជំរះលាងបាបអស់អំពីសន្តានម្តង ស្រេចការងូតទឹកហើយ យកក្អមដងទឹកត្រឡប់ទៅកាន់ទេវ-ស្ថានវិញ ជំរះស្រោចស្រង់សិវលិង្គហើយយកក្អមទៅត្រងទឹកដែលហូរទៅតាមទរនៃបល្លង្កយោនី យកមកស្រោចក្បាលខ្លះ

ដីកខ្លះតាមសមគួរ ឈ្មោះថាបានទូវសេចក្ដីត្រជាក់ត្រជំជាសិរី-សួស្ដី និងជ្រះអស់ចង្រៃឧបទ្រពទាំងពួង ។

នៅមានរបៀប ១ យ៉ាងទៀត ដែលពួកព្រាហ្មណធ្វើនៅក្រុងបាងកក (សៀម) ប្លែកអំពីដែលពោលហើយខ្លះដូច្នេះ នៅថ្ងៃពេញបូណ៌មីខែមាឃ ពួកព្រាហ្មណយកសិវលិង្គមកដំកល់ក្នុងទីមួយដ៏សមគួរ ទើបដាំសសរ ៤ ដើមជា ៤ មុមជុំវិញសិវលិង្គ យកខ្សែចងខ្វែងប្រទាក់អំពីសសរទាំង ៤ ហើយយកផ្ទាំងទឹក ១ ទៅចងព្យួរត្រង់រវាងកណ្ដាល ឲ្យត្រង់ពីលើសិវលិង្គ ទើបចោះបាតផ្ទាំងទម្លុះឲ្យទឹកសេចស្រក់ចុះលើសិវលិង្គ ហើយយកផ្ទាំង ១ ទៅត្រងនៅចំពួយបល្លង្កយោនី បើទឹកនោះលេចអស់ទៅត្រូវថែមឡើង ទាល់តែអស់វេលារាត្រីនោះដល់វេលាទៀបភ្លឺ ទើបនាំគ្នាដណ្ដាំបាយលាយដោយទឹកដោះ សប្បិ ទឹកឃ្មុំ ស្ករ និងគ្រឿងទេសដែលរាប់ថា ជាអាហារយ៉ាងប្រណីតរបស់គេ បរិភោគហើយនាំគ្នាទៅងូតទឹកព្រែកព្រោះនៅឆ្ងាយអំពីព្រះគង្គា កក់សក់ជំរះកាយហើយយកទឹកដែលស្រង់សិវលិង្គមកស្រោចជំរះមន្ទិលថែមទៀត សំក់ដែល

ជ្រះក្នុងវេលានោះគេរើសបណ្តែតទឹកទៅ ប៉ុណ្ណោះជាសួរេបពិធីសិវរាត្រី ។

ផលនៃការបដិបត្តិក្នុងលទ្ធិព្រហ្មញ្ញ

ពួកអ្នកកាន់សាសនាព្រាហ្មណ៍គោរពរាប់អានព្រះព្រហ្ម ព្រះសិវ ព្រះនារាយណ៍ជាសរណៈទីពឹង និងប្រព្រឹត្តតាមពាក្យប្រដៅក្នុងគម្ពីរត្រៃវេទ ។ បើនឹងបំណែកផលប្រយោជន៍ដែលប្រតិបត្តិក្នុងលទ្ធិនេះគួរញែកជា ២ ប្រភេទ គឺ ១ ផលក្នុងលោកនេះ ២ ផលក្នុងលោកឯមុខ ។ ប្រភេទទី ១ ដោយច្រើនបាននឹងពួកឃរាវាសអ្នកប្រាថ្នាគុណវិសេសឯណានីមួយ ក៏ប្រព្រឹត្តវត្តបំពេញតបៈកម្មថ្វាយព្រះជាម្ចាស់ រមែងបានទទួលផលទៅជាអ្នកវិសេសមានឫទ្ធានុភាពផ្សេងៗក្នុងផ្លូវសឹកសង្គ្រាមជាដើម ។ ប្រភេទទី ២ បានពួកអ្នកឃើញទុក្ខក្នុងឃរាវាសវិស័យ បេញបួសជាតាបសឫសីអាស្រ័យនៅក្នុងដែនដងព្រៃ បរិភោគមូលផលាផលជាអាហារ ប្រព្រឹត្តក្នុងផ្លូវបព្វជិត បង្អោនជីវិតថ្វាយព្រះជាម្ចាស់ ដើម្បីបានលុះភូមិជាន់ខ្ពស់ក្នុងលទ្ធិនោះគឺ ១ រាជឫសី ២ មុនី ៣ មហាឫសី ៤ ព្រហ្មឫសី ។ ព្រហ្មឫសីជាកំពូលនៃភូមិ

ធម៌ក្នុងលទ្ធិនេះ អ្នកដែលនឹងបានលុះភូមិនេះបាន តោងសង្កត់ចិត្តឲ្យស្ងប់ចាកសេចក្ដីស្អប់សេចក្ដីស្រឡាញ់ជាដើមឲ្យមែន ៗ កាលបានសំរេចភូមិឬសីអំពាលនេះហើយរលាស្លាប់ទៅ មានអំណាចទៅកើតក្នុងព្រហ្មលោកប៉ុណ្ណោះជាយ៉ាងខ្ពស់បំផុត (មិនដល់ព្រះនិព្វាន) តែមើលទៅប្រហែលជាគេសំគាល់ថា ទីនោះជានិព្វានរបស់គេហើយ នេះរាប់ថាជាកំពូលនៃផលទាំងពួង ។

## សរុបសេចក្ដី

បើនឹងពិនិត្យមើលទៅ ក្នុងលទ្ធិនេះឃើញថា នៅប្រឡូកប្រឡំទៅដោយរាគាទិកិលេសច្រើនណាស់ ដូចជាក្នុងរឿងមហាភារតនឹងរឿងរាមាយណជាដើមសំដែងថា ឫសីទាំងឡាយ សុទ្ធតែជាអ្នកមានប្រពន្ធកូនទាំងអស់ ព្រោះគេកាន់ថា បុរសណាគ្មានកូនប្រុសដ៏កើតអំពីលោហិតរបស់ខ្លួន បុរសនោះកាលស្លាប់ទៅ រមែងធ្លាក់ទៅសោយទុក្ខក្នុងរណ្ដៅនរក ១ ឈ្មោះ "បុត" បើមានកូនប្រុស កូននោះនឹងការពារមិនឲ្យធ្លាក់នរកនោះបាន សព្ទថា បុត ទើបបានជាឈ្មោះ

សម្រាប់ហៅកូនប្រុសឯរាបដល់សព្វថ្ងៃនេះ ប្រែថាអ្នកការពារអាពុកឲ្យរួចចាកនរកឈ្មោះបុត ។ មិនតែប៉ុណ្ណោះឫសីទាំងឡាយនោះជាទីរាប់អានរបស់ជនទាំងពួង ថាជាអ្នកឲ្យនូវសេចក្ដីសួស្ដីមង្គលបានផង បើកូនក្រមុំអ្នកណានឹងរៀបអាពាហ៍ពិពាហ៍នឹងប្រុសឯណានីមួយ មាតាបិតាតោងសុំសួស្ដីមង្គលអំពីឫសី ដែលជាទីរាប់អានរបស់ខ្លួនជាមុនសិនហើយទើបរៀបការជាខាងក្រោយ ប្ដីប្រពន្ធគូនោះក៏នឹងបានសេចក្ដីបំរើនរុងរឿងថ្កើងកេរ្ដិ៍ឈ្មោះ តាំងពីក្រមុំកំលោះរហូតយាវជីវំ ។ ប្រវេណីនេះ តាមក្នុងសេចក្ដីកត់ហេតុរបស់សម្ដេចព្រះបមក្លៅ រជ្ជកាលទី ៤ នៃប្រទេសស្យាម បានស្ដេចទៅប្រពាតប្រទេសឥណ្ឌៀក្នុងកាល ព. ស. ២៤១៤ ក៏ថានៅមានការដែលនឹងធ្វើពិធីបូជាយញ្ញ បំពេញតបៈ ប្រព្រឹត្តវត្តទរមានរាងកាយថ្វាយព្រះជាម្ចាស់ទាំងប៉ុន្មាន ក៏នៅក្នុងប្រាថ្នាផលសុទ្ធតែកាមគុណ ទោះបីដូច្នោះ ក៏នៅរាប់អានថាជាព្រាហ្មណជាន់ខ្ពស់ មានញាណនឹងតបៈ គឺសេចក្ដីត្រាស់ដឹងនឹងតេជៈផ្សេង ៗ គ្នា សូម្បីក្នុងសេចក្ដីដែលថា អ្នកនឹងបានរបុះភូមិ

ព្រហ្មឫសីតោងសង្កត់ចិត្តឲ្យស្ងប់មែនៗ បើដោយគិតទៅ ពួកយើងបុថុជ្ជនសព្វថ្ងៃមានកិលេស ៣ កង គឺ រាគ ទោស មោហជាធម្មតា ពួកព្រហ្មឫសីក៏មិនរលោះទៅជាងយើងប៉ុន្មានដូចយ៉ាងព្រះគោតមឫសីមាននាងអហល្យាជាភរិយា មានព្រះសតានន្ទមុនីជាបុត្រ នេះរាគ ។ ព្រះវិស្វាមិត្រព្រហ្មឫសីញុះឲ្យព្រះរាមសម្លាប់នាងតារកា ឬហៅថា កាកនាសូរ នេះទោស ។ ព្រះវសិដ្ឋព្រហ្មឫសីចេញអំពីនគរមិថិលាជាមួយនឹងព្រះបាទទសរថនឹងទៅនគរស្រីអយុធ្យា ប្រទះនឹងរាមបរសុ គឺរាមាសូរក្នុងរវាងផ្លូវ ខ្លាចក្រែងត្រូវនឹងព្លូថៅរបស់រាមបរសុ តោងនិយាយបញ្ជ្រៀតប្រាប់ពួកព្រាហ្មណ៍ជាមួយគ្នា នេះមោហ ។ ដូច្នេះការបំពេញតបៈអស់វេលារាប់ម៉ឺនឆ្នាំ តើនឹងជាគ្រឿងបន្ទោកិលេសអ្វីបានខ្លះ កាលចិត្តត្រូវកិលេសទាំង ៣ នេះឯណានីមួយគ្របសង្កត់ហើយ ឈានវិសេសដែលសម្រាប់ធ្វើបាដិហារ្យ តើនឹងកើតឡើងដោយផ្លូវណា ។ កុំថាឡើយតែពួកឫសី សូម្បីព្រះជាម្ចាស់ឯង គឺព្រះព្រហ្ម ព្រះសិវ ព្រះវិស្ណុដែលរាប់ថាជាសរណៈវត្ថុជាន់ខ្ពស់បំផុត ក៏សុទ្ធតែនៅមានប្រពន្ធកូន នៅមាន

ភាគ ទោស មោហពេញបរិបូណ៌មិនប្លែកអ្វីនឹងយើងដែល បុប្ផុជ្ជនធម្មតា ដូច្នេះឃើញគួរសមយ៉ាងណាដែលនឹងជ្រកក្បាលទៅយកលោកជាសរណទីពឹង សម្រាប់ក្នុងសម័យដែលស្រុកទេសនៅទន់ទាបដោយចំណេះវិជ្ជា ហើយទាំងគ្មានលទ្ធិសាសនាដទៃ ៗ ជាគ្រឿងប្រកបនឹងជ្រើសរើស ក៏ឃើញថាគួរទទួលកាន់សាសនាបែបនេះជាបណ្ដោះអាសន្នទៅសិន កាលស្រុកទេសចំរើនដោយចំណេះវិជ្ជា ទាំងមានសាសនាឯទៀត ៗ កើតឡើងជាគ្រឿងប្រៀបធៀបគ្នាហើយ ក៏គួរជានាំយកមកប្រៀបធៀប ហើយកាន់យកយ៉ាងឯណានីមួយដែលមានសារៈជាង ដែលនឹងក្ដាប់ទុកមិនក្រឡេកមើលមុខណាសោះ បើពានលើត្រូវក៏ជាការគាប់ប្រសើរ បើពានលើខុសរមែងជាការចាញ់ប្រៀបមនុស្សផងគ្នា ដូច្នេះអ្នកនឹងកាន់សាសនាណាត្រូវតែពិនិត្យកុំខាន ទើបសម្រេចប្រយោជន៍សមបំណងដោយពិត ។

# រឿងព្រេងខ្មែរ

## ១ — អំពីក្បួនដែលទេវតា សែកសោយ

កាលណោះមានបុរសកំសត់ពីរនាក់ប្តីប្រពន្ធ ដល់នៅជាមួយគ្នាយូរទៅបានកូនប្រុសមួយ កូននោះកើតឡើងវេលាណាមានទេវតាអាក្រក់នោះមកថែរក្សាសែករោយ តាំងពីទេវតាអាក្រក់មកសែកសោយក្មេងនោះថ្ងៃណា ឪពុកម្តាយស្លាប់ចោលអស់ទៅ ក្មេងនោះនៅជាមួយនឹងជីដូន ៗ ក៏ថែរក្សាលុះទាល់តែចំរើនអាយុបាន ២០ ឆ្នាំ មានមួយថ្ងៃក្មេងនោះចូលទៅក្នុងព្រៃដើម្បីនឹងរកកាប់ឧស កំពុងតែរកកាប់ឧស មានទេវតាមួយព្រះអង្គទៀតដែលជាទេវតាល្អ ជួយចំរុងចំរើនយសសក្តិភោគសម្បត្តិ ទេវតានោះនិយាយនឹងទេវតាអាក្រក់ថា តាំងពីអ្នកឯងចូលមករក្សាមនុស្សនេះកាលណា ម្តាយអាពុកស្លាប់ចោលអស់ហើយក្រលំបាកពន់ពេកណាស់ ឃើញថា ឬទ្ធិអ្នកឯងពូកែមែន ទេវតាអាក្រក់និយាយតបទៅវិញថា អ្នកជឿជាអំណាចខ្ញុំពូកែទេ ទេវតាល្អឆ្លើយថា ខ្ញុំជឿហើយ ប៉ុន្តែខ្ញុំសូមរក្សាមនុស្សនេះម្តង ទេវតាអាក្រក់ព្រមបើកអំណាចឲ្យទេវតាល្អថែរក្សា ហើយបោះ

ទៅ ទេវតាល្អបណ្ដាលចិត្តមនុស្សនោះកំពុងតែកាប់ឧសក៏ដាក់ជឹងចុះហើយភ្ញាក់ខ្លួនព្រឹត លោគិតថា ឱអញបើអញរស់នៅគ្រាន់អញនឹងរកស៊ីចិញ្ចឹមជីដូនអញ បើប្រសិនណាអញស្លាប់ទៅបានអ្នកណានឹងរកស៊ីចិញ្ចឹមជីដូនអញទៀត បើដូច្នេះអញគិតទៅនិយាយបបួលយាយអញទៅនៅខ្ញុំសេដ្ឋី គ្រាន់តែសុំបាយស៊ីប្រហែលជាគេព្រមហើយ ថាតែប៉ុណ្ណោះលែងកាប់ឧសត្រឡប់ទៅផ្ទះវិញ ទៅដល់និយាយប្រាប់ជីដូនតាមដំណើរសព្វគ្រប់ដែលខ្លួនគិតកាលទៅកាប់ឧស ជីដូនបានស្ដាប់ហើយក៏ចូលចិត្តព្រមតាមចៅ ។

បុរសកំសត់ទាំងពីរនាក់ជីដូននឹងចៅ ក៏នាំគ្នាដើរទៅផ្ទះមហាសេដ្ឋី ដល់ចូលទៅក្នុងកំផែងរបងហើយទៅអង្គុយបត់ជើងនៅមាត់ជណ្ដើរមហាសេដ្ឋី លុះបន្តិចទៅមហាសេដ្ឋីប្ដីប្រពន្ធនាំគ្នាចេញមកក្រៅ ក៏ក្រឡេកទៅឃើញបុរសទាំងពីរនាក់អង្គុយ ក៏សួរថា ឯងមកនេះគឺមានប្រាថ្នាអ្វី បុរសកំសត់នោះក៏ឆ្លើយជំរាបទៅសេដ្ឋីថា ខ្ញុំមកនេះ គឺមកសុំនៅធ្វើជាខ្ញុំបម្រើលោកពីរនាក់ជីដូននឹងចៅនេះគ្រាន់តែយកបាយចិញ្ចឹមជីវិត មហា-

សេដ្ឋីស្តាប់ហើយថា អើឯងនៅចុះ បុរសនោះជំរាបទៅមហាសេ-ដ្ឋីថា ខ្ញុំសូមលោកនៅបម្រើខាងលើផ្ទះបាយហើយនឹងផ្ទះធំមហា-សេដ្ឋីព្រម ទើបឯយាយចាស់នោះសុំគ្រាន់តែជេញមាន់ទាកុំឲ្យស៊ីស្រូវកាលណាបើគេយកស្រូវទៅហាល បុរសនោះខំយកចិត្តទុកដាក់បម្រើសេដ្ឋីមិនឲ្យខាសចិត្តបន្តិចសោះ មហាសេដ្ឋីមានចិត្តអាណិតស្រឡាញ់រាប់អាន លុះយូរទៅបានប្រហែល៣-៤ឆ្នាំបុរសនោះសុំមហាសេដ្ឋីទៅនៅឃ្វាលក្របីវិញ ដល់ទៅនៅឃ្វាលក្របី ផ្លាស់អស់ញូវខ្សែចាស់ទាំងប៉ុន្មានជួសជុលក្រោលនោះស្អាតល្អឡើង ក្របីទាំងអស់ចំនួន ១០០ ដល់យូរទៅមហាសេដ្ឋីប្ដីប្រពន្ធនិយាយគ្នាថា យើងតាំងពីអានេះទៅនៅឃ្វាលក្របីយើងមិនដែលទៅមើលវាម្ដងសោះ ដូច្នេះយើងនាំគ្នាទៅមើលម្ដង ក៏នាំប្ដីប្រពន្ធទៅ ៗ ដល់មើលទៅក្របី ខ្សែញូវ ក្រោលក៏ពេញចិត្តព្រមទាំងអស់ ត្រឡប់មកវិញនិយាយគ្នាថា អានេះជាមនុស្សល្អ កាលដែលអាខ្ញុំយើងរក្សាពីមុនមកមិនដែលមានប្រដាប់សំរាប់ក្របីថ្មីយ៉ាងនេះទេ ឥឡូវនេះមកមានព្រម អានេះជាមនុស្សចិត្តត្រង់នឹងចៅហ្វាយនាយ ។

បុរសទៅឃ្វាលក្របីរាល់ថ្ងៃមានកាលមួយថ្ងៃនោះពេលល្ងាចដេញក្របីត្រឡប់មកក្រោលវិញមកដល់ត្រពាំងមួយដេញក្របីចុះទៅត្រពាំងទឹកទៅជាន់លើជុំមាសនៅក្នុងបឹងនោះបែរទៅខាងណាក៏សុទ្ធតែជុំមាសពេញបឹងទាំងអស់ បុរសថា ដុំថ្មអ្វីក៏ច្រើនម្ល៉េះប៉ះជើងស្ទើរស្លាប់ ថាហើយក៏លូកទៅយកដុំមាសមួយដុំមកថា អញយកដុំថ្មនេះទៅផ្ញើយាយអញ ព្រោះថ្មនេះល្អ បុរសនោះដេញក្របីយកមកក្រោល ដល់រួចស្រេចហើយក៏យកដុំនោះទៅឲ្យជីដូន ៗ បានឃើញដុំមាសហើយសួរថា ចៅយកពីណាមកយកទៅវិញទៅ យាយមិនហ៊ានយកទេ ដុំមាសអ្វីធំម្ល៉េះ បុរសដឹងជាដុំមាសដូច្នោះហើយ ក៏យកទៅទុកក្នុងបឹងវិញទៅហើយចំណាំកន្លែងនោះទុក រួចត្រឡប់មកវិញ ។

មានមួយថ្ងៃនោះព្រះករុណាចង់ល្បងបិត្តពួកកុង្សីយសេ-នាបតីទ្រង់មានព្រះបន្ទូលទៅនឹងអមាត្យថា អាឯងទៅប្រាប់កុង្សីយទាំង ៤ ថា ល្ងាចនេះឲ្យទៅដេកចាំព្រះបរមរាជវាំងនៅចុងរោង អមាត្យយកព្រះបន្ទូលទៅជំរាបកុង្សីយទាំង ៤ តាមដំណើរ កុង្សីយទាំងនោះក៏រៀបខ្លួនមកដេកតាមព្រះរាជឱង្ការ

មកដេកនោះមិនគិតប្រុងប្រយ័ត្នសោះ គិតមកដេកទាល់តែភ្លឺ លុះយប់ជ្រៅស្ងាត់ស្ដេចទ្រង់យាងមកទតកុង្សីយទាំង៤នោះៗឃើញដេកទាំងអស់ស្ដេចយាងត្រឡប់ទៅព្រះក្រឡាបន្ទំវិញ ដល់ព្រឹកឡើងទ្រង់ត្រាស់ព្រះបន្ទូលឲ្យចាប់កុង្សីយទាំង ៤ នោះ យកទៅកាប់ចោលទៅ លុះល្ងាចក្រោយទៀតទ្រង់មានបន្ទូលឲ្យហៅមហាសេដ្ឋីទាំង ៤ ឲ្យមកដេកដូចកាលមុន មហាសេដ្ឋីដែលជាចៅហ្វាយបុរសកំសត់នោះភ័យណាស់ ព្រោះមិនដឹងជាមានរឿងអ្វីបានជាស្ដេចឲ្យសម្លាប់កុង្សីយទាំង៤នោះ តឡូវមកដល់ខ្លួនទៀតជាមុខជាស្លាប់ហើយ កូនប្រពន្ធទាំងប៉ុន្មានយំសោកទាំងអស់គ្នា លុះបន្តិចទៅឮទៅដល់បុរសកំសត់ ៗ ក៏ឡើងមកសួរថា ហេតុដូចម្ដេចក៏បានជាយំសោកយ៉ាងនេះ មហាសេដ្ឋីប្រាប់ទៅវិញតាមរឿង បុរសថា បើដូច្នេះខ្ញុំសូមទៅដេកជំនួសមហាសេដ្ឋីឮដូច្នោះ ហើយក៏អរណាស់ឲ្យរកសំពត់អាវល្អយកមកឲ្យបុរសកំសត់នោះស្លៀកជាមុខជានឹងស្លាប់ហើយ លុះបុរសរៀបខ្លួនរួចស្រេចហើយទៅដេកចាំវាំង ជាមួយនឹងពួកមហាសេដ្ឋីឯទៀត តែទៅនោះបុរសនោះយកទាំងដាវមួយទៅផង ទៅ

ដល់តាំងតែដេក ពួកមហាសេដ្ឋីឯទៀតគេនៅអង្គុយនិយាយគ្នា លេងលុះយប់ជ្រៅក៏នាំគ្នាដេកអស់ទៅ បុរសនោះដឹងជាគេដេកស្ងាត់តាំងក្រោកឡើងអង្គុយតែម្នាក់ឯង លុះដល់យប់ជ្រៅស្ងាត់ ស្តេចទ្រង់ចេញមកដូចមុនទៀត មកដល់ត្រង់ចុងរោង បុរសនោះក្រឡេកឃើញទាញដាវបានដេញកាប់ ៗ ផុត ស្តេចរត់រូបទៅ ក្នុងវេលាយប់នោះស្តេចចេញមក ៣ ដង បុរសនោះដេញកាប់ទាំង ៣ ដងរត់ទៅវិញ លុះព្រឹកឡើងស្តេចទ្រង់មានបន្ទូលឲ្យចាប់យកសេដ្ឋីទាំង ៣ នាក់ដែលដេកនោះយកទៅកាប់ចោល ហើយទ្រង់មានបន្ទូលឲ្យហៅបុរសកំសត់នោះទៅ រួចស្តេចទ្រង់មានព្រះបន្ទូលសួរបុរសកំសត់ថា ឯងសេដ្ឋីណាឈ្មោះអ្វី បុរសកំសត់ទូលទៅវិញថា ទូលព្រះបង្គំជាខ្ញុំជាកូនមហាសេដ្ឋីជាចៅហ្វាយវានោះ ស្តេចមានព្រះបន្ទូលឲ្យទៅហៅមហាសេដ្ឋីដែលជាចៅហ្វាយបុរសកំសត់នោះមកដល់ទ្រង់មានព្រះបន្ទូលសួរថា នេះជាកូនអ្នកឯងមែនឬអ្វី មហាសេដ្ឋីក៏ក្រាបបង្គំទូលឆ្លើយទទួលថា កូនមែន ស្តេចមានបន្ទូលថា បើកូនមហាសេដ្ឋីឯង អញសុំធ្វើជាកូនអញ មហាសេដ្ឋីក៏ថ្វាយបុរសនោះទៅស្តេចហើយក្រាប

បង្គំលាទៅវិញ ស្ដេចនោះមានព្រះរាជបុត្រីមួយព្រះអង្គក៏រៀប ផ្សំគ្នានឹងបុរសកំសត់យកគ្នាជាប្ដីប្រពន្ធទៅ ហើយអភិសេក ឲ្យឡើងសោយរាជសម្បត្តិ «នេះគឺអំណាចដែលទេវតាល្អបុះមក សែកសោយបែរក្សា» លុះសោយរាជយូរទៅស្ដេចនឹកឃើញដល់ ទោមាសដែលនៅបឹង ត្រាស់បង្គាប់ទោមហាសេនាអាពុកឲ្យទៅ ជីកមាសនោះមកដាក់ឃ្លាំងទុក ។

មានមួយថ្ងៃស្ដេចបុរសនោះចង់ចេញចុងរោង ឲ្យពួក កុង្សីយសេនាបតីគាល់ ក៏ទៅទូលស្ដេចឪពុក ៗ ហាមថា ឯង ជាតិជារាស្ត្រ បើចេញទៅយកមហេសីទៅផង ស្ដេចបុរស ទ្រង់យាងចេញទៅចុងរោងជាមួយនឹងអគ្គមហេសីនាម៉ឺនទាំង ពួងគាល់ត្រៀបត្រា ក្នុងសម័យនោះទេវតាដែលអាក្រក់រក្សា បុរសនោះអំពីដើមត្រឡប់មកវិញក៏ជួបនឹងទេវតាល្អ ហើយ និយាយថា ឥឡូវនេះអ្នកឯងរក្សាមនុស្សនេះ ពីទៅលំបាកលុះ ទាល់តែបានធ្វើទៅដល់ស្ដេចថែមទៀត នេះឃើញថា អំណាច អ្នកឯងក្លាកៃមែន បើដូច្នេះអ្នកចេញទៅឲ្យខ្ញុំរក្សាម្ដងវិញ ទេវតា ល្អប្រគល់ស្ដេចកំសត់ឲ្យទេវតាអាក្រក់ហើយហោះទៅ ក្នុង

ពេលនោះភ្លៀងផ្គរ ទេវតាអាក្រក់បណ្ដាលចិត្តស្ដេចបុរសនោះមួយរំពេច ស្ដេចនោះគិតមិនឃើញ លោមានបន្ទូលថា នៅចំពោះមុខពួកនាម៉ឺនគាល់ត្រៀបត្រាហើយថា អញឮផ្គរលាន់ស្រណោះកាលនៅឃ្វាលក្របីពីដើមណាស់ ថាតែប៉ុណ្ណោះហើយមហេសីឮហើយស្ទុះរត់ទៅឯបិតាហើយនិយាយទូលបិតា ព្រះវរបិតាមិនគួរយកខ្ញុំទៅឲ្យអាមនុស្សឃ្វាលក្របីនេះសោះ ខ្ញុំលែងយកហើយ ព្រោះទៅកណ្ដាលចំពោះមុខពួកនាម៉ឺនគាល់ត្រៀបត្រា ហើយថា ឮផ្គរលាន់ស្រណោះកាលនៅឃ្វាលក្របីពីដើមណាស់ ខ្ញុំខ្មាសពួកនាម៉ឺនសព្វមុខមន្ត្រីណាស់ដូច្នេះខ្ញុំមិនយកទេ ស្ដេចបិតាឮដូច្នោះហើយឲ្យចាប់ស្ដេចបុរសយកទៅដាក់គុកទៅ ដាក់គុកបានពាក់កណ្ដាលថ្ងៃ ទេវតាល្អដែលរក្សាមុននោះត្រឡប់មកវិញ ហើយនិយាយទៅនឹងទេវតាអាក្រក់ថា អ្នកមានឫទ្ធិណាស់ ចូលមករក្សាភ្លាម ស្ដេចបុរសនេះបានជាប់គុក ដូច្នេះអ្នកអញ្ជើញទៅចុះ ទុកឲ្យខ្ញុំរក្សាវិញនេះគឺដោយអំណាចទេវតាល្អវិញ តាំងបណ្ដាលចិត្តស្ដេចបុរសៗនឹកឃើញភ្លាមថា អញមិនគួរភ្លាត់សំដីឲ្យទាល់តែជាប់គុកសោះ

ប៉ុន្តែគ្មានអ្នកណាដឹងជាអញជាប់គុកឡើយទេ ដូច្នេះអញបង្គាប់ទៅសេដ្ឋីឪពុកអញឲ្យយកមាសដែលយកពីក្នុងបឹងនោះ ដំធ្វើជាក្របី ១០០ ដាក់លើជើងពានមាស ១០០ ឲ្យយកមកឲ្យអញក្នុងថ្ងៃស្អែកនេះពីព្រឹក គិតតែប៉ុណ្ណោះហើយតាំងប្រើមេរក្សាគុកឲ្យទៅប្រាប់សេដ្ឋីថា ស្ដេចមានព្រះបន្ទូលថា ឲ្យយកមាសដំធ្វើជាក្របី ១០០ ដាក់លើជើងពានមាស ១០០ ដែរ ហើយយកទៅថ្វាយស្ដេចទៅដល់កន្លែងដែលស្ដេចគង់ សេដ្ឋីឮហើយក៏តាំងហៅជាងទាំងពួងឲ្យ ធ្វើក្នុង ១ យប់ទាល់តែហើយលុះព្រឹកឡើងឲ្យពួកមេបាវសេដ្ឋីនោះ ១០០ នាក់ទូលយកទៅថ្វាយ លុះដល់ចូលក្នុងវាំង ស្ដេចបិតាក្មេកទតមកឃើញឲ្យអមាត្យរត់ទៅមើលហើយទៅទូលវិញ ស្ដេចមានបន្ទូលឲ្យហៅអ្នកទូលក្របីនោះយកទៅហើយទ្រង់មានព្រះបន្ទូលសួរថា ហងឯងរាល់គ្នាយកក្របីមាសនេះទៅណា មេអស់ទាំងនោះទូលថា ខ្ញុំយកទៅថ្វាយស្ដេច ថាតែប៉ុណ្ណោះស្ដេចនោះទ្រង់ហៅទៅកូនដែលជាប្រពន្ធស្ដេចកំសត់ឲ្យចេញមកមើល ហើយមានព្រះបន្ទូលថា កូនអើយ ដែលប្ដីឯងវាថាត្រណោះកាលឃ្វាលក្របី

នោះគឺមិនមែនក្របីសត្វនោះទេ កូនមើលក្របីនេះតើ ឈ្ហើយកូនកុំខឹងយកប្ដីទៅ ថាតែប៉ុណ្ណោះឱ្យទៅដោះយកស្ដេចបុរសកំសត់នោះមកហើយ អភិសេកនឹងនាងនោះ ឱ្យឡើងសោយរាជសម្បត្តិសុខសប្បាយរៀងទៅព្រមទាំងយាយនោះ ។

ហេតុនេះមនុស្សយើងសុទ្ធតែមានទេវតារក្សាគ្រប់គ្នា បើទេវតាណាដែលល្អក៏បំរុងបំរើនឱ្យមានសិរីសួស្ដីទ្រព្យសម្បត្តិ បើទេវតាណាដែលអាក្រក់នោះបណ្ដាលឱ្យបង់ទ្រព្យសម្បត្តិ នាំឱ្យជាប់គុកប្រវាក់ស្លាប់ទាំងខ្លួនក៏មាន ហេតុនេះបើបានដឹងដូច្នេះត្រូវតែរៀបលំដោះគ្រោះថ្នាក់ចេញ ទើបនឹងបានសេចក្ដីសុខ តែកាលណាបើនឹងថា ខ្លួនមិនសូវសប្បាយឬមានហេតុអ្វីឯទៀត ។

២ — អំពីប៉ុស្តកំពង់ធំ

ស្រុកកំពង់ធំពីដើមឡើយហៅឈ្មោះថា ស្រុកពស់ធំ កាលណោះមានពស់នាគរាជមួយធំណាស់ នៅក្រោមព្រះវិហារកំពង់ធំសព្វថ្ងៃនេះ តែឥឡូវនេះពស់នោះចេញទៅបាត់ហើយ ៗ វាទៅតាមខាងកើតថ្នល់ចាស់ ដែលនៅខាងលិចវត្តកំពង់ធំសព្វថ្ងៃនេះ ហើយរូងដីកើតជាអូរតាំងពីវត្តលុះមកដល់ស្ទឹងសែននេះ តែមិនដឹងជាពស់នោះទៅឯណា ។

អូរដែលស្នាមពស់លូននោះគេសន្មតហៅថាអូរពស់ ប៉ុន្តែដល់មកឥឡូវនេះ ពាក្យមនុស្សចេះតែឡាយ ៗ ទៅបានជាហៅកំពង់ធំវិញ ពស់នោះចេញទៅត្រង់ស្រះខាងជើងព្រះវិហារវត្តកំពង់ធំសព្វថ្ងៃនេះ គេបានទាំងយកថ្មទៅសន្ធប់រន្ធនោះនៅសព្វថ្ងៃនេះ ។

### ៣ — រឿងខ្មោចចូលដប

ដើមឡើយ មានបុរសម្នាក់មានប្ដីប្រពន្ធជាអ្នកកំសត់ រកស៊ីកាប់បំការ ថ្ងៃ ១ បុរសនោះមកពីកាប់បំការ បានផ្លាស់សំពត់ងូតទឹក ខ្មោចឃើញ វាក្រឡាខ្លួនវាដូចបុរសនោះ ហើយវាយកសំពត់បុរសនោះស្លៀក ហើយវាដើរទៅដល់ផ្ទះបុរសនោះ បានហៅប្រពន្ធបុរសនោះឲ្យរៀបបាយម្ហូបអាហារឲ្យវាអាស្រ័យ លុះបុរសជាប្ដីនោះទៅដល់ផ្ទះខ្លួនហើយបានប្រកែកគ្នានឹងខ្មោចនោះ គឺថាផ្ទះនឹងប្រពន្ធខ្លួនទាំងអស់គ្នា លុះប្រកែកគ្នាទៅមក នាំគ្នាទៅប្ដឹងចៅក្រមសាលាជំរះមិនស្រេច បាននាំគ្នាទៅដល់ស្ដេចទ្រង់រាជ្យ, ព្រះមហាក្សត្រិយ៍សោកពិសោត្យថា បើដូច្នេះឲ្យយកដបពីរមកដាក់ចំពោះមុខហើយស្ដេចមានបន្ទូលថាបើអ្នកណាជាម្ចាស់ផ្ទះជាប្ដីនាងប្រពន្ធនោះឲ្យចូលក្នុងដបរួច បើមិនមែនប្ដីមិនមែនម្ចាស់ផ្ទះទេ ចូលក្នុងដបនោះមិនរួចទេ, ទើបខ្មោចនោះក្រឡាខ្លួនចូលក្នុងដបនោះ ស្ដេចឲ្យបុកឆ្នុកដបនោះជិតហើយយកទៅដុតភ្លើងចោលទៅ ហើយស្ដេចបានប្រគល់ប្រពន្ធនោះឲ្យទៅប្ដីវិញ ។

(រឿងនេះចប់តែប៉ុណ្ណោះ)

## ខ្លឹមរឿង


– បុណ្យរំលឹកដល់ជីវ៉ាត់-ឆន . . . . . . . . . . . . . . . . . . . . ៨៣

– រឿងស្ដេចឧទយន ដកយកពីសេចក្ដីល្បែង អំពីគុណភាពរឿងនិងព្រឹត្តកថា របស់ លោកហ្វេលិក្ស៍ឡាកូត, ក្រម្ការ ជុំ-មៅ ប្រែចេញពីភាសាបារាំងសែសមក ជាភាសាខ្មែរ (ត) . . . . . . . . . . . . . . . . . . . . ៩៩

– សាសនប្រវត្តិ, ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ រៀបរៀង (ត) . . . . . . . . . . . . . . . . . . . . ១១៧


## រូបថត


រូបថត ជីវ៉ាត់-ឆន . . . . . . . . . . . . . . . . . . . . ៩១

# TABLE DES MATIÈRES


I Cérémonie de transmission de mérite du secrétaire Roth-Chhan.............................................. 87

II La légende d'Udayana extraite de l'Essai sur Gunadhya et la Brhatkatha par Félix Lacôte, traduit du Français en Cambodgien par Kromokar Choum-Mau (suite)..... 99

III Sasanapravatti ou l'Histoire des Religions, par Préas Maha Pitou Krasém pandit à la Bibliothèque Royale (suite). 117


## ILLUSTRATION :


Portrait du secrétaire Roth-Chhan.................... 91

បុណ្យរំលឹកតាដល់ដី រ័តន៍-ឌន

កាលនៅថ្ងៃ ១២ កើតខែចែត្រ ឆ្នាំចជស័ក ត្រូវនឹងថ្ងៃ ១៤ អាវ្រិល ឆ្នាំ ១៩៣៨

# ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

រៀបរៀង

## បុណ្យរំលឹកដល់ប៊ីរ័តន៍-ធន

នៅថ្ងៃ ១២ កើតខែចេត្រ ឆ្នាំឆស័កត្រីស័កនិងថ្ងៃ ១៥ អាវរិល ឆ្នាំ ១៩៣៥

ហេតុដែលប៊ីរ័តន៍-ធន ស្លាប់ដូចម្តេច ដូចមានក្នុងពាក្យសុន្ទរកថា របស់លោកឡឺស៊ិជងត៍សុបេរិយ៉េរ ដែលប្រែនាំមកចុះខាងក្រោមនេះស្រាប់ហើយ លុះមកដល់ថ្ងៃដូចមានខាងលើនេះ រាជការប្រតិកត្តរាត៍ និងរាជការព្រះករុណា ព្រមដោយពពួកញាតិមិត្តរបស់ប៊ីរ័តន៍-ធន បានរួបរួមគ្នាធ្វើបុណ្យរំលឹកដល់ឧបការៈរបស់ប៊ីរ័តន៍-ធន និងឧទ្ទិស្សកប្បនាផលដល់វិញ្ញាណរបស់ប៊ីរ័តន៍-ធន ដែលទៅកាន់បរលោកហើយ តាមទំនៀមក្នុងព្រះពុទ្ធសាសនា នៅទីផ្ទះប៊ីរ័តន៍-ធន ក្នុងឃុំលេខ ៥ ក្រុងភ្នំពេញ គឺរាជការប្រតិកត្តរាត៍ចេញប្រាក់២០០ រៀលប្រគល់ឲ្យបងប្អូនរបស់ប៊ីរ័តន៍-ធន ចាត់ការចាប់ចាយធ្វើបុណ្យ. រាជការព្រះករុណា ជាអ្នកជំនួយក្នុងការបុណ្យ គឺធ្វើបារាំក្រាលអាសនៈ ទាំងរៀបតុ-កៅអី សម្រាប់ទទួលព្រះសង្ឃ និងភ្ញៀវដែលមកក្នុងការបុណ្យនោះ, និងរៀបតាំងរូបថតនិងធាតុរបស់ប៊ីរ័តន៍-ធន ។

របៀបបុណ្យដូរខ្ទះ

ពីល្ងាចថ្ងៃ ១៤ អាវ៉ិល បំរើនព្រះបរិត្តក្នុងបារាំបុណ្យ មានអ្នករាជការខ្មែរក្នុងក្រុមក្នុងក្រសួងផ្សេង ៗ មានក្រសួងព្រះបរមរាជវាំងជាដើម ទៅកំដរនឹងទៅជួយជាច្រើននាក់, កាលបំរើនព្រះបរិត្តចប់ហើយ មានទេសនា ១ កណ្ឌ ។

ព្រឹកឡើងថ្ងៃ ១៥ វេលាម៉ោង ៨ ព្រឹក ជួបជុំអ្នករាជការបារាំងមានលោកឡឺរេស៊ីដង់ស៊ុបេរ៉ិយើរជាប្រធាន អ្នករាជ-ការខ្មែរមានលោកសេនាបតីទាំ ៥ ជាដើម នឹងព្រះសង្ឃ ៦០ រូប មានព្រះសិរីសម្មតិវង្សជាដើមដែលគេនឹងនិមន្តមកបង្សុក្កូលនឹងឆាន់ក្នុងពេលព្រឹកនោះ, កាលជួបជុំព្រមហើយ លោកឡឺរេស៊ីដង់ស៊ុបេរ៉ិយើរ ថ្លែងសុន្ទរកថា ដូចមានតទៅនេះ

ស្មូត្រទាវ

របស់លោកគ្រូស្មូត្រឯកឧត្តម

ក្នុងកាលដែលរ៉េមកជាប្រុសទៅចំពោះមុខពុលក្បូរបស់ កងការប្រឹក្សាក្ដី ដើម្បីនឹងកាត់ទោសហើយនឹងផ្ដើមលើក ដល់ រ៉េត-ធន ក្នុងគ្រាក្រោយបំផុតនេះ វាមានសេចក្ដីរំភើប ក្ដួលក្ដុកក្នុងចិត្តជាយ៉ាងក្រៃពេក ។ រ៉េត-ធន ដល់នូវមរណ-មរណ: លោកដំឡើង [illegible] ចិត្តកំណាព្យបណ្ដាលនៅ របស់ក្មួយក្នុងដែលក [illegible] យនោះ ភិសម្ដាប់ បង់ ។



រ៉េត-ធន កើត [illegible] ឆ្នាំ១៩១១ នៅក្រុង ភ្នំពេញ ។ លុះធំឡើងបានចូលសិក្សាវិជ្ជាការសាលាកំរិតសែស នៅសាលាកូលេសស៊ីសុវត្ថិ ជាកូនសិស្សជំនាន់ទី ១ ក្រោយ នោះបានចូលធ្វើការជាស្មៀនរាជរដ្ឋាភិបាល កាលនៅ ថ្ងៃ ៣ ខែកក្កដា ឆ្នាំ ១៩៣១ ដោយចំណាប់ផលប្រឡង ជាសញ្ញាបត្រ (ឌីប្លូម) ក្នុងសាលានោះ ។

# សុន្ទរកថា

## របស់លោកឡឺរេស៊ីដង់ស៊ុប៉េរីយើរ

ក្នុងឱកាសដែលខ្ញុំមកជាប្រមុខនៅទីចំពោះមុខបុណ្យរបស់រាជការប្រូតិកតូរ៉ាត់ ដើម្បីនឹងគំនាប់ហើយនឹងធ្វើបុណ្យរំលឹកដល់ រ័តន៍-ឆន ក្នុងគ្រាក្រោយបំផុតនេះ ខ្ញុំមានសេចក្ដីរំជួលក្ដួលក្តុកក្នុងចិត្តជាយ៉ាងក្រៃពេក ។ រ័តន៍-ឆន ដល់នូវអកាលមរណ នៅកង់ឡឺរូឡាំង ដោយអំណាចចិត្តកំណាចឃោរឃៅរបស់ពួកភ្នងដែលកម្រាបពុំទាន់បានរាបទាបនោះ វាសម្លាប់បង់ ។

រ័តន៍-ឆន កើតនៅថ្ងៃ២ ខែណោវ៉ែម ឆ្នាំ១៩១១ នៅក្រុងភ្នំពេញ វេលាធំឡើងបានចូលសិក្សាវិជ្ជាភាសាបារាំងសែសនៅសាលាកុលែសស៊ីសុវត្ថិ ជាកូនសិស្សដ៏សំខាន់ ១ ក្រោយនោះបានចូលធ្វើរាជការជាសេក្រេទារិបម្រុងរាជការ កាលនៅថ្ងៃ ៧ ខែសូយេត ឆ្នាំ ១៩៣១ ដោយបំណាច់ដែលប្រឡងបានសញ្ញាបត្រ (ឌីប្លូម) ក្នុងសាលានោះ ។

វេលាដែលធ្វើរាជការនៅមន្ទីរ ឡឺរេស៊ីដង់ត៍ ស៊ុបេរិយើរ បណ្ដាអ្នករាជការផងគ្នាស់គាល់ឃើញថា រ័តន៍-ធន នេះជាអ្នកមានគំនិតមារយាទល្អ មានអាការកិរិយាសុភាព មុខគួរឲ្យស្រឡាញ់ មុខគួរឲ្យប្លូលចិត្តផង រ័តន៍-ធន មានកំលាំងទឹកចិត្តនឹងអត្តភាពស្វាហាប់គួរដល់ការងារគ្រប់ជំពូក នឹងគួរដល់ការរាជការទាំងក្នុងរាជការប្រតិកត្ដូរ៉ាត៍ ទាំងក្នុងរាជការព្រះករុណា មិនមានទាស់ធ្លងត្រង់ណា ជាអ្នកសមគួរនឹងបានឡើងទៅជាមន្ត្រីដ៏ថ្កើងយសទៅថ្ងៃក្រោយដោយងាយ ។

លក្ខណៈដ៏ប្រសើរនេះហើយ ដែលមកនាំបណ្ដាលឲ្យមានចិត្តក្លាហានចង់កាន់ការដ៏ធំទូលាយឆ្ងាយលត្ដោបទៅទៀត ហេតុនោះកាលមកដល់ខែឧកត្ដូប ឆ្នាំ ១៩៣៣ រ័តន-ធន ទើបធ្លើយទទួលដោយស្មោះស្មគ្រគឹដួងចិត្តរបស់ខ្លួន សុំទៅធ្វើការនៅមន្ទីរ ដេឡេគេ នៅហ្សូរធ្លង នៅទីនេះហើយ ដែលរ័តន៍-ធនបានធ្វើការយ៉ាងអស់ពីចិត្តសមដួបប្រាថ្នា នៅទីនេះហើយ ពុទ្ធោអើយ ដែល រ័តន-ធន៍ បានប្រទះនឹងអកាលមរណា ក្នុងរវាងអាយុទើបនឹងបាន ២៤ ឆ្នាំប៉ុណ្ណោះ ។

ដោយយោបល់ប្រាជ្ញាដ៏ភ្លឺត្រចះ ដោយអំណាចដែលបាន រៀនសូត្រមក រ័ត៌-ធន បានរំពៃយល់ប្រយោជន៍ដោយច្បាស់ លាស់ក្នុងការ ដែលកម្រាបចលាចលនៅទីប្រទល់ដែននៃព្រះ នគរដែលពុំទាន់បានរាបទាប ឲ្យបានរាបទាបនៅជាសុខក្សេម ក្សាន្តទៅដោយពិត រ័ត៌-ធន បានយកចិត្តទុកដាក់ក្នុងការនេះ ជាបំផុត បានទ្រាំស៊ូរទទួលសេចក្ដីនឿយព្រួយលំបាកជាមួយ នឹងពួកទាហាន ដោយទឹកមុខដ៏រីករាយស្រស់បស់ជានិច្ច បាន ដើរផ្លូវចម្ងាយជាច្រើនពាន់ គីឡូម៉ែត្រ ដើម្បីនឹងពិនិត្យឲ្យស្គាល់ ច្រកល្ហកនៃនិគមជនបទនោះ ៗ ដែលមាននៅក្នុងកំឡុងទីនោះ ទាំងប៉េះនិយាយភាសាភ្នងដោយយ៉ាងធាប់ ស្គាល់រហូតដល់ ទៅទំនៀមទម្លាប់ភ្នង នឹងស្គាល់ចិត្តភ្នងដែលវាតែងចង់ព្យាបាទ គុំគួននឹងអ្នកទាំងពួង រាជការមានតែ រ័ត៌-ធន នេះហើយ ដែលជាកំលាំងជួយក្នុងកិច្ចការទាំងពួង ដែលទាក់ទាមទៅមក ក្នុងរវាងរាស្ត្រភ្នង ៗ មិនតែប៉ុណ្ណោះ រ័ត៌-ធន បានធ្វើសៀវភៅ បទានុក្រម ភាសាភ្នងប្រែជាភាសាខ្មែរ – បារាំង ១ សៀវភៅ សឹងពុំទាន់បានបោះពុម្ពផ្សាយនៅឡើយ ដោយយល់ឃើញថា

ពុំទាន់ធួនល្មមនឹងចិត្ត ការនោះយើងនឹងរៀបចំធ្វើបង្ហើយ ឲ្យបានបោះពុម្ពផ្សាយទៅថ្ងៃក្រោយ ឈ្មោះ រ័ត៌ន-ធន នឹងជាប់នៅក្នុងសៀវភៅនោះផង ។

ដោយសេចក្តីក្លាហានយ៉ាងខែងរ៉ែង នឹងដោយសេចក្តីឈឺផ្សាលដូច្នេះនេះ រ័ត៌ន-ធន ទើបបានឈរនៅមុខគេបង្អស់ ក្នុងបំណោមអ្នករាជការផងគ្នាដែលនៅក្នុងមន្ទីរ ដេទ្បេគេ រ័ត៌ន-ធន យកចិត្តទុកដាក់ជួយចៅហ្វាយនាយរបស់ខ្លួន ក្នុងការដែលនឹងកម្រាបពួកបាស់បោរបលាបល ឲ្យបានសុខសាន្តត្រានជានិច្ច ហើយមានចិត្តសប្បាយរីករាយនឹងនិយាយអធិប្បាយ អំពីកិច្ចការដែលបានធ្វើមកហើយ ឲ្យពួកញាតិ-មិត្រស្តាប់ ។

ឥឡូវនេះ ខ្ញុំសូមឱនសិរសាគំនាប់នៅទីកណ្តាលសេចក្តីទុក្ខសោករបស់ពពួកញាតិរបស់ រ័ត៌ន-ធន នឹងបណ្តាអស់លោកដែលស្រឡាញ់រាប់អានឈ្មោះ រ័ត៌ន-ធន ហើយបានរំលែកសេចក្តីទុក្ខសោកនោះអំពីពពួកញាតិមកតែរៀងខ្លួន ។

នែ រ័ត៌ន-ធន នេះជាបំណាច់រង្វាន់គុណធម៌របស់អ្នកឯងដែលតែងស្ថិតនៅរហូតកល្បាវសាន ឥតមានសាបសូណ្យ

កិច្ចការដែលអ្នកឯងស្រឡាញ់ចូលចិត្ត ហើយនឹងដែលអ្នកឯងយកចិត្តទុកដាក់ខ្វាស់ខ្វែងធ្វើ ដោយអស់អញ្ជើញរំគេញក្នុងចិត្ត រហូតដល់ពេលដែលដួលស្លាប់នេះ យើងនឹងទទួលកាន់ធ្វើតទៅ ដោយឥតធុញទ្រាន់តិចឡើយ ។

សុំតែឲ្យអ្នកឯងនៅជាសុខសព្វទិវារាត្រីចុះ គុណគាប់ដែលអ្នកឯងធ្វើហើយទាំងប៉ុន្មាន ស្ថិតជាប់នៅក្នុងខួរក្បាលរបស់យើង បំណាច់ស្នាដៃរបស់អ្នកឯងស្ថិតនៅក្នុងដួងចិត្តរបស់យើងជានិច្ច ឈ្មោះអ្នកឯងនឹងចូលរួមជាមួយនឹងឈ្មោះ មោន-សៀរ ម៉ែត្រ ទ្រហ្វ បាឡាត់ល្បហ្វែក នឹងគាទិល ដែលជាអ្នករួមសេចក្ដីទុក្ខសោកផង សឹងហាក់បីដូចជាហាបារាំងសែសនឹងខ្មែរនេះជាបងប្អូនរួមឧទរផងគ្នា ។

អស់សេចក្ដីតែប៉ុណ្ណោះ

កាលចប់សុន្ទរកថា របស់លោកឡឺរេស៊ីដង់សុប៉េរីយើរ ហើយព្រះសង្ឃ ៦០ រូបបង្សុកូល ៗ ហើយ មានការបែកសៀវភៅធម៌ចំនួន ១០០ ក្បាល ដែលក្រុមពុទ្ធសាសនបណ្ឌិត្យ

បោះពុម្ពជាជំនួយការបុណ្យនេះរួចហើយលោកឡើងរេសុីជងត៍សុ-
បេរីយើរព្រមដោយអ្នករាជការខ្លះ ក៏អញ្ជើញត្រឡប់ ។

ក្រោយនោះ គេរៀបតាវេរភត្តថ្វាយព្រះសង្ឃឆាន់ ដល់
វេលាថ្ងៃរសៀល ទេសនាសង្គាយនា ៣ អង្គ ជាសួរេបពិធី
បុណ្យតែប៉ុណ្ណោះ ។

នាងមាគន្ទិយា ជាកូនរបស់ព្រាហ្មណ៍ មាគន្ទិយ ។ ព្រាហ្មណ៍អាពុកម្ដាយលើកថ្វាយឲ្យធ្វើជាមហេសី នៃព្រះសម្មាសម្ពុទ្ធ តែព្រះអង្គមិនទទួល ។ ក្នុងវេលានោះ មាគន្ទិយព្រាហ្មណ៍ នឹងភរិយាក៏ចូលបួសក្នុងព្រះពុទ្ធសាសនាទៅប្រគល់បុត្រីឲ្យទៅមារបស់នាងនោះបីបាច់រក្សា មានោះក៏ឈ្មោះថា មាគន្ទិយ (មាគន្ទិក)ដែរ ។ ព្រាហ្មណ៍ជាមាយល់ឃើញរូបរាងរបស់ក្មួយនេះ គួរថ្វាយជាព្រះទេពីព្រះបាទឧទេន ហើយក៏នាំយកទៅឯក្រុងកោសម្ពី ។ ក្នុងវេលានោះព្រះបាទឧទេនទ្រង់ទតឃើញក៏ជាប់ព្រះទ័យស្នេហាហើយទ្រង់ទទួលទុក ក្នុងបណ្ដាព្រះទេពីធំ ៗ ទាំងប៉ុន្មាន ព្រះរាជទានបរិវារ ៥០០ នាក់សម្រាប់បំរើដូចជានាងសាមាវតី នឹងនាងវាសុលទត្តាដែរ ។ ក្នុងសម័យនោះ មានសេដ្ឋី ៣ នាក់ឈ្មោះឃោសិត ១ កុក្កុដ ១ នឹងបាវារិក ១ បានសាងព្រះវិហារ ១ ម្នាក់ថ្វាយដល់ព្រះសម្មាសម្ពុទ្ធ គឺឃោសិតារាម ១ កុក្កុដារាម ១ នឹងបាវារិការាម ១ ។ ព្រះសម្មាសម្ពុទ្ធក៏បានទ្រង់យាង

មកគង់ក្នុងព្រះវិហារទាំង ៣ នោះ ១ ម្តងៗ តាមសេចក្តីនិមន្ត របស់ម្ចាស់វត្ត ។

មានអ្នកលក់ផ្កាម្នាក់ឈ្មោះ សុមន ជាមនុស្សបំរើរបស់សេដ្ឋីទាំង ៣ និមន្តបានព្រះសម្មាសម្ពុទ្ធមកទទួលបង្ហាន់ក្នុងទីផ្ទះ ។ ក្នុងវេលានោះនាងខុជ្ជុត្តរាជាបាវនាងសាមាវតីដែលតែងមកទិញផ្កាឲ្យចៅហ្វាយនៅផ្ទះសុមនរាល់ៗថ្ងៃ បានឱកាសស្តាប់ព្រះសទ្ធម្មទេសនាអំពីសំណាក់ព្រះបរមគ្រូ ហើយក៏បានសម្រេចដល់ព្រះសោតាបត្តិផល ។ លុះដល់នាងខុជ្ជុត្តរាត្រឡប់មកវិញ ក៏តាំងសម្តែងធម៌ដែលចាំឲ្យស្រីបរិវារនាងសាមាវតីទាំង ៥០០ ស្តាប់ ។ តាំងពីថ្ងៃនោះមកពួកស្រីទាំង ៥០០ សុំឲ្យនាងខុជ្ជុត្តរាទៅស្តាប់ធម៌ទេសនាអំពីសំណាក់ ព្រះសម្មាសម្ពុទ្ធរាល់ៗ ថ្ងៃ ដើម្បីយកមកសម្តែងឲ្យស្តាប់តទៅទៀត៖ លុះតក្រោយមកក៏មានប្រាថ្នាចង់ឃើញព្រះបរមគ្រូ ដោយខ្លួនឯង ។ លុះគិតដូច្នេះហើយក៏តាំងចោះទំលុះជញ្ជាំងបន្ទប់ខាងក្នុង ដើម្បីនឹងមើលឲ្យឃើញព្រះបរមគ្រូ ក្នុងវេលាដែលព្រះអង្គយាងទៅកាន់ផ្ទះសេដ្ឋីទាំង ៣ មួយអន្លើដោយព្រះអរ-

ហន្តាទីណាស្រែពទាំងឡាយ ។ ក្នុងវេលានោះនាងមាគន្ទិយា បានប្រទះឃើញរឿងហេតុដូច្នេះ ហើយដោយនាងគិតតែអំពីការព្យាបាទព្រះសម្មាសម្ពុទ្ធ ក៏ទូលបង្កូសអំពីនាងសាមាវតីដល់ព្រះបាទឧទេនជាស្វាមីថា នាងសហាយស្មន់នឹងព្រះ ។ ព្រះបាទឧទេន ក៏ទ្រង់បាត់ឲ្យបិទវន្ធដញ្ញាំងបន្ទប់ទាំងអស់បេញ ហើយឲ្យបោះបង្អួចពីខាងពិតាន ។ នាងមាគន្ទិយាញុះមនុស្សឲ្យជេរជៀលត្មះព្រះបរមគ្រូជាប្រើនពាសពេញផ្លូវ ។ ក្នុងវេ-លានោះព្រះអានន្ទទូលសុំឲ្យព្រះសម្មាសម្ពុទ្ធនិមន្តបេញពីទីក្រុងនោះតែព្រះអង្គមិនយល់ព្រម ។

នាងមាគន្ទិយារំពឹងក្នុងចិត្តថា ៈអញត្រូវគិតឧបាយយ៉ាងណាទៀត ? "លុះគិតស្រេចហើយក៏ឲ្យយកមាន់រស់ទៅប្រគល់ឲ្យនាងសាមាវតី ដើម្បីធ្វើក្រយាស្ងោយថ្វាយស្ដេច តែនាងសាមាវតីមិនព្រមទទួលធ្វើ ដោយនាងខ្ជាប់ក្នុងសីលបាណាតិ-បាត ក្រោយមកនាងមាគន្ទិយាឲ្យយកមាន់ដដែល ទៅឲ្យនាងសាមាវតីដើម្បីធ្វើបង្អាន់ថ្វាយព្រះ តែនាងមាគន្ទិយាលួបបង្គាប់មនុស្សបំរើឲ្យសំឡាប់មាន់នោះជាមុន នាងសាមាវតី

ឃើញមាត់ស្លាប់ស្រាប់ ក៏ទទួលបាត់បែងធ្វើបង្ហាត់ថ្វាយព្រះទៅ ។ ក្នុងវេលានោះព្រះបាទឧទេន ក៏មិនព្រមខ្វល់នឹងនាងសាមាវតី ។ នាងមាគន្ទិយាគិតឧបាយថ្មី ១ ទៀត គឺបញ្ចូលពស់ ១ ទៅក្នុងពិណាដែលព្រះបាទឧទេន តែងដេញផ្សាំងដំរី ហើយដែលមិនដែលឃ្លាតពីព្រះអង្គសោះ ។ ព្រះមហាក្សត្រតែងទ្រង់ស្តេចទៅក្រសាលនឹងព្រះទេពីគ្រប់អង្គម្តងម្នាក់ៗ ក្នុងពេលនោះត្រូវវេននាងសាមាវតី ហើយនាងមាគន្ទិយាធ្វើជាទូលឃាត់ព្រះបាទឧទេនកុំឲ្យយាងទៅ ព្រោះនាងយល់សប្តិមិនល្អ លុះស្តេចមិនព្រមក៏សុំជូនទៅ ហើយលួចដកឆ្នុកពិណាឲ្យពស់ចេញមក លើព្រះថែនដែលព្រះបាទឧទេនគង់ ទើបនាងមាគន្ទិយាស្រែកឡើង ដូច្នេះហើយបានថា ខ្ញុំម្ចាស់ឃើញនិមិត្តអាក្រក់ ។ ម្តងនេះព្រះបាទឧទេនទ្រង់ជឿថា នាងសាមាវតីបង់ធ្វើឲ្យអន្តរាយជីវិតព្រះអង្គមែន ក៏ទ្រង់ចាប់ធ្នូឡើងបាញ់ដំរង់ទៅនាង ប៉ុន្តែលុះបាញ់ទៅព្រួញនោះក៏ត្រឡប់វិលមកខាងព្រះអង្គវិញ ។ ក្នុងវេលានោះព្រះបាទឧទេនទ្រង់បន្ទូលបរិភាសថា អម្បាលដល់ព្រួញដែលឥតវិញ្ញាណ

គង់វាស្គាល់សីល ស្គាល់គុណសម្បត្តិរបស់នាងសាមាវតីហើយ ខ្ញុំនេះអញជាមនុស្សមិនបានស្គាល់គុណសម្បត្តិនេះមានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់បោះធ្នូចោល ហើយក្រាបចុះប្រែបជើងនាងសាមាវតីអង្វរសុំឲ្យនាងជួយឧបត្ថម្ភជាទីពឹង នាងក្រាបទូលឡើងថា មានតែព្រះពុទ្ធជាម្ចាស់ដែលជាទីពឹងទីរលឹករបស់នាងទើបនាងសុំឲ្យព្រះបាទឧទេនអារាធនានិមន្ត ព្រះសម្មាសម្ពុទ្ធមួយអន្លើដោយព្រះសង្ឃ ៥០០ អង្គ ដើម្បីសម្ដែងធម្មទេសនាក្នុងទីដំណាក់របស់នាង ។ ក្នុងវេលានោះព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់បាត់ព្រះអានន្ទ នឹងភិក្ខុ ៥០០ អង្គឲ្យចូលមកក្នុងព្រះបរម-រាជវាំង ហើយព្រះមហាក្សត្រទ្រង់ប្រគេនបីវរគ្រប់អង្គទាំងអស់ ។

ឯនាងមាគន្ទិយាបេះតែគិតព្យាបាទជានិច្ច បានសំឡុបឲ្យមាចូលមកក្នុងដំណាក់នាងសាមាវតី តាំងបិទទ្វារបង្អួចបង្ខាំងនាងសាមាវតីនឹងបរិវារទាំង ៥០០ ហើយយកសំពត់នឹងប្រេងពីក្នុងឃ្លាំងមកជ្រលក់ដុតដំណាក់នោះឡើង ។ ក្នុងវេលានោះ

ព្រះបាទឧទេនទ្រង់ស្ទុះរត់មកជួយ តែជួយមិនទាន់ នាងសាមាវតី នឹងស្រីទាំងប៉ុន្មានស្លាប់ក្នុងភ្លើងអស់ទៅ ។ ទ្រង់ក៏មានសេចក្តីសង្ស័យនឹងនាងមាគន្ទិយា ហើយទ្រង់មានព្រះបន្ទូលសួរថា ដែលនាងធ្វើនេះជាការប្រណែនឈ្នានិះ ហើយបងឃើញច្បាស់ថា ព្រោះតែនាងស្រឡាញ់បង ទើបនាងធ្វើដូច្នេះ នេះហើយជាភស្តុតាងយ៉ាងច្បាស់លាស់ ដែលនាងស្រឡាញ់បង ។ ក្នុងវេលានេះបងនឹងឲ្យរង្វាន់ដល់នាង ព្រមទាំងបងប្អូននឹងពួកនាងទាំងអស់ ។ មានមនុស្សជាច្រើនចូលមកដើម្បីទទួលរង្វាន់ ដែលមិនមែនជាញាតិ មិនមែនជាពួកក៏ចូលមកដែរ ។ ក្នុងវេលានោះព្រះមហាក្សត្រទ្រង់ឲ្យចាប់ទាំងអស់បោះទៅក្នុងរណ្តៅ ហើយឲ្យយកចំបើងទៅគរពីលើដុតភ្លើងឡើង ហើយក៏ឆេះខ្លោចទាំងអស់គ្នា ព្រះបាទឧទេនទ្រង់ឲ្យអារសាច់នាងមាគន្ទិយាមកឲ្យទំពាស៊ីផង ។

"ត្រង់នេះមានជាប់រឿងជាអតីតកាលទៀត" ។

ទោះជាមានយកគាថា ក្នុងព្រះធម្មបទលេខ ២១ ដល់ ២៣[1] មកបញ្ចូលក្នុងរឿងមាគន្ទិយានឹងសាមាវតីក្តី ក៏គង់មានរឿងរ៉ាវឯទៀតជាច្រើន ដែលអាចនឹងយកមកប្រកបនឹងគាថាដែលត្រូវគ្រប់រឿងនេះបាន ។ ការដែលព្រះពុទ្ធឃោសាចារ្យបានរើសយកមកបញ្ចូលក្នុងរឿងនេះ ខ្ញុំយល់ព្រមតាមតែក្នុងស្ថានដែលលោកចង់បញ្ចូលដោយគំនិតលោកយល់ឃើញថា ជាមានប្រយោជន៍ ។ ប៉ុន្តែឯរឿងនេះ ហេតុអ្វីក៏យករឿងកំណើតព្រះបាទឧទេននឹងរឿងតាំបរត់នាងវាសុលទត្តាមកបញ្ចូលផង? យើងមើលឃើញច្បាស់លាស់ណាស់ ថាបើជាយករឿងទាំងអស់នេះមកផ្ទឹមគ្នាទៅឃើញថា នាងសាមាវតីជាតួឯកក្នុងរឿង ។ ហើយគេយល់ថា រឿងនាងសាមាវតីនេះ ត្រូវជាប់ជាមួយគ្នានឹងរឿងនាងមាគន្ទិយាហើយ ប៉ុន្តែបំណែករឿងនាង វាសុលទត្តាវិញនោះឃើញថា ជាសេចក្តីក្រៅរឿងដោយពិត យើងពិនិត្យឃើញថា ជាការទាស់

(១) អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា (២១) ឯតំ វិសេសតោ ញត្វា អប្បមាទម្ហិ បណ្ឌិតា អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា (២២) តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ (២៣) ។

ណាស់ ដែលយករឿងនេះមកដាក់បញ្ចូល នាំឲ្យជាប់រឿងមុនឥតប្រយោជន៍ ។ ម្យ៉ាងវិញទៀត រឿងនេះក្នុងភាគដំបូងដាក់សារបាឋថា ឧទេនស្ស ឧប្បត្តិ ហើយក្នុងភាគដែលនិយាយពីនាងវិសុលទត្តា និងនាងមាគន្ទិយា គេដាក់សារ-បាឋថា ឧទេនស្ស បន អបរាបិ វិសុលទត្តា នាម ទេវី អហោ-សិ ។ អបរា បន មាគន្ទិយា នាម រញ្ញោ សន្តិកា អគ្គមហេសិ-ដ្ឋានំ លភិ ។ អ្នកដែលមើលរឿងអាចនឹងភាន់ច្រឡំ ហើយជឿថា គេនឹងនិទានរឿងព្រះបាទឧទេនទាំងមូលព្រមទាំងអគ្គម-ហេសីផ្សេង ៗ ទាំងអស់របស់ព្រះអង្គ ។ សេចក្ដីបញ្ចូលផ្សំរបស់ព្រះពុទ្ធឃោសាចារ្យនេះ មានសភាពជាបេញមកពីកន្លែងពីរផ្សេងគ្នា ។ គឺជារឿងរបស់នាងសាមាវតី ហើយដែលមានយករឿងភាវ ២ កន្លែងរបស់ព្រះបាទឧទេនមកបញ្ចូលជាមួយទៀតដោយការមិនប៉ិនប្រសប់ ឯរឿងពីរកន្លែងដែលយកមកបញ្ចូលនេះ យើងបានប្រទះឃើញនៅជាប់គ្នាក្នុង បបញ្ចសូទនី ។

យើងប្រទះឃើញរឿងនាងសាមាវតី (ស្យាមាវតី) ជាថ្មីទៀតក្នុងមូលសវ៌ាស្តិវាទវិនយ ។ ក្នុងទីនេះតួរឿងហាក់ដូចជា

មានទំនងច្បាស់លាស់ គឺថាបើគេពិចារណាតាមបទត្រង់ដែលនាងសាមាវតី បានទទួលការសិក្សាអំពីសំណាក់ព្រះសារីបុត្ត ហើយដែលព្រះសារីបុត្តអាចញាំងឲ្យសម្រេចបាននោះអាចនឹងយល់បានថា ព្រះសម្មាសម្ពុទ្ធទ្រង់បានអនុញ្ញាតក្នុងស្ថានខ្លះឲ្យពួកភិក្ខុនៅក្នុងដំណាក់ស្ដេចបានវេលាក្រោយថ្ងៃលិចទៅ ។ ឯកន្លែងសំខាន់របស់រឿងនោះ អាចនឹងនិយាយឲ្យអស់តែ ២-៣ បន្ទាត់; បំណែកព្រះគន្ថរចនាចារ្យលោកយកសេចក្ដីតាំងពីណាឆ្ងាយមកពោល ។ រឿងនាងស្យាមាវតីនេះមានបែកជា ២ បំណែកៈ ទី ១ គឺរុទ្រាយណអវទាន, ទី ២ គឺមាកន្ទិក-អវទាន ដែលលោកអ្នកតែងគម្ពីរទិវ្យាវទានបានយកមកបំបែកចេញពីគ្នាទៅជានិទានទី ៣៧ នឹង ៣៦ ប៉ុន្តែបំណែកខាងគម្ពីរបិនឃើញរៀបរៀងតៗ គ្នាតាមធម្មតា ហើយបន្ថែមកន្លែងដែលគេកាត់ចោលក្នុងគម្ពីរជាភាសាសំស្ក្រឹតថែមទៀត ។

ឯបំណែកទី ១ (គឺរុទ្រាយណ) នោះមានសម្ដែងអំពីដើមកំណើតរបស់នាងស្យាមាវតី ។ ក្នុងទីនេះ នាងស្យាមា-

វតីជាបុត្រីភិរុដ៍ជាសេនាបតីរបស់ស្ដេចនៅនគរពោរុក; ភិរុសេនា-បតីបានប្រគល់ឲ្យទៅនាងសៃលាភិក្ខុនី ដើម្បីនាំទៅឯឃោសិត-សេដ្ឋីជាសំឡាញ់នៅក្រុងកោសម្ពី ។ តាមអដ្ឋកថាបាឡី ថានាងស្យាមាវតីជាបុត្រីសេដ្ឋីម្នាក់នៅក្នុងប្រទេសក្រៅ; តែក្នុងទីនេះនាងត្រឡប់ជាបុត្រីសេនាបតីក្នុងប្រទេសក្រៅវិញ; ក្នុងអដ្ឋកថាបាឡីថា នាងរត់ពីស្រុកដោយមានកើតជំងឺផ្សង; ក្នុងទីនេះនាងរត់ពីនគរពោរុកដោយមានកើតភ្លៀងធ្លាក់ដី ។ ក្នុងស្ថាននេះយើងយល់ច្បាស់ថា ប្រវេណីតៗមក ត្រូវការឲ្យនាងស្យាមាវតីដែលអគ្គមហេសីព្រះបាទឧទយននេះ ជាអ្នកក្រៅក្រុងកោសម្ពីហើយខ្វាត់ខ្វាត់ចូលមកក្នុងក្រុងកោសម្ពី ដោយមានហេតុភេទជាទីលំបាកវេទនា ហើយមានមនុស្សចិត្តបុណ្យទទួលទុក ។ ដែលថានាងស្យាមាវតីជាបុត្រីភិរុសេនាបតីនៅពោរុកនោះជាការពោលបួម ដើម្បីនឹងបញ្ចូលរឿងរុទ្រាយណនឹងរឿងវិនាសក្រុងពោរុក ។ រឿងនេះមានប៉ះទាក់ទងពីរកន្លែងនឹងរឿងឧទយន ។ ជាដើមគឺឈ្មោះឧទយទ នឹងរុទ្រាយណមានទំនងប្រហែលគ្នាណាស់ (ផ្ទួនកាលឃើញសរសេរជាឧទ្រាយណផង) ឃើញថា

ឈ្មោះខាងក្រោយនេះក៏ជាឈ្មោះមុននោះដែរ ។ ម្យ៉ាងទៀតអំពីដែលព្រះពុទ្ធរូប ១ ព្រះអង្គ និមន្តពីកោសម្ពីទៅក្នុងក្រុងពោរុកនោះជាការអាចនឹងនាំឲ្យប្រឡំរឿងបាន; ប៉ុន្តែខាងបំណែកសាស្ត្រាចារ្យកែន់ លោកបញ្ជាក់ថា ឈ្មោះទាំងពីរនេះមិនមែនរូបតែ ១ ទេ ព្រោះទីក្រុងពោរុកនោះ លោកបានរកឃើញក្នុងដំបន់ តុកេស្តង់ ។

ពួកអ្នកស្រុកទីបេត៌ ពោលថា ព្រះបាទឧទយន ក្សត្រក្រុងពារាណសី បានបាត់ការកសាងព្រះពុទ្ធរូប ១ ព្រះអង្គអំពីខ្លឹមបន្ទន់លឿង ។ ហ្វានត្សង់ ពោលថា ព្រះបាទឧទយនព្រះចៅក្រុងកោសម្ពី បានបង្គាប់ឲ្យជាងម្នាក់សាងព្រះពុទ្ធរូបនេះ ថាជាងនេះបានទៅឯស្ថានសួគ៌ ដោយអានុភាពព្រះមោគ្គល្លានដើម្បីនឹងពិនិត្យគយគន់ព្រះរូបព្រះបរមសម្មាសម្ពុទ្ធឲ្យប្បាស់នឹងភ្នែកខ្លួនហើយថាព្រះបាទប្របសេនជិត (បសេនទិ) លុះទ្រង់ជ្រាបដំណឹងនេះហើយក៏បានបាត់ការកសាង ១ ព្រះអង្គដូចគ្នាដែរ ។ ខាងបំណែក ជេនៈ ក៏មានរឿងដូចគ្នានេះដែរ ប៉ុន្តែបំណែកគេគឺជារូបព្រះជិនៈ ព្រះបាទឧទយនទំនងជាកើតសឹកសង្គ្រាមនឹង

គ្នា ដោយបទ្យោតមានប្រាជ្ញានឹងដណ្ដើមយកព្រះពុទ្ធរូបនេះ ។ ឯព្រះពុទ្ធរូបនេះ ហ្លួន-ត្សង់ថា បានប្រទះឃើញទៅស្រុកពីម៉្វ គឺ (ភិមា) ហើយថាបានឃើញព្រះពុទ្ធរូបនោះសម្ដែងបាដិហារ្យផង; ថាវេលាដែលព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាននោះ ព្រះពុទ្ធរូបនេះ ហោះដោយអាកាសវេហាស៍ ចេញពីក្រុងកោសម្ពី ទៅចុះនៅក្រុងរោរុក (ពាក្យចិនហៅហូឡៅឡូក្យា) ។ ក្នុងវេលានោះមានព្រះអរហន្ត ១ អង្គគោរពនមស្សការព្រះពុទ្ធរូបនោះ ហើយស្ដេចក្រុងរោរុក បង្គាប់ឲ្យអ្នកស្រុកជញ្ជូនខ្សាច់យកទៅចាក់គរលុបអង្គព្រះអរហន្តនោះ ទើបមានបណ្ដាលកើតជាភ្លៀងធូលីខ្សាច់ក្នុងក្រុងឡើង; ព្រះពុទ្ធរូបក៏សម្ដែងបាដិហារ្យហោះចេញពីក្រុងរោរុកទៅកាន់ស្រុកភិមា ។

ក្នុងមូលសវាស្តិវាទវិនយ រឿងព្រះបាទរុទ្រាយណ ចាប់ផ្ដើមតាំងពីត្រង់ដែលស្ដេចនេះបានប្ដូរដង្វាយទៅវិញទៅមក ជាមួយនឹងព្រះបាទពិម្ពិសារ ។ ព្រះបាទពិម្ពិសារបានផ្ញើព្រះពុទ្ធរូប ១ ព្រះអង្គទៅថ្វាយ ។ លុះព្រះពុទ្ធរូបនិមន្តទៅដល់ មានសេដ្ឋីច្រើនរូបនៅក្នុង មធ្យទេស បានពន្យល់សេចក្ដីដែលផ្ញើជាប់

នឹងព្រះពុទ្ធរូបនោះថ្វាយស្តេចរុទ្រាយណ ហើយតមកស្តេចក៏បានក្រាបទូលសុំភិក្ខុ១អង្គអំពីព្រះបរមសម្មាសម្ពុទ្ធ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ចាត់ព្រះកត្យាយណ (កច្ចាយន) នឹងភិក្ខុ៥០០អង្គដែលជាអ្នកបញ្ចូលសាសន៍ឲ្យនិមន្តទៅ ។ ប៉ុន្តែព្រះកច្ចាយននឹងភិក្ខុទាំង ៥០០ អង្គនេះមិនអាចនឹងចូលទៅក្នុងទីដំណាក់ស្រីក្នុងវាំងបាន ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់ហាម ។ តែបាននាងសេលាភិក្ខុនី នឹងភិក្ខុនី៥០០អង្គ ចូលទៅសម្តែងធម៌ក្នុងដំណាក់ពួកស្រីខាងក្នុង ។ ព្រះបាទរុទ្រាយណទ្រង់ដេញពិណាឲ្យនាងចន្ទ្រប្រភាជាអគ្គមហេសីរាំ (សេចក្តីត្រង់នេះក៏មានទំនងដូចព្រះបាទឧទយនទៀត) វេលាដែលព្រះនាងកំពុងរាំនោះព្រះមហាក្សត្រទ្រង់សំគាល់ឃើញភិនភាគនៅព្រះអង្គនាង ប្រាប់ហេតុថាសេចក្តីមរណៈនឹងជិតមកដល់ហើយក្នុងរវាង ៧ ថ្ងៃ ។ ក្នុងវេលានោះព្រះនាងក៏ប្រញាប់ចូលបួសក្នុងព្រះពុទ្ធសាសនា ក្នុងពេលដែលនៅរស់ ៧ ថ្ងៃនោះ លុះបានស្តាប់ធម៌ទេសនាដោយច្បាស់លាស់អំពីសំណាក់ព្រះសម្មាសម្ពុទ្ធហើយ ព្រះនាងក៏ទូលព្រះស្វាមីថាសុំឲ្យទ្រង់ចូលទ្រង់ព្រះផ្នួសក្នុងព្រះបវរពុទ្ធសាសនា បើ

ទ្រង់មានប្រាថ្នានឹងឲ្យជួបគ្នាក្នុងទេវលោកនាយ ។ ក្នុងវេលានោះព្រះបាទឧទ្ទាយណ ប្រគល់រាជសម្បត្តិឲ្យសិខណ្ឌិនកុមារជាព្រះរាជបុត្រ ហើយបួសទ្រង់ព្រះផ្នួស ក្រោយមកព្រះរាជកុមារឲ្យយកប្រហារជីវិតទៅ ដោយមានសេចក្តីបារម្ភណ៍ដល់រាជសម្បត្តិ ។ តក្រោយមកសេចក្តីខុសឆ្គងរបស់ សិខណ្ឌិន នាំឲ្យវិនាសនគររោរុកដូចដែលហ្វូន-ត្សាង បានពោលដោយឡែកផ្សេងនោះ ។ គឺក្នុងវេលានោះហើយដែលភិរុសេនាបតីបានប្រគល់នាងស្យាមាវតី បុត្រីឲ្យនាងសែលាភិក្ខុនី ។ ខ្ញុំមិនយកជាធុរៈឡើយ រឿងស្យាមាកជាបុត្រាសេនាបតីទី ២ ឈ្មោះហិរុ ដែលបានប្រគល់ប្រគេនព្រះកច្ចាយន ហើយដែលគេបះត់ទៅជាមួយនឹងនាងទេវធីតាដែលរក្សាក្រុងរោរុក, ព្រមទាំងរឿងជាអតីតកាល ដែលជារឿងបញ្ចប់ បំណែកនេះនឹងបរិច្ឆេទទី ៣៧ នៃទិវ្យាវទាន ។

តាមក្នុងគម្ពីរចិន ដែលគេប្រែពីសេចក្តីផ្សេងក្រៅពីភាសាបាឡី នោះមានរឿងតទៅទៀត គឺរឿងឃោសិតសេដ្ឋី ដែលបានធ្វើជាសេនាបតី ស្តេចឧទយន នឹងបានថ្វាយឃោសិតារាម

ដល់ព្រះបរមសម្មាសម្ពុទ្ធ ។ សេដ្ឋីនេះហើយដែលបានយក
នាងស្យាមាវតីធ្វើជាកូនចិញ្ចឹម ហើយនាងស្យាមាវតីមានស្ដេច
ជាច្រើនអង្គចង់បានធ្វើជាអគ្គមហេសី មានស្ដេចឧទយនជាដើម;
តែក្នុងវេលានោះ នាងព្រមទទួលយកស្ដេច ហត្ថាឡេវក ព្រះ
ចៅក្រុងអាជវី ដែលគេបាននិយាយរឿងជាទីអស្ចារ្យជាមុន ។
ប៉ុន្តែក្នុងថ្ងៃដែលនាងស្យាមាវតី ទៅដល់ក្រុងអាជវី ស្ដេចនោះក៏
ទ្រង់ព្រះផ្នួសទៅ ខានយកនាងជាអគ្គមហេសី ហើយនាង
ស្យាមាវតីក៏នៅៗក្រុងអាជវីនោះទៅ តាំងគោរពប្រតិបត្តិដល់
សង្ឃក្នុងទីនោះ ។ ក្រោយនោះបន្តិចស្ដេចក៏ទ្រង់ទិវង្គតទៅ
ហើយខ្លួននាងក៏ត្រឡប់មកឯក្រុងកោសម្ពីវិញ. ក្នុងវេលានោះ
ហើយដែលព្រះបាទឧទយនមកដណ្ដឹងនាងជាថ្មីទៀត ហើយ
ក៏បានតាមព្រះទ័យប្រាថ្នា ។ ឯរឿងនាងខុជ្ជុត្តរា (កុញ្ជោត្តរា)
នឹងអ្នកលក់ផ្កា ក៏មានដូចគ្នាឥតមានខុសអំពីរឿងក្នុងគម្ពីរបាឡី
ឡើយ (តែក្នុងទីនេះគេថាអ្នកលក់ទឹកអប់វិញ) ។ នាងខុជ្ជុត្តរា
បានតាំងធម៌ទេសនា ព្រះសម្មាសម្ពុទ្ធទៅសម្ដែងឲ្យនាងស្យាមា-
វតីស្ដាប់ ។

តពីនេះជាប់រឿងមាគន្ទិកឡើងដែលជាបរិច្ឆេទទី ៣៦ នៃគម្ពីរទិវ្យាវទាន ។ មាគន្ទិកជាព្រាហ្មណ៍ម្នាក់នៅក្នុងស្រុកកល្មាសទម្យព្រាហ្មណ៍នេះមានកូនស្រី ១ មានរូបឆោមល្អជាប់ស្រីទាំងអស់ឈ្មោះអនូបមាព្រាហ្មណ៍បានយកបុត្រីទៅថ្វាយព្រះបរមសម្មាសម្ពុទ្ធឲ្យធ្វើជាអគ្គមហេសី។វេលានោះព្រះសម្មាសម្ពុទ្ធទ្រង់មិនទទួល ហើយតាំងពីនោះមកនាងអនូបមា មានសេចក្ដីគុំគួនបងព្យាបាទមួយជីវិតនឹងព្រះបរមសម្មាសម្ពុទ្ធ ។ គឺជារឿងនាងមាគន្ទិយារបស់ព្រះពុទ្ធឃោសាឥតមានល្បៀង។ តពីនេះទៅជាប់រឿងភិក្ខុចាស់១អង្គ មានសេចក្ដីស្រឡាញ់នាង អនូបមា ហើយស្លាប់ដោយកំហឹងធ្លាក់ទៅនរក រួបពីនេះមានរឿងអតីតកាលយ៉ាងវែង គឺរឿង (សិម្ហនឹងពួករាក្សសីនៅតាម្រទ្វីប) ដែលគម្ពីរទិវ្យាវទានយកមកប៉ប្រិញយ៉ាងខ្លី ។ រួបពីនេះចាប់និយាយរឿងមាគន្ទិកទៀត ចាប់តាំងមាគន្ទិកមកដល់ក្រុងកោសម្ពី ។ មាគន្ទិក ឈប់ជាមួយនឹងនាងអនូបមាក្នុងទីសួន១កន្លែង ។ "នាយសួនច្បារបានទៅក្រាបទូលព្រះបាទឧទយន ព្រះចៅក្រុងវត្សសំហាដូច្នេះ "បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឥឡូវ

មានស្រីម្នាក់មានរូបឆោមលោមពណ៌ល្អឥតខ្ចោះ ចូលមកនៅក្នុងទីស្នួន នាងនេះសមនឹងព្រះករុណាជាអម្ចាស់ជីវិតណាស់" ។ វេលានោះស្តេចក៏យាងទៅក្នុងទីស្នួន បានឃើញហើយក៏ព្រឺព្រួចព្រះអង្គកាយ គ្រាន់តែក្រឡេកឃើញក៏គួបព្រះហឫទ័យស្រឡាញ់ ។ ក្នុងវេលានោះស្តេចមានព្រះបន្ទូលទៅកាន់តាបសមាកន្ទិកថា "នាងនេះជាប្រពន្ធនរណា" ក្រាបទូលថា កូនក្រមុំទូលបង្គំជាខ្ញុំ មិនមែនជាភរិយាអ្នកឯណាទេ បើដូច្នោះព្រមឱ្យខ្ញុំឬទេ ក្រាបទូលទូលបង្គំថ្វាយព្រះករុណា" ក្នុងវេលានោះស្តេចក៏យកនាងអនូបមាទៅឱ្យនៅក្នុងព្រះបរមរាជវាំងជាមួយនឹងអគ្គមហេសីឯទៀត ព្រះរាជទានស្រីបំរើ ៥០០ នាក់ នឹងប្រាក់ ១ ប៉ឺ ៥០០ កហាបណជាថ្លៃទឹកអប់នឹងភ្នួងមាលា ។

ក្នុងវេលាក្រោយតពីនោះមក មហាក្សត្រទ្រង់តាំងមនុស្សពីរនាក់ទៀតឱ្យធ្វើរាជការ ម្នាក់មានមុខក្រសួងត្រូវថ្វាយដំណឹងល្អ ហើយម្នាក់ទៀតមានមុខក្រសួងត្រូវថ្វាយដំណឹងអាក្រក់ ។

# សាសនប្រវត្តិ

## ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ

រៀបរៀង

(គ)

## បរិច្ឆេទទី ៩

### លើកទី ២

### ព្រះពុទ្ធសាសនាលទ្ធិថេរវាទ

បន្ទាប់នឹងសាសនាព្រាហ្មណនោះ ព្រះពុទ្ធសាសនាលទ្ធិថេរវាទឬលទ្ធិអាចរិយវាទផ្សាយមកក្នុងប្រទេសកម្ពុជានេះមុន មានអ្នកខ្លះយល់ថា លទ្ធិអាចរិយវាទផ្សាយមកមុន ដែលជាដូច្នេះប្រហែលជាអាងបុរាណវត្ថុ ក្នុងលទ្ធិនេះមានរូបលោកេស្វរជាដើម សឹងមាននៅក្នុងកំឡុងក្រុងមហិន្ទ្របុរី ដែលសាងឡើងក្នុងរវាង ព.ស. ១៣០០ ដល់ ១៥០០ នោះឯង ។ តែដោយមតិរបស់ខ្ញុំយល់ថា លទ្ធិថេរវាទផ្សាយមកមុន ក្នុងពេលដែលខ្មែរកំពុងកាន់សាសនាព្រាហ្មណនោះឯង ដែលពោលដូច្នេះ ដោយអាស្រ័យការស្វះស្វែងស្រាវជ្រាវរកទៅ ឃើញមានមូលល្មមជឿយកជាពិតបាន គឺៈ

១ ក្នុងសម័យក្រោយពុទ្ធកាលមិនយូរប៉ុន្មាន ដរាបមកដល់ ព.ស. ៥០០ មានជនជាតិខេមរនាំគ្នាចុះមកពីដែនមជ្ឈិមប្រទេសមកតាំងភូមិលំនៅនៅក្នុងស្រុកដែលហៅថា ទ្វារវតី

ហៅក្នុងកាលឥឡូវនេះថា នគរបឋម នៅជាខាងជើងក្រុងបាងកកមិនឆ្ងាយប៉ុន្មាន ក្នុងមនុស្សអំបាលនោះ អ្នកខ្លះកាន់សាសនាព្រាហ្មណ៍ អ្នកខ្លះកាន់ព្រះពុទ្ធសាសនា អ្នកណាកាន់សាសនាអ្វីក៏នាំសាសនានោះយកមកប្រព្រឹត្តប្រតិបត្តិនិងប្រដៅអ្នកដទៃតទៅ ព្រោះក្នុងពេលនោះព្រះពុទ្ធសាសនាបានផ្សាយសុះសាយទូទៅក្នុងដែនឥណ្ឌាហើយ ។

២ ក្នុងកាល ព.ស. ២៣៦ ព្រះសោណថេរនឹងព្រះឧត្តរថេរនាំព្រះពុទ្ធសាសនាមកប្រតិស្ឋានក្នុងប្រទេសមន ដែលមានអាណាខេត្តជាប់គ្នានឹងប្រទេសកម្ពុជា បានប្រដៅប្រជាជនជាតិមនឲ្យកើតជ្រះថ្លាថ្វាយខ្លួនជាឧបាសកឧបាសិកានឹងបព្វជ្ជាឧបសម្បទាមានបំនួនច្រើនឡើងដោយលំដាប់ ហើយក៏ផ្សាយចេញទៅក្នុងប្រទេសដ៏តខាង ប្រទេសកម្ពុជាក៏បានទទួលរាប់អានព្រះពុទ្ធសាសនាដែលផ្សាយអំពីប្រទេសនោះក្នុងសម័យនោះដែរ ឬនឹងថា ព្រះថេរទាំងពីរមកប្រកាសសាសនាក្នុងទីនេះតែម្តងក៏គួរប្រើន ព្រោះមានរបស់ដែលជាភស្តុតាងច្រើនជាងប្រទេសមន ។

៣ ប្រាកដក្នុងរឿងប្រវត្តិខ្មែរដែលក្រុមព្រះដាំរង់រាជានុភាព ទ្រង់រៀបរៀងទុកក្នុងសៀវភៅព្រះរាជពង្សាវតារ (ស្យាម) ច្បាប់ព្រះរាជហត្ថលេខា ទំព័រ ៣៧ ដែលបោះពុម្ពកាល ព.ស. ២៤៥៧ ថា "ភូមិប្រទេសខ្មែរអំពីដើមតាំងនៅទីទាបខាងត្បូង តាំងអំពីស្រុកខ្មែរសព្វថ្ងៃនេះ ឡើងទៅតាមឆ្នេរសមុទ្រដរាបដល់ទន្លេវីស្ណុ (គឺម៉ែណាំប៉ោព្រះយ៉ាសព្វថ្ងៃនេះ) រហូតទៅទល់នឹងប្រទេសមន(១) ខនេះគួរជឿយកជាពិតបាន ដោយភាសាអ្នកស្រុកដើមក្នុងទីអំបាលនេះនិយាយភាសាខ្មែរ សូម្បីសព្វថ្ងៃនេះពួកមលេយូ ក៏នៅប្រើភាសាខ្មែរបង្គាប់ដីរទូទៅ ក៏ក្នុងផ្ទៃទីអំបាលនេះ មានបូរាណវត្ថុដែលខ្មែរសាងទុកនៅជាតឹកតាងច្រើន តែរបស់ទាំងនេះមានន័យគួរឲ្យសង្កេត គឺត្រើយខាងកើតនៃទន្លេវីស្ណុ ច្រើនសាងជាទេវស្ថានក្នុងសាសនាព្រាហ្មណ ត្រើយខាងលិចច្រើនសាងជាវត្ត នឹងព្រះចេតីយ៍ក្នុងព្រះពុទ្ធសាសនាលទ្ធិថេរវាទ តែដូច្នេះតាំងអំពីចុងដែនមលេយូរហូតទៅទល់នឹងប្រទេសមន ។

(១) សម័យនោះគ្មានសៀមនៅក្នុងវាងកណ្ដាលដូច្នេះទេ ។

៤ ក្នុងវេលានេះប្រទះឃើញបូរាណវត្ថុផ្សេង ៗ ជារបស់ក្នុងព្រះពុទ្ធសាសនា និងជារបស់ក្នុងសាសនាព្រាហ្មណ៍ ដែលស្គាល់បានថា សាងឡើងក្នុងសម័យនោះ ៗ មាននៅក្នុងតំបន់នោះ ៗ គឺនៅស្រុកនគរបឋម មានព្រះបឋមចេតិយ៍ជារបស់បូរាណ ធ្វើដោយឥដ្ឋរូបសណ្ឋានដើមដូចគ្នានឹងព្រះចេតិយ៍សញ្ចីរបស់ព្រះបាទធម្មាសោក ចេតិយ៍នេះក្នុងសៀវភៅឈ្មោះបឋមចេតិយ៍ ដែលចៅព្រះយ៉ាទិពាករវង្ស រៀបរៀងនឹងបោះពុម្ពកាល ព.ស. ២៤៦៩ ក៏ថាខ្មែរបានកសាងឡើងម្តង ។ នៅទីនោះ គេបានជីកទៅប្រទះឃើញសិលារូបកង់ចក្រ គឺធម្មចក្រ នឹងពាក្យបារិកព្រះធម៌ជាភាសាមគធ, ព្រះទែនពុទ្ធ-អាសន, ស្នាមព្រះពុទ្ធបាទ, របស់អំបាលនេះគេសាងឡើងសម្រាប់បូជាតាំងអំពីសម័យមុនមានព្រះពុទ្ធរូប សមតាមពណ៌ដំមាននៃការសើបសាសនារបស់អ្នកប្រាជ្ញបូរាណគតិ ក្នុងប្រ-ទេសឥណ្ឌាថា ក្នុងសម័យរជ្ជកាលព្រះបាទធម្មាសោករាជមិនទាន់មានប្រពៃណីសាងព្រះពុទ្ធរូបនៅឡើយ មានសាងតែព្រះស្តូបចេតិយ៍ នឹងរបស់ដំនួសព្រះពុទ្ធរូបមានកង់ចក្រជាដើម

ព្រះពុទ្ធរូបជារបស់ទើបសាងឡើងក្នុងជាន់ក្រោយ ដូចមានពោលក្នុងបរិច្ឆេទទី ១០ ។ មួយទៀត បុរាណវត្ថុបែបដែលឃើញនៅព្រះបឋមចេតីយ៍ មិនបំពោះមានតែនៅទីនោះមួយកន្លែងប៉ុណ្ណោះ មានផ្សាយមកក្នុងត្រើយខាងកើតទៀតជាច្រើនអន្លើ សៀមគេបានស្រាវជ្រាវរកទៅ ឃើញមានរាយមកក្នុងមណ្ឌលរាជបុរី មឿងសុពណ្ណបុរី និងមឿងលពបុរី ដែលជាទីក្រុងចាស់របស់ខ្មែរ មឿងនគររាជនិងនគរភ្នំ ដែលជាអាណាខេត្តរបស់ខ្មែរក្នុងបុរាណសម័យ ។ នៅស្រុកនគរភ្នំសឹងតាំងនៅតាមឆ្នេរទន្លេខោង មានព្រះចេតីយ៍ ១ អង្គហៅថា ព្រះជាតុភ្នំ[១] ជារបស់ខ្មែរសាងក្នុងសម័យជាន់ដើមបំផុត មុនសាងក្រុងមហិន្ទ្របុរី ជាច្រើនរយឆ្នាំ មានស្នារដៃមិនសូវល្អផ្ចិតផ្ចង់ មិនដូចស្នារដៃយក្នុងសម័យសាងក្រុងមហិន្ទ្របុរី ។

៥ តាមព្រះមតិព្រះបាទសម្តេចព្រះមហាមកុដ(ព្រះចមក្លៅ) និងក្រុមព្រះដំរុងរាជានុភាពដែលរាប់ថា ជាអ្នកប្រាជ្ញបូរាណគតិក្នុងទ្វីបនេះ ក៏ទ្រង់យល់ថា ព្រះពុទ្ធសាសនាលទ្ធិថេរវាទបាន

---
១ ពាក្យថា ព្រះធាតុភ្នំនេះក៏ជាពាក្យខ្មែរទៅហើយ ។

ផ្សាយមកក្នុងប្រទេសនេះតាំងអំពីសម័យ ព. ស. ២៣៦ ដល់ ៥០០ ជាប្រាកដ ។ ព្រះបាទសម្តេចព្រះបរមក្សៅបានឲ្យចារិកទុកនៅព្រះបឋមចេតិយ៍ថា មឿងនេះជាមឿងដែលបានទទួលព្រះពុទ្ធសាសនាមកប្រតិស្ឋាន តាំងអំពីសម័យព្រះបាទធម្មាសោករាជបញ្ជូនព្រះថេរមកប្រកាសផ្សព្វ ។

ដោយហេតុអំបាលនេះ ទើបសន្និដ្ឋានថា ក្នុងរវាង ព. ស. ២៣៦ ដល់ ៥០០ ព្រះពុទ្ធសាសនាលទ្ធិថេរវាទ បានផ្សាយមកក្នុងប្រទេសកម្ពុជានេះហើយជាប្រាកដ ។ មិនតែក្នុងសម័យនេះ សូម្បីក្នុងសម័យក្រោយមក គឺពី ព. ស. ៥០០ ដល់ ១២០០ ក៏មានដំណឹងថា ព្រះពុទ្ធសាសនាលទ្ធិនេះមាននៅក្នុងប្រទេសកម្ពុជាដែរ គឺ:

១ កាលមានប្រពៃណីសាងព្រះពុទ្ធរូបឡើងក្នុងប្រទេសឥណ្ឌា ពួកឥណ្ឌាក៏នាំបែបនោះមកសាងក្នុងប្រទេសសុវណ្ណភូមិនេះទៀត ពួកខ្មែរក៏បានទទួលរាប់អានប្រពៃណីថ្មីនេះដែរ ខនេះយើងអាចសង្កេតដឹងបានដោយលក្ខណព្រះពុទ្ធរូបបុរាណដែលសាងឡើងជាដំបូងក្នុងប្រទេសនេះ យ៉ាងព្រះពុទ្ធរូបគ្រា

សំដែងព្រះធម្មចក្រ គង់សំយុងព្រះបាទដូចយ៉ាងអង្គុយកៅអីជាដើម ជារបស់សាងមុនបង្អស់តាមបែបប្រទេសមគធ ដែលមានសាងឡើងក្នុងសម័យគុប្តរាជវង្ស ប្រមាណជា ព.ស. ៩០០ ក៏មកឃើញមាននៅក្នុងតំបន់ស្រុកអំបាលនេះ នៅវត្តព្រះបឋម-ចេតីយ៍ក៏មានមួយអង្គដែរ[១] ។

២ ប្រាកដក្នុងរឿងចាមទេវីវង្ស ដែលព្រះពោធិរង្សីបេរតែងជាភាសាមគធ ចំនួន ៥ ខ្សែ ថា ក្នុងកាលព្រះមហាក្សត្រិយ៍ខ្មែរតាំងរាជធានីនៅស្រុកលវោ ទ្រង់ចាត់ព្រះរាជធីតាព្រះនាមចាមទេវីឲ្យទៅគ្រប់គ្រងស្រុកហរិភុញ្ជ័យ ឬហៅថា ឡានណាឥឡូវនេះនៅក្នុងអាណាខេត្តរបស់សៀមភាគខាងលើ) ក្នុងកាល ព.ស. ១២០០ គ្រាដែលព្រះនាងទៅ បាននាំទាំងព្រះពុទ្ធសាស-នាលទ្ធិថេរវាទទៅផ្សាយក្នុងប្រទេសនោះផង គឺ ព្រះនាងនិមន្តព្រះពុទ្ធរូប ១ អង្គទៅ សព្វថ្ងៃនេះនៅក្នុងវត្តមហាធាតុ មឿងលំ-ភូន អ្នកស្រុកហៅថា «ព្រះលវោ» តាមហេតុដែលនិមន្តទៅពី

១ មានរូបថតនៅក្នុងសៀវភៅជំណាលពុទ្ធចេតីយ៍ ទំព័រ ១៨០ ដែលខ្ញុំប្រែមកអំពីសៀវភៅសៀម ។

សំដែងព្រះធម្មចក្រ គង់សំយុងព្រះបាទដូចយ៉ាងអង្គុយកៅអីជាដើម ជារបស់សាងមុនបង្អស់តាមបែបប្រទេសមគធ ដែលមានសាងឡើងក្នុងសម័យគុប្តរាជវង្ស ប្រមាណជា ព.ស. ៩០០ ក៏មកឃើញមាននៅក្នុងតំបន់ស្រុកអំបាលនេះ នៅវត្តព្រះបឋម-ចេតីយ៍ក៏មានមួយអង្គដែរ(១) ។

២ ប្រាកដក្នុងរឿងចាមទេវីវង្ស ដែលព្រះពោធិរង្សីថេរតែងជាភាសាមគធ ចំនួន ៥ ខ្សែ ថា ក្នុងកាលព្រះមហាក្សត្រិយ៍ខ្មែរតាំងរាជធានីនៅស្រុកលវោ ទ្រង់ចាត់ព្រះរាជធីតាព្រះនាមចាមទេវីឲ្យទៅគ្រប់គ្រងស្រុកហរិភុញ្ជ័យ ឬហៅថា ឡានណាឥឡូវនេះនៅក្នុងអាណាខេត្តរបស់សៀមភាគខាងលើ) ក្នុងកាល ព.ស. ១២០០ គ្រាដែលព្រះនាងទៅ បានទាំងនាំព្រះពុទ្ធសាស-នាលទ្ធិថេរវាទទៅផ្សាយក្នុងប្រទេសនោះផង គឺ ព្រះនាងនិមន្តព្រះពុទ្ធរូប ១ អង្គទៅ សព្វថ្ងៃនេះនៅក្នុងវត្តមហាធាតុ មឿងលំ-ភូន អ្នកស្រុកហៅថា «ព្រះលវោ» តាមហេតុដែលនិមន្តទៅពី

---

១ មានរូបថតនៅក្នុងសៀវភៅដំណាលពុទ្ធចេតីយ៍ ទំព័រ ១៨០ ដែលខ្ញុំប្រែមកអំពីសៀវភៅសៀម ។

ស្រុកលវោ វេលាព្រះនាងទៅគង់នៅទីនោះហើយ មានសាងវត្តព្រះស្តូបចេតីយ៍ ព្រះពុទ្ធរូបជាច្រើន ដូចមានប្រាកដក្នុងរឿងនោះស្រាប់ ។

៣ សិលាចារិកនៅស្រុកលវោ ជារបស់ដែលព្រះមហាក្សត្រិយ៍ខ្មែរចារិកទុក តែក្នុងពុទ្ធសករាជប៉ុន្មានមិនប្រាកដ ដោយប្រមាណមើលប្រហែលជាក្នុងរវាង ព.ស. ១២០០ ដល់ ១៥០០ រួមសម័យជាមួយគ្នានឹងព្រះនាងចាមទេវី វេលានេះសៀមនាំយកសិលាចារិកផែននោះ ទៅដំកល់ទុកនៅហោព្រះសមុតវជិរញាណ ក្រុងបាងកក ដាក់លេខ ៩ ជាសំគាល់ សេចក្តីក្នុងសិលាចារិកនោះនិយាយសរុបថា «គ្រានោះប្រទេសកម្ពុជា មានព្រះសង្ឃសមណវង្ស ទាំងនិកាយស្ថវិរទាំងនិកាយមហាយាន» ដូច្នេះ ។

ដោយគ្រឿងអាងទាំងនេះ ទើបនាំឲ្យខ្ញុំយល់ថា ព្រះពុទ្ធសាសនាលទ្ធិថេរវាទផ្សាយមកក្នុងប្រទេសកម្ពុជា មុនលទ្ធិអាចរិយវាទ តែកាលស្រាវជ្រាវរកបុរាណវត្ថុមកជាគ្រឿងប្រកបនេះឃើញមានតែពីត្រឹមពាក់កណ្តាលប្រទេសកម្ពុជាទៅខាងលើ

ពាក់កណ្ដាលមកខាងក្រោម នៅពុំទាន់បានប្រទះឃើញ ៗ តែរបស់ក្នុងលទ្ធិអាចារិយវាទច្រើន ដូច្នេះគួរសន្និដ្ឋានថា លទ្ធិថេរៈវាទដែលផ្សាយមកក្នុងវេលានោះ ប្រហែលជាមិនបានផ្សាយទួទៅទាំងប្រទេស ផ្សាយមកតែក្នុងភាគខាងលើដោយច្រើនព្រោះរាជធានីគោកធ្លោះតាំងនៅក្នុងស្រុកលើឯណោះ ។

# បញ្ជីរឿង

ទំព័រ


១ — បុណ្យបញ្ចុះសីមា នៅវត្តបឋមភនិការាម នៅទីកង់ឡឺវ៉ឡង់ (ដូងលើ)
ព្រះមហាហួត ក្រុមជំនុំប្រែព្រះត្រៃបិដក អធិប្បាយ .......... ១៣៧

២ — រឿងស្តេច ឧទយន ដកយកពីសេចក្តីល្បងអំពីគុណកាព្យ និងព្រឹហត្កថា
របស់លោកហ្វេលិក្ស៍ឡាកូត ក្រម្ការ ជុំ-មៅ ប្រែចេញពីភាសាបារាំង
សែសមកជាភាសាខ្មែរ (ត)...................... ១៦៣

៣ — សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណា-
ល័យ រៀបរៀង (ត)...................... ១៧៧


# រូបថតក្រៅរឿង


ផ្លូវចូលទៅទ្វារជ័យប្រាសាទអង្គរធំ.....រូបលេខ ១ និងលេខ ២ . . ១៣១-១៣៣

# TABLE DES MATIÈRES


I Cérémonie de la pose de Sīmā à la pagode de Pathamavānikārama au Camp Le Rolland (Haut Chhlông) compte rendu par Maha Huot, Membre de la Commission du Tripitaka........................................ 137

II La légende d'Udayana extraite de l'Essai sur Guṇādhya et la Bṛhatkathā par Félix Lacôte, traduit du Français en Cambodgien par Kromokar Choum-Mau (suite)...... 163

III Sāsanapravatti ou l'Histoire des Religions par Préas Maha Pitou Krasém pandit à la Bibliothèque Royale (suite). 177


## ILLUSTRATION:


Hors-texte représentant la chaussée de la porte de la Victoire d'Angkor Thom..............Pl. I. II........ 131-133



នគរធំ-ផ្លូវចូលទៅទ្វារជ័យ



នគរធំ-ផ្លូវចូលទៅទ្វារជ័យ

# អធិប្បាយពីស្រុកក្នុង

## ដំណើរទៅស្រុកភ្នង

រាជការប្រតិកត្តរាត់បារាំងសែស បានរៀបចំដីទំនេ ១ កន្លែង ដែលតាំងនៅជាបន្លោះដីរបស់ខ្មែរនឹងស្រុកកូសាំងស៊ីនជាទីនៅរបស់មនុស្ស ១ ពួកមានសេចក្ដីចេះដឹងតិច បម្រើនមិនទាន់ពួកមនុស្សដែលនៅស្រុកជំនុំជិតទន្លេសមុទ្រ ព្រោះពួកនោះនៅក្នុងព្រៃដាច់ស្រយាលប្រកបដោយភ័យអន្តរាយច្រើន មានខ្លាដំរីនឹងបាញ់ទឹកដីជាដើម មិនសូវមានអ្នកចេះដឹងណាដឹកនាំបំណោះវិជ្ជាទៅផ្សាយឲ្យ មិនដូចពួកមនុស្សបានតាំងស្ថានទីនៅជិតផ្លូវទៅមករបស់នានាប្រទេស ដែលតែងបានបំឡងរបៀបបែបផែននឹងផ្លាស់ប្ដូរទំនៀមទំលាប់ទាស់ខុសជារបស់ដើមចោលចេញមកជាលំដាប មនុស្សព្រៃ ១ ពួកនេះហើយដែលយើងហៅថា ជាតិភ្នង ។ រាជការមានសេចក្ដីប្រាថ្នាចង់ឲ្យជាតិភ្នង បានចម្រើនសេចក្ដីចេះដឹងដូចជាតិឯទៀតឡើងផងនោះ បានជារាជការខាងស្រុកកូសាំងស៊ីន នឹងអាណាមក៏បានរៀបចំជាតិភ្នងដែលនៅខាងចុងខែត្រដែននោះ ៗ ឲ្យបានចេះដឹងឡើងខ្លះ នឹងមានសេចក្ដីរាបសាបានខ្លះហើយ នៅតែបំណែកពួកភ្នងដែល

ចូលខាងដីរបស់ខ្មែរយើងនេះ មិនទាន់បានរៀបចំឲ្យបានស្រួល នៅឡើយ បានជារាជការខាងខ្មែរយើងបានបញ្ជូនពួកទាហាន ក្រុមពីជ័យសង្គ្រាមនឹងក្រុមរក្សាស្រុកឲ្យទៅរៀបចំស្រុកក្នុងនោះ តែស្រុកក្នុងដូចបាននិយាយមកហើយថាជាស្រុកព្រៃ គ្មានវត្ត អារាម ១ សោះ ហើយពួកទាហានខ្មែរសុទ្ធតែជាអ្នកកាន់ព្រះពុទ្ធ-សាសនាដែលមានដំណើរត្រូវនៅក្នុងទីនោះ ឈ្មោះថាឃ្លាតពី ព្រះពុទ្ធព្រះធម៌ព្រះសង្ឃ រកទីពឹងគ្មាន ត្រូវការបង់ធ្វើសីលទានអ្វី ក៏រកលោកសង្ឃនឹងធ្វើបុណ្យមិនបាន ។ ប្រយោជន៍កុំឲ្យពួក ទាហានទាល់គំនិតឥតទីពឹងយ៉ាងនេះ ទើបរាជការរកនិមន្ត ភិក្ខុសង្ឃខ្លះតាមដែលលោកស្ម័គ្រព្រះទ័យល្មមនឹងទៅបាន ប្រ-យោជន៍នឹងនាំសាសនាទៅប្រតិស្ឋានក្នុងទីនោះ ក៏រកបានលោក សង្ឃខ្លះដែលទំទ្រាំទៅនៅក្នុងទីនោះ ។ ការដែលពួកលោកស្ម័គ្រ ទៅនៅទីនោះ បើមិនគិតឲ្យវែងឆ្ងាយទេ ក៏នឹងឃើញថា ដំណើរ ដែលទៅនោះអសារឥតការរកផលប្រយោជន៍គ្មាន ឬនឹងត្រូវ សង្ស័យថា ជាអ្នកប្រព្រឹត្តទាស់ខុសនឹងវិន័យបញ្ញត្តិក៏ថាបានតែ បើគិតឲ្យជ្រៅឲ្យវែងទៅទៀត ក៏នឹងឃើញថា ព្រះពុទ្ធសាសនា

ដែលនឹងផ្សាយទៅដល់ទីនោះ បាក់ឫសជាប់នៅបាននោះ អា-
ស្រ័យដោយសេចក្ដីព្យាយាមសង្វាតរបស់ពួកលោក ដែលមាន
ព្រះទ័យស្អិតធ្ងន់អត់ទ្រាំទាំងអស់នោះ ដែលឈ្មោះថា ជាអ្នកដឹក
នាំព្រះពុទ្ធសាសនាទៅជាដំបូងមុនគេ ដូចគ្នានឹងព្រះថេរានុថេរ
ក្នុងរជ្ជសម័យព្រះបាទធម្មាសោក ដែលត្រូវបញ្ជូនឲ្យទៅប្រ-
កាសសាសនាក្នុងនានាប្រទេស ត្រូវបានជួបប្រទះតទល់នឹង
សេចក្ដីលំបាកច្រើនយ៉ាង ឬដូចគ្នានឹងក្នុងពុទ្ធសម័យកាលព្រះ
អរហន្តសម្មាសម្ពុទ្ធបរមគ្រូរបស់យើង ដែលទើបនឹងបានត្រាស់
ជាដំបូងទ្រង់ប្រោសសត្វឲ្យបានជាព្រះអរហន្តចំនួន៦០អង្គតាម
សេចក្ដីក្នុងមហាខន្ធកគម្ពីរមហាវគ្គវិនយបិដកដំណាលថា ព្រះ
ដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះអរហន្តទាំង ៦០ រូបនោះមក
ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានរួចពីអន្ទាក់គ្រប់យ៉ាង
ដែលជារបស់ទិព្វនឹងជារបស់មនុស្សហើយ អ្នកទាំងឡាយក៏
បានរួចពីអន្ទាក់អស់នោះហើយដែរ ម្នាលភិក្ខុទាំងឡាយចូរអ្នក
ទាំងឡាយត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍នឹងសេចក្ដីសុខ
ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍

នឹងសេចក្ដីសុខដល់ទេវតានឹងមនុស្សទាំងឡាយ តែលោកទាំងឡាយកុំទៅផ្លូវ ១ ពីរនាក់ ហើយត្រូវសំដែងធម៌ឲ្យល្អខាងដើម កណ្ដាល នឹងទីបំផុត ចូរប្រកាសព្រហ្មចារ្យដ៏បរិសុទ្ធឲ្យអស់សេចក្ដីគ្រប់ព្យញ្ជនឲ្យពេញបរិបូណ៌ ពួកសត្វដែលមានកំណើតមានធូលីតិចក្នុងភ្នែកគង់មាន (ទោសមកពី) មិនបានស្ដាប់នឹងសាបសូន្យឃ្លាតចាកធម៌ ពួកសត្វដែលនឹងយល់ធម៌គង់នឹងមានមិនខាន បំណែកតថាគតនឹងទៅសំដែងធម៌ក្នុងស្រុកឧរុវេលាសេនានិគម ។

សេចក្ដីនេះក៏ល្មមឃើញថា ការដែលនាំសាសនាទៅផ្សាយក្នុងស្រុកទេសផ្សេង ៗ នេះ ជាកិច្ចត្រូវតែខំសង្វាតធ្វើ ព្រោះឈ្មោះថា ជាការប្រតិបត្តិត្រូវតាមបំណងព្រះសម្ពុទ្ធបរមគ្រូ ។

លោកដែលខំទ្រាំទៅនៅស្រុកភ្នងនោះ ក៏ប្រយោជន៍នាំសាសនាទៅប្រតិស្ឋានក្នុងទីនោះដែរ ទំនងដូចគ្នានឹងកិច្ចដែលព្រះអរិយជាន់ដើមបានធ្វើមកហើយ ប្លែកគ្នាតែឥឡូវនេះ ពួកលោកដែលទៅនោះមិនមែនជាអរិយផង គឺនៅជាបុថុជ្ជនប៉ុណ្ណោះ ។ កុំថាតែក្នុងព្រះពុទ្ធសាសនាដែលមានសេចក្ដីត្រូវ

ការបំផុតត្រង់ខំផ្សាយសាសនានេះ សូម្បីសាសនាដទៃ ត្រង់ការផ្សាយសាសនារបស់គេនេះ ជាកិច្ច១ដែលគេត្រូវខំយកចិត្តទុកដាក់ជាទីបំផុត គួរគប្បីក្រឡេកមើលពួកប្រដៅសាសនាដទៃ ដែលមានក្នុងស្រុកយើងសព្វថ្ងៃនេះ ទុកជាគ្មានអ្នកណាទំនុកបំរុងដោយបច្ច័យអ្វីសោះ ក៏ស៊ូបាយទ្រព្យសម្បត្តិរបស់ខ្លួន គិតធ្វើដូចម្ដេចឲ្យតែមានពួកបរិសទ្យចូលក្នុងសាសន៍ខ្លួន ត្រឹមតែបានមនុស្សចូលសាសន៍ផង ក៏មានសេចក្ដីត្រេកអរប្រហែលបានយានវាហនយ៉ាងសំខាន់ យកមកប្រើប្រាស់យ៉ាងនោះឯង ។ ស្រុកលំបាកទៀមកមនុស្សល្ងង់លំបាកនឹងប្រដៅដូចយ៉ាងស្រុកភ្នំនេះ ពួកប្រដៅសាសនាខាងក្រៅនេះ ក៏គង់ខំរុករានទៅប្រដៅដែរ ត្រឹមតែលោកសង្ឃយួនប៉ុណ្ណោះក៏យើងគួរឃើញថា គេមានសេចក្ដីសង្វាតគ្រាន់បើដែរ ព្រោះគេបានតាំងវត្តជាច្រើនកន្លែងក្នុងស្រុកយើង ឯយើងវិញដូចជាមិនទាន់មានវត្តដែលបានទៅតាំងក្នុងស្រុកជាទីលំនៅរបស់យួនសូន្យនោះទេ ។ បំណែកខាងពុទ្ធសាសនាដែលយើងយល់ថាជានិយ្យានិកធម៌ សម្រាប់ស្រោចស្រង់សត្វឲ្យរួចចាកទុក្ខមែន

យ៉ាងនេះហើយ យើងក៏មិនគួរព្រងើយកន្តើយនឹងការជួយដឹកនាំពួកមនុស្សដែលនៅល្ងង់ជាមិច្ឆាទិដ្ឋិ មានខ្លួននៅជាខាងក្រៅសាសនានោះឲ្យបានបេះដឹងឡើង ឲ្យលះគំនិតខុសបោលបេញដែរ សេចក្តីប្រតិបត្តិយ៉ាងនេះឈ្មោះថា មិនមែនជាអសារឥតការក្នុងព្រះពុទ្ធសាសនាទេ យល់ឃើញថា មិនមែនខាស់ខុសអ្វីនឹងវិនយបញ្ញត្តិសោះ គួរតែបានសេចក្តីសរសើរជាទីបំផុត ពួកលោកដែលនាំសាសនាទៅប្រតិស្ឋានក្នុងស្រុកភ្នំនោះ ដោយត្រូវទទួលគ្រោះលំបាកច្រើនយ៉ាងក្នុងស្រុកនោះ ឬដោយត្រូវនិន្ទាឬស្បាមើលងាយខ្លះ អំពីសំណាក់មនុស្សពាលគិតខ្លីក្នុងស្រុកជាមួយគ្នានេះ ឈ្មោះថា ជាកំឡាំងព្រះពុទ្ធសាសនា ស៊ូផ្ដូរអាយុជីវិតនឹងព្រះពុទ្ធសាសនាមែន ទុកស្មើគ្នានឹងទាហានទ័ពស្រួចដែលស៊ូលះជីវិតបេញទៅផ្ចាញ់ពួកបច្ចាមិត្រ ដើម្បីការពារសេចក្តីទុក្ខរបស់អ្នកស្រុកជាប្រយោជន៍ដល់ស្រុកនគរផែនដីដែលជាស្រុកកំណើតរបស់ខ្លួនដែរ ។ គំនិតមើលងាយដល់មនុស្សដែលស៊ូទ្រាំទុក្ខជំនួសផែនដីនឹងមនុស្សជាសាធារណ៍ក្តី គំនិតដែលឃើញគេបានអ្វីលើសតិចតួច

ហើយអាក់អន់ចិត្តគិតឫស្យាក្តី បើប្រសិនជាមាននៅក្នុងខ្លួនអ្នកណាអ្នកនោះពេញឈ្មោះថា ពាលពេញទី មិនឈ្មោះថា បានប្រតិបត្តិតាមបវេណីរបស់លោកជាសប្បុរសបណ្ឌិតទេ ហើយមនុស្សពាលយ៉ាងនេះ បើមាននៅកុះករក្នុងទីណា ក៏គប្បីប្ដូលចិត្តចុះថា ដូចគ្នានឹងដើមបញ្ញើក្អែក ឬសារីម៉ាវឹងវល្លិជាដើមដែលជាជាតិឈើជុះអាស្រ័យនឹងឈើឯទៀត នៅពីខាងលើទើរបានខ្ពស់ព្រោះបានឈើខាងក្រោមជួយគាំទ្រ បែកទងវារប្រទាក់ជាក់ស្រែះស្មុកស្មាញគ្របសង្កត់ឈើដែលនៅខាងក្រោមខ្លួននោះ ឲ្យវិនាសអន្តរធានខានលូតលាស់តទៅទៀតបានដូច្នោះឯង ។

ទីណាមានភិក្ខុសង្ឃនៅជានិច្ចហើយ ទីនោះក៏ត្រូវសង្ឃសន្មតសីមារោងឧបោសថឡើង ដើម្បីសេចក្តីស្រួលដល់កិច្ចដែលត្រូវធ្វើសង្ឃការផ្សេង ៗ មានឲ្យឧបសម្បទាដល់កុលបុត្រជាដើម ប្រយោជន៍កុំឲ្យពួកលោកដែលទៅនៅស្រុកភ្នង លំ-បាកដោយទីលំនៅគ្មានសីមាយ៉ាងនេះ រាជការក៏បានបញ្ជូនប្រដាប់ប្រដាសីមានឹងឫសសីមាជាដើម រហូតដល់ទៅវត្តឯទៀត

មានព្រះពុទ្ធរូប, គ្រែធម្មាសន, តុៈ ថាសជាដើមផង ទៅដឹកល់ទុកក្នុងទីនោះ ។ ពីកាលថ្ងៃ ២៧ ខែយូរ៉ាំងឆ្នាំ ១៩៣៤ នេះ រាជការបានចាត់លោកគ្រូព្រះបាឡីផ្លូសំរិដ្ឋា (មឿង) និងអាត្មាភាពឲ្យទៅជួយបញ្ចុះសីមាវត្តថ្មី ១ នៅលើបន្ទាយរ៉ូឡង់ (ស្រុកភ្នង) តែក្នុងដំណើរដែលត្រូវទៅនេះ លោកអគ្គលេខាធិការក្រុមពុទ្ធសាសនបណ្ឌិត្យ បានឲ្យលោកភិក្ខុ ១ អង្គ ឈ្មោះ ទិក ទៅជាមួយផងព្រោះលោកមានកំណើតក្នុងស្រុកនោះ បង្គ្រប់គណៈសង្ឃ និងលោក ៣ អង្គដែលនៅស្រុកភ្នងហើយនោះ និងលោកអ្នកអាចារ្យ ហឹម ម្នាក់ទៀត ដែលធ្លាប់ធ្វើជាអាំងស្ប៉ិកទ័រត្រួតត្រាក្រសួងសិក្សាធិការ ប៉ែកខាងសាលារៀនវត្តទៅជាមួយផងប្រយោជន៍ទៅធ្វើជាអាចារ្យ រៀបចំការសីមានោះ បព្វជិតនិងគ្រហស្ថទាំង ៤ រូបនេះ ក៏បានដំណើរទៅដោយរថយន្តរាជការក្នុងវេលាយប់ម៉ោង ៣ ថ្ងៃ ២៧ យូរ៉ាំងឆ្នាំនេះ តាមផ្លូវទៅកំពង់លួង ឆ្លងស្ទឹងឡាងនៅទីព្រែកក្ដាម ដម្រង់ទៅដល់ទីផ្សារស្គន់ហើយបែរស្ដាំដៃ តាមផ្លូវទៅដល់ទីរួមខេត្តកំពង់ចាម បានចម្ងាយផ្លូវ ១២៥ គីឡូម៉ែត្រ ទើបឆ្លងស្ទឹងឡាងទៅឡើងត្រើយ

ខាងស្រុកទន្លេបិទ ហើយទៅតាមផ្លូវឆ្លងកាត់ស្រុកជុប ខណ្ឌត្បូង នឹងខណ្ឌមេមត់ ចម្ងាយផ្លូវបាន ៨៥ គីឡូម៉ែត្រ ផុតពីអាណាខែត្រកំពង់ចាមចូលក្នុងអាណាខែត្រក្រចេះ គឺផុតពីខណ្ឌមេមត់ចូលក្នុងខណ្ឌស្នួល បានចម្ងាយ ៤៥ គីឡូម៉ែត្រទៀត ឈប់សឹងក្នុងទីសាលាខណ្ឌស្នួលនោះ ១ យប់ ទទួលថ្ងៃនោះលោកចៅហ្វាយខណ្ឌស្នួលមិននៅ ដោយមានកិច្ចរាជការទៅត្រួតត្រាការក្នុងទីដទៃ នៅតែលោកស្រីជាភរិយា នឹងបណ្ដាកូនក្មួយមនុស្សបម្រើរបស់លោកតែលោកស្រីនោះក៏មានចិត្តសទ្ធាជ្រះថ្លាល្អជាទីបំផុត បានទទួលភារឲ្យមនុស្សបាត់ទឹកក្ដៅទឹកត្រជាក់នឹងរៀបចំទីសេនាសនក្នុងផ្ទះ ១ ដោយឡែកបម្រាប់ដល់លោកសង្ឃ នឹងពួកគ្រហស្ថដែលទៅជាមួយនោះដោយត្រឹមត្រូវស្រួលស្អាតល្អជាទីបំផុត លុះព្រឹកឡើងថ្ងៃទី ២៨ យូវាំង លោកឲ្យមនុស្សរៀបចំបង្អាន់ប្រគេនឆាន់ដោយសព្វគ្រប់ហើយ បានរៀបបង្អាន់ដោយឡែកទុកដាក់យកទៅឆាន់តាមផ្លូវផង ក្នុងពេលម៉ោង ៧ ក៏ចេញពីខណ្ឌស្នួលតាមផ្លូវដែលចូលទៅក្នុងអាណាខែត្រយួន ៣ កន្លែងគឺៈ ស្រុក

ឡុកនិញ,  ប៉ុយឌូប និងសឺ បម្ងាយ ៥៥ គីឡូម៉ែត្រទើប
ត្រឡប់ចូលក្នុងដីភ្នងរបស់ខ្មែរវិញ ទៅជួបបន្ទាយប៉ាល់កេជា
ដំបូង បម្ងាយពីស្រុកសឺមកប៉ាល់កេនេះ ១៣ គីឡូម៉ែត្រ
ក្នុងបន្ទាយនេះ មានមេបារាំងម្នាក់សក្តិសែរសង់នឹងពួកទាហាន
ក្រុមរក្សាស្រុកខ្លះនៅត្រួតត្រាក្នុងទីនោះ ពីប៉ាល់កេទៅបម្ងាយ
៣៧ គីឡូម៉ែត្របានដល់បន្ទាយកាទី ផ្លូវដែលទៅដល់បន្ទាយ
នេះមានឡើងភ្នំបុះភ្នំខ្លះដោយកន្លែង ហើយក្នុងរវាងពាក់
កណ្តាលផ្លូវនេះមានកន្លែងរាជការចាស់ ១ ឈ្មោះស្រែខ្ញុំ ដែល
ទើបតែនឹងរើបេញ ។ ក្នុងបន្ទាយកាទីនេះមានមេបារាំងម្នាក់
សក្តិលីយើតឺណង់ (សក្តិពីរ) នឹងបារាំងម្នាក់ទៀតសក្តិសែរសង់
មានទាហានក្រុមរក្សាស្រុកច្រើនជាង ៣០ នាក់ បានឈប់សំង
ក្នុងទីនោះ ១ យប់ ដល់ព្រឹកឡើងថ្ងៃទី ២៩ យូរាំងបានបេញពី
បន្ទាយកាទីទៅតាមផ្លូវបម្ងាយ ៤៧ គីឡូម៉ែត្រ ឃើញមានផ្លូវ
១ បែកខាងឆ្វេងដែបម្ងាយ ៣០ គីឡូម៉ែត្រដម្រង់ទៅលើបន្ទាយ
១ ហៅថា ប៉ូរណែត តពីផ្លូវបែកនោះបម្ងាយ ៥ គីឡូម៉ែត្រ
ទើបបានដល់ទៅបន្ទាយរ៉ូឡង់ ដែលមានវត្តត្រិបញ្ចុះសីមានោះ

ក្នុងពេលម៉ោង ១១ កន្លះថ្ងៃជិតត្រង់ ដល់ពេលរសៀលម៉ោង ៣ បាននាំគ្នាទៅជួបនឹងលោកកាពីតេនឈ្មោះមានសៀរម៉ារ្សង់ ដែលជានាយកត្រួតត្រាទីនោះ បានប្ដឹងពីរឿងដែលត្រូវបញ្ចុះសីមាហ៊ា នឹងត្រូវធ្វើក្នុងពេលយប់ម៉ោង ៧ ថ្ងៃនេះ លោកក៏យល់ព្រមទាំងអស់ឥតមានយល់ទាស់ លុះដល់ពេលដែលបានកំណត់ទុកនោះហើយ អស់ពួកអ្នករាជការខាងក្រុមពី-ជ័យសង្គ្រាមព្រមទាំងភរិយាជាច្រើនបានមកប្រជុំគ្នាក្នុងទីវិហារថ្មីនោះ លោកអ្នកអាចារ្យ ហ៊ឹម បាននាំអុបទៀនធូបធ្វើសក្ការ-បូជានមស្សការព្រះរតនត្រ័យហើយក៏សមាទាននិច្ចសីលលោកលោក ៦ រូបគឺៈ ព្រះបាទរ្ឃដ្ឋសិរីវិជ្ជា (មឿង) ១ អាត្មាភាព ១ លោកអាចារ្យមើកនៅវត្តដែលត្រូវបញ្ចុះសីមានោះ ១ លោកអាចារ្យស៊ុនៅវត្តខាងបន្ទាយប៉ូរណៃត ១ លោកអាចារ្យមុំនៅវត្តខាងបន្ទាយកាទី ១ នឹងលោកភិក្ខុ ទ្វិក ដែលទៅជាមួយគ្នាពីក្រុងភ្នំពេញ ១ បានបំរើនព្រះបរិត្តចប់ស្រេចហើយ ពួកឧបាសកឧបាសិកាទាំងអស់បានចេញផុតពីខែត្រនិមិត្រសីមា នៅឈរចាំប្រាប់និមិត្រពីក្រៅ លោកគ្រូព្រះបាទរ្ឃដ្ឋសិរីវិជ្ជាបានសួរនិមិត្រពីទិសបូព៌ (ខាង

កើត) ទៅទិសអាគ្នេយ៍ ទក្សិណ និរតី បស្ចិម ពាយព្យ ឧត្តរ ឥសាន ហើយមកស្សូវត្រូតទិសបូណ៌ ម្តងទៀត លោកអាចារ្យ និងពួកអ្នករាជការទាហានបានប្រាប់ថា មានថ្មជានិមិត្តៗ ជាលំដាប់គ្រប់ទិសទាំងអស់ រួចហើយលោកទាំង ៦ អង្គបានធ្វើនមស្សការព្រះរតនត្រ័យចប់ហើយ ក៏សូត្រកម្មវាចា សន្មតសីមា ។ តាមបំណងដើមថា វេលាសន្មតសីមាហើយ នឹងកាត់ឫស តែទទួលពេលនោះភ្លៀងខ្យល់ខ្លាំង លោកកាពីតែនលំបាកនឹងអញ្ជើញមកកាត់ឫសសីមាផង ទើបព្រមព្រៀងគ្នាថា ឲ្យបង្អង់ដល់ពេលព្រឹកម៉ោង ៧ សឹមកាត់ឫស លុះព្រឹកឡើងថ្ងៃទី ៣០ យូវ៉ាំងដល់ពេលម៉ោងដែលបានកំណត់ហើយនោះ លោកកាពីតែនបានអញ្ជើញមកជួបជុំគ្នាក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធបដិមាករ ទើបលោកអ្នកអាចារ្យហ៊ឹម បានគោះគាំង ៣ អន្លង់ ហើយពួកទាហានផ្លុំត្រែ ៣ ដងទើបកាត់ឫសសីមានោះព្រមគ្នាទាំងអស់រួចហើយបានបាញ់កាំភ្លើង ១ កាំភ្លើង តអំពីនេះលោកកាពីតែនមានសុន្ទរកថាមករកលោកទាំង ៦ អង្គថា ខ្ញុំមានសេចក្តីត្រេកអរណាស់ ដែលលោកគ្រូគ្រប់ព្រះអង្គបានខំ

សង្ឃាតនិមន្តមកជួយធ្វើការនេះឲ្យសម្រេច នឹងមានសេចក្ដីត្រេកអរជាទីបំផុត ដែលបានព្រះពុទ្ធសាសនាមកប្រតិស្ឋានដល់ទីនេះទាំងនឹកសង្ឃឹមថា តទៅមុខពួកអ្នកស្រុកនេះនឹងបានអាស្រ័យគុណព្រះពុទ្ធសាសនា បានបេះដឹងបម្រើនសតិបញ្ញាស្គាល់ការខុសត្រូវមិនខាន រួចហើយលោកគ្រូព្រះបាឡ៍ដ្ឋសំវិជ្ឈាបាននិ-យាយតបទៅវិញថា អាត្មាភាពគ្រប់រូបក៏បានដឹងច្បាស់ថា ភូមិប្រទេសនេះជាទីកន្ដារដាច់ស្រយាលលំបាកដោយការទៅមក មានតែកាត់ព្រៃខ្លាដំរីឆ្លងវាលឡើងភ្នំចុះភ្នំយ៉ាងនេះ បើប្រសិនជាមិនបានសេចក្ដីទំនុកបម្រុងរបស់រាជការផង នោះពុទ្ធសាសនាក៏មិនអាចនឹងផ្សាយមកដល់ទីនេះបាន លុះលោកនិយាយរួចហើយ អាត្មាភាពក៏បាននិយាយពន្យល់ទៅលោកកាពីតេនទៀតថា ក្នុងព្រះពុទ្ធសាសនាមានកិច្ចត្រូវសន្មតទីដែលហៅថា សីមា ដូចជាការដែលកំពុងធ្វើឥឡូវនេះៗក៏ប្រយោជន៍កំណត់ខេត្តដែនសម្រាប់ធ្វើសង្ឃកម្មផ្សេង ៗ មានឧបោសថនឹងបវារណាជាដើម ដូចគ្នានឹងរបៀបរាជការដែលកំណត់នគរ ខេត្ត ខណ្ឌ ឃុំ រហូតដល់ស្រែចំការជាដើម ដោយមានគ្រឿងសំគាល់ថា នគរ ឬ

ខេត្រជាដើម នោះមានព្រៃប្រទល់ត្រឹមព្រៃកនោះភ្នំនោះជាដើម ការដែលកំណត់ខេត្រដែនយ៉ាងនេះ តោងមានអ្នករាជការជំនុំយល់ព្រមទើបទុកជាស្រេចគ្រឿងកំណត់នេះឯងមានប្រយោជន៍នឹងធ្វើរាជការងាយមិនប្រឡូកប្រឡំគ្នា ដែលហៅថាព័ន្ធឃុំព័ន្ធខេត្រនោះយ៉ាងណា ការដែលសង្ឃប្រជុំសន្មតទីកន្លែងណាមួយឲ្យជាវិសុង្គាមគឺទីដែលញែកចេញពីស្រុកដោយមានគោលបរិកផ្សេង ៗ មានភ្នំព្រៃកនឹងផ្លូវជាដើមដូចក្នុងទីនេះកំណត់យកថ្មទាំង ៨ ដុំដែលតាំងនៅជុំវិញវិហារនេះជាខេត្រដែន, គ្រឿងសំគាល់អស់នេះហៅថានិមិត្ត ទីដែលសង្ឃសន្មតនេះមានប្រយោជន៍នឹងធ្វើសង្ឃកម្មផ្សេងៗ ងាយស្រួល ដូចខេត្រដែនដែលរដ្ឋបាលបានកំណត់ទុកជាការងាយសម្រាប់ធ្វើរាជការផ្សេង ៗ យ៉ាងនោះដែរ ខេត្រដែនដែលរដ្ឋបាលបានកំណត់ទុកក្តី ខេត្រដែនដែលសង្ឃបានសន្មតក្តី ហៅថាសីមាដូចគ្នា ចប់សេចក្តីប៉ុណ្ណោះហើយលោកកាពីតេនក៏លាត្រឡប់ចូលទៅបន្ទាយវិញ តពីនោះពួកអ្នករាជការក្នុងទីនោះ បានរៀបចង្ហាន់វេរប្រគេនឆាន់ដោយបរិ-

បុណ្យដល់ពេលរសៀលបានរៀបចំទីកន្លែង ១ ខាងក្នុងបន្ទាយប្រជុំស្ដាប់ធម៌ទេសនាបុច្ឆាវិសជ្ជនាពីរអង្គគឺលោកគ្រូព្រះបាឡាត់សិរីជ្ជានឹងអាត្មាភាពបំនួន ១ ម៉ោងកន្លះទើបបប់ធម៌ទេសនា ។

វត្តដែលបានបញ្ចុះសីមាពីថ្ងៃសុក្រ ៣ រោច ខែបឋមាសាឍឆ្នាំចធស័ក ព. ស. ២៤៧៧ ត្រូវនឹងថ្ងៃទី ២៩ ខែយូវាំងឆ្នាំ ១៩៣៤ នេះបានសន្មតឲ្យឈ្មោះថា វត្តបឋមវានិការាម ប្រែថា វត្តប្រតិស្ឋានក្នុងព្រៃជាដំបូង ឬថា វត្តរបស់មនុស្សនៅព្រៃជាដំបូង គឺថាវត្តតាំងឡើងជាដំបូងសម្រាប់ដល់ជាតិភ្នងនោះឯង ។ ក៏ក្នុងបន្ទាយរ៉ូឡង់នោះមានមេបារាំងត្រួតត្រា ៨ នាក់មានលោកកាពីតេន ឈ្មោះមោនសៀរម៉ារ្យង់ ជាប្រធាននឹងទាហានក្រុមពិជ័យសង្គ្រាមរួមទាំងនាយនឹងនាយជាលំដាប់ផងបំនួន ៨០ នាក់ មានវិទ្យុទោរលេខ (ខ្សែលួសខ្យល់) សម្រាប់បញ្ជូននឹងទទួលដំណឹងពីទីក្រៅ មានគោមអគ្គិសនីបំភ្លឺរាល់យប់ ជាទីទួលវាលរាបស្មើធំទូលាយ មានទីឱកាសឲ្យអាកាសយានចុះបាន មានខ្យល់បក់ល្ហើយជានិច្ច ហើយជាទីមិនខ្ពស់ជាងភ្នំក្រុងភ្នំពេញប៉ុន្មាន ជាទីគួរសប្បាយ ទីនេះ

ទំនងស្រួលជាងទីដទៃ តទៅប្រហែលជានឹងបានតាំងជាទី១ណ្ណាសម្រាប់រាជការរដ្ឋបាលមិនខាន ។

លុះព្រឹកឡើងថ្ងៃទី ១ ស្ទុយេតបានលាលោកកាពីតេនត្រឡប់មកវិញបានឈប់សឹងនៅបន្ទាយប៉ាល់កេ១យប់ ដល់ថ្ងៃទី២ ស្ទុយេតពេលព្រឹកម៉ោង៧ក៏ចេញពីបន្ទាយប៉ាល់កេដល់ក្រុងភ្នំពេញ ពេលម៉ោង ៧ យប់ ។ ដំណើរដែលទៅមកតាមផ្លូវក៏ឥតមានសេចក្ដីអន្តរាយអ្វីទេ បានសេចក្ដីសុខស្រួលគ្រប់គ្នាទាំងអស់ ។

## សេចក្ដីសន្និដ្ឋាន

ពីត្រឹមក្រុងភ្នំពេញទៅដល់បន្ទាយរ៉ូឡង់តោះ បម្ងាយ ៤២២ គីឡូម៉ែត្រ តាំងពីស្រុកទន្លេបិទរហូតទៅ ផែនដីខ្ពស់ជាងក្រុងភ្នំពេញយើងបន្តិចម្ដង ៗ ទៅដល់បន្ទាយរ៉ូឡង់តោះ ផែនដីខ្ពស់ជាងក្រុងភ្នំពេញយើងប្រមាណជាង ៨០០ម៉ែត្រ (ជិត១គីឡូម៉ែត្រ) ពីត្រឹមបន្ទាយប៉ាល់កេទៅដល់បន្ទាយរ៉ូឡង់ប្រើនផ្លូវព្រៃទះតែភ្នំ ផ្លូវថ្នល់ធ្វេងកាត់ជើងភ្នំខ្លះ បង្កេះភ្នំខ្លះ លើខ្នងភ្នំខ្លះ រាប់

ទីដែលរថយន្តត្រូវឡើងចុះបានជាង ១០០ កន្លែង ផុតពីទន្លេបិទ ទៅច្រើនផែនដីក្រហម ហើយតាំងពីខណ្ឌមេមត់ទៅមិនសូវមាន ភូមិស្រុកច្រើន ជាផែនដីទំនេ ព្រៃមានតែវាលនឹងព្រៃរហោ-ស្ថានមានចំការកៅស៊ូដោយអន្លើ ៗ តាមផ្លូវថ្នល់រៀងទៅ បើប្រ-សិនជាពួកមនុស្សនាំគ្នា ទៅតាំងភូមិលំនៅឃ្លាតពីគ្នា ៣-៤-គីឡូម៉ែត្រភូមិ ១ ៗ ទៅទល់នឹងស្រុកឡុកនិញ តដែនស្រុកកូសាំងស៊ីនោះ បានជាង ៣០ ភូមិ ហើយអ្នកដែលទៅនៅទីនោះ ៗ នឹងសម្បូរដីធ្វើស្រែចំការទាំងឈើព្រៃសម្រាប់សង់ផ្ទះ ឬធ្វើឧសក៏បរិបូណ៌ច្រើន ឃើញជាស្រួលជាជាងការនៅចម្រុះគ្នាតែមួយកន្លែង ៗ ដែលមានស្រែចំការសម្រាប់ធ្វើចិញ្ចឹមជីវិតយ៉ាងច្រើនត្រឹម ២-៣ ម្នាក់ ហើយក្រដោយឧសភ្លើង ដុតតែចម្បើងនឹងគាវត្នោតជាដើម តែជាធម្មតារបស់មនុស្សតែងតុសគំនិតគិតមិនលេច ចង់បានចង់មាននឹងគេដែរ តែមិនដឹងនឹងបែររេទៅផ្លូវណា ព្រោះគ្មានគេដឹកនាំឬមកពីមិនស្រុះគ្នា ជួបគ្នានឹងសត្វស្លាបខ្លះ យ៉ាងកុកដែលអាស្រ័យនៅក្នុងទីឆ្ងាយពីបឹងទន្លេ ជាទីខ្សត់ទឹកខ្សត់ត្រីលំបាកដោយចំណី មានស្លាបល្មមហើរ

រកចំណីបានឆ្ងាយ ៗដែរ តែមិនស៊ូទៅ នៅរីលរវល់តែក្បែរឈើដែលធ្លាប់នៅនោះ បួនក៏បានចំណី បួនក៏ទេ ស្កាំងស្គមកំព្រឹងនៅនោះឯង ហេតុលកន្លែងធ្លាប់នៅមិនរួចនឹងហាមកពីប្រាជ្ញាតិចក៏មិនមែន ទំនងជាជាប់អាល័យកន្លែងឬមកពីគិតមិនធ្លុះក៏មិនដឹង ។ សង្ខារគ្រប់យ៉ាងក្នុងលោកដែលផុលផុសកើតមានឡើងហើយក្នុងលោក មានតែរិបរិលសាបសូន្យទៅជាធម្មតាដូចគ្រឿងលោហភាជនមានផ្តិលតុះ ហាសជាដើម ដែលបុគ្គលជាប់ពាល់ប្រើសព្វថ្ងៃ មានតែរិបរិលឬស្រអាប់ពណ៌រស្មីជាធម្មតា លុះតែឧស្សាហ៍ដុសខាត់ថែរក្សាជានិច្ចទើបគង់ទ្រង់បាន យូរបន្តិច ត្រកូលដែលធ្លាប់មានទ្រព្យសម្បត្តិ ឬយសយក្តិអំណាចមកហើយ មិនយូរប៉ុន្មានវង្សត្រកូលនោះ ៗ មកគង់បានសេចក្តីវិបត្តិឃ្លាតឋយពីរបស់ដើមគឺធ្លាក់ខ្សត់ក្រឬឋយយសសក្តិបន្តិចម្តង ៗ ទាល់តែមានអ្នកណាមួយក្នុងត្រកូលនោះមានតេជានុភាពបារមីខ្លាំងជួយយឹតយោង ទើបអាចចម្រើនឡើងវិញមនុស្សដែលនៅក្នុងទីណាមួយយូរ ៗ ទៅតកូនចៅជាលំដាប់មក រមែងមានគំនិតខ្សោយខ្ញាំទាល់នឿយណាយគិតមិនជ្រៅ

ទៅមិនឆ្ងាយ បានជាធ្លាក់ក្រហើយក៏នៅតាំងគំនិតមិនដឹងជានឹងបែរទៅប្រកណា ដីទូលាយដូចនិយាយមកហើយនេះ បើប្រសិនជាពួកអ្នកស្លូមខាន ពួកអ្នកអនាថារកស្រែបំការគ្មាន នឹងពួកមនុស្សដែលនៅច្រៀតគ្នាច្រើន នាំគ្នាទៅតាំងទីលំនៅជាលំដាប់តាមផ្លូវនោះ រៀងគ្នាទៅនឹងបានមានដីទូលាយរកស៊ីមិនខាន តែតាមកំឡាំងរបស់មនុស្សពួកនេះប្រហែលជាមិនស្រេះគ្នាទេ ដរាបតែកំឡាំងអំណាចរាជការជួយចាត់ការឲ្យទើបសម្រេចបាន គឺចាត់ឲ្យនៅជារបៀប ចាត់មេការពន្យល់ពីរបៀបជាំជុំះ នឹងតាំងក្រុមទាហាន ៤-៥ នាក់ជួយការពារសត្រូវក្នុងបន្លោះ ៤-៥ ភូមិតាំង ១ កន្លែងរៀង ៗ ទៅ ។ បើប្រសិនជាការនោះប្រព្រឹត្តទៅបានយ៉ាងនេះស្រុកខ្មែរនឹងមានមនុស្សនៅរាយគ្នាពេញផែនដី មានរបររកស៊ីគ្រប់គ្នា ទាំងបម្រើនខាងក្សេត្រកិច្ចនឹងពាណិជការបរិបូណ៌មិនខាន តែការដែលមិនប្រព្រឹត្តទៅបានយ៉ាងនេះ ប្រហែលជាផែនដីទីនោះមិនសូវមានផលដូចម្ដេចក៏មិនដឹង ។

ជាតិភ្នង

ទីដីដែលបាននិយាយមកហើយ បើទោះជាមានព្រៃរហោស្ថានយ៉ាងណា ក៏គង់មានស្រុកភូមិខ្លះដោយអន្លើ ៗ ពីត្រឹមផុតស្រុកសិរហូតហួសបន្ទាយរ៉ូឡង់ទៅឃើញ មានសុទ្ធតែព្រៃភ្នំនឹងវាលធំ ៗ ដែលជាទីលំនៅរបស់ភ្នង តែភ្នងនោះក៏មិនមែននៅកុះករពេញពាសទាំងព្រៃនោះទេ នៅឆ្ងាយ ៗ ពីគ្នា ដើរបម្ងាយ ១ ព្រឹកទើបប្រទះភូមិ ១ ក៏មាន ភូមិប្រទេសទីនោះវឹងរិតតែទំនេរច្រើនជាងដីខាងអាយមកខាងយើងទៀត ។

ហេតុអ្វីក៏យើងហៅពួកមនុស្សដែលនៅព្រៃនោះថាជាតិភ្នង? ពួកនោះហេតុអ្វីក៏មិនប្ញលចិត្តស្លៀកពាក់ ជាតិប្រុសសុទ្ធតែប៉ុង ? ។

តាមសេចក្ដីសន្និដ្ឋានថា ពាក្យថាភ្នងនេះជាពាក្យបុរាណជាឈ្មោះមហាអាណាចក្រខ្មែរពីដើម ព្រោះប្រាកដក្នុងពង្សាវតារថា ក្នុងរវាងមុនគ្រិស្តសករាជ ១៤០០ ឆ្នាំ មានអ្នកដំណើរចិនម្នាក់មកដល់ស្រុកខ្មែរ បានកត់សំគាល់ហេតុផ្សេង ៗ ហើយហៅឈ្មោះស្រុកខ្មែរនេះថានគរហ្វូណាង ពាក្យ

ថាហ្វូណាងនេះទំនងជាចិនគ្មានអក្សរជ្រើជើង និងសរសេរថា ភ្នងដូច្នេះមិនកើត បានជាសរសេរឃ្លាតទៅជាហ្វូណាង ដល់បម្លងច្រើនតៈច្រើនភាសាមកទៀតក៏ជាធម្មតា ត្រូវតែអៀងបានជាក្លាយមកជាហ្វូណានទៀត ។ ស្រុកដែលជាទីនៅរបស់ស្តេចមន្ត្រីអ្នករាជការសេវកាមាត្យ រមែងមានសេចក្តីចម្រើនជាងមនុស្សដែលនៅចុងដែន មានការផ្លាស់ផ្តូរទំនៀមទម្លាប់ភាសានឹងឈ្មោះជានិច្ច អ្នកនៅស្រុកចុងដែនផ្លាស់ផ្តូរតាមផងមិនទាន់ ថែមទាំងស្រុកជាន់ដើមមិនសូវមានផ្លូវគមនាគមន៍លំបាកដោយការទៅមករកគ្នាទៀត អាការកិរិយានេះទៀងតែប្លែកគ្នាជាធម្មតា បំណែកភាសាក្នុងនោះសោត ពាក្យខ្លះក៏ត្រូវនឹងពាក្យខ្មែរ ដូចរាប់ថាប្រាំ ខ្លះក៏ស្រដៀងគ្នាដូចរាប់ ១-២-៣-៤ ថា ម៉យ-បារ-ប៉ៃ-ប៉ួន តែសំនៀងភាសាច្រើនសំដីមាំ ៗ បំពង់កធំ ស្រដៀងភាសាចាម ហេតុនោះភាសាក្នុងគង់មានត្រូវនឹងភាសាចាមខ្លះមិនខាន ព្រោះជាតិចាមក៏ជាជាតិគូគ្នានឹងខ្មែរ មកពីបុរាណយូរណាស់ដែរហើយ តាមពង្សាវតារក៏ប្រាកដថា កាលពីដើមមានពួកផ្សាចាមចូលមកលុកលុយ

ខ្លះដែរ ពាក្យថាភ្នងសមគួរជាឈ្មោះជាតិអ្នកស្រុកនេះពីដើម មិនមែនជាពាក្យអ្នកសិរាប់ហៅមនុស្សព្រៃល្ងង់ប៉ុណ្ណោះ ដូច យ៉ាងយើងហៅសព្វថ្ងៃនេះឡើយ ព្រោះអ្នកដំណើរមិនដែល បានកត់យកឈ្មោះនេះទៅ ក៏កត់ក្នុងរាជស្តេច មានសេចក្តី បំរើនបេះកសាងប្រាសាទផ្សេង ៗ ដែលនៅសម្បើមអស្ចារ្យដល់ មកសព្វថ្ងៃនេះដែរ ។ ឯសំលៀកបំពាក់របស់ភ្នងនោះមានផ្លូវ សន្និដ្ឋានច្រើនយ៉ាង គឺការដែលមនុស្សយើងមានកាយអាក្រាត នេះ ជាធម្មជាតិដែលមនុស្សគ្រប់ជាតិត្រូវប្រកបប្រទះជាដំបូង មុនដែលនឹងបេះធ្វើសំពត់ស្លៀកនោះ ក្នុងស្រុកយើងនេះប្រាកដ ក្នុងពង្សាវតារថា ក្នុងពេលដែលហ៊ុនទៀន (កោណ្ឌញ្ញ) ជាក្លិង្គ-ព្រាហ្មណ៍ចូលមកលុកលុយនោះ អ្នកស្រុកនេះនៅមិនទាន់ មានសំពត់ស្លៀកពាក់ទេ ទើបតែបេះស្លៀកពាក់ដោយសារពួក ក្លិង្គព្រាហ្មណ៍បង្ហាត់បង្ហាញជាខាងក្រោយមកដល់ជាន់មនុស្ស បេះធ្វើប្រាសាទវិចិត្រយ៉ាងវិសេសហើយនោះ ត្រង់គ្រឿងស្លៀក ពាក់ក៏ឃើញថាស្មើរ ១ តែប៉ុងដែរ ហើយលែងខ្លួនទទេគ្មាន អាវពាក់ រហូតដល់សេនាទាហានដែលចេញទៅច្បាំងតាម

រូបបំឡាក់ក្នុងរបៀងផញ្ចាំងជុំវិញនគរវត្តនោះ ក៏ឃើញថាមិនទាន់បម្រើនខាងគ្រឿងស្លៀកពាក់ប៉ុន្មានដែរ ប្រដាប់តែងខ្លួនក៏មិនលើសក្នុងសព្វថ្ងៃនេះប៉ុន្មាន ហេតុនោះបែបស្លៀកពាក់របស់ក្នុងនោះក៏យល់ឃើញថា ជាប់ទម្លាប់បូរាណមកដែរ តែមកដល់សម័យសព្វថ្ងៃនេះ ក្នុងនៅតែប្រកាន់បែបប៉ុណ្ណោះ យល់ឃើញថា ដោយសារធ្លាប់មកម្យ៉ាង ដូចគ្នានឹងពួកកួ្លគ ទំនៀមងាប់ ១ ពួក ទុកជារកស៊ីមានមាសពេជ្រច្រើនយ៉ាងណា តែត្រង់សំពត់ស្លៀកនៅតែមានជាយមិនស្មើ ស្លុយម្ខាងខ្លីម្ខាងស្លាប់ក្រឡាលែងរើរូបនៅនោះឯង ម្យ៉ាងទៀតយល់ឃើញថាពួកក្នុងដែលធ្លាប់បុំងមកយ៉ាងនេះ ហើយថែមទាំងនៅព្រៃទៀតកិច្ចដែលស្អិតស្អាងរាងកាយក៏គង់ថយឯង ព្រោះមិនដឹងជាតែងទៅអួតប្រាប់អ្នកណា បើមានតែផ្ទឹកសុក្រិស្រែឡៅទទេ ទុកជា-លាបម្សៅប្រស់ទឹកអប់ទាល់ល្ហាប ក៏មិនបានជួបមនុស្សម្នាក់គ្រាន់នឹងអួត ម្យ៉ាងទៀតប្រទេសទីនោះឯងធម្មជាតិបង្គាប់ឲ្យក្នុងស្លៀកពាក់ល្អមិនកើត ព្រោះត្រូវតែរុករើកញែកព្រៃជានិច្ច ដែលជាការងាយស្រួលដល់អ្នកលាត់សើយ គួរឃើញដូចជាពួកអ្នក

ស្លៀកពាក់ត្រឹមត្រូវហើយ វេលាត្រូវភ្លៀងរាស់ឬចូលព្រៃជាដើមក៏គង់សើយលាត់ដែរ ឬវេលាដែលនៅក្នុងទីបិទបាំង ដូចក្នុងផ្ទះបើគ្មានភ្ញៀវមករកទេ ក៏គង់លែងខ្លះខ្លះ ៗ សម្រាប់ស្រុកក្ដៅបើមិនសូវមានខ្មាសទេ ក៏មិនសូវត្រូវការដោយគ្រឿងស្លៀកពាក់ប៉ុន្មាន រហូតដល់សត្វដែលកើតក្នុងស្រុកក្ដៅក៏មិនសូវត្រូវការដោយរោមប៉ុន្មាន មិនដូចពួកសត្វដែលនៅក្នុងស្រុកត្រជាក់ត្រូវការរោមវែងស្កុកស្កុល ឬមនុស្សក្នុងស្រុកត្រជាក់នោះត្រូវការដោយគ្រឿងស្លៀកពាក់ច្រើនទាំងឡក្រាស់នោះទេ ជាតិភ្នងនៅក្នុងស្រុកក្ដៅមានព្រៃជាជញ្ជាំងបិទបាំង មានទម្លាប់ដើមជាប់ដោយមក ថែមទាំងខ្វះការសិក្សាទៀត ក៏ជាធម្មតាត្រូវតែនៅប៉ុងយ៉ាងនោះឯង ៗ ក្នុងវេលាដើរដំណើរទៅស្រុកនោះ បានជួបប្រទះភ្នងប្រុសម្នាក់ ដាក់កូនតូចក្នុងស្ពាយពត់ហើយបងព្យួរនឹងកទំនងដូចគ្នា នឹងស្រីកន្ដាំងពរកូន តែភ្នងដាក់កូនមកខាងមុខវិញ មានភ្នងម្នាក់ទៀតពាក់កងស្ពាន់ ធ្វើជាវង់ព័ទ្ធតាំងពីជិតក្លៀកដែមកដល់កដៃ ត្រង់កយើញមានអង្កាំ១ខ្សែនឹងកងកស្ពាន់ដំដាសណ្ឋាន ៣ ជ្រុង ១ វង់ ត្រចៀកសងខាង

ពាក់ក្រសាល់ភ្លុក ប្រមាណប៉ុនត្រសាល់អំបោះហុងធុនតូច ធ្មេញខាងលើមានស្នាមអារកាត់ពាក់កណ្ដាល ទុកសក់ប្លង គ្រឿងតែងតួប៉ុណ្ណេះ ប្រហែលជាអស់ហ្នាក់របស់គេហើយ ។ ការកាត់ធ្មេញ ១ ពោះត្របៀក ១ ទុកសក់ ១ នឹងប៉ុង ១ ដូចគ្នាទាំងអស់ តែត្រង់ត្របៀកនោះ បើគ្មានត្រសាល់ភ្លុកនឹងគេក៏ស៊កាត់ដើមព្រៃតូច ៗ យកមកពាក់ជំនួសដែរ ការពាក់ត្រសាល់នេះពួកស្រី ៗ ក្នុងស្រុកយើងក៏ទើបតែលែងពាក់មកមិនយូរប៉ុន្មានដែរ ។ ជាតិភ្នងមានទំនៀម ១ ដូចដីរគឺភ្នងណាសុខចិត្តចូលមកធ្វើការរកស៊ី ក្នុងទីដែលរាជការបានតាំងហើយវេលាត្រឡប់ទៅវិញ ប្រើវតែភ្នងព្រៃសម្លាប់ចោលដូចគ្នានឹងដីរស្រុកចូលហ្លួងដីរព្រៃមិនបានដូច្នោះ ចិត្តសោតក៏មិនទាន់ខុសគ្នាពីសត្វប៉ុន្មាននៅមិនទាន់ស្គាល់កន្លែងគួរហ៊ានគួរខ្លាចទេ ត្រូវពេលក្រោធខឹងឡើងហ៊ានមិនស្គាល់ងាប់ ហេតុនោះការរក្សាភ្នងប្រយ័ត្នឲ្យប្រហែលការរក្សាក្របីកាច ហើយត្រូវប្រយ័ត្នគំនុំរបស់វា ប្រហែលគំនុំរបស់ពូជគោខ្មែរ ។ ភ្នងដែលឈ្មោះថាបុះបួលខ្លបខ្លាចមែន ប្រហែលដល់ពេលដែលវាសុខចិត្តស្លៀក

ពាក់គ្រប់គ្នាបើនៅតែប៉ុងទេ គួរកុំអាលទុកបិត្តឲ្យសោះឡើយ ។

អធិប្បាយមកនេះ ជាសេចក្ដីសន្និដ្ឋាន តាមសេចក្ដីយល់ក្រែងមានទាស់ខុសមិនសមត្រង់ណា ក៏សូមមេត្តាអភ័យអំពីលោកអ្នកដឹងរឿងនេះដោយជ្រៅជ្រះផង ។

ភ្នំពេញនៅថ្ងៃ ១៩ សួយេត ឆ្នាំ ១៩៣៤ ។

ព្រះមហា ហួត

### រឿងព្រះបាទឧទេន (ត)

មាន ១ ថ្ងៃតពីវេលានោះមក ព្រះបាទឧទេន នាងសាមាវតី នឹងនាងអនុបមា នៅជាមួយគ្នា ក្នុងទី ១ ។ ក្នុងវេលានោះស្ដេចទ្រង់កណ្ដាស់ នាងសាមាវតីភ្លាត់មាត់ថា៖ សូមបង្គំព្រះពុទ្ធជាម្ចាស់ នាងអនុបមាភ្លាត់មាត់ថា៖ សូមបង្គំព្រះរាជាជាម្ចាស់ ។ វេលានោះនាងអនុបមាទូលថា៖ នាងសាមាវតីបរិភោគអាហារព្រះករុណាវិសេស ហើយទៅគោរពឯសមណគោតមវិញ ស្ដេចមានព្រះបន្ទូលតបវិញថា ម្នាលនាងអនុបមា ដែលតាមហេតុភេទពិតត្រង់នោះមិនមែនដូច្នេះទេ នាងសាមាវតីជាអ្នកជឿប្បាស់ក្នុងគុណព្រះពុទ្ធ ហើយនាងភ្លាត់មាត់រកព្រះពុទ្ធដោយឥតមានបំណង នាងអនុបមាក៏ស្ងៀមមិនស្ដី ទើបនាងខ្សឹបនឹងស្រីបំរើម្នាក់ថា កាលណាព្រះរាជានាងសាមាវតីនឹងអញនៅជាមួយគ្នា ឲ្យឯងធ្វើជាឲ្យធ្លាក់ភាជន៍ស្ពាន់អ្វី ១ ទៅលើជណ្ដើរ ស្រីបំរើក៏ទទួលពាក្យ លុះដល់ជួបជុំទាំង ៣ អង្គដូចសន្យាហើយ ស្រីបំរើក៏ធ្វើឲ្យធ្លាក់ភាជន៍ស្ពាន់ ១ ទៅលើជណ្ដើរ ។ នាងសាមាវតីក៏ភ្លាត់មាត់ទៀតថា

សូមបង្គំព្រះពុទ្ធជាម្ចាស់ នាងអនុបមាក៏ក្រាបទូលដូចកាលពីមុននោះទៀត ។

ព្រះបាទឧទេនទ្រង់ដាក់វេន ដើម្បីស្ដេចទៅក្រសាលនឹងនាងទាំងពីរ ១ ថ្ងៃម្នាក់ ។ ក្នុងថ្ងៃដែលជាវេន នាងសាមាវតី ព្រះមហាក្សត្រទ្រង់បង្គាប់ព្រានឆ្នាក់ឲ្យយកសត្វមាន់រស់មកថ្វាយ លុះព្រានយកមកថ្វាយស្ដេចត្រាស់ប្រើឲ្យយកទៅប្រគល់ឲ្យនាងអនុបមា នាងអនុបមាបានឮក៏ទូលទៅស្ដេចថា ក្រាបទូលថ្ងៃនេះមិនមែនវេនខ្ញុំម្ចាស់ទេ គឺជាវេនរបស់នាងសាមាវតី ស្ដេចក៏ត្រាស់ប្រើព្រានឲ្យយកទៅប្រគល់ឲ្យនាងសាមាវតីវិញ ព្រានយកទៅប្រគល់ឲ្យនាងសាមាវតី ហើយទូលថា ព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យធ្វើព្រះក្រយាស្ងោយ ។ វេលានោះនាងប្រាប់ទៅព្រានវិញថា ខ្ញុំមិនមែនជាអ្នកធ្វើមាន់ទេ? ការសម្លាប់សត្វរស់មិនមែនជាការរបស់ខ្ញុំទេ! ព្រានក៏យកសេចក្ដីនេះទៅក្រាបទូលស្ដេចថា នាងសាមាវតីពោលថា នាងមិនមែនអ្នកធ្វើមាន់ទេ? ការសម្លាប់សត្វរស់មិនមែនជាការរបស់ខ្ញុំទេ! វេលានោះនាងអនុមាបបានឮ ហើយទូលទៅស្ដេចថា

សូមទ្រង់ព្រះមេត្តាប្រោស ប្រសិនបើជាប្រាប់ថា ឲ្យយកទៅធ្វើបង្អាន់សមណគោតមវិញ ប្បាស់ជាបប្ចលបារិព្រារធ្វើស្រេប ១ រំពេច ព្រះមហាក្សត្រក៏ទ្រង់យល់ថា អាចនឹងមានទំនងដូច្នេះទៅបាន ទើបទ្រង់បង្គាប់ដល់ព្រានថា ប្អូនឯងទៅប្រាប់នាងឲ្យយកមាន់នេះទៅធ្វើបង្អាន់ថ្វាយព្រះទៅ ព្រានក៏យកមាន់នោះចេញទៅ តែនាងអនូបមាខ្សឹបប្រាប់ថា "ត្រូវឯងសម្លាប់មាន់នេះសិនសឹមយកទៅឲ្យ" ព្រានក៏សម្លាប់មាន់នោះទៅហើយក៏យកទៅប្រគល់ឲ្យនាងស្យាមាវតីប្រាប់ថា "មានព្រះបន្ទូលឲ្យនាងធ្វើបង្អាន់ថ្វាយព្រះ" នាងស្យាមាវតីឃើញមាន់ស្លាប់ស្រាប់ដូច្នេះក៏បប្ចលបារិព្រារចាត់ចែងធ្វើដោយរួសរាន់ ៗ ក្នុងវេលានោះព្រានត្រឡប់មកទូលព្រះរាជាវិញថា សូមទ្រង់ព្រះមេត្តាប្រោសតទ្បូវនាងកំពុងតែខ្វល់ខ្វាយធ្វើជាមួយនឹងបារិព្រារ" នាងអនូបមាបានឮដូច្នោះក៏ទូលថា "សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាបានទ្រង់ព្រះសណ្តាប់ឬទេ បើថាមិនត្រូវសម្លាប់សត្វមានជីវិតក៏ត្រូវតែកុំសម្លាប់ដើម្បីធ្វើបង្អាន់សមណគោតមដែរ តែបើត្រូវសម្លាប់ដើម្បីធ្វើបង្អាន់ឲ្យសមណ ក៏ត្រូវសម្លាប់ដើម្បីធ្វើព្រះក្រ-

យាស្មោយដែរ នាងស្យាមាវតីបានពោលប្រកែកថា មិនព្រម
សម្លាប់ធ្វើព្រះក្រយាស្ងោយទេ ហេតុអ្វីក៏ព្រមសម្លាប់ធ្វើបង្អាក់ស-
មណគោតម ក្នុងវេលានោះព្រះបាទឧទេនទ្រង់ព្រះពិរោធ គិត
នឹងប្រហារនាងស្យាមាវតី ត្រង់នេះមកដល់ត្រង់ដែលស្ដេចបាញ់
នាងស្យាមាវតីហើយព្រួញវិលត្រឡប់មកវិញ ព្រះរាជាក៏លុះក្នុង
គុណព្រះរតនត្រ័យ ហើយទ្រង់ក៏អនុញ្ញាតឲ្យនិមន្តពុទ្ធបរិសឲ្យ
មកសម្ដែងធម្មទេសនា ក្នុងទីដំណាក់នាងស្យាមាវតី ។

ឯនាងអនុបមា បេះតែមានសេចក្ដីគុំគួននឹងព្យាបាទ
សងសឹកជានិច្ច ។ មានកាលថ្ងៃ ១ ព្រះបាទឧទេន ស្ដេចយាង
ទៅបង្ក្រាបប្រទេសរាជដែលបាស់បោរ ។ ក្នុងវេលានោះទ្រង់បាន
ផ្ដាំផ្ញើនាងស្យាមាវតីនឹងមាគន្ទិក ព្រមទាំងត្រាស់ប្រាប់ឲ្យដឹង
ថា ទ្រង់បើកអំណាចឲ្យនាងស្យាមាវតីធ្វើអ្វី ៗ បានតាមចិត្ត ។
នាងអនុបមាដំរូវឲ្យអាពុកធ្វើការសងសឹកជួស ដោយអង្វរផង
ដោយកំហែងបង្ខំផង លុះដល់អាពុកចូលគំនិតជាមួយផង គិត
រកឧបាយជាមួយគ្នា ។ វេលាដែលមាគន្ទិកទៅដណ្ដឹងសួរនាង
ស្យាមាវតី ថានាងត្រូវការអ្វី នោះនាងថា មិនមានត្រូវការអ្វី

ឡើយ ប៉ុន្តែនាងប្រាប់ទៅវិញថា ពួកស្រីៗទាំងនេះក្នុងវេលាយប់ត្រូវការរៀនធម៌ព្រះសម្មាសម្ពុទ្ធនឹងពន្លឺបង្កៀង ដូច្នេះត្រូវឲ្យរកសំបកឈើ...,ប្រេងល្ហុង...នឹងដីខ្មៅ" មាគន្ទិកក៏យកវត្ថុទាំងនេះមកគរយ៉ាងច្រើនក្នុងបន្ទប់ខាងក្រៅហើយ យកភ្លើងដុត ។ ក្នុងវេលានោះពួកអាពុកម្ដាយនូវបងប្អូនស្រីៗ ទាំងនោះរត់មកជួយលត់ភ្លើងនោះ; ប៉ុន្តែមាគន្ទិកកាន់ដាវដាប់នៅដៃទាំងផ្លូវមិនឲ្យចូល រករឿងថា ពួកទាំងនេះបួលបំពាបំពានជំ-ណាក់ស្ដេច; នាងសាមាវតី ដោយបុញ្ញឫទ្ធិកុសលសីលទាន របស់នាង ក៏អណ្ដែតខ្លួនឡើងទៅលើអាកាស ហើយសម្ដែងធម៌ទេសនាបន្តិចក៏ធ្លាក់ចុះមកក្នុងគំនរភ្លើងធំ ជាមួយនឹងពួកស្រីបំ-រើទាំងប៉ុន្មានទៅ មានតែនាងខុជ្ជុត្តរា ១ដែលរួចពីសេចក្ដីមរណនោះ ។ មាគន្ទិក ដកខ្លួនគេចស្រឡះចេញពីពួកខ្មោចដែលស្លាប់ក្នុងភ្លើងទាំងនោះ ហើយពួកអាពុកម្ដាយទាំងអស់ក៏រត់ទៅយំសោកទីទៃៗ ។

រឿងរ៉ាវនេះ ក៏បានជ្រាបដល់ព្រះទិព្វសោតថ្លៃនៃព្រះបរម-សម្មាសម្ពុទ្ធ គឺជាឱកាស១ដែលព្រះអង្គត្រូវសម្ដែងធម៌ទេសនាអំពីហេតុផលនេះ ។

ក្នុងស្ថាននេះ តើអ្នកណាដែលត្រូវនាំដំណឹងទៅក្រាបទូលព្រះបាទឧទយន? «គឺជាភារៈរបស់អ្នកដែលត្រូវពិតទូលដំណឹងអាក្រក់» អ្នកដែលត្រូវនាំដំណឹងអាក្រក់នេះព្រមសុខចិត្តទៅប៉ុន្តែសុំឲ្យបានកងទាហាន១កងជូនទៅព្រមទាំងសំពត់ ១ ផ្ទាំងគូររឿងរ៉ាវទាំងប៉ុន្មានដែលនាំឲ្យនាងស្យាមាវតីស្លាប់នោះ ។ លុះបានដូចចិត្តហើយក៏បេញទៅពីក្នុងនគរចូលទៅក្នុងប្រទេសដទៃតាំងខ្លួនធ្វើជាស្ដេច ហើយសរសេរជាសេចក្ដីទៅទូលព្រះបាទឧទយន សុំឲ្យជួយតយុទ្ធនឹងមច្ចុ (សេចក្ដីស្លាប់) ដែលកាប់យកកូនខ្លួនទៅ លុះបានទទួលសេចក្ដីនេះហើយ ព្រះបាទឧទ-យនទ្រង់ព្រះពិចារណាថា ស្ដេចនេះឆ្កួតទេឬអ្វី? ប៉ុន្តែទ្រង់ឆ្លើយតបវិញយ៉ាងស្រួលថា ទ្រង់ព្រមជួយ តែសូមឲ្យស្ដេចជួយបង្ក្រាបបច្ចាប្រទេសរាជដែលបាស់ពោរជាមុនសិន កងទ័ពស្ដេចក្លែងនេះក៏បង្ក្រាបខ្មាំងនោះរាបទាបទៅ ហើយក៏ចូលរំឭកដល់

ព្រះបាទឧទយនអំពីដែលទ្រង់បានសន្យានោះ វេលានោះព្រះបាទឧទយនមានព្រះបន្ទូលថា «អ្នកឯងឆ្កួតទេឬ អ្នកណាគេដែលស្លាប់ហើយរស់ឡើងវិញបាន?» បើដូច្នោះសូមឲ្យព្រះអង្គផ្ទៀងទតសំពត់គំនូរនេះ លុះទតហើយក៏បន្លឺព្រះសូរសៀងឡើងថា «នាងសាមាវតីស្លាប់ក្នុងភ្លើង មែនឬ? ស្ដេចក្លែងឆ្លើយថា «សមដូចព្រះបន្ទូលព្រះអង្គនោះហើយ ក្នុងវេលានោះព្រះបាទឧទយន មានព្រះបន្ទូលថា «បើកុំតែឯងមានឧបាយកលដូច្នេះ ប្រហែលជាអញកាត់ក្បាលឯងចោលបង់ទៅហើយ ។

វេលាដែលស្ដេចយាងត្រឡប់មកក្រុងកោសម្ពីវិញ ព្រះបាទឧទយនទ្រង់បង្គាប់ឲ្យយោគន្ធរាយណជាសេនាបតី ចាប់យកខ្លួនមាគន្ទិកនឹងនាង អនុបមា យកទៅដុតក្នុងទីសម្រាប់បូជា ។ ប៉ុន្តែសេនាបតីនោះយកអនុបមាទៅបំពួនក្នុងបន្ទប់ក្នុងដីវិញ ។ ព្រះមហាក្សត្រទ្រង់បួលកាន់ទុក្ខ ៧ ថ្ងៃ លុះផុត ៧ ថ្ងៃហើយទ្រង់ក៏ស្បើយទុក្ខស្បើយក្រោធ ហើយទ្រង់សួររកនាងអនុបមា ក្នុងវេលានោះយោគន្ធរាយណសេនាបតីទូលសុំទោស អំពីដែលខ្លួនមិនបានធ្វើតាមព្រះរាជបញ្ជា ព្រះមហា-

ក្សត្រក៏ទ្រង់ព្រះរាជានុញ្ញាតឲ្យ ។ វេលានោះគេនាំយកនាងអនុបមាពីក្នុងបន្ទប់រូងដីមក នាងក៏ឥតមានឈឺថ្កាត់អ្វីព្រោះអត់អាហារ ៧ ថ្ងៃនោះឡើយ ។ ព្រះបាទឧទេនទ្រង់យាងទៅរកព្រះសម្មាសម្ពុទ្ធហើយក្រាបទូលសួរថា ហេតុអ្វីបានជានាងសាមាវតីស្លាប់ក្នុងភ្លើង ហើយហេតុអ្វីបានជានាងខុជ្ជុត្តរារស់រួចពីអណ្ដាតភ្លើងតែម្នាក់ឯង ព្រះបរមសម្មាសម្ពុទ្ធទ្រង់សម្ដែងប្រាប់ព្រះបាទឧទេន «រឿងជាអតីតកាលរបស់នាងសាមាវតី» ហើយលុះស្ដេចយាងត្រឡប់ទៅវិញផុតទៅ ព្រះបរមគ្រូទ្រង់សម្ដែងរឿងទី ២ និងទី ៣ ទៀត អំពីនាងខុជ្ជុត្តរា និងនាងអនុបមា ក្នុងកាលជាតិដែលកន្លងមកហើយ ។ រឿងនេះមិនជាប្រយោជន៍ដល់យើងក្នុងទីនេះទេ ។

កាលក្នុងជាតិដែលកន្លងមកហើយ នាងអនុបមាមានសំឡាញ់ម្នាក់ជាកូនព្រាហ្មណ៍ ១ នាងកូនព្រាហ្មណ៍នោះបានថ្វាយទានដល់ព្រះសង្ឃ ១ អង្គ ហើយក្នុងជាតិនេះបានមកកើតជាកូន

សេដ្ឋី ១ ឈ្មោះឃោសិល(១) នាងនេះមានរូបឆោមល្អប្រិមប្រិយ៍ ឈ្មោះនាងស្រីមតី ។ ព្រះបាទឧទយនទ្រង់ពេញព្រះរាជហឫទ័យ ហើយទ្រង់យកជាអគ្គទេពី ។ មាន ១ ថ្ងៃនាងសុំឲ្យបានឃើញព្រះសង្ឃទាំងឡាយ ហើយថាបើគេមិនព្រមឲ្យបានឃើញ នាងនឹងសូអត់អាហារឲ្យស្លាប់ ។ ឯផ្ទះឃោសិលសេដ្ឋីនោះនៅក្បែរប្រកិតគ្នានឹងព្រះរាជដំណាក់ព្រះបាទឧទយន ។ ព្រះបាទឧទ-យនទ្រង់បង្គាប់ ឲ្យសេដ្ឋីអាពុកនាងចាត់រៀបបង្អាន់ថ្វាយព្រះសង្ឃ ហើយទ្រង់ឲ្យបោះរន្ធកំផែងដែលខាងផ្ទះសេដ្ឋីនឹងព្រះដំ-ណាក់ ដើម្បីបំពេញបំណងនាងស្រីមតី ។ ព្រះសម្មាសម្ពុទ្ធទ្រង់ចាត់ព្រះសារីបុត្តឲ្យនិមន្តមក ព្រះសារីបុត្តក៏ទេសនាប្រោសនាងក្នុងដំណាក់ ហើយនៅសម្ដែងហួសពេលច្បាប់បញ្ញត្តិ លុះដល់ជិតថ្ងៃលិច ព្រោះក្នុងវេលានោះនាងស្រីមតី មិនទាន់បានដល់ សោតាបត្តិនៅឡើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតរឿងនេះ ។

(១) គម្ពីរទិវ្យាវទានយករឿងនាងស្រីមតីក្នុងជាតិនេះ នឹងរឿងនាងអនុបមាក្នុងជាតិមុនមកតផ្ជាប់គ្នា ឃើញថាជាការមិនប៉ុនប្រសប់ឡើយ តាមក្នុងគម្ពីរជាភាសាចិននោះរឿងនេះដាច់ពីគ្នាដោយឡែក ។ នាងស្រីមតីនេះកាលពីជាតិមុនមិនមែនជានាងព្រាហ្មណីដូចពោលខាងលើទេ គឺជាស្រីបំរើរបស់ឃោសិលវិញទេតើ ។

បទខាងក្រោយនេះគឺជាសេចក្ដីបន្ថែម ដើម្បីឲ្យឃើញនូវពុទ្ធានុញ្ញាត ១ កន្លែងក្នុងព្រះវិន័យ ។ តួបុគ្គលក្នុងនាងស្រីមតីក៏ជាតួបុគ្គលក្នុងនាងស្យាមាវតីដូចគ្នា: អាពុកដូចគ្នា, បំណាំងបង់ឃើញព្រះដូចគ្នា, បានធ្វើឧបាយដូចគ្នា ក្នុងអដ្ឋកថាបាឡី ត្រង់ពោះវន្ទដញ្ចាំង ប៉ុន្តែក្នុងទីនេះមានសេចក្ដីអនុញ្ញាតអំពីព្រះបាទឧទេនផង ។ យើងល្បងលុបបទត្រង់ចុងក្នុងរឿងនាងស្រីមតី ហើយលុបបទខាងដើមរបស់រឿង វុទ្រាយណ-អវិទានចេញ ហើយយកទៅដេរផ្ចាប់គ្នាយ៉ាងស្រួលតាមទំនងរឿងដែលត្រូវតទៅ នោះយើងនឹងបានរឿងនាងស្យាមាវតីនឹងនាងអនុបមា យ៉ាងច្បាស់លាស់ គឺថារឿងនេះដូចគ្នានឹងរឿង នាងសាមាវតី និងនាងមាគន្ទិយា ក្នុងអដ្ឋកថាបាឡីឯនោះ ។ ក្រៅអំពីផលបុណ្យនឹងផលបាបដែលត្រូវបានដល់នាងទាំងពីរ និងក្រៅអំពី «រឿងជាអតីត» ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងនោះ ខ្ញុំយល់ឃើញថា រឿងនេះជារឿងដែលកើតកាប់ចាក់គ្នាក្នុងបណ្ដាពួកស្ត្រីដែលជាព្រះស្នំរបស់ស្ដេច គឺថាស្ដេចទ្រង់ស្រៀកព្រះទ័យលើ១ៗ ហើយនាងមួយមានសេចក្ដី

ឈឺចិត្តរករឿងបំផ្លាញគូសត្រូវដោយដុតឲ្យស្លាប់ក្នុងភ្លើង ទើបស្ដេចជាស្វាមីបន្ទាទោសនាងដែលមានទោសនោះ ក្នុងសេចក្ដីបាឡី, រឿងនេះគេបញ្ជាប់ត្រង់បទដែលនាំឲ្យស្លុតចិត្ត, ឯបំណែកខាងសេចក្ដីសំស្ក្រឹតវិញគេបញ្ជាប់ត្រង់បទដែលជាការតក្កជាការមារយា ។ លោកអ្នកតែងរឿងជាភាសាបាឡី ត្រូវការដំរូវឲ្យនាងស្យាមាវតី ជាអ្នកជឿច្បាស់ក្នុងព្រះពុទ្ធសាសនាដំរូវឲ្យនាងអនូបមា ជាសត្រូវនឹងព្រះសម្មាសម្ពុទ្ធ សេចក្ដីនេះខ្ញុំក៏ព្រមតាមដូច្នេះដែរ ។ ប៉ុន្តែដែលគេយករឿងរ៉ាវនេះទៅរបនា ដើម្បីដំរូវលើគោលនៃព្រះវិន័យ ១ បទនោះខ្ញុំមិនទទួលជឿផងឡើយ ។ ដែលប្រទះឃើញបែបដូច្នេះជាច្រើនណាស់ក្នុងគម្ពីរផ្សេង ៗរបស់ព្រះពុទ្ធសាសនា ។ គឺអ្នកតែងគម្ពីរបានស្រង់យករឿងរ៉ាវល្បែងសំរាប់ស្រុកយកមកកែប្រែឡើងដោយសមខ្លះមិនសមខ្លះ ។ ក្នុងស្ថាននេះខ្ញុំយល់ថា អ្នកតែងគម្ពីរប្រណិបត្យតាមលំអាន ដែលយើងត្រូវស្មានក្នុងពួកអ្នកតែងគម្ពីរមហាភារតដូច្នោះដែរ គឺថាក្នុងប្រជុំគម្ពីរក្នុងសាសនានីមួយ ៗ ត្រូវតែឲ្យមានគ្រប់បែបទាំងអស់ មានធម៌ជាដើមហើយមានឃ្លាំងរឿងគ្រប់បែបយ៉ាង ។

ឯរឿងរ៉ាវទាំងនេះ សំរាប់ជាប្រយោជន៍ដល់អ្នកកាន់ព្រះពុទ្ធសា-សនា ដែលមានប្រាជ្ញាស្មារតីយ៉ាងធម្មតា ដូចយ៉ាងរឿងរ៉ាវរបស់ "បុរាណ" សំរាប់ជាប្រយោជន៍ដល់អ្នកកាន់សាសនាព្រាហ្មណយ៉ាងធម្មតាដូច្នោះដែរ ។

រួមសេចក្ដីទៅថា ក្នុងបរិត្តិហេតុការណ៍ផ្សេង ៗ នៃស្ដេចឧទយន នោះយើងមាន ២ កំណាត់ជាប់ពីគ្នាដែលព្រះពុទ្ធ-ឃោសាលោកយកមកត តែតឲ្យទៅជារឿងតែមួយមិនកើត គឺទី ១ កំណើតស្ដេចឧទយននឹងការនាំបំរត់នាងវាសវទត្តា ទី ២ រឿងនាងស្យាមាវតីនឹងអនុបមា (ដោយកាត់រឿងរុទ្រាយណនឹងស្រីមតីចេញ) ។ លើកតែរឿងកំណើតស្ដេចឧទយនចេញ ដែលមិនបានប្រទះឃើញក្នុងវិន័យ របស់ពួកមូលសវ៌ាស្តិវាទិន ឯបំណែកកំណាត់ឬភាគរឿងទាំងពីរនោះ បានប្រទះឃើញក្នុងគម្ពីរពួកនេះទាំងអស់ ប៉ុន្តែជាប់ពីគ្នា គឺកំណាត់ទី ១ ជាប់ទៅក្នុងរឿងរបស់ស្ដេចបជ្ជោត ។ ខ្ញុំគិតមានឆ្ងល់ឡើយអំពីដែលមិនបានប្រទះឃើញ បរិត្តិហេតុការទាំងមូលរបស់ស្ដេចឧទយនក្នុងរឿងស្ដេចបជ្ជោតនោះ គឺថាបើឲ្យមានបរិត្តិហេតុ

នេះទៅ នឹងនាំឲ្យទទើសទទែងដល់ប្រវត្តិហេតុការណ៍នៃស្ដេចបង្ហោត ។ ហេតុដូច្នេះទើបឃើញថា ក្នុងរឿងនេះស្ដេចឱទយនមានមុខក្រសួងមិនជាទីសរសើររាប់អានឡើយ ហើយបំណែកខាងក្នុងរឿងនាងស្យាមាវតីវិញនោះព្រះអង្គមានមុខក្រសួងជាទីសរសើរជាទីស្រឡាញ់ពេញចិត្តណាស់ គឺទ្រង់គោរពព្រះបរមសម្មាសម្ពុទ្ធ ទ្រង់សម្រួលការសម្ដែងផ្សាយធម៌ទេសនាព្រះបរមគ្រូ ហើយយាងទៅទូលសាកសួរសូមសេចក្ដីទូន្មានអំ-ពីព្រះសម្ពុទ្ធ ។ ជាត្រូវទំនងណាស់ ហើយដែលគេមិនបានពោលឲ្យហួសដល់ត្រង់ចូលកាន់សំណាក់ព្រះពុទ្ធសាសនា ។ ឯប្រវត្តិ-ការដែលរឿងនេះខ្ចីយកមកដាក់នោះ គឺត្រង់ជ័យជំនះរបស់ស្ដេចឱទេន ប្រវត្តិការណ៍នេះឃើញទាស់ផ្ទុយគ្នានឹងដែលមានសម្ដែងក្នុងរឿងស្ដេចបង្ហោត ក្នុងគម្ពីររបស់ពួកមូលសវាស្តិវាទិន ។ បើរឿងនេះមានចូលក្នុងរឿងស្ដេចបង្ហោតដោយការខ្ចីយក ១ បទទៅនោះជាការត្រូវដឹងថាមិនមែនជាមិនមានរឿងនេះក្នុងទីឯទៀតដោយបប់គ្រប់គ្រាន់ឡើយ ។ គេមានសង្ស័យនឹងព្រះពុទ្ធ-ឃោសាចារ្យជាយូរណាស់មកហើយថា លោកបានមើលសិក្សា

គម្ពីរពួកឧត្តរដិកាយ ។ តើលោកមិនបានដឹងរឿងព្រះបាទឧទយនខ្លះឬអ្វី ដែលជាទីនាំឲ្យលោកយកមករៀបចំរឿងរ៉ាវដូចដែលយើងបានឃើញហើយនេះ? សេចក្ដីគ្រាន់តែជាសន្និដ្ឋានឈ្មោងយល់ទេ តែបើសេចក្ដីឈ្មោងយល់នេះក៏ជាការសំខាន់ល្មមស្ដាប់ដែរ ។ តើរឿងប្រវត្តិស្ដេចឧទយននោះ លោកយកពីណាមក? ហើយរឿងទាំងឡាយដែលពោលអំពីស្ដេចឧទយននោះបានពីណាមក? ។

(មានតទៅទៀត) ។

# សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត

រៀបរៀង

(ត)

លើកទី ៣

លទ្ធិអាចរិយវាទ

ខ្ញុំបានពោលហើយក្នុងបរិច្ឆេទទី ៣ ថា ក្នុងរវាង ព.ស. ៩០០ ដល់ ៩៨០ លទ្ធិអាចរិយវាទបានផ្សាយចេញអំពីមជ្ឈិមប្រទេស ទៅក្នុងបច្ចន្តប្រទេសប៉ែកខាងកើត ដោយមានដំណឹងខាងឥណ្ឌៀថា ក្នុងរជ្ជកាលព្រះចៅស្កន្ធគុប្ត (ម. ខន្ធគុត្ត) ដែលគ្រប់គ្រងឥណ្ឌៀខាងលើ ជាក្សត្រិយ៍មានព្រះតេជានុភាពខ្លាំង ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនា លទ្ធិអាចរិយវាទឲ្យរុងរឿងឡើង ហើយទ្រង់អារាធនាព្រះសង្ឃគណនេះ ឲ្យចេញទៅប្រកាសសាសនាក្នុងតាងប្រទេសទាំងឡាយ ។ ពួកដែលមកប្រទេសប៉ែកខាងកើត បុះភេត្រាឆ្លងសមុទ្រឥណ្ឌៀមកឡើងនៅនគរស្រីវិជ័យខ្លះ ខ្លះរហូតមកឡើងនគរចម្ប៉ា នឹងនគរកម្ពុជា ។ មួយពួកទៀត ចេញអំពីប្រទេសគន្ធារទៅប្រទេសប៉ែរ្ស ឬដើរកាត់កណ្ដាលទ្វីបអាស៊ីទៅរហូតដល់ប្រទេសចិន ។ តែរឿងព្រះពុទ្ធសាសនាផ្សាយទៅប្រទេសចិន មានពោលក្នុងទីដទៃថា ក្នុងរជ្ជកាលព្រះចៅ ជិនស៊ីហង់តេ រវាង ព.ស. ២៩៧

ដល់ ៣៣៣ មិនបានទទួលរាប់អានព្រះពុទ្ធសាសនាម្ដងហើយ ដោយពួកសមណជាតិតាតនាំទៅប្រកាសផ្សាយ ។

បំណែកឯប្រទេសកម្ពុជាយើងបានទទួលរាប់អានពីកាលណា ជាខគួរឲ្យគិតមើល បើតាមដំណឹងខាងលើនេះក៏គួរជាថា ប្រទេសកម្ពុជាបានទទួលរាប់អានលទ្ធិអាចរិយវាទតាំងពីរវាង ព.ស. ៩០០ ដល់ ៩៤០ នោះហើយបើគិតធៀបតាមព្រះរាជពង្សាវតារខ្មែរ ត្រូវនឹងរជ្ជកាលព្រះបាទកោណ្ឌញ្ញរាជ ដោយអនុមានមើលក៏គួរជឿយកជាពិតបាន ព្រោះព្រះរាជាអង្គនេះបុះមកអំពីប្រទេសឥណ្ឌៀ កាលនៅឯប្រទេសដើមក៏គង់ជាធ្លាប់រាប់អានមកហើយ លុះលោកមកបានជាធំក្នុងប្រទេសនេះ ក៏គង់ជាទ្រង់ស្វះស្វែងរកយកមកបង្កើតឲ្យមានឡើងក្នុងប្រទេសរបស់ព្រះអង្គ ឬទទួលរាប់អានរបស់ដែលផ្សាយមកឯងក្នុងវេលានោះក៏ថាបាន ។ តាមសិលាចារិកនៅស្រុកស្រីលរៅដែលពោលហើយក្នុងលើកទី ២ ប្រមាណមើលពេលប្រហែលជាក្នុងរវាង ១២០០ ដល់ ១៥០០ ថាមានលទ្ធិមហាយាននៅក្នុងប្រទេសនេះហើយ ខនេះគួរជឿយកជាពិតបាន ព្រោះមានវត្ថុជាតឹកតាង

នៅក្នុងទីនោះមែន តែបើនឹងដេញដោលរកថា មានមកពីពុទ្ធសករាជប៉ុន្មាន គង់គ្មានអ្នកណាតបបាន ។ លុះមកដល់រជ្ជកាលព្រះបាទសម្តេចព្រះជយវរម័ន មហារាជទី ២ ព. ស. ១៣៤៥ ដរាបដល់រជ្ជកាលព្រះបាទសម្តេចព្រះជយវរម័ន មហារាជទី ៧ ព.ស. ១៧០០ ប្លាយ ទើបឃើញថា លទ្ធិនេះបំរើនរុងរឿងជាយ៉ាងខ្លាំង ដោយមានបូរាណវត្ថុផ្សេង ៗ ធ្វើអំពីថ្មនឹងសម្រិទ្ធិ ដែលជារបស់ក្នុងលទ្ធិនេះនៅមានដល់សព្វថ្ងៃនេះ គឺប្រាសាទបាយ័ន (ពីដើមជាអារាមស្ថានក្នុងលទ្ធិមហាយានវេលាក្រោយព្រះបាទយសោវរម័ន ទ្រង់កែទៅជាទេវស្ថាន) ប្រាសាទបាលេលៃយ ប្រាសាទពិធូរ ៣ នេះនៅក្នុងកំផែងក្រុងមហិន្ទ្របុរី, ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយក្តី ប្រាសាទតាសោម ប្រាសាទក្រោលគោ ប្រាសាទនាគព័ន្ធ ប្រាសាទព្រះខាន់ ៦ នេះនៅក្រៅកំផែងក្រុង, ប្រាសាទបន្ទាយឆាង នៅខណ្ឌមង្គលបុរី ខែត្របាត់ដំបង អំបាលនេះជាដើម សុទ្ធតែជាអារាមស្ថានក្នុងលទ្ធិនេះ នៅមានរូបផ្សេង ៗ ទៀត គឺរូបព្រះអាទិពុទ្ធ ឬព្រះអមិតាភ រូបព្រះភៃសជ្យគុរុ ព្រះក្រិង

ព្រះបាដិហារ្យ ព្រះបីកាយ ព្រះពោធិសត្វលោកេស្វរ ព្រះបញ្ញាបារមិតា ។ល។ មាននៅក្នុងប្រាសាទដែលបេញឈ្មោះមកហើយខ្លះ មាននៅក្នុងទីដទៃខ្លះ គាប់ានមស្សការព្រះអាទិពុទ្ធ ព្រះលោកេស្វរ ព្រះបញ្ញាបារមិតាជាភាសាសំស្ក្រឹត មាននៅប្រាសាទបន្ទាយនាង ។ បំណែកឯក្នុងស្រុកបាស់របស់ខ្មែរអំពីដើមមានស្រុកស្រែលវោជាដើម ក៏មានរបស់ទាំងនេះដែរ ។ ឯក្បួនខ្នាត របស់លទ្ធិនេះសាបសូណ្យទៅស្ទើរតែគ្មានសល់ សព្វថ្ងៃនេះឃើញមានគម្ពីរ ១ ឈ្មោះបញ្ចគតិ ដែលព្រះអស្វឃោសតែង នៅក្នុងព្រះរាជបណ្ណាល័យកម្ពុជា ។

សូមឲ្យជ្រាបថា ក្នុងរវាងពេលដែលលទ្ធិមហាយានមកប្រតិស្ឋានប្រមាណ ៦០០ ឆ្នាំនោះ ប្រទេសយើងបំរើនរុងរឿងជាបំផុត ព្រះមហាក្សត្រិយ៍សុទ្ធតែទ្រង់នូវព្រះតេជានុភាព ឯព្រះពុទ្ធសាសនាលទ្ធិមហាយាននោះក៏រុងរឿងណាស់ ដូចមានបុរាណវត្ថុ ដែលពោលមកហើយជាតាងស្រាប់ ទាំងសាសនាព្រាហ្មណ៍ក៏ត្រឡប់រុងរឿងណាស់ដែរ ប្រហែលគ្នានឹងលទ្ធិមហាយានឬជាង តែបើសង្កេតមើលរបស់ដំណោលដែល

សាងនៅក្នុងខេត្តផ្សេង ៗ ក្រៅអំពីក្រុងទៅ ឃើញថាសាសនាព្រាហ្មណរុងរឿងជាង ព្រោះឃើញមានវត្តក្នុងលទ្ធិនេះ រាយទូទៅក្នុងអាណាចក្រកម្ពុជាទាំងមូល ឯរបស់ក្នុងលទ្ធិមហាយានឃើញមាននៅក្រុងមហិន្ទ្របុរីនោះច្រើន ក្រៅពីនោះឃើញមាននៅក្នុងទីរួមខេត្តកំពង់ធំខ្លះ ទីរួមខេត្តបាត់ដំបងខ្លះ និងស្រុកស្រីសោភ័ណខ្លះប៉ុណ្ណោះ ។ ព្រះមហាក្សត្រិយ៍ក្តី រាស្រ្តទាំងពួងក្តី អង្គខ្លះនឹងអ្នកខ្លះរាប់អានសាសនាព្រាហ្មណ អង្គខ្លះនឹងអ្នកខ្លះរាប់អានព្រះពុទ្ធសាសនាលទ្ធិអាចរិយវាទ អង្គខ្លះនឹងអ្នកខ្លះរាប់អានទាំងពីរយ៉ាងជាមួយគ្នា ខនេះសូមឲ្យអ្នកសិក្សាបូរាណគតិពិនិត្យមើលបូរាណវត្តដែលសាងក្នុងសម័យនោះនឹងអាចដឹងបាន ។ន័យមួយទៀត សម្រាប់សេចក្តីយល់របស់ខ្ញុំថា ក្នុងពេលនោះសូម្បីលទ្ធិថេរវាទក៏មានក្នុងប្រទេសកម្ពុជានេះដែរ តែប្រហែលជាស្ងួបស្ងើងបន្តិច ព្រោះមិនសូវមានមនុស្សជ្រះថ្លារាប់អាន ដោយឃើញមានអារាមស្ថានដ៏ជាដំ-ណែលក្នុងលទ្ធិនេះ មានវត្តគោកធ្លកជាដើមដ៏មានសន្លឹកសីមាឬជាសំគាល់ សឹងមាននៅក្នុងក្រុងមហិន្ទ្របុរី និងសិលាចា-

វិកនៅស្រុកស្រែលអាក់ថាមានទាំងលទ្ធិស្ថវិរទាំងលទ្ធិមហាយាន នឹងរឿងតាមទេវវង្សថា ព្រះនាងជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានសាងព្រះអារាមនឹងព្រះស្តូបចេតីយ៍ នៅស្រុកហរិភុញ្ជ័យ កាលត្រូតមើលបូរាណវត្ថុក្នុងទីនោះហើយ ឃើញមានសុទ្ធតែរបស់ក្នុងលទ្ធិថេរវាទ របស់ក្នុងលទ្ធិអាចារិយវាទគ្មានសោះ អំពាលនេះជាដើមជាគ្រឿងអាង ទើបនាំឲ្យសន្និដ្ឋានទៅថ្លៃនោះ ហើយលទ្ធិនេះដំណាលសមណវង្សមកអំពីព្រះសោណថេរ នឹងព្រះឧត្តរថេរដែលប្រកាសសាសនាក្នុងដែនសុវណ្ណភូមិនេះឯង មិនមែនផ្សាយមកអំពីប្រទេសដទៃក្រៅនេះ ។

លើកទី ៤

លទ្ធិថេរវាទ បែបលង្កាវង្ស

កាលកន្លងទៅប្រមាណជា ព. ស. ១៧៥០ ព្រះពុទ្ធសាសនាលទ្ធិមហាយានក្នុងប្រទេសកម្ពុជា ក៏រៀវរោយថយចុះទាល់តែផុតវង្ស លទ្ធិហីនយានត្រឡប់រុងរឿងជាជំនួសឡើងវិញ ។ គួរឲ្យពិចារណាមើលថា ខ្មែរយើងធ្លាប់រាប់អានលទ្ធិ

មហាយានមកយូរហើយ ក៏ហេតុម្តេចទើបលើកលែងរាប់អាន តាមផ្លូវដែលបានពិនិត្យទៅហើយឃើញថា៖

១ ដោយខ្មែរយើងបានព្រះត្រៃបិដកបែបលង្កា ដែលជារបស់ត្រឹមត្រូវបំផុតមករៀនសូត្រ ។

២ ដោយមានពួកបព្វជិតខ្មែរ ចេញទៅស៊ើបព្រះពុទ្ធ-សាសនាក្នុងលង្កាទ្វីប កាលឃើញរបៀបគេល្អ ក៏សិក្សាហើយនាំមកផ្សាយក្នុងប្រទេសរបស់ខ្លួន ឬមានទាំងព្រះសង្ឃលង្កាឯង មកនៅក្នុងប្រទេសនេះក៏ថាបាន ។

អធិប្បាយក្នុងខអំពាលនេះទៅទៀត តាមដំណើរដើមថា ក្នុងរជ្ជកាលព្រះបាទអនុរុទ្ធ ព្រះចៅរាជាធិរាជភូមា គ្រប់គ្រងរាជសម្បត្តិនៅក្រុងអរិមទ្ទបុរី ក្នុងកាល ព.ស. ១៦០០ ជាធម្ម-រាជទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនាលទ្ធិថេរវាទ ឲ្យរុងរឿងឡើងក្នុងប្រទេស តែក្នុងដែនសុវណ្ណភូមិគ្មានប្រទេសណាមានព្រះត្រៃបិដកចប់បរិបូណ៌ ហេតុនោះព្រះបាទអនុរុទ្ធទើបត្រាស់បញ្ជូនសមណទូតឲ្យទៅសុំចំឡងព្រះត្រៃបិដកឯលង្កាទ្វីប ខណៈដែលចំឡងស្រេចហើយ ដាក់សំពៅនាំមកព្រះនគរវិញ មានដំណឹង

តាមក្នុងព្រះរាជពង្សាវតារខ្មែរយើងថា សំពៅដែលនាំព្រះត្រៃបិដកនឹងព្រះពុទ្ធរូបកែវមរកតនោះ ត្រូវខ្យល់ព្យុះបក់មកជាប់នៅក្នុងអាណាខេត្តកម្ពុជា ក្រម្ការខេត្តពីសបាននាំយកទៅថ្វាយព្រះមហាក្សត្រិយ៍ សឹងវេលានោះគង់នៅក្រុងមហិន្ទ្របុរី តែក្នុងរជ្ជកាលណាមិនអាចដឹងបានជាប្រាកដ ក្នុងព្រះរាជពង្សាវតារថា ក្នុងរជ្ជកាលព្រះបាទធនញ្ជយៈការព្យរាជ តែជាក់សករាជខុសគ្នាឆ្ងាយ បើដោយអនុមានមើលប្រហែលជាក្នុងរជ្ជកាលព្រះបាទសូរ្យវរម័នទី ២ ព្រោះពុទ្ធសករាជនៅក្នុងរវាងជិតគ្នា ត្រាស់ឲ្យហែរហមនាំយកទៅប្រតិស្ឋាន ទុកនៅប្រាសាទនគរតូប ហើយឧទ្ទិស្សនគរតូបនោះថ្វាយជាវត្តក្នុងព្រះពុទ្ធសាសនាទៅវិញ ទើបនាំគ្នាហៅថា នគរវត្តជាប់តាំងអំពីនោះមក គ្រានោះត្រាស់ឲ្យចារចំឡងព្រះត្រៃបិដកអំពីច្បាប់អក្សរភូមានោះ ជាក់មកជាអក្សរខ្មែរ ឲ្យចារិកទុកនៅក្របសាស្ត្រាខ្មែរគ្រប់គម្ពីរថា "កម្ពុជក្សរទ្វាត" សឹងប្រែថា "អក្សរខ្មែរនៅប្រាសាទនគរវត្ត" ជាគ្រឿងសំគាល់សឹងមាននៅដល់សព្វថ្ងៃនេះ ប្រទេសកម្ពុជារាប់ថា មានព្រះត្រៃបិដកបប់គ្រប់បរិបូណ៌ពីត្រឹមនោះមក វេលា

ក្រោយសេចក្ដីនោះជ្រាបដល់ព្រះបាទអនុរុទ្ធ ៗ ទ្រង់ឲ្យមកសុំព្រះត្រៃបិដកច្បាប់អក្សរភូមានោះទៅវិញ ទុកតែព្រះកែវមារកតថ្វាយព្រះមហាក្សត្រិយ៍ខ្មែរ ដោយទ្រង់អំណរគុណដែលបានរើសព្រះត្រៃបិដកទុក ។ ព្រះកែវមារកតដំបូងបេញពីឥណ្ឌៀទៅលង្កាបេញអំពីលង្កាមកស្ថិតនៅក្នុងប្រទេសកម្ពុជា វេលាក្រោយបានទៅលាវ របូតពីលាវបានទៅសៀមនៅដល់សព្វថ្ងៃនេះ ។ កាលខ្មែរយើងបានព្រះត្រៃបិដកមកជាសម្បត្តិដ៏ប្រសើរ ក្នុងព្រះនគរធំហ្នោះហើយ ប្រជាជនទាំងឡាយមានភិក្ខុសង្ឃជាដើម កើតជ្រះថ្លានាំគ្នាសិក្សារៀនសូត្រព្រះត្រៃបិដកបែបថ្មីនោះ ។ តាមសេចក្ដីក្នុងសិលាចារិកមួយកន្លែងនោះថា ព្រះនាងជ័យរាជទេវីអគ្គមហេសីសម្ដេចព្រះជ័យវរ្ម័នទី ៧ បេះព្រះត្រៃបិដកបានទ្រង់ប្រដៅគម្ពីរពុទ្ធសាសនានៅវត្តនាគេន្ទ្រ១ វត្តតិលកោត្តរ១ វត្តនរេន្ទ្រាស្រម១តែជាគម្ពីរខាងលទ្ធិមហាយាន ឬខាងលទ្ធិមហា-យាន ក្នុងទីនោះមិនបានបង្ហលឲ្យច្បាស់ តាមផ្លូវសន្និដ្ឋានគួរជាខាងលទ្ធិហីនយាន ព្រោះក្នុងពេលនោះលទ្ធិមហាយានរៀវ

រោយចុះហើយគ្មានអ្នកណាសាងវត្តវាំឡើយ ដោយហេតុនេះ លទ្ធិមហាយានទើបសាបសូន្យទៅ ។

ក្រោយនោះមកទៀត ក្នុងកាល ព. ស. ១៦៩៦ ព្រះចៅបរក្កមពាហុ ទ្រង់កំចាត់ពួកទមិឡចេញអំពីលង្កាទ្វីបបាន ត្រឡប់វាយបានទាំងស្រុកទមិឡមកផង ស្រេចព្រះរាជសង្គ្រាមហើយ ទ្រង់អារាធនាព្រះសង្ឃមានព្រះមហាកស្សបត្ថេរជាប្រធានធ្វើសង្គាយនាធម្មវិន័យ រាប់ជាសង្គាយនាគ្រាទី ៧ នឹងទ្រង់ទំនុកបំរុងដោយផ្លូវដ៏ទៃៗ ទៀតជាច្រើន អំពីនោះមកក៏មានកិត្តិសព្ទនោះល្បីយខ្ចរខ្ចាយមកក្នុងប្រទេសសុវណ្ណភូមិ គ្រានោះមានភិក្ខុក្នុងប្រទេសភូមា មន លាវ ខ្មែរ ចេញទៅស៊ើបសាសនានៅលង្កា កាលទៅឃើញវត្តប្រណិបត្តិរបស់ព្រះសង្ឃលង្កាតាមបែបដែលថេរះថ្មី ក៏កើតសេចក្តីជ្រះថ្លាសុំសិក្សារៀនសូត្រ តែគ្រានោះព្រះសង្ឃលង្កាកើតសេចក្តីរង្កៀសថា សមណវង្សក្នុងនានាប្រទេសបែកញែកគ្នាមកយូរណាស់ហើយ មិនទុកចិត្តក្នុងវិហារធម៌របស់ព្រះសង្ឃតាងប្រទេស ទើបណែនាំឲ្យឧបសម្បទាឡើងជាថ្មី ទើបព្រមឲ្យរួមឧបោសថសង្ឃកម្ម ពួកភិក្ខុតាងប្រទេស

ក៏ព្រមធ្វើតាមវិធីញត្តិឡើងជាថ្មីរាប់ថា មានតាំងអំពីនោះជាដើម មកភិក្ខុអំបាលនោះនៅសិក្សាលទ្ធិធម្មវិន័យយ៉ាងលង្កាតាមសមគួរហើយ ក៏ត្រឡប់មកកាន់ស្រុកទេសរបស់ខ្លួនវិញ ជួនកាលបបួលទាំងព្រះសង្ឃលង្កាមកជាមួយផងក៏មាន ដូចមានប្រាកដក្នុងសិលាកល្យាណីនោះស្រាប់ កាលមកដល់ស្រុកទេសរបស់ខ្លួនហើយ អ្នកស្រុកឃើញកិរិយាប្រព្រឹត្តត្រឹមត្រូវល្អជាងព្រះសង្ឃដើមក្នុងប្រទេសក៏កើតជ្រះថ្លា នាំយកកូនចៅទៅទុកឲ្យនៅរៀនសូត្រក្នុងសំណាក់ព្រះសង្ឃលង្កាវង្ស ច្រើនឡើង ៗ ដោយលំដាប់ ។ ពោលចំពោះព្រះសង្ឃខ្មែរដែលបានចេញទៅសិក្សាធម្មវិន័យឯលង្កាប៉ុន្មានលើកប៉ុន្មានដង ឈ្មោះអ្វីខ្លះនោះមិនអាចដឹងបានសព្វគ្រប់ ដឹងបានតែ ១ រឿងដែលមានពោលក្នុងសិលាកល្យាណីថា ព្រះតាមិលន្ទថេរជារាជបុត្រស្ដេចខ្មែរទៅរៀនសូត្រនៅលង្កាទាល់តែបានពហុស្សូត្រ ហើយត្រឡប់មកស្រុកវិញជាមួយនឹងភិក្ខុជាតិមន ឈ្មោះឆបដថេរ ។ បំណែកឯព្រះសង្ឃលង្កាមកនៅក្នុងប្រទេសកម្ពុជា មានពោលក្នុងព្រះរាជពង្សាវតារកម្ពុជាថា ព្រះមហាក្សត្រិយ៍ខ្មែរ ឲ្យទៅនិមន្តព្រះសង្ឃ

លង្កាមក ៧ អង្គ ហើយទ្រង់តាំងឲ្យមានសមណជាត្រទូងរ័តន៍ (រាជាគណា) ទាំង ៧ អង្គ គឺជាសម្ដេចព្រះសុគន្ធាធិបតី ១ ព្រះមង្គលទេព្វាចារ្យ ១ ព្រះធម្មលិក្ខិត ១ ព្រះពោធិវង្ស ១ ព្រះវនរ័តន៍ ១ ព្រះមហាព្រហ្មមុនី ១ ព្រះមហាពិមលធម្ម ១ ព្រះថេរទាំង ៧ អង្គនេះនៅក្នុងប្រទេសកម្ពុជារហូតទៅ មិនឮថាត្រឡប់ទៅលង្កាវិញទេ ។ ព្រះថេរអំបាលនេះមកក្នុងរជ្ជកាលណា មិនអាចដឹងបានជាប្រាកដ តែក្នុងព្រះរាជពង្សាវតារថា មកក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះកេតុមាលា តាមផ្លូវពិចារណាឃើញថា មិនមែនមកក្នុងរជ្ជកាលនោះ ព្រោះក្នុងរជ្ជកាលនោះកំពុងរាប់អានលទ្ធិមហាយានពេញបន្ទុកលទ្ធិមហាយានកំពុងរុងរឿង ម្ដេចក៏ទៅនិមន្តពួកហីនយានិកនិកាយមកធ្វើអ្វី ១ ទៀតក្នុងសម័យនោះមិនទាន់មានប្រវេណី តាំងសមណសក្តិព្រះសង្ឃផង បើថាមកក្នុងសម័យនេះទើបត្រូវ ។ ក្នុងងារអំបាលនេះ ងារថា ព្រះវនរ័តន៍នេះកើតឡើងក្នុងប្រទេសលង្កាជាដំបូង កាលព្រះសង្ឃលង្កាវង្សផ្សាយមកក្នុងប្រទេសកម្ពុជា នឹងក្នុងប្រទេសសៀម ខ្មែរសៀមក៏តាំងងារនេះឡើងតាមយ៉ាងលង្កា ក្នុងរជ្ជកាលព្រះបាទភ្នូវគោក-

ពាហុទ្រង់ព្រះរាជទានតាមព្រះសង្ឃ មន ១ អង្គជា ព្រះសិរីវនរតនសាមិដូចមានក្នុងសិលាកល្យាណី ។

ផ្លូវដែលនឹងស្រាវរកទៅទៀតឲ្យឃើញថា ព្រះសង្ឃលង្កាវង្សផ្សាយមកក្នុងប្រទេសនេះមែន គឺព្រះសង្ឃលង្ការង្កៀសព្រះសង្ឃនានាប្រទេសដូចដែលពោលហើយ ក្នុងវិធីញត្តិកាលព្រះសង្ឃលង្កាវង្សផ្សាយមកក្នុងប្រទេសនេះ មិនបានរួមឧបោសថសង្ឃកម្មនឹងព្រះសង្ឃស្រុកអាយនេះ កើតជាព្រះសង្ឃ ២ ពួក គឺនិកាយដើម ១ និកាយលង្កាវង្ស ១ តែជានិកាយហីនយានដូចគ្នា សូម្បីក្នុងប្រទេសភូមា មន លាវ សៀម ក៏ជា ២ និកាយដូច្នេះ ហេតុនេះប្រហែលជាមានពិធីញត្តិព្រះសង្ឃនិកាយដើមនឹងបញ្ចុះសីមាវិត្តចាស់ ៗ ខ្លះឡើងទៀត ដោយវិត្តបូរាណក្នុងក្រុងចាស់ ៗ ច្រើនតែមានសន្លឹកសីមា ២ ជាន់ ។ រឿងសីមា ២ ជាន់នេះ តាមព្រះមតិរបស់សម្តេចព្រះមហាសមណក្រមព្រះយ៉ាវជិរញាណ នឹងក្រមព្រះដាំរុងរាជានុភាពថា កាលដើមគង់បញ្ចុះសីមាមួយ ៗ ដូចគ្នាទាំងអស់ លុះពួកលង្កាវង្សចូលមកតាំងរង្កៀសទាំងខ្លួនទាំងការងាររបស់និកាយដើម ទើបព្រះ

មហាក្សត្រិយ៍ទ្រង់អារាធនាព្រះសង្ឃលង្ការវង្ស ឲ្យធ្វើសីមាបណ្ដាវត្តហ្លួងថែមម្ដងទៀត ដើម្បីឲ្យធ្វើសង្ឃកម្មបានទាំងនិកាយដើមទាំងនិកាយលង្ការវង្ស វត្តណាដែលធ្វើសីមាថែមទៀតហើយ វត្តនោះតោងមានសីមាគូជាសំគាល់ ហេតុនោះវត្តដែលមានសីមាគូ ឃើញសុទ្ធតែវត្តស្ដេច បំណែកឯវត្តរាស្ត្រឃើញមានសន្លឹកសីមារៀងមួយ ៗ ដូចសព្វថ្ងៃ ។ អំណាិសយួរមកក៏រួមគ្នាជានិកាយតែមួយទៅវិញ ដោយសេចក្ដីសាមគ្គីគ្នា ។

បំណែកឯសៀមតាំងអំពីដើមមក នៅក្នុងអំណាចប្រទេសកម្ពុជាជាច្រើនរយឆ្នាំ រវាងដែលនៅក្នុងអាណាព្យាបាលខ្មែរនោះ ខ្មែរកាន់សាសនាព្រាហ្មណ សៀមក៏កាន់សាសនាព្រាហ្មណតាម ខ្មែរកាន់ព្រះពុទ្ធសាសនាលទ្ធិមហាយាន សៀមក៏កាន់ព្រះពុទ្ធសាសនាលទ្ធិមហាយានតាម ខ្មែរកាន់ព្រះពុទ្ធសាសនាលទ្ធិហីនយាន សៀមក៏កាន់ព្រះពុទ្ធសាសនាលទ្ធិហីនយានតាម លុះមកដល់ព. ស. ១៨០០ សៀមតាំងខ្លួនជាឯករាជឡើងបានក្នុងប្រទេសកម្ពុជា គឺតាំងនៅស្រុកសុខោទៃយសូម្បីតាំងខ្លួនបានដូច្នោះ សៀមក៏នៅនិយមរាប់អានក្នុងសេចក្ដី

អារ្យធម៌របស់ខ្មែរ ព្រោះខ្មែរជាអារ្យជាតិមកយូរហើយ គឺលទ្ធិទំនៀមទម្លាប់ក្ដី ប្រវេណីក្ដី សាសនាក្ដី សៀមយកដម្រាប់តាមខ្មែរទាំងអស់ រហូតដល់ទៅអក្សរនិងភាសាក៏នៅប្រើរបស់ខ្មែរ ដូចមានសិលាចារឹកនៅក្រុងសុខោទៃយជាសាក្សីស្រាប់ លុះដល់ ព.ស. ១៨២៩ ស្ដេចសៀមឈ្មោះឃុនរាមកំហែង គិតធ្វើបែបអក្សរសៀមឡើងជាដំបូង បែបអក្សរនោះក៏ប្រឌិតយកជើងអក្សរខ្មែរទៅធ្វើជាតួអក្សរសៀមនោះឯងដោយច្រើន កាលកើតអក្សរសៀមហើយ សៀមក៏មិនសូវប្រើអក្សររបស់ខ្លួន ក្នុងគម្ពីរធម៌អាថ៌ក្ដី ក្បួនខ្នាតអ្វីៗក្ដី ជាភាសាមគធក្ដី ជាសម្រាយក្ដី ឃើញប្រើតែអក្សរខ្មែរដោយច្រើន រហូតមកដល់វេលាដែលតាំងក្រុងទេពសព្វថ្ងៃនេះ ។

កាលសៀមតាំងឥស្សរភាពបានហើយ ក៏លើកកងទ័ពមកញាំញីប្រទេសកម្ពុជាជាច្រើនដង ព្រោះកាលផុតរាជវង្សវរ្ម័នមកហើយ ប្រទេសកម្ពុជាថយអំណាចចុះ ដូចយ៉ាងក្នុងកាល ព.ស. ១៨៩៥ ក្នុងរជ្ជកាលព្រះបរមលម្ពង្សរាជាទី ១០ ក្នុងបរមនាថរាជវង្សនិងក្នុងរជ្ជកាលព្រះធម្មាសោករាជ ព. ស.

១៩១៥ សិងសោយរាជ្យនៅក្នុងក្រុងមហានគរបុរីនៅឡើយ កង
ទ័ពសៀមបានមកញាំញីផ្ចាញ់យកទ្រព្យសម្បត្តិ អំពីប្រទេស
កម្ពុជាទៅជាអនេក ដូចយ៉ាងគម្ពីរព្រះត្រៃបិដក តម្រាប់តម្រា
ផ្សេង ៗ គ្រឿងរាជ្យ គ្រឿងអាវុធយុទ្ធភណ្ឌ និងកៀរគោយ
យកមនុស្សប្រុសស្រីទៅជាឈ្លើយប្រើនពន់ប្រមាណ យក
បានទាំងអាណាខេត្តរបស់ខ្មែរទៅជាងពាក់កណ្ដាល កាលខ្មែរ
ថយមកតាំងក្រុងនៅបន្ទាយល្វែកហើយ ក៏តាមមកកំទេច
ទៀតជាច្រើនលើក ហេតុនោះប្រទេសកម្ពុជាទើបធ្លាក់ទៅជា
ប្រទេសទន់ទាប ព្រះត្រៃបិដកក៏មានមិនគ្រប់ ព្រោះសៀម
ផ្ចាញ់យកទៅជាសម្បត្តិរបស់គេអស់ ទោះបីម្ល៉ឹង ការព្រះ
សាសនាក្នុងសម័យនេះ រាប់ថាជាទី ២ រងប្រទេសសៀមបុះមក
ប្រទេសក្រៅអំពីនេះជាទី ៣ ទី ៤ រងខ្មែរទៅទៀត ។ះ០៚—

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាឡីនិងប្រែ) ១ ចប់ចំនួន ១០០ សៀវភៅ.... | ថ្លៃ | ២៥០រ,១០ |
| ទស្សនាវដ្ដី | — | ៤, ០១ |
| សាសនកិច្ចានុក្រម ១២ ខ្សែ | — | ០, ៥០ |
| ដំណាលពុទ្ធចេតិយ | ១ សៀវភៅ ថ្លៃ | ១, ៨០ |
| អំពីព្រះពុទ្ធសាសនា | — | ១, ៥០ |
| កច្ចាយនូបត្ថម្ភក ខ្សែ ១ | — | ១, ៣០ |
| " " ខ្សែ ២ | — | ១, ៤០ |
| អភិធម្មត្ថសង្គហ | — | ០, ៩០ |
| មិលិន្ទបញ្ហា ខ្សែ ១ | — | ០, ៩០ |
| " " ខ្សែ ២ | — | ០, ៧០ |
| អរិយសច្ចកថា | — | ០, ៥០ |
| វុត្តោទយ | — | ០, ៦៥ |
| ធម្មបទដ្ឋកថា | — | ០, ៦៥ |
| សុរិយាត្រឡើងស័ក | — | ០, ៦០ |
| សតិបដ្ឋានសុត្ត | — | ០, ៥០ |
| មរណានុស្សតិ | — | ០, ៣០ |
| បញ្ញាសជាតក | — | ០, ៥០ |
| គិហិបដិបត្តិ | — | ០, ៤៥ |
| អំពីប្រាសាទនៅអង្គរ | — | ០, ៣៥ |
| មាតាបិតុឧបដ្ឋាន | — | ០, ៣៥ |
| សិង្គាលោវាទសុត្ត | — | ០, ៣០ |
| ទសបារមីកថា | — | ០, ៣០ |
| សាមណេរវិន័យ | — | ០, ៣០ |
| បាដិមោក្ខសង្ខេប | — | ០, ៣០ |
| សេកសោមបណ្ឌិត | — | ០, ៣០ |
| អំពីព្រះនិព្វាន | — | ០, ៦០ |
| ១០០ គាថា | — | ០, ២១ |

| | | |
|---|---|---|
| មនោបុព្វកថា.......................... | ១ សៀវភៅថ្លៃ | ០, ១៥ |
| ពុទ្ធាភិទានុសាសនី.......................... | — | ០, ៩៥ |
| កាលាមសុត្តនិងបរាភវសុត្ត.......................... | — | ០, ១៥ |
| គតិលោកខ្សែ ១.......................... | — | ០, ១៥ |
| ច្បាប់ថ្មី.......................... | — | ០, ១៥ |
| កាព្យសក្រាវ ទី ១.......................... | — | ០, ៩៥ |
| " " ២.......................... | — | ០, ៩៥ |
| " " ៣.......................... | — | ០, ១៥ |
| ញាណកថា.......................... | - | ០, ១២ |
| សំវេជនីយធម៌.......................... | — | ០, ១២ |
| សីមាវិនិច្ឆ័យ.......................... | — | ០, ១០ |
| អនត្តលក្ខណសុត្ត.......................... | — | ០, ១០ |
| តាគោចមាទិកថា.......................... | — | ០, ០៨ |
| សេចក្តីដាស់តឿន.......................... | — | ០, ០៦ |
| សុភទោសកថា.......................... | — | ០, ០៥ |
| អក្ខទោសកថា.......................... | - | ០, ០៥ |
| ព្រះចង្កូមកែវ.......................... | — | ០, ៩០ |
| ពុទ្ធប្រវត្តិ .......................... | — | ០, ០៥ |
| រឿង ១ ពាន់ ១ យប់.......................... | — | ០, ០៤ |
| បាយាសិរាជញ្ញសុត្ត.......................... | — | ០, ០៤ |
| គិរិមានន្ទសុត្ត.......................... | — | ០, ០៧ |
| ពាក្យកាព្យក្រមអ៊ូ.......................... | — | ០, ០៥ |
| សប្បុរិសធម៌.......................... | — | ០, ០៥ |
| សារទេសនា.......................... | — | ០, ០៣ |
| អនុត្តរិយសុត្ត.......................... | — | ០, ០២ |
| បុណ្ណោវាទសុត្ត.......................... | — | ០, ០២ |
| សត្តបរិត្តនិងទ្វាទសបរិត្ត.......................... | — | ០, ៣៥ |
| ធម្មបទីប.......................... | — | ០, ៤០ |
| ស្បៀកទូន្មានក្មេងបៅបិន.......................... | — | ០, ៩៥ |

| | | |
|---|---|---|
| ល្បើកទូន្មានកូនចៅចិន . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ជយវរម័ន ទី ៧ (អក្សរខ្មែរ). . . . . . . . . . . . . . . . . | — | ០, ២៥ |
| អត្តានុសាសនី. . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| ជយវរម័នទី ៧ (អក្សរបារាំង) . . . . . . . . . . . . . . . | — | ០, ៤៥ |

## រូបផ្តិតពុម្ពខ្សែ ១

| | | |
|---|---|---|
| រូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . . . . | ថ្លៃ | ០រ ២៥ |
| " " ក្រដាសទន់ . . . . . . . | — | ០, ០៦ |
| " ព្រះស៊ីសុវត្ថិ. . . . . . . . . . . . . . . . . | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . . . . . | — | ០, ១០ |
| រូបសម្តេចព្រះវររាជជននី. . . . . . . . . . . . . . . . . . | — | ០, ០២ |
| ព្រះពុទ្ធរូបមានអគ្គសាវកអង (របនាពភរ). . . . . . . . . . | — | ០, ០៥ |
| ព្រះពុទ្ធរូប និព្វាន . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ៣ ព្រះអង្គ . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ១ ព្រះអង្គ. . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក ១ សន្លឹក. . . . . . . . . . . . | — | ០, ០៦ |
| រូបព្រះពុទ្ធបាទ ១ សន្លឹក. . . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបព្រះឥន្ទ្រលាស់ពត់រឿងពុទ្ធបរិវត្តន៍ . . . . . . . . . . . . | — | ០, ០៣ |
| ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀង). . . . . . . . . . . . | — | ០, ០៣ |
| ព្រះពុទ្ធរូបបាយ័ន ១៣ សន្លឹក ១ សន្លឹក. . . . . . . . . . . . | — | ០, ០២ |
| រូបគំនូរ តេមិយជាតក ១៣ សន្លឹក. . . . . . . . . . . . . . | — | ០, ១៥ |
| " មហាជនកជាតក ១៣ សន្លឹក . . . . . . . . . . . | — | ០, ១៥ |
| " សុវណ្ណសាមជាតក ១៣ " . . . . . . . . . . . . . | — | ០, ១៥ |
| ប្រក្រតិទិនឆ្នាំថ្មី. . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ព្រះពុទ្ធរូបមានព្រះឥន្ទ្រនិងព្រះព្រហ្មឈរអម . . . . . . . . . . | — | ០, ០៥ |

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

INSTITUT
DE CIVILISATION
INDIENNE
No D. 2627

1935

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ៧

ខែ្ញ ១០, ១១, ១២, រួមគ្នា

ក្បួនរៀបរៀងនេះបានទទួលការយល់ព្រម

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

BIBLIOTHÈQUE ROYALE DU CAMBODGE

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៨

គ. ស. ១៩៣៥

1935

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

PER. 933
Vol. 7

# បញ្ជីរឿង

ទំព័រ


១ — រឿងស្ដេចឧទេយន ដកពីសេចក្ដីល្បងអំពីគុណកាព្យ នឹងព្រឹហត្កថា របស់ លោកហ្វេលិក្សឡាកូត ក្រមការ ដុំ - ម៉ៅ ប្រែចេញពីភាសាបារាំងសែសមក ជាភាសាខ្មែរ (ត) . . . . . . . . . . . . . . . . . . . . ៧

២ — សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យរៀបរៀង (ត) . . . . . . . . . . . . . . . . . . . . ១៦

៣ — សេចក្ដីកត់ហេតុព្រះអង្គម្ចាស់សាវ៉ាំងទតមន្ទីរពុទ្ធសាសនបណ្ឌិត្យ នឹងលាពុទ្ធសាសនបណ្ឌិត្យទៅវិញ . . . . . . . . . . . . . . . . . . ១៩

៤ — បុណ្យសម្ពោធឆ្លងសាលាបាឡីរងនៅវត្តសំបួរមាស ឃុំជើងក្រៀវ ស្រុករលាផ្អៀរ កំពង់ឆ្នាំង . . . . . . . . . . . . . . . . . . . . ៣១

៥ — រឿងខ្មែរដែលមិនទាន់ចេញផ្សាយ គឺរឿងបុរស ៣ នាក់ ម្នាក់ជក់កញ្ឆា ម្នាក់ជក់អាភៀន ម្នាក់ផឹកស្រា . . . . . . . . . . . . . . . . . . ៤១


## រូបប្ដិតពុម្ព


១ — ព្រះរូបព្រះអង្គម្ចាស់សាវ៉ាំង នឹងក្រុមជំនុំខ្មែរ . . . . . . . . . . . . . . ១៧

២ — រូបព្រះសង្ឃនឹងឧបាសកឧបាសិកា ក្នុងឱកាសសម្ពោធឆ្លងសាលាបាឡីរងនៅ វត្តសំបួរមាស (កំពង់ឆ្នាំង) . . . . . . . . . . . . . . . . . . . ២៩


## រូបក្រៅរឿង


ប្រាសាទតាសោម ជ្រុងខាងឥសាណនៃគោបុរខាងលិច . . . . . . . . . ៥



PER 933

ÉCOLE FRANÇAISE
BIBLIOTHÈQUE

# TABLE DES MATIÈRES

Pages

I. La légende d'Udayana, extraite de l'Essai sur Gunadhya et la Brahatkatha par Félix Lacôte, traduit du Français en Cambodgien par Krommokar Choum-Mau (suite)..... 7

II. Sasanapravatti ou l'Histoire des Religions, par Préas Maha Pitou Krasém, pandit à la Bibliothèque Royale (suite). 11

III. Visite de S. A. R. le Tiao Savang Président de l'Institut Bouddhique de Louang-Brabang à l'Institut Bouddhique de Phnôm-Penh .......................... 19

IV. L'inauguration de l'École élémentaire de Pâli à Sambour-Méas khum Chœung-Kreo à Kompong-Chhnang.... 31

V. Contes populaires cambodgiens inédits :
L'opiuman, le fumeur de haschisch et l'alcoolique....... 41

## ILLUSTRATIONS :

I. S. A. R. le Prince Savang et S. A. R. le Prince Monireth au milieu des Membres de la Commission du Tripitaka... 17

II. Clergés et laïcs à l'inauguration de l'École élémentaire de Pâli à la pagode de Sambour-Méas.................... 29

III. Hors texte représentant Tasom-Angle Nord-Est du Gopu Ouest.............................. ....... 5



ប្រាសាទតាសោម — ជ្រុងខាងឥសាណនៃគោបុរខាងលិច ។
ប្រាសាទនេះគេសាងឧទ្ទិស្សដល់ព្រះពុទ្ធសាសនាមហាយាន ក្នុងរវាង ព.ស. ១៣៥០ ឆ្នាំ ។

## រឿងព្រះបាទឧទយន(ក)

តាមរឿងរ៉ាវដែលមានតៗមកក្នុងស្រុកទីបេត៍ថា ព្រះបរមសម្មាសម្ពុទ្ធទ្រង់ប្រោសបានស្ដេចឧទយន ហើយព្រះរាជបុត្ររបស់ស្ដេចនេះទ្រង់ព្រះនាមថារាស្ត្របាល បានបួសទ្រង់ព្រះផ្នួសក្នុងព្រះពុទ្ធសាសនា ។ គម្ពីរកមិសតកសម្ដែងមានទំនងដូចគ្នាអំពីព្រះរាជបុត្រដែលទ្រង់ព្រះនាមថា សរណ (តែស្ដេចឧទយនក្សត្រក្រុងសុវីរនេះជាប្រឡំគ្នានឹងស្ដេចឧទយន ក្សត្រក្រុងកោសម្ពី ឬដូចម្ដេចមិនដឹង) ។ ក្នុងសំយុត្តនិកាយ បរិច្ឆេទទី ៤ យើងឃើញព្រះបាទឧទេន ទទួលការសិក្សាអំពីសំណាក់ព្រះភារទ្វាជ ។ ក្នុងស្ថាននេះដូចគ្នានឹងក្នុងកមិសតក ដែលមានក្នុងគម្ពីរនៅស្រុកទីបេត៍ដែរ ។ ព្រះថេរ បិណ្ឌោលភារទ្វាជសម្ដែងធម្មទេសនាក្នុងឃោសិតារាម ព្រះបាទឧទេនឃើញអ្នកនគរដើររជយទៅក៏យាងទៅឯព្រះបិណ្ឌោលភារទ្វាជនេះ ក្នុងវេលានោះព្រះថេរមិនគោរពមកព្រះអង្គដូចអ្នកទាំងពួង ហើយទ្រង់ព្រះក្រោធ យាងត្រឡប់ទៅព្រះដំណាក់វិញ ក្រោយនោះបន្តិចទ្រង់យាងមកឯឃោសិតារាមទៀត ដោយតាំងព្រះទ័យថា នឹង

មកកាត់ព្រះកេសាព្រះបេរដែលព្រហើនឥតគួរសមនេះ ។ ក្នុងវេលានោះព្រះបេរក៏ជៀលគ្នាសឡស្ដេច ហើយព្រះបាទឧទេនក៏វង្វេងស្មារតីភាន់ភាំង វេលាដែលទ្រង់យាងទៅបាញ់សត្វក៏វង្វេងផ្លូវក្នុងព្រៃរកផ្លូវមិនឃើញកំណត់៦ខែ ហើយទ្រង់សំណាក់នៅទីខ្ទមអ្នកគង្វាលគោ ។ ក្នុងពេលដែលវង្វេងនោះទ្រង់ក៏មានព្រះស្មារតីឡើងវិញ ព្រមទាំងកើតជំនឿក្នុងព្រះពុទ្ធសាសនាឡើង ។ ទ្រង់និមន្តព្រះបិណ្ឌោលភារទ្វាជទៅគោរពនមស្សការកំណត់ ៧ ថ្ងៃ ក្នុងវេលាដែលព្រះសម្មាសម្ពុទ្ធទ្រង់យាងចូលមកក្នុងក្រុងកោសម្ពីនោះព្រះបាទឧទេនទ្រង់និមន្តឲ្យគង់ក្នុងទីនោះកំណត់៣ខែមួយអន្លើដោយព្រះអរហន្តខីណាស្រពទាំងឡាយ ព្រះបរមគ្រូក៏ទ្រង់សម្ដែងព្រះសទ្ធម្មទេសនាប្រោសក្នុងទីនោះ ។ ភាគដើមរបស់រឿងនេះមាននៅក្នុងដើមជាតក លេខ ៤៩៧ តែរបៀបសេចក្ដីប្រែខុសគ្នា ។ ព្រះបិណ្ឌោលភារទ្វាជបេរ លោកហោះដោយអាកាសវេហាស៍ លុះត្រូវពេលក្ដៅណាស់ លោកហោះចុះទៅសម្រាកក្នុងសួនច្បារព្រះបាទឧទេនក្នុងក្រុងកោសម្ពី ។ ក្នុងពេលនោះស្ដេចតែងយាងមកក្រសាលជាមួយនឹងស្នំទាំងឡាយ

តាំងពីពវ៉ៃមកហើយៗក្នុងថ្ងៃទ្រង់សោយនូវទឹកមេរ័យ ហើយក៏ទ្រង់ផ្ទំលក់ទៅ ។ ឯបំណែកពួកស្នំក៏ដើរបែកគ្នាពាសផ្កាសទៅក្នុងសួន ខ្លះបេះផ្កាខ្លះបេះផ្លែ ហើយក៏បានប្រទះនឹងព្រះថេរនោះ ព្រះថេរក៏សម្តែងធម៌ឲ្យស្តាប់ ។ ក្នុងវេលានោះព្រះមហាក្សត្រទ្រង់តើនឡើង ហើយត្រាស់សួររកពួកស្រីស្នំ ទើបមានគេក្រាបទូលថា កំពុងតែអង្គុយដឹកង់ជុំវិញភិក្ខុ ១ អង្គដែលសម្តែងធម៌ទេសនា ។ ព្រះបាទឧទេនទ្រង់ព្រះក្រោធបង់ចាប់ភិក្ខុនោះដាក់ឲ្យស្រមោចភ្លើងខាំ ហើយទ្រង់ត្រាស់បង្គាប់ឲ្យយកស្រមោច ១ ការុងយកទៅចាក់ពីលើព្រះថេរ ។ ក្នុងវេលានោះព្រះថេរក៏ហោះរត់ទៅឯព្រះជេតវនារាម យកសេចក្តីទៅក្រាបទូលដល់ព្រះបរមគ្រូ ។

សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម រៀបរៀង

(គ)

## រូបបែបលក្ខណព្រះពុទ្ធរូបនិងពោធិសត្វរូប

## ក្នុងលទ្ធិមហាយាន

តាមដែលបានពិនិត្យទៅឃើញថា ពួកមហាយានិកនិកាយក្នុងប្រទេសគន្ធារជាដើម បានសាងបែបព្រះពុទ្ធរូបនិងពោធិសត្វរូបទុកក្នុងសម័យព្រេងនាយជាច្រើនបែប មានលក្ខណាការផ្សេងគ្នាដូច្នេះ ។

១ គ្រាភូមិស្បស៌មុទ្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះជង្ឃ (ជង្គង់) ខាងឆ្វេង, ព្រះហស្តស្តាំដាក់ផ្កាប់លើព្រះជង្ឃខាងស្តាំ ចុងព្រះអង្គុលីចង្អុលចុះទៅផែនដី ។ ធ្វើដំណាលកាលព្រះអង្គគង់នៅលើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្ស ទ្រង់ផ្ចាញ់មារាធិរាជ ដែលមកប្រវិញ្ចន៍ប្បាំងដណ្តើមយករតនបល្ល័ង្កថាជារបស់ខ្លួន កាលនឹងពិសោធ្យរកពីកតាងថា អ្នកណាជាម្ចាស់ដោយពិត ទើបទ្រង់ផ្សងចង្អុលទៅផែនដី ដើម្បីយកនាងទេពធរណីដែលរក្សាផែនដី ជាសាក្សីក្នុងរឿងនេះ ។

២ គ្រាធ្យានមុទ្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តទាំងពីរដាក់ផ្កាជម្រែតគ្នាលើព្រះភ្នែនពីខាងមុខ ជាកិរិយាសមាធិ ។ ធ្វើដំណាលកាលព្រះមហាសត្វធ្វើសមាធិបំរើនអនាបានសតិកម្មដ្ឋានបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណនៅក្រោមដើមពោធិព្រឹក្ស ។

៣ គ្រាអភយមុទ្រ ធ្វើជាព្រះពុទ្ធរូបឈរក៏មាន គង់ពត់ព្រះភ្នែនក៏មាន បើជាព្រះរូបឈរ ធ្វើព្រះហស្តខាងឆ្វេងសំយោកចុះក្រោម ព្រះហស្តស្តាំលើករាស្មើព្រះឧរា, បើជាព្រះរូបគង់ពត់ព្រះភ្នែន ព្រះហស្តឆ្វេងដាក់ផ្ងាលើព្រះភ្នែន ព្រះហស្តស្តាំរាដូចមុន តាមគតិផណ្ដៅ សូម្បីរាព្រះហស្តទាំងពីរក៏ហៅថាអភយមុទ្រដែរ ។ ធ្វើដំណាលកាលព្រះសាស្តាបានត្រាស់ឡើងហើយ ស្តេចចារិកទៅក្នុងលោកដើម្បីប្រោសសត្វសូម្បីលោកនេះប្រកបដោយភ័យអន្តរាយច្រើន ក៏ព្រះអង្គឥតភ្លឹកឬសត្វលោកណាមួយគិតប្រទុស្តរាយព្រះអង្គ ៗ ក៏មិនប្រកាន់យកទោសភ័យដល់អ្នកនោះ ។

៤ គោបក្រមុទ្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែកក៏មាន គង់សំយុងព្រះបាទដូចអង្គុយកោអីក៏មាន ព្រះហស្តស្តាំលើកស្មើព្រះឧរា ហើយជីបម្រាមព្រះហស្តពីរជាវង់មូលដូចរូបកង់ចក្រ ព្រះហស្តឆ្វេងដាក់ផ្កាលើព្រះភ្នែកក៏មាន ជាប់ជាយចីវរក៏មាន៖ ម្យ៉ាងទៀត ធ្វើព្រះហស្តទាំងពីរជាកិរិយាចាប់កង់ចក្របង្វិល, ដូចកាលគេធ្វើរូបគ្រឿងប្រកប ជារូបកង់ចក្ររូបម្រឹគនៅព្រៃឥសិបតនមិគទាយវ័ន និងរូបភិក្ខុបញ្ចវគ្គីយ៍ ។ ធ្វើដំណាលកាលព្រះបរមសាស្ដាទ្រង់សំដែងព្រះធម្មចក្រដ៏ជាបឋមទេសនាប្រោសបញ្ចវគ្គីយ៍នៅព្រៃឥសិបតនមិគទាយវ័ននាដំបន់នគរពារាណសី ។

៤ គ្រាបក្រមុទ្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្លៅក៏មាន គង់សំយុងព្រះបាទដូចអង្គុយកៅអីក៏មាន ព្រះហស្តស្ដាំលើកស្មើព្រះឧរា ហើយជីបម្រាមព្រះហស្តពីរជារង្វង់មូលដូចរូបកង់ចក្រ ព្រះហស្តឆ្វេងដាក់ផ្ងាលើព្រះភ្លៅក៏មាន ចាប់ជាយចីវរក៏មាន៖ ម្យ៉ាងទៀត ធ្វើព្រះហស្តទាំងពីរជាកិរិយាចាប់កង់ចក្របង្វិល, ដូចកាលគេធ្វើរូបគ្រឿងប្រកប ជារូបកង់ចក្ររូបម្រឹគនៅព្រៃឥសិបតនមិគទាយវ័ន និងរូបភិក្ខុបញ្ចវគ្គីយ៍ ។ ធ្វើដំណាលកាលព្រះបរមសាស្ដាទ្រង់សំដែងព្រះធម្មចក្រជាបឋមទេសនា ប្រោសបញ្ចវគ្គីយ៍នៅព្រៃឥសិបតនមិគទាយវ័នទាដំបន់នគរពា-រាណសី ។



ព្រះរូបព្រះអង្គម្ចាស់សាវ៉ាងនឹងព្រះអង្គម្ចាស់មុនីរេត នៅកណ្ដាលក្រុំជំនុំព្រះត្រៃបិដក

សេចក្តីកាត់ហេតុ

# ព្រះអង្គម្ចាស់សារ៉ាំងទេតមន្ទីរពុទ្ធសាសនបណ្ឌិត្យ

នៅថ្ងៃ ៥ មេ ១៩៣៥

នឹង

# លាពុទ្ធសាសនបណ្ឌិត្យទៅវិញ

នៅថ្ងៃ ២១ មេ ១៩៣៥

## ព្រះអង្គម្ចាស់សាវ៉ាងទតមន្ទីរពុទ្ធសាសនបណ្ឌិត្យ

នៅថ្ងៃ ១៥ ខែម៉េ ឆ្នាំ ១៩៣៥

នឹង

## លាពុទ្ធសាសនបណ្ឌិត្យទៅវិញ

នៅថ្ងៃ ២១ ខែម៉េ ឆ្នាំ ១៩៣៥

ក្នុងឱកាសបុណ្យសម្ពោធព្រះពុទ្ធរូបសិលា នៅទីក្រុងម-ហានគរ នៅថ្ងៃ ១៧ ខែម៉េឆ្នាំ ១៩៣៥ នោះរាជការប្រតិកត្ងរាត់បានថ្វាយដំណឹងទៅព្រះចៅស៊ីស្វាងវង្ស ព្រះចៅក្រុងហ្លួងព្រះបាង សុំអញ្ជើញព្រះអង្គម្ចាស់សាវ៉ាង ជាព្រះរាជឱរសវជ្ជទាយាទ ឲ្យស្តេចយាងមកក្រសាលផង ដោយភាវៈជាមិត្រមេត្រីនឹងគ្នា ។

កាលនៅថ្ងៃ១៥ម៉េ វេលាម៉ោង១១ព្រឹក ព្រះអង្គម្ចាស់សាវ៉ាងមួយអន្លើដោយព្រះអនុជ ២ អង្គគឺ ព្រះអង្គម្ចាស់ខាំផាន់១ ព្រះអង្គម្ចាស់សុពណ៌វង្ស១ ស្តេចយាងមកពីព្រៃនគរដល់ផ្ទះលោកឡឺរេស៊ីដង់ស៊ុបេរីយើរ នៅក្រុងភ្នំពេញ ដោយព្រះទីនាំងរថយន្តព្រះរាជទ្រព្យ មានលោកអ្នកឧកញ៉ា ស្រី-ធម្មាធិរាជ ជាអ្នកនាំស្តេច ។

វេលានោះរាជការព្រះករុណាបានឲ្យព្រះអង្គម្ចាស់អធិបតី១ សម្តេចចៅហ្វ៊ាវាំង១ ព្រះមហាពិទូរ១; រាជការប្រូតិកតូរាត់ បានចាត់ឲ្យលោកដេឡេគេអមរាជការខ្មែរ ទៅទទួលស្តេចនៅផ្ទះលោកឡឺរេស៊ីដង់ស៊ុបេរិយើរ ។ ដល់ម៉ោងប៉ុណ្ណោះក៏ស្តេចយាងមកដល់ ទ្រង់បដិសណ្ឋារទៅវិញទៅមកល្មមសមគួរ ហើយ ព្រះអង្គម្ចាស់អធិបតីមួយអន្លើដោយអស់លោកដែលអញ្ជើញទៅទទួលក៏ថ្វាយគំនាប់លាមកវិញ ។

## ទតពុទ្ធសាសនបណ្ឌិត្យ

វេលារសៀលម៉ោង៤កន្លះ ស្តេចយាងមកទតមន្ទីរពុទ្ធសាសនបណ្ឌិត្យនិងព្រះរាជបណ្ណាល័យ ជាមួយនឹងព្រះអនុជ ២អង្គ ។ គ្រានោះ មានអ្នករាជការទាំងខ្មែរទាំងបារាំង្ស នឹងគណព្រះសង្ឃ គឺ ព្រះអង្គម្ចាស់អធិបតី (សម្តេចក្រុមព្រះវរចក្ររណរិទ្ធិមិនបានស្តេចយាងមក ដោយទ្រង់ប្រឈួន) នឹងអស់លោកកុង្ស៊ុយសេនាបតី គឺ សម្តេចចៅហ្វាវាំងវរៈវៀងជ័យអធិបតី, ក្រុមហ្លួងសីសុវត្ថិសុភាណុវង្ស ទីចក្រី, លោកអ្នកឧកញ៉ាអគ្គមហាសេនា, ក្រុមយុនវិសុទ្ធិខត្តិយវង្ស, លោក

អ្នកឧកញ៉ា យោមរាជ ជាដើម ។ អ្នករាជការបារាំង មានលោកដេទ្បេគេ នឹងលោកឡំបែរ ជាដើម ។ គណៈព្រះសង្ឃមានក្រុមពុទ្ធសាសនបណ្ឌិត្យ នឹងសាលាបាឡី មានលោកគ្រូព្រះសិរីសម្មតិវង្ស លោកគ្រូព្រះមហាព្រហ្មមុនី លោកគ្រូព្រះឧត្តមមុនី លោកគ្រូព្រះសាសនសោភណ លោកគ្រូព្រះវិសុទ្ធិវង្សជាដើម នឹងអ្នករាជការក្រុមព្រះរាជបណ្ណាល័យ បានមកជួបជុំព្រមចាំទទួលគួរសម ។

ដល់វេលាជួបមានខាងលើ ព្រះអង្គម្ចាស់សារ៉ាំងស្តេចយាងមកដល់ ។ ព្រះសោភណភាសិត នឹងព្រះមហាពិទូរចុះទៅទទួលអញ្ជើញស្តេចចូលក្នុងព្រះរាជបណ្ណាល័យ ព្រះអង្គម្ចាស់អធិបតី នឹងអស់លោកសេនាបតី មន្ត្រីទាំងពួងដែលប្រជុំនៅទីនោះ ក៏ទទួលបដិសណ្ឋារតាមសមគួរហើយក៏អញ្ជើញស្តេចឲ្យគង់ព្រះទីនាំងកៅអីដែលរៀបចំថ្វាយនៅទីបន្ទប់ធំ ។

គ្រានោះ សម្តេចចៅហ្វ៊ាវាំង ។ ក្រោកឡើងទូលថ្លែងថាៈ រាជការព្រះករុណា នឹងរាជការប្រតិកត្វរាត់ បានទ្រង់ជ្រាបនឹងបានជ្រាបដំណឹងថា ទ្រង់ព្រះករុណាស្តេចយាងមក

ឋានមន្ទីរពុទ្ធសាសនបណ្ឌិត្យ និងព្រះរាជបណ្ណាល័យក្នុងគ្រានេះ ក៏មានសេចក្ដីសោមនស្សនឹងទទួលទ្រង់ ទើបចាត់ឲ្យបណ្ដាខ្ញុំរាជការទាំងអស់គ្នានេះ មកទទួលរាជបដិសណ្ឋារដោយសេចក្ដីដែលទ្រង់រាប់អានស្មោះបំពោះពីព្រះរាជហឫទ័យ ។ ១ ទៀតក្នុងឱកាសដែលទ្រង់យាងមកឋានប្រទេសកម្ពុជានេះ យើងខ្ញុំទាំងអស់គ្នាសូមថ្វាយព្រះពរជ័យ ឲ្យទ្រង់គង់នៅជាសុខក្សេមក្សាន្តសម្រាន្តព្រះហឫទ័យគ្រប់តិរិយាបថ ដរាបដល់ស្ដេចត្រឡប់ក្រុងហ្លួងព្រះបាងវិញ ។

លំដាប់នោះព្រះអង្គម្ចាស់សាវ៉ាងក្រោកឡើងថ្លែងព្រះសុន្ទរកថាតបថា ខ្ញុំមានសេចក្ដីសោមនស្សអំណរព្រះតេជព្រះគុណរាជការព្រះករុណានឹងរាជការប្រតិកត្ត្វរាត់ ដែលមេត្តាប្រោសរៀបចំទទួលខ្ញុំ ដោយឋានៈដ៏គួរសម នឹងអំណរគុណគណៈព្រះសង្ឃគ្រប់អង្គដែលនិមន្តមកសន្និបាតក្នុងទីនេះជាទីបំផុត ។ ហេតុដែលឲ្យខ្ញុំមកដល់ទីនេះ ក៏ដោយគុណបុណ្យរាជការប្រតិកត្ត្វរាត់ នឹងរាជការព្រះករុណាព្រះចៅក្រុងកម្ពុជាធិបតីមេត្តាប្រោសរាប់អានអញ្ជើញឲ្យមក ខ្ញុំនេះបើនិយាយតាមព្រះ

រាជពង្សាវតារវិញ ឃើញថា ប្រទេសកម្ពុជានឹងលាវធ្លាប់ជាមិត្រមេត្រីនឹងគ្នាមក តាំងអំពីបូរាណកាលមកហើយ ដូចមានប្រាកដក្នុងគម្ពីរចាមទេវីវង្ស ពង្សាវតារក្រុងហរិភុញ្ជ័យដែលជាក្រុងចាស់១កន្លែងរបស់ជាតិលាវ និយាយថា ក្នុងសម័យនោះព្រះមហាក្សត្រក្រុងហរិភុញ្ជ័យបានចាត់រាជបម្រើឲ្យទៅដណ្ដឹងព្រះរាជធីតាក្សត្រក្រុងកម្ពុជា សិងតាំងក្រុងនៅស្រុកលវោ (ឥឡូវនេះហៅ លពបូរី) ទៅធ្វើជាអគ្គមហេសី ព្រះនាងចាមទេវីនេះប្រាកដក្នុងព្រះរាជពង្សាវតារថាជាអ្នកមានសតិបញ្ញាហើយជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងមុតមាំ បាននាំព្រះពុទ្ធសាសនាអំពីប្រទេសកម្ពុជាទៅផ្សាយក្នុងក្រុងហរិភុញ្ជ័យ ព្រះនាងបានសាងព្រះវិហារអារាម ព្រះពុទ្ធរូប ព្រះស្តូបចេតីយ៍ជាច្រើនណាស់ណា វេលានេះបាក់បែកអស់ហើយ នៅសល់កេរ្តិ៍ដំណែលបន្តិចបន្តួច ល្មមជាគ្រឿងសំគាល់បាន ដោយហេតុជាប់ក្រសែលោហិត ទំងធ្លាប់ជាមិត្រមេត្រីមកតាំងអំពីសម័យព្រេងនាយ ដូច្នេះខ្ញុំទើបចាំបានមិនភ្លេច ហើយខ្ញុំស្មានថាព្រះមហាក្សត្រក្រុងកម្ពុជា នឹងប្រជារាស្ត្រទាំងឡាយ ក៏គង់

ថាបានជួបគ្នានេះ ខ្ញុំមានសេចក្ដីរីករាយបំផុតនឹងមកកាន់ប្រទេសនេះ ស្មើហាក់បីជួបទៅកាន់បងប្អូនដែលស្និទ្ធ ព្រោះប្រទេសទាំងពីរនេះធ្លាប់ជាសម្ពន្ធមេត្រីជួបពោលហើយ ទាំងរាជការប្រតិកត្តរាគ៌ បារាំងសែសនេះសោត ក៏ជាប្រតិកត្តរាគ៌អាណាព្យាបាលប្រទេសសារជួបគ្នា ។

សេចក្ដីបំណងរបស់ខ្ញុំដែលមកកាន់ប្រទេសនេះ ក៏ដើម្បីពិនិត្យមើលកិច្ចការព្រះពុទ្ធសាសនា គឺការជំរះនឹងប្រែព្រះត្រៃបិដករបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ, នឹងការបោះពុម្ពផ្សាយរបស់ព្រះរាជបណ្ណាល័យ, ការសិក្សាវិជ្ជាបាលីរបស់សាលាបាឡី ។ កាលមកដល់ទីនេះហើយខ្ញុំបានក្រឡេកគយគន់មើលទៅកិច្ចការទាំងនោះ ឃើញសុទ្ធតែបម្រើនគួរសមហើយខ្ញុំទើបមានសេចក្ដីអំណរនឹងគណៈសង្ឃដែលមានសេចក្ដីព្យាយាមធ្វើកិច្ចដែលកម្រអំបាលនេះ ឲ្យកើតមានឡើងឲ្យងាយស្រួលនឹងសិក្សាបដិបត្តិ រាប់ថាបានធ្វើប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុតដល់ជាតិខ្មែរ ។

អស់សេចក្ដីតែប៉ុណ្ណោះ

ទ្រង់លាពុទ្ធសាសនបណ្ឌិត្យទៅវិញ

នៅថ្ងៃ ២១ ខែម៉េ ឆ្នាំ ១៩៣៥

ព្រះអង្គម្ចាស់សារ៉ាំងនឹងព្រះអនុជ ២ អង្គ មកគង់នៅក្នុងប្រទេសកម្ពុជានេះ ១ អាទិត្យ ថ្ងៃ ២២ ខែម៉េឆ្នាំ ១៩៣៥ ជាថ្ងៃដែលត្រឡប់ទៅក្រុងហ្លួងព្រះបាងវិញ មុននឹងស្ដេចត្រឡប់គឺនៅថ្ងៃ ២១ ម៉េ វេលាម៉ោង ៥ ល្ងាច ស្ដេចមកលាពុទ្ធសាសនបណ្ឌិត្យ ជួបជុំដោយព្រះសង្ឃក្រុមជំនុំប្រែព្រះត្រៃបិដក នឹងអ្នករាជការព្រះរាជបណ្ណាល័យទទួលស្ដេច គ្រានោះទ្រង់យកប្រើវេមដៃឈ្មោះថា ឆាងឆ្មើកឡាន គឺមេដៃដំរីសមួយលានមកប្រទានដល់អ្នកដែលមានសគុណបំណាច់ក្នុងព្រះពុទ្ធសាសនា គឺប្រគេនដល់លោកគ្រូព្រះឧត្ដមមុនី អ៊ុំ-សូរ អធិបតីរងក្រុមជំនុំប្រែព្រះត្រៃបិដក ១ លោកគ្រូព្រះមហាព្រហ្មមុនី អ៊ូ អធិបតីរងក្រុមជំនុំប្រែព្រះត្រៃបិដក ១ នឹងប្រទានដល់ព្រះសោភ័ណភាសិត ជួន-ណុត អ្នកប្រែភាសានៅព្រះរាជបណ្ណាល័យ ១ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ១ ៗ ក្រៅអំពីនេះ ទ្រង់ប្រគេនលោកគ្រូ ព្រះ

ធម្មលក្ខណញាណ វត្តពោធិវាល ខេត្តបាត់ដំបង ១ លោកគ្រូសាក្យបុត្រ (ខ្លិម) មេគណ នៅវត្តពោធិអណ្ដែត ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ១ លោកមេគណ វត្តក្របេះ ខេត្តក្របេះ ១ និងប្រទានដល់លោកយ៉ាញ់-សួន ចៅហ្វាយស្រុកទ្រីតុងខេត្តមាត់ជ្រូក ១ ។

ស្រេចហើយទ្រង់ប្រាយបង្គំលាព្រះសង្ឃក្រុមជំនុំប្រែព្រះត្រៃបិដក និងលាអ្នករាជការក្រុមព្រះរាជបណ្ណាល័យត្រឡប់ទៅវិញ ។



នេះព្រះរូបព្រះអង្គម្ចាស់សាវ៉ាង នឹងរូបលោករេស៊ីដងត៍ កំពង់ឆ្នាំង ។

បុណ្យសម្ពោធឆ្លងសាលាធាឡីរង

# នៅវត្តសំបួរមាស ឃុំជើងគ្រៀវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

**នៅថ្ងៃ ២១ ខែមេ ឆ្នាំ១៩៣៥**

### បុណ្យសម្ពោធឆ្លងសាលាបាឡីរង

## នៅវត្តសំបួរមាស ឃុំជើងក្រៀវ ស្រុករលាប្អៀរ ខេត្រកំពង់ឆ្នាំង

នៅថ្ងៃ ២១ ខែមេ ឆ្នាំ ១៩៣៥

គណៈវត្តសំបួរមាស បានសាងសាលាបាឡីរង ១ នៅក្នុងទីវត្តនោះ ដល់មកថ្ងៃ ២១ ខែមេឆ្នាំ ១៩៣៥ នេះ ជាថ្ងៃដែលត្រូវធ្វើបុណ្យសម្ពោធឆ្លង ជួបជុំព្រះសង្ឃនឹងឧបាសកឧបាសិកានឹងអ្នកមុខអ្នកការ ឯទៀតជាច្រើននាក់ គឺលោកឡេរេស៊ីដង់ត៍នឹងលោកចៅហ្វាយខេត្រ កំពង់ឆ្នាំង លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ នឹងព្រះអង្គម្ចាស់សារ៉ាង នឹងព្រះអនុជ ២ អង្គ ជាព្រះរាជបុត្រព្រះចៅស៊ីស្វាងវង្ស ព្រះចៅក្រុងហ្លួងព្រះបាង នឹងលោកគ្រូព្រះសាសនសោភ័ណ លោកគ្រូព្រះវិសុទ្ធិ-វង្សជាដើម បានស្ដេចយាងទៅ នឹងអញ្ជើញទៅជាកិត្តិយសក្នុងការសម្ពោធនេះ គ្រានោះអាចារ្យ ជាអាចារ្យវត្តនោះបានសូត្រសុន្ទរកថាជាភាសាខ្មែរថា សូមក្រាបប្រតិបត្តិ លោកឡេរេស៊ីដង់ត៍ នឹងលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ សូមពិត ព្រះតេជព្រះគុណគ្រប់អង្គ សូមជំរាបអស់លោកនឹងអស់អ្នកទាំងឡាយ ។

ក្នុងឱកាសនេះ យើងខ្ញុំទាំងអស់គ្នាជាឧបាសក-ឧបាសិកាបំណុះវិត្តសំបួរមាសនេះ មានសេចក្តីត្រេកអរដោយក្រៃលែងបំពោះលោកទាំងឡាយ ដែលបានអញ្ជើញមកជាអធិបតីនិងជាមង្គលក្នុងឱកាសបុណ្យនេះ យើងខ្ញុំសូមថ្លែងសេចក្តីដោយសង្ខេបអំពីកិច្ចការដែលជាប់ទាក់ទងដល់ព្រះពុទ្ធសាសនាក្នុងទីនេះ ជំរាបជូនដល់អស់លោកទាំងឡាយ ។

ក្នុងទីស្រុកនេះ ប្រមាណជាង ២០ ឆ្នាំកន្លងទៅហើយ យើងខ្ញុំទាំងអស់គ្នាអ្នកកាន់ព្រះពុទ្ធសាសនា មានសេចក្តីលំបាកពេកណាស់ ក្នុងការស្វែងរកផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនា យកមកប្រតិបត្តិឲ្យត្រឹមត្រូវតាមច្បាប់ជាគោលក្នុងព្រះត្រៃបិដក ព្រោះក្នុងសម័យនោះរាជការពុំទាន់បានទំនុកបំរុងកិច្ចការក្នុងព្រះពុទ្ធសាសនាដោយពេញទីនៅឡើយ ម្ល៉ោះហើយអ្នករៀនសូត្រចេះដឹងផ្លូវខាងព្រះពុទ្ធសាសនាក៏មានតិចសៀវភៅធម៌អាថ៌ដែលប្រែចេញពីព្រះត្រៃបិដកក៏ពុំសូវមាន ។

តាំងពីដួបរាជការព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងរាជការប្រតិកត្ថូរាត់បានបង្កើតឲ្យមានសាលាបាឡីជាន់ខ្ពស់ ១

នៅក្រុងភ្នំពេញពីឆ្នាំ ១៩២៥ រហូតដល់មករាជការគួរសរសើរ-ម៉ងយ៉ុណោវ៉ាល់ បានព្រមព្រៀងជាមួយនឹងរាជការព្រះករុណាជាម្ចាស់ជីវិតលើត្បូង បានបង្កើតឲ្យមានក្រសួងពុទ្ធសាសន-បណ្ឌិត្យមួយឡើងទៀតពីថ្ងៃ ២៥ ឃាំងវីយេរ ១៩៣០ ដើម្បីនឹងទំនុកបំរុងខាងកិច្ចនៃព្រះពុទ្ធសាសនា ឲ្យបានចំរើននឹងឲ្យបានតាំងនៅដោយការមាំមួនតទៅ ព្រមទាំងបានបង្កើតឲ្យមានក្រុមជំនុំប្រែព្រះត្រៃបិដកក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យថែមទៀត ដើម្បីនឹងបើកផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ដែលបិទដោយភាសាបាឡី ឲ្យបានភ្លឺស្វាងច្បាស់ប្រាកដដល់អ្នកដែលមិនបានចេះភាសាបាឡីគ្រប់គ្នាទៅបាន ។

តាំងពីដូចសាលាបាឡីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យព្រមទាំងពុទ្ធសាសនបណ្ឌិត្យកើតឡើងនៅស្រុកខ្មែរនេះ យើងខ្ញុំទាំងអស់គ្នាក៏បានទូលាយក្នុងការស្វែងរកផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ក៏មានសេចក្ដីភ្លឺស្វាងរុងរឿងដោយប្រើនដោយបានអាស្រ័យនឹងលោកអ្នកចេះដឹងដែលចេញពីសាលាបាឡីជាន់ខ្ពស់ លោកទេស្នាពន្យល់ឲ្យស្គាល់ការខុសត្រូវគ្រប់យ៉ាង

នឹងដោយបានអាស្រ័យ នឹងសៀវភៅធម៌អាថ៌ដែលបោះពុម្ពផ្សាយចេញពីព្រះរាជបណ្ណាល័យ, សាលាបាឡីនឹងពុទ្ធសាសនបណ្ឌិត្យ ។

លុះតមកទៀត រាជការព្រះករុណាជាម្ចាស់ជីវិត បានព្រមព្រៀងជាមួយនឹងរាជការប្រតិកេត្តូរាត់ បានបង្កើតឲ្យមានសាលាបាឡីរងនៅខេត្តក្រៅ ដោយព្រះរាជប្រកាសលេខ ៤៨ ចុះថ្ងៃ ៤ អាវរិល ១៩៣៣ យើងខ្ញុំទាំងអស់គ្នាក៏រឹងរឹតតែមានសេចក្ដីត្រេកអរថែមឡើងទៀត មានបំណងនឹងសាងសាលាបាឡី និមន្តលោកអាចារ្យឲ្យមកបង្ហាត់បង្រៀនក្នុងទីវត្តនេះ តែពេលនោះស្រុកធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃសេចក្ដីក្រីក្រ ពុំអាចនឹងបាត់បែងធ្វើកើត តែសេចក្ដីប្រាថ្នាពុំហោយរលត់បាត់ទៅវិញ ។

លុះមកដល់ឆ្នាំនេះ យើងខ្ញុំទាំងអស់គ្នាបានផ្ដើមសាងសាលាបាឡីនេះ ដោយបូលធនធានបន្តិចម្នាក់ ៗ រួបរួមគ្នា តែពុំបានគ្រប់គ្រាន់ដល់កិច្ចកសាងនេះឡើយ តែដែលបានធ្វើស្រេចប៉ុណ្ណោះ ដោយឧបាសក (សន) ជាមេឃុំចាស់ ព្រមទាំងភរិយា

មានសទ្ធាក្លាហានបានបំណាយប្រាក់ចំនួន (៤០) រៀលសាងរហូតដល់ហើយស្រេច លុះស្រេចហើយ លោកគ្រូចៅអធិការព្រមទាំងយើងខ្ញុំទាំងអស់គ្នា បានធ្វើសេចក្ដីប្រតិបត្តិប្ដឹងទៅលោកចៅហ្វាយខេត្ត ។ លោកក៏បានយកបិត្តទុកដាក់ដោយមេត្តាជួយប្ដឹងលោកឡឺរេស៊ីដង់ជាអធិបតីក្នុងខេត្ត លោកឡឺរេស៊ីដង់ក៏បានបញ្ជូនទៅរាជការធំ សូមឲ្យបាត់លោកអាចារ្យមួយអង្គមកបង្ហាត់បង្រៀន រាជការធំក៏បានអនុញ្ញាតឲ្យលោកអាចារ្យ ម៉ម-តេង ដែលមានសញ្ញាបត្រពីសាលាបាឡីជាន់ខ្ពស់មកធ្វើជាអាចារ្យបង្ហាត់បង្រៀនក្នុងសាលានេះតាមសេចក្ដីសុំ ។

ឥឡូវពេលនេះ ជាពេលមង្គលសួស្ដី កំណត់ថាជាពេលសម្ពោធឆ្លងសាលា នឹងបើកសាលាបាឡីឲ្យរៀនតទៅ ។

យើងខ្ញុំទាំងអស់គ្នា មានសេចក្ដីត្រេកអរដ៏ពន្លឹកនឹងសេចក្ដីអរគុណរាប់ពុំបាន បំពោះអស់លោកទាំងឡាយ មានលោកឡឺរេស៊ីដង់នឹងលោកអគ្គលេខាធិការជាដើម ដែលបានអញ្ជើញមកក្នុងទីសន្និបាតនេះ ដើម្បីជាមង្គលជាកិត្តិយស ក្នុងឱកាសបុណ្យនេះ ។

ម្យ៉ាងទៀតយើងខ្ញុំមានសេចក្ដីសង្ឃឹមថា សាលាបាឡី ក្នុងវត្តយើងនេះដោយអំណាចសេចក្ដីទំនុកបម្រុងរបស់លោកឡឺ វេស៊ីដង់ត៍ និងលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងលោកចៅហ្វាយខេត្ត លោកចៅហ្វាយស្រុកនឹងបាន បំរើនរុងរឿងឥតអាក់ឥតទៅពុំខានឡើយ ។

ទីបំផុតនេះ យើងសូមឧទ្ទិស្សផលដែលកើតឡើងអំពី ការបុណ្យនេះ ថ្វាយដល់ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ជូន ដល់រាជការប្រូតិកត្វរាត់បារាំងសែស លោកឡឺវេស៊ីដង់ត៍នឹង លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ និងអស់លោក អ្នកទាំងឡាយក្នុងទីសន្និបាតនេះសូមឲ្យបានសេចក្ដីសុខ និង សេចក្ដីចំរើនគ្រប់ប្រការអស់កាលជាអង្វែងតទៅ ។

លុះចប់សុន្ទរកថាហើយ លោកឡឺវេស៊ីដង់ត៍ បានក្រោក ឡើងមានប្រសាសន៍តបសុន្ទរកថាលោកអាចារ្យថា លោកមាន សេចក្ដីអំណរជាយ៉ាងក្រៃពេក ក្នុងការដែលគណសង្ឃបរិស័ទ្យ និងគណឧបាសកឧបាសិកា មានសទ្ធាជ្រះថ្លាចាត់ការបង្កើតឲ្យ មានសាលាបាឡីរង ១ ខ្នងនៅទីវត្តនេះ ដើម្បីឲ្យភិក្ខុសាមណេរ

អ្នកត្រូវការរៀនសូត្រ នឹងបានរៀនសូត្រដោយស្រួល ហើយលោកមានប្រសាសន៍ថា ពីថ្ងៃនេះទៅមុខ បើគណៈអ្នកទំនុកបម្រុងត្រូវការអ្វីៗ ដែលជាការឬជារបស់សម្រាប់ទំនុកបម្រុងសាលាបាលីនេះ គប្បីចូលទៅជំរាបប្តឹងដល់លោក កុំឲ្យកោតញញើត បើមិនជាការហួសវិស័យទេ លោកនឹងទទួលបាត់ការឲ្យ ។

ចប់ប្រសាសន៍ហើយ ព្រះសង្ឃក៏សូត្រជយន្តោ ។

លំដាប់នោះព្រះអង្គម្ចាស់សាវ៉ាំងទ្រង់មានព្រះបន្ទូលចំពោះនឹងព្រះភិក្ខុសង្ឃអំពាលនោះថា ទ្រង់មានព្រះហឫទ័យសោមនស្សពន់ពេកណាស់ ដែលទ្រង់មានព្រះដំណើរមកក្រុងកម្ពុជាហើយបានមកប្រទះជួបនឹងការដែលទំនុកបម្រុងព្រះពុទ្ធសាសនាដូច្នេះ ជាកិច្ចដែលត្រូវព្រះហឫទ័យទ្រង់ជាបំផុត ទ្រង់នឹងរំលឹកចាំជាប់ទុកជានិច្ចដោយមិនបានភ្លាំងភ្លេចទៅវិញទេ ។

រួចទ្រង់ប្រគេនសញ្ញាបត្រ ១ សន្លឹក ដល់លោកគ្រូព្រះសាក្យបុត្រ (ខ្លឹម) មេគណនៅវត្តពោធិអណ្តែតស្រុកកំពង់សែង ទ្រង់មានបន្ទូលថា របស់នេះមិនមែនជាគ្រឿងឥស្សរិយយសទេ

គឺជាភ័ស្តុតាងអំពីព្រះករុណាព្រះបាទសម្តេចព្រះចៅ ស៊ីស្វាងវង្ស ព្រះចៅក្រុងហ្លួងព្រះបាង ទ្រង់ផ្ញើមកប្រគេនដោយទ្រង់ជ្រាបថា លោកគ្រូម្ចាស់នេះ ជាអ្នកយកព្រះទ័យទុកដាក់ប្រឹងប្រែងប្រដៅភិក្ខុសាមណេរ នឹងឧបាសកឧបាសិកាឲ្យរៀនសូត្រនឹងប្រព្រឹត្តប្រតិបត្តិតាមធម្មវិន័យ ជាដំបូងតាំងពីរាជការផ្តើមបាត់បែងរៀបចំគណសង្ឃឲ្យរៀបរយឡើងនោះ ។

រួចទ្រង់ប្រគេនបែកប្រទានរូបព្រះចេតីយ៍វិសួន (របស់លាវ) ដល់ព្រះសង្ឃនឹងគ្រហស្ថក្មេងចាស់ទាំងឡាយបំនួនជាង ១០០០ នាក់ ។ កាលប្រទានរូបហើយ ព្រះអង្គម្ចាស់ទាំង ៣ អង្គ នឹងលោកឡឺវេស៊ីដឹងត៍លោកស្រីអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានយាងទៅនឹងអញ្ជើញទៅទត-មើលពិពិធភណ្ឌស្ថាន គឺកន្លែងដាក់របស់បូរាណ រួចហើយក៏ថតព្រះរូបព្រះអង្គម្ចាស់ នឹងលោកឡឺវេស៊ីដឹងត៍ នឹងភិក្ខុសង្ឃជាច្រើនអង្គនៅខាងមុខសាលាបាឡីរងនោះ ។

ស្រេចពិធីតែប៉ុណ្ណោះ ៕

# រឿងព្រេងខ្មែរ

## ១ — រឿង បុរស ៣ នាក់មានឈ្មោះពុំប្រាកដ

ទី ១ ចេះជក់អាភៀន

ទី ២ " កញ្ឆា

ទី ៣ " ផឹកស្រា

អ្នកនេះសុទ្ធតែកូនអ្នកមាន អាពុកម្ដាយជេរវាយប្រដៅរៀងខ្លួនពីការជក់នឹងផឹកមិនស្ដាប់ បុរសទាំងនេះទ្រាំទ្រនឹងការទរមានប្រដៅមេបាពុំបាន ៗ លាអាពុកម្ដាយរៀងខ្លួនហើយម្នាក់ ៗ សុំប្រាក់អាពុកម្ដាយ ៣ ណែន ៗ ម្នាក់ អ្នក ៣ នាក់ក៏យកប្រាក់នោះទៅទិញស្រា-អាភៀន-កញ្ឆា តាមបំណង់រៀងខ្លួនអស់ ១ ណែនម្នាក់ហើយក៏ធ្វើដំណើរទៅ. លុះដល់ទៅសាលា ១ ឈ្មោះទាំង ៣ នាក់បានជួបជុំគ្នាហើយសួរគ្នាតាមដម្មើរឈ្មោះទាំង ៣ នាក់ត្រូវចិត្តគ្នាក៏យកគ្នាធ្វើមិត្រសំឡាញ់រួបផឹកជក់ក្នុងពេលយប់នោះ លុះព្រឹកឡើងនាំគ្នាដើរទៅទៀតដល់ទៅភូមិ ១ បានឃើញសេះ ១ យ៉ាងល្អក៏នាំគ្នាមើលហើយជំនុំគ្នាថា យើងទិញវៃបែកគ្នាជិះផ្លាស់គ្នាម្ដងម្នាក់សោះពីបាក

ដើរ បុរសទាំង ៣ នាក់ព្រមចិត្តគ្នាវិញ សួរដល់ម្ចាស់សេះថា ថ្លៃប៉ុន្មាន ម្ចាស់សេះប្រាប់ថា ថ្លៃ ៦ ណែន ក៏ឲ្យ ៦ ណែន ដល់បានសេះនោះមករាល់ពេលយប់ផ្លាស់គ្នាយាមរក្សាសេះនោះ ម្តងម្នាក់ៈ

អ្នកយាមទី ១ រក្សាពីពេលល្ងាច

អ្នកយាមទី ២ រក្សាពេលអាធ្រាត

អ្នកយាមទី ៣ រក្សាពេលរៀបភ្លឺ

អ្នកប្រមឹក់យាមដល់ទៅស្រវឹងស្រាយ៉ាងខ្លាំងក៏ពោលនូវពាក្យវាចាឡេវឡាអួតអាងថា បើមានអាចោរលួចសេះអញចូលមកពីខាងលិច - កើត - ត្បូង - ជើងអញវាយផាក់ទាត់ឲ្យល្អិតឲ្យស្គាល់ដៃអញ បុរសនោះក៏លើកដៃជើងបែបគុនដាល់ សេះនោះក៏ផ្អើលដាច់ទៅ រកតាមវាប់ពុំបានរួចត្រឡប់មកវិញស្រែកយ៉ាងខ្លាំងប្រាប់បុរសទាំងពីរនាក់ថា ដ្បិតអាចោរលួចសេះយើងទៅហើយ អញស្គាល់មុខអាចោរច្បាស់ ក៏លើកគ្នាទៅតាម មាន ១ ថ្ងៃនោះមហាក្សត្រិយ៍ក្នុងនគរនោះ បាត់ប្រើនាម៉ឺនធំម្នាក់ ងារជាយោមរាជឲ្យមកត្រួតត្រានគរ ជួបនឹងបុរសទាំង

បីនាក់ បុរសដែលប្រមឹកនោះក្រឡេកឃើញលោកយោមរាជក៏ប្រកាន់ថា អ្នកឯងហ្នឹងហើយលួចសេះអញ ពីយប់មិញលមិញ យោមរាជខឹងគិតវាយជាក់ បុរសទាំង ៣ នាក់ក៏រត់ទៅទូលស្ដេច ៗ មានព្រះរាជឱង្ការប្រាប់បុរសទាំង ៣ នាក់ថា បើរកទៅឃើញថា ឯងពោះខុសត្រូវធ្វើទោសដល់ជីវិត បើទាយត្រូវឲ្យធ្វើយោមរាជហើយដាក់ឲ្យតុលាការពីសោត្យដូច្នេះ ស្ដេចឲ្យយកគ្រាប់ឪឡឹកចំនួនប្រហែលជា ៤ ឬ ៥ គ្រាប់ ដាក់ក្នុងប្រអប់ ១ រួចត្រាស់បង្គាប់ហៅបុរសទាំង ៣ នាក់មកសួរថា របស់អ្វីក្នុងហិបនេះ បុរសទាំង ៣ នាក់ ក៏លើកប្រអប់នោះមកអង្រួនមើលស្ដាប់សំឡេងឮស្សូររឹក ៗ អ្នកប្រមឹកតឿនទៅអ្នកអាភៀន ៗ តឿនទៅអ្នកកញ្ឆាថា ទាយទៅ ៗ ចាំអីទៀត បើវាឮរឹក ៗ ជាគ្រាប់ឪឡឹកហើយ ៗ បុរសទាំង ៣ នាក់ ក៏ប្រជុំយទូលស្ដេចថា ក្នុងប្រអប់នេះគ្រាប់ឪឡឹក ដល់បើកទៅគ្រាប់ឪឡឹកមែន ស្ដេចឲ្យហូតងាលោកយោមរាជនោះទៅ រួចតាំងបុរសទាំង ៣ នាក់ឲ្យធ្វើជាយោមរាជ ១ ថ្ងៃម្នាក់ ។

រឿងនេះចប់តែប៉ុណ្ណោះហើយ

# បញ្ជីរឿង

ទំព័រ

១— សេចក្ដីសរសើរគុណលោកល្វី-ហ្វីណូត . . . . . . . . . . . . . . . . ៤៣

២— សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម រៀបរៀង (ត) . . . . . . . . . ៥៩

៣— រឿងស្ដេចឧទយនៈ ដកយកពីសេចក្ដីល្បង អំពីគុណាឍ្យនឹងព្រឹហត្កថា របស់
លោកហ្វេលិក្ស៍ឡាកូត ក្រម្ការដុំ-មៅ ប្រែចេញពីភាសាបារាំងសែស
មកជាភាសាខ្មែរ (ត) . . . . . . . . . . . . . . . . . . . ៦៥

៤— សេចក្ដីកត់ហេតុរឿងប្រជុំជាកិត្តិយសនៅទីក្រុងវែត្រមាត់ដ្រិក . . . . . . . ៧៣

៥— រឿងព្រេងខ្មែរដែលមិនទាន់ចេញផ្សាយ គឺរឿងខ្លាឃ្មុំនឹងដើមពង្រ . . . . . ៧៩

## រូបថត

ព្រះរូបព្រះអង្គម្ចាស់សាវ៉ាង នឹងរូបលោកដេឡូតេនៅទីក្រុងវែត្រមាត់ដ្រិក. ៧១

រូបលោកល្វី-ហ្វីណូត តាំងធ្វើបុណ្យឧទ្ទិសកុសលដល់លោក នៅព្រះរាជ-
បណ្ណាល័យ . . . . . . . . . . . . . . . . . . . . ៥១

# TABLE DES MATIÈRES


Pages

I. Cérémonie de transmission de mérite à la mémoire de Louis-Finot. . . . . . . . . . . . . . . . . . . . . . . . . . . . . . . 47

II. Sāssanapravatti ou l'Histoire des Religions par Préas Maha Pitou Krasém pandit, à la Bibliothèque Royale (suite). . . 59

III. La légende d'Udayana, extraite de l'Essai sur Gunadhya et la Brhatkathā par F. Lacôte traduit par Krommokar Choum-Mau. (suite). . . . . . . . . . . . . . . . . . . . . . . . . . . . . 65

IV. Cérémonie de transmission de décoration du mérite du million d'Éléphants blancs du Laos à M. le Délégué administrateur de Triton (Chaûdoc) . . . . . . . . . . . . . . . . . . . . 73

V. Contes populaires cambodgiens inédits:
L'ours et l'arbre Pongro . . . . . . . . . . . . . . . . . . . . . . . . 79


## ILLUSTRATIONS:


I. S. A. R. le Prince Savang ayant à son côté M. le Délégué de Triton. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 71

II. Portrait de Louis Finot sur l'autel de la cérémonie de transmission de mérite à sa mémoire à la Bibliothèque Royale . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 51

# សេចក្ដីសរសើរគុណលោក ល្វី-ហ្វីណូត៍

## ឧទ្ទិស្សកុសលជូនលោកល្វី-ហ្វីណូត៍

កាលនៅថ្ងៃ ៤ ខែយូវាំង ឆ្នាំ ១៩៣៥ វេលារសៀល ក្រុមព្រះរាជបណ្ណាល័យ នឹងពួកលោកគ្រូសាលាបាឡីបាន រៀបចំបង្សុកូល ឧទ្ទិស្សកុសលជូនទៅលោកល្វី-ហ្វីណូត៍នៅទី ព្រះរាជបណ្ណាល័យ ដែលស្លាប់នៅក្រុងបារីសដោយរោគជរា កាលនៅថ្ងៃ ២០ ម៉េ ឆ្នាំ ១៩៣៥ ។

ក្នុងឱកាសនេះមានអ្នករាជការទាំងបារាំងទាំងខ្មែរអញ្ជើញ មកជាច្រើនគ្នា គឺខាងបារាំងមានលោកឱុសសេ សែហ្មុកាបិណេ នឹងលោកមុងតូរ៉ានីជាដើម បំណែកឯខាងខ្មែរ មានសម្តេច ចៅហ្វាវាំង នឹងលោកអគ្គមហាសេនា ជាដើម ។

វេលានោះ ក្រុមព្រះរាជបណ្ណាល័យបានរៀបតាំងរូបថត របស់លោកលើតុក ១ កណ្តាលព្រះរាជបណ្ណាល័យ ហើយប្រ-ដាប់ដោយផ្កាកម្រងផ្កាភ្លូងស្រស់ជាច្រើន ។ ដល់វេលាក៏និមន្ត ព្រះសង្ឃក្នុងសិស្សសាលាបាឡី ទាំងអស់ចំនួនជាង ១០០ អង្គមកបង្សុកូល ។

អំពីកិត្តិគុណរបស់ល្វី-ហ្វីណូត៍ដូចម្តេច ដូចមានតទៅនេះ ។



នេះរូបលោក ល្វី-ហ្វីណូត៍

## សេចក្ដីសរសើរគុណរបស់លោក ល្វី-ហ្វីណូត

លោក ល្វី-ហ្វីណូត ជាអាចារ្យបង្រៀនឧត្ដមវិជ្ជានៅសាលាជាន់ខ្ពស់ក្នុងស្រុកបារាំង ក្រុងបារីស ហើយធ្វើជាចាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស លោកជាអ្នកប្រាជ្ញធំ ១ ក្នុងបណ្ដាពួកអ្នកប្រាជ្ញក្នុងប្រទេសអឺរ៉ុប ។

លោកមានបំណេះចេះដឹងគម្ពីរដីកាខាងព្រះពុទ្ធសាសនាក្នុងពួកហីនយានជាភាសាបាឡី នឹងគម្ពីរដីកាខាងព្រះពុទ្ធ-សាសនាក្នុងពួកមហាយានជាភាសាសំស្ក្រឹត ។

លោកបានអញ្ជើញមកធ្វើការក្នុងប្រទេសអាំងដូស៊ីនតាំងពីឆ្នាំ ១៨៩៨ ដរាបដល់ឆ្នាំ ១៩៣០ ទើបលោកអញ្ជើញទៅស្រុកបារាំងលែងត្រឡប់មកវិញ ដោយលោកកាន់តែមានវ័យចំរើនឡើងលុះក្នុងអំណាចជរាធម៌ ដល់មកឥឡូវនេះលោកទទួលមរណភាពដោយអំណាចរោគសម្រាប់សង្ខាររបស់លោកក្នុងថ្ងៃ ២០ ខែមេ ឆ្នាំ ១៩៣៥ នេះក្នុងជន្មាយុគំរប់... ឆ្នាំ ។

យើងតាំងពីបានដឹងថាលោក ល្វី-ហ្វីណូត ទទួលមរណ-ភាពហើយសឹងមានសេចក្ដីស្ដាយលោក រកអ្វីប្រៀបពុំបាន

ដោយយើងបានដឹងច្បាស់ថាលោក ល្វី-ហ្វីណូត៍ដែលលោកមកធ្វើការក្នុងប្រទេសអាំងដូស៊ីន លោកបានធ្វើឲ្យកើតប្រយោជន៍ដល់ពពួកជនក្នុងប្រទេសអាំងដូស៊ីនដោយច្រើនណាស់។ យើងសូមថ្លែងដោយសង្ខេបចំពោះកិច្ចការ ដែលលោក ល្វី-ហ្វីណូត៍ធ្វើឲ្យមានប្រយោជន៍ចំពោះមកក្នុងក្រុងកម្ពុជាដូចសេចក្ដីតទៅនេះ:

លោកបានពិនិត្យមើលសិលាចារិក គឺអក្សរខ្មែរបូរាណដែលគេឆ្លាក់ជាប់នឹងថ្មដែលគេបោះបង់ចោលជាយូរអង្វែងឆ្នាំ ហើយជាភាសាសំស្ក្រឹតខ្លះ ភាសាខ្មែរបូរាណខ្លះ ក្រុងបូរាណស្ថានច្រើនកន្លែងលោកបានប្រឹងធៀបរៀបផ្សំផ្សំមើលទាល់តែបានដឹងសេចក្ដីច្បាស់លាស់ថា ក្រុងកម្ពុជានេះ កាលពីក្នុងពុទ្ធសករាជប៉ុណ្ណោះជនជាតិខ្មែរកាន់សាសនាអ្វីខ្លះ ក្នុងជាន់ណាកាន់សាសនាណា ក៏អាចដឹងដោយច្បាស់លាស់ ។

លោកមានចិត្តសប្បុរសជួយទំនុកបំរុងព្រះពុទ្ធសាសនាដូចក្នុងសាលាបាឡីជាន់ខ្ពស់នៅទីក្រុងភ្នំពេញសព្វថ្ងៃនេះ កាលដែលលោកធ្វើការក្នុងប្រទេសអាំងដូស៊ីននៅឡើយ លោកបាន

ជាវព្រះត្រៃបិដកពីប្រទេសអឺរ៉ុបយកមកដំកល់ទុកជាសម្បត្តិក្នុងសាលាបាលី មិនតែប៉ុណ្ណោះលោកជួយសង្គ្រោះទទួលបង្ហាត់បង្រៀនភាសាសំស្ក្រឹតដល់លោកពីរអង្គ គឺលោកព្រះសាសនសោភណ ណាត និងលោកព្រះវិសុទ្ធិវង្ស គាត ដែលរាជការប្រូតិកតូរ៉ាត់បញ្ជូនទៅឲ្យរៀនក្នុងសំណាក់លោក នៅសាលាបារាំងសែស ក្រុងហាណូយ ពីឆ្នាំ ១៩២២-២៣ លោកខំឈ្លៀតពេលបង្រៀនឲ្យបានបេះភាសាសំស្ក្រឹត និងរឿងរ៉ាវព្រះពុទ្ធសាសនា ដែលបែកលទ្ធិជាមហាយាន-ហីនយាន ក្នុងស្រុកឥណ្ឌា និងព្រះពុទ្ធសាសនាដែលផ្សាយចូលទៅក្នុងប្រទេសផ្សេង ៗ មានប្រទេសចិនជាដើមព្រមទាំងផែនទីក្នុងស្រុកឥណ្ឌាក្នុងពុទ្ធសម័យ ដើម្បីឲ្យបានបំណោះទាំងអស់នេះមកផ្សាយក្នុងក្រុងកម្ពុជា ។

ឯប្រយោជន៍ដែលលោកបានធ្វើចំពោះមកលើព្រះពុទ្ធសាសនាជាច្រើនប្រការណាស់ ខ្ញុំនឹងរៀបរាប់ពុំអស់ ខ្ញុំសូមថ្លែងបញ្ចប់សេចក្តី ឲ្យឃើញអំពីសេចក្តីសប្បុរសលោកក្នុងទីបំផុតខាងក្រោយ គឺក្នុងពេលដែលលោករៀបនឹងអញ្ជើញត្រឡប់ទៅ

ស្រុកបារាំងវិញ លោកបានមកលាក្រុមជំនុំព្រះរាជបណ្ណាល័យ មានសម្តេចចៅហ្វាវាំងវរវៀងជ័យជាដើម ព្រមទាំងព្រះសង្ឃ ក្នុងសាលាបាឡីទាំងអស់ នៅថ្ងៃ ១៨ ខែឃាំងវីយេរឆ្នាំ ១៩៣០ វេលាម៉ោង ៤ រសៀល នៅវេលាមុននឹងលាលោកបានមាន ប្រសាសន៍ជាពាក្យឧត្តម គួរឲ្យចង់ស្តាប់ណាស់ លោកមាន ប្រសាសន៍ថា លោកធ្វើការក្នុងប្រទេសអាំងឌូស៊ីនប្រមាណ ៣០ ឆ្នាំមកហើយ លោកបានមកធ្វើការក្នុងក្រុងកម្ពុជានេះជា រាល់ឆ្នាំ បានពិនិត្យតាមពង្សាវតារ និងសិលាចារិកគ្រប់អន្លើ ឃើញថាក្រុងកម្ពុជានេះមិនមែនជាស្រុកថយថោកទេ ជាស្រុក ឧត្តមប្រសើរណាស់ គឺស្រុកសម្បូណ៌ដោយអ្នកចេះដឹងច្រើន មានសួភាពរាបសាល្អច្រើន គ្រាន់បើជាងប្រទេសឯទៀត ៗ តែគមកស្រុកខ្មែរត្រឡប់ទៅជាថយថោកពុំប្រសើរដូចជាន់ដើម ដោយអ្នកស្រុកមានចិត្តគំនិតមិនរួបរួមគ្នាផង មិនចេះសង្គ្រោះ និងទំនុកបំរុងដល់អ្នកដែលចេះដឹងផង ។

ក៏ឥឡូវនេះ ក្រុងកម្ពុជាឃើញដុះសេចក្តីចំរើនឡើងវិញ ហើយ គឺសាលាបាឡីនិងព្រះរាជបណ្ណាល័យនេះឯងហើយដែល

ជាកន្លែងសម្រាប់បណ្ដុះបំណោះវិជ្ជាខាងព្រះពុទ្ធសាសនា នាំឲ្យកើតមានប្រាជ្ញាភ្លឺស្វាង នាំឲ្យកើតមានសុភាពរាបសារល្អឡើង សាលាបាឡីនឹងព្រះរាជបណ្ណាល័យនេះ ទុកដូចថ្លើមប្រមាត់ឬបេះដូងរបស់ជនជាតិខ្មែរ អស់លោកទាំងឡាយគួរតាំងចិត្តជួយឧបត្ថម្ភឲ្យបានសាលាបាឡី នឹងព្រះរាជបណ្ណាល័យនេះចំរើនឡើង ។ ល ។

លោកមានប្រសាសន៍ចំពោះទៅក្រុមជំនុំព្រះរាជបណ្ណាល័យរួចហើយលោកងាកមកមានប្រសាសន៍ចំពោះនឹងអស់ព្រះសង្ឃគ្រប់អង្គថា អស់លោកទាំងឡាយសុទ្ធតែជាកល្យាណមិត្តរបស់ខ្ញុំ ខ្ញុំសូមលាលោកគ្រប់អង្គហើយ ពេលនេះជាបច្ឆិមទស្សនគឺពេលដែលខ្ញុំបានជួបបាននិយាយខាងក្រោយបំផុតត្រឹមម្តងនេះហើយ ៗ លោកនិយាយរំលឹកថា សូមលោកគ្រប់អង្គយកព្រះទ័យទុកដាក់ក្នុងការបង្ហាត់បង្រៀនច្បាប់ព្រះពុទ្ធសាសនាឲ្យបានចំរើនឡើង សូមកុំឲ្យប្រហែសធ្វេស សូមលោកកុំភ្លេច ព្រះពុទ្ធដីកាព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គរៀបនឹងបរិនិព្វាន ព្រះអង្គបានផ្តាំភិក្ខុទាំងឡាយថា អាមន្តយាមិ ភោ

ភិក្ខវេ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ម្នាលភិក្ខុទាំងឡាយ តថាគតហៅអ្នករាល់គ្នាមកប្រាប់មករំលឹកកុំឲ្យភ្លេចសង្ខារទាំងឡាយ មានសេចក្ដីអស់ទៅនឹងវិនាសទៅជាធម្មតា អ្នកទាំងឡាយកុំប្រមាទកុំធ្វេសប្រហែសឡើយ ត្រូវប្រុងប្រយ័ត្នរាល់ៗគ្នា ។

លោក ល្វី ហ្វីណូត៍ លោកបានមានប្រសាសន៍ប៉ុណ្ណេះហើយទើបលោកក៏លាត្រឡប់ទៅវិញ ។ ប្រសាសន៍របស់លោកទាំងអស់នេះ ល្មមយកមកធ្វើឲ្យឃើញជាគ្រឿងភស្តុតាងរបស់ចិត្ត នឹងអធ្យាស្រ័យរបស់លោកដែលមានបំណងចង់ឲ្យព្រះពុទ្ធសាសនាក្នុងស្រុកខ្មែរនេះបានចំរើនលឿនទៅមុខ ។

# សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម រៀបរៀង

(គ)

៥ គ្រាវរមុទ្រ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែនក៏មានឈរក៏មាន បើជារូបគង់ពត់ព្រះភ្នែន ធ្វើព្រះហស្តស្តាំលាតផ្កាគង់លើព្រះជង្ឃខាងស្តាំ តែហុចបេញទៅមុខបន្តិច ជាកិរិយាទទួលត្រង់ ព្រះហស្តឆ្វេងប្រត់ផ្កាប់លើព្រះជង្ឃឆ្វេង បើជារូបឈរ ធ្វើព្រះហស្តស្តាំហុចផ្កាបេញទៅមុខ ជាកិរិយាទទួលត្រង់ដូចមុន ព្រះហស្តឆ្វេងសំយោកស្មៀមតាមធម្មតា ។ ធ្វើដំណាលកាលព្រះសាស្តាលាតព្រះហស្តផ្កាឲ្យទានបតីប្រិបទឹកទក្ខិណោទកដាក់លើបាតព្រះហស្តតាមទំនៀមស្រុកទេស ក្នុងកាលដែលគេថ្វាយវត្ថុណាគឺមួយ ដូចយ៉ាងកាលព្រះបាទពិម្ពិសារថ្វាយសួនវេឡុវនជាពុទ្ធវិហារជាដើម កាលទ្រង់ទទួលដោយអាការយ៉ាងនេះហើយ ក៏ទ្រង់អនុមោទនាប្រទានពរតាមសមគួរ ។

៦ គ្រាវិតកិមុទ្រ ធ្វើជាព្រះពុទ្ធរូបឈរ ព្រះហស្តទាំងពីរឱបព្រះឱរា ជាកិរិយារំពឹង ។ ធ្វើដំណាលកាលព្រះសាស្តាគង់នៅវេឡុវនវិហារទ្រង់ព្រះឈួនធ្ងន់ ទាល់តែព្រះឥន្ទ្រមកបំរើព្រះវល័ញ្ឆ ក្រោយនោះទ្រង់បំរើនព្រះឥទ្ធិបាទធម៌ទាំង ៤ ទៅ

ព្រះភោគក៏រម្ងាប់បង់ ។ (តាមព្រះពុទ្ធរូបបែបចាស់ដែលពួកផណ្ដៀលើសាងឡើង ឃើញមានប្រើពាក្យថា មុទ្រ ប្រកបខាងចុងតាមតែត្រឹម ៦ គ្រាប៉ុណ្ណោះ ពាក្យនេះជាភាសាសំស្ក្រឹតប្រែថា ម្រាមដៃ ដោយអធិប្បាយថា មានម្រាមដៃជាគ្រឿងសំគាល់ ត្រូវនឹងពាក្យមគធថា មុទ្ធសញ្ញា វេលាប្រកបប្ចូលនឹងសព្ទដទៃ គាប្បីប្រែអនុរូបទៅតាមសព្ទនោះផង ដូចយ៉ាងពាក្យថា ភូមិស្បូសមុទ្រ ប្រែថា មានម្រាមដៃចង្អុលទៅផែនដីដូច្នេះជាតួយ៉ាង ។

៧ គ្រាលេលា ឬហៅគ្រាយាងយាស ធ្វើជាព្រះពុទ្ធរូបឈានព្រះបាទយាង គឺឈានព្រះបាទខាងស្ដាំមុន បង្ហើបកែងព្រះបាទខាងឆ្វេងបន្តិច ព្រះហស្តធ្វើជាកិរិយាបង្ហោយ ជួនកាលគេធ្វើជាលើកព្រះហស្តស្ដាំបែបរា បង្ហោយតែព្រះហស្តឆ្វេង ។ ធ្វើដំណាលកាលព្រះសាស្ដាស្ដេចយាងទៅក្រុងកបិលពស្តុជាដំបូង ដោយនិមន្តនកិច្ចនៃព្រះពុទ្ធបិតា ដែលត្រាស់ប្រើកាឡុទាយីអាមាត្យឲ្យមកនិមន្ត ។

៨ គ្រាឱបបាត្រ ធ្វើជាព្រះពុទ្ធរូបឈរព្រះហស្ដទាំងពីរទ្រង់ឱបបាត្រតាមបែបឥណ្ឌៀ ធ្វើជាគង់ពត់ព្រះភ្នែនឱបបាត្រក៏មាន ៗ ធ្វើដំណាលកាលព្រះសាស្ដាស្ដេចយាងទៅក្រុងកបិលពស្ដុជាដំបូង ដោយព្រះពុទ្ធបិតាត្រាស់ប្រើការឡូទាយីអាមាត្យឲ្យមកនិមន្ត កាលស្ដេចដល់ក្រុងកបិលពស្ដុហើយ ក៏ទ្រង់ឱបបាត្រគោចរបិណ្ឌបាតតាមដំណាក់ព្រះរាជវង្សានុវង្សរៀង ៗ ទៅដរាបដល់ដំណាក់ព្រះពុទ្ធបិតា ៗ ទតឃើញត្រាស់ឃាត់ថា កុំធ្វើដូច្នេះ ខុសរាជប្រវេណី, ព្រះរាជវង្សរបស់យើងមិនដែលមានអ្នកណា ១ ធ្វើយ៉ាងនេះ ព្រះសាស្ដាត្រាស់តបថា មហារាជកុំឃាត់ តថាគតធ្វើតាមអរិយវង្សទេ ។

៩ គ្រាមហាប្រាដិហារ្យ ឬយមកប្រាដិហារ្យ តាមដែលគេធ្វើមានច្រើនយ៉ាង យ៉ាងទី ១ ធ្វើជាព្រះពុទ្ធរូបច្រើនអង្គជារូបអង្គុយខ្លះ ឈរខ្លះ ផ្ទំខ្លះ បង្ក្រមខ្លះ ក្នុងផែនជាមួយគ្នាជួនកាលមានទាំងរូបតិរច្ឆានជាគ្រឿងប្រកបផង យ៉ាងទី ២ ធ្វើជាព្រះពុទ្ធរូបគង់លើផ្កាឈូកទន្ទឹមគ្នា ៣ អង្គ ធ្វើព្រះហស្ដយ៉ាងគ្រាបក្រមុទ្រ, យ៉ាងទី ៣ ធ្វើជាព្រះពុទ្ធរូបឈរក៏មាន

អង្គុយក៏មាន តែធ្វើព្រះហស្តច្រើនបែបដូចរូបព្រះនារាយណ៍បែងភាគ ទាល់តែអ្នកខ្លះហៅ ព្រះបែងភាគ យ៉ាងក្រោយនេះមាននៅសាលារចនាក្រុងភ្នំពេញ ។ ធ្វើដំណាលកាលព្រះសាស្តាទ្រង់ធ្វើប្រាដិហារ្យផ្ចាញ់តិរត្ថីយ៍នៅនគរសាវត្ថី ។

# រឿងស្ដេចឧទយន (គ)

# រឿងស្ដេចឧទយន (គ)

រឿងរ៉ាវព្រះបាទឧទយន ជារឿងដែលគេដឹងស្គាល់ក្នុងជាន់នោះទូទៅដោយប្រាកដ ។ យើងបានឃើញក្នុងជាតកលេខ ៤០៩ មានពោលដល់កាលដែលនាំបំរត់នាងវាសុលទត្តាដូចជាដែលមានសម្តែងក្នុងអដ្ឋកថាព្រះធម្មបទដូច្នោះដែរ ហើយសេចក្តីដែលស្រង់មកពោលនេះ លុះតែអ្នកដែលធ្លាប់មើលរឿងរ៉ាវព្រះបាទឧទេនដោយសព្វគ្រប់ទើបយល់បាន ។ ជីវិញឈ្មោះភទ្ទវតិកា ចូលមករកព្រះសម្មាសម្ពុទ្ធក្នុងឃោសិតារាមហើយពោលជូញជូរអំពីស្តេចឧទេនជាចៅហ្វាយថា កាលពីដើមស្តេចបែរក្បាលយ៉ាងប្តិតប្ដឹមកោតខ្លាច ហើយនិយាយថាៈ ឯងមានគុណលើអញធ្ងន់ណាស់ ជីវិតអញ នគរអញ នឹងប្រពន្ធអញ អញជំពាក់ឯង; លុះឥឡូវនេះស្តេចមិនយកព្រះទ័យទុកដាក់ ដោយខ្ញុំចាស់មិនបានការអ្វី ។ ព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅឯព្រះបាទឧទេន ហើយទ្រង់មានព្រះបន្ទូលសួរថា ភទ្ទវតិកាទៅណាទៅ ក្នុងវេលានោះព្រះបាទឧទេនទ្រង់ទូលតបវិញថាមិនដឹង ទើបព្រះបរមសម្មាសម្ពុទ្ធទ្រង់ត្មាស់អំពីសេចក្តីរមឹលគុណ

តាំងពីនោះមកព្រះបាទឧទេនតាំងបាត់ការបៃរក្សា ដំរីភទ្ទវតិកាដូចកាលអំពីដើមវិញ ។

បំណែកព្រះធម្មបទដែលជាភាសាចិន ដែលលោក ស-បាល បានប្រែពីភាសាចិនមក នោះក្នុងភាគទី ៣៣ មានសម្ដែងថា ព្រះបាទឧទយនជាស្ដេចកាន់ធម៌អាចឹ ។ ភាគដែលពោលនេះគឺត្រង់រឿងនាងស្យាមាវតី នឹងនាងអនុបមា តែជាសេចក្ដីប្រតកាត់ខ្លីរៀបចំឲ្យខុសអំពីច្បាប់ដើមយ៉ាងឆ្ងាយមក ។ សុំឲ្យពិចារណាមើលចុះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្រុងកោសម្ពី ក្នុងព្រះវិហារឈ្មោះមី-យិន (គឺឃោសិតារាម) ទ្រង់សម្ដែងធម៌ទេសនាប្រោសមនុស្សនឹងទេវតា ។ ក្នុងសម័យនោះស្ដេចដែលសោយរាជ្យនគរកោសម្ពីទ្រង់ព្រះនាមឧទយន ហើយព្រះអគ្គមហេសីប្រកបដោយសីលបរិសុទ្ធ (គឺនាងស្យាមាវតី) ។ នូវវេលាដែលបានដំណឹងថា ព្រះសម្មាសម្ពុទ្ធយាងចូលមកក្នុងនគរព្រះមហាក្សត្រ ព្រះអគ្គទេវីក៏យាងទៅស្ដាប់ធម៌ទេសនាមួយអន្លើដោយព្រះស្នំទាំងអស់ ហើយក៏លុះជឿច្បាស់ក្នុងគុណ

ព្រះរតនត្រ័យ ។ ក្នុងពេលនោះមានព្រាហ្មណ៍ម្នាក់មានកូនក្រមុំ ១ មានរូបឆោមល្អប្រពៃរកផ្ទឹមគ្មាន (ពាក្យត្រង់នេះគឺជាសេចក្តីប្រែអំពីឈ្មោះអនុបមា)មក ។ លុះឃើញលំអនៃព្រះសម្មាសម្ពុទ្ធជាទីគាប់ចិត្ត ក៏យកបុត្រីទៅថ្វាយ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកែក ។ ព្រាហ្មណ៍ខឹងក៏យកទៅថ្វាយព្រះបាទឧទយន ៗ ទ្រង់ទទួលយក ហើយដំកល់ឡើងជាព្រះឧបហេសីទី ២ ។ នាងនេះកើតសេចក្តីប្រណែនព្យាបាទដល់ព្រះមហេសីទី ១ ហើយគិតរកឧបាយនឹងបំផ្លាញ ក្នុងថ្ងៃ ១ វេលាដែលព្រះមហេសីទី ១ កំពុងជាប់កិច្ចក្នុងការជាផ្សព្វព្រះពុទ្ធសាសនាដែលលះបោះបង់មិនបាន នោះនាងធ្វើឧបាយដើម្បីឲ្យស្តេចត្រាស់ហៅ តែព្រះនាងមិនព្រមយាងមកតាមព្រះបន្ទូល ។ ព្រះបាទឧទេនទ្រង់ព្រះក្រោធ ហើយទ្រង់ត្រាស់ឲ្យនាំខ្លួនព្រះនាងមកបំពោះព្រះភ័ក្ត្រ ហើយទ្រង់យកធ្នូមកប្រុងនឹងបាញ់ ឯព្រួញនោះវេលាដែលបាញ់ទៅក៏ត្រឡប់មករកព្រះមហាក្សត្រវិញ ក្នុងវេលានោះស្តេចទ្រង់ត្រាស់សួរនេះជាអានុភាពអ្វី ព្រះនាងក្រាបទូលថា គឺខ្ញុំម្ចាស់ដល់នូវព្រះត្រៃរតនៈជាទីពឹង ។ ព្រះបាទឧទេនទ្រង់

បណ្ដោញព្រះមហេសីទី ២ ឲ្យទៅនៅនឹងអាពុកម្ដាយវិញ ហើយព្រះអង្គស្ដេចទៅរកព្រះសម្មាសម្ពុទ្ធ ហើយក៏បានលុះជឿក្នុងព្រះពុទ្ធសាសនា ។



នេះព្រះរូបព្រះអង្គម្ចាស់សាវ៉ាំង នឹងរូបលោក
ឡឺដើរឡេគេ ទ្រីគុង

# ការប្រជុំជាកិត្តិយស

## នៅស្រុកទ្រីតុង ខែត្រមាត់ជ្រូក

នៅថ្ងៃ ២២ ខែមេុ ឆ្នាំ ១៩៧៥

## ការប្រជុំជាកិត្តិយស
## នៅស្រុកទ្រីតុង ខេត្តមាត់ជ្រូក

នៅថ្ងៃ ២២ ខែមេ ឆ្នាំ ១៩៣៥

នៅថ្ងៃ៥រោចខែពិសាខ ឆ្នាំកុរសប្តស័ក ព.ស. ២៤៧៨ ត្រូវនឹងថ្ងៃ២២ខែមេ ឆ្នាំ១៩៣៥ មានការប្រជុំជាកិត្តិយស នៅវត្តស្វាយទង ស្រុកទ្រីតុង ខេត្តមាត់ជ្រូក ដោយព្រះក-រុណាជាអម្ចាស់ជីវិតលើត្បូង ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់ជ្រាបថា លោកយ៉ាញ់-ស្ងួន ចៅហ្វាយស្រុកទ្រីតុង ជាអ្នកយកចិត្តទុកដាក់ទំនុកបម្រុងព្រះពុទ្ធសាសនាក្នុងស្រុកនោះ ឲ្យបានបំ-រើនរុងរឿង គួរឲ្យកើតសេចក្ដីជ្រះថ្លា ទើបទ្រង់ព្រះមេត្តាប្រោសព្រះរាជទានគ្រឿងឥស្សរិយយសអស្សរិទ្ធិក្រុងកម្ពុជា (ស៊េវ៉ាលីយេរ) ។ នៅថ្ងៃដូចមានខាងលើនេះលោកស្រីអគ្គលេខាធិ-ការនៃពុទ្ធសាសនបណ្ឌិត្យទទួលគ្រឿងឥស្សរិយយសនោះនឹងប្រើរៀយកទៅប្រគល់ឲ្យលោកយ៉ាញ់-ស្ងួន ។ ក្នុងឱកាសប្រជុំបំពាក់គ្រឿងឥស្សរិយយសនេះ ព្រះអង្គម្ចាស់សាវ៉ាង ព្រះរាជ-ឱរសព្រះចៅក្រុងហ្លួងព្រះបាងនឹងព្រះអនុជ ២ អង្គ នឹងលោក

ឡាតមីនិស្ត្រាទ័រ មាត់ជ្រូក បណ្ដូលស្ដេចយាងទៅនឹងអញ្ជើញទៅជាកិត្តិយសផង ។ វេលារសៀលម៉ោង ៤ ជួបជុំព្រមទាំងព្រះសង្ឃទាំងគ្រហស្ថចំនួនប្រមាណ ៣០០ នាក់ ។

គ្រានោះលោកឡាតមីនិស្ត្រាទ័រយកគ្រឿងឥស្សរិយយសទៅបំពាក់ឲ្យលោកចៅហ្វាយយ៉ាញ់-សួន ជាគ្រឿងសំគាល់ក្នុងការដែលមន្ត្រីនេះយកចិត្តទុកដាក់ទំនុកបម្រុងព្រះពុទ្ធសាសនាដោយមាំមួន សឹងគួរទុកជាគំរូយ៉ាងដល់មន្ត្រីទាំងឡាយអ្នកកាន់កាប់ការផែនដីក្នុងដំបន់ស្រុកនីមួយ ៗ គប្បីឈ្មោលជ្រោមជ្រែងព្រះសាសនាឲ្យបានរុងរឿង ព្រោះព្រះពុទ្ធសាសនានេះជាបណ្ដាលចិត្តរបស់ខ្មែរយើង គួរហើយតែពួកយើងគប្បីប្រឹងប្រែងទំនុកបម្រុងឲ្យជារបស់បរិសុទ្ធ កុំឲ្យមួហ្មងដោយទោសមន្ទិលឡើយ ។

លំដាប់នោះ ព្រះអង្គម្ចាស់ សារ៉ាំង ទ្រង់យកប្រីវេគ្រឿងឥស្សរិយយសឈ្មោះ "ដំរីសមួយលាន" ប្រទានដល់លោកចៅហ្វាយយ៉ាញ់-សួន ហើយទ្រង់មានបន្ទូលថា ប្រីវេគ្រឿងឥស្សរិយយសនេះ ព្រះករុណាព្រះចៅក្រុងហ្លួងព្រះបាង

ទ្រង់ព្រះមេត្តាប្រោសឲ្យយកមកប្រទានទុកជាទីរលឹក ដោយទ្រង់ជ្រាបថា លោកចៅហ្វាយជាអ្នកសប្បុរសយកចិត្តទុកដាក់ទំនុកបម្រុងព្រះពុទ្ធសាសនាឲ្យរុងរឿងក្នុងព្រះនគរ ។

លោកចៅហ្វាយយ៉ាញ់-សួន ក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីសោមនស្សត្រេកអរនឹងព្រះមហាករុណាធិគុណព្រះករុណាព្រះចៅក្រុងហ្លួងព្រះបាង នឹងទ្រង់ព្រះករុណាវិសេសដែលទ្រង់ព្រះមេត្តាប្រោសរាប់អាន ហើយនឹងប្រទានគ្រឿងឥស្សរិយយសជាសំគាល់ កាលណាទ្រង់ព្រះករុណាស្ដេចត្រឡប់ដល់ក្រុងហ្លួងព្រះបាងវិញហើយ សូមទ្រង់ព្រះមេត្តាយកសេចក្ដីណា ១ ដ៏សមគួរ ក្រាបបង្គំទូលព្រះករុណាអង្គនោះឲ្យទ្រង់ជ្រាបក្រោមល្អងធុលីព្រះបាទថា ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីអំណរព្រះមហាករុណាធិគុណជាបំផុត សូមឲ្យទ្រង់ព្រះបំរើនសព្វទិវាភាត្រី ។

ស្រេចហើយព្រះសង្ឃសូត្រជយន្តោ ថ្វាយព្រះពរដល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះចៅក្រុងកម្ពុជាធិបតីនឹងព្រះករុណាព្រះចៅក្រុងហ្លួងព្រះបាងជាដើម ។ រូបព្រះអង្គ

ម្ចាស់សារ៉ាំងទ្រង់បែកប្រទានរូបព្រះចេតីយ៍វិសុទ្ធ ដល់ព្រះសង្ឃ
និងគ្រហស្ថទាំងឡាយ បណ្ដាដែលទៅប្រជុំនៅទីនោះ ។

ប៉ុណ្ណោះជាសួរចេតិធីប្រជុំហើយ ។

## រឿងខ្លាឃ្មុំនឹងដើមជ្រៃ

មានសម័យថ្ងៃ ១ ស្ដេចខ្លាឃ្មុំ ១ អផ្សុកក្នុងខ្លួនចង់ចេញពីទីបន្ទំទៅលេងព្រៃស្មសានស្មានស្ងាត់ឆ្ងាយ ដល់ចេញត្រេចទៅបាន ១ ថ្ងៃអស់កំឡាំងក៏ដេកនៅក្រោមដើមជ្រៃ ១ ដើម្បីសម្រាកកំឡាំង ប៉ុន្តែនៅចុងជ្រៃនោះមានកូនក្មេងម្នាក់ជាអ្នកគង្វាលគោ-ក្របី តែងតែនឹងស្នាក់នៅចុងជ្រៃនោះរាល់វេលា ។

មាន ១ ថ្ងៃពេលព្រះសុរិយាជ្រេទេទាបទៅកូនក្មេងនោះបង់ចុះពីចុងជ្រៃដើរទៅរកប្រមូលគោក្របីមកផ្ទះ វេលានោះស្រាប់តែឃើញស្ដេចខ្លាឃ្មុំ ១ យ៉ាងធំនៅដេកក្រោមម្លប់ជ្រៃនោះ កូនក្មេងខ្លាចស្ដេចខ្លាមិនហ៊ានចុះពីចុងជ្រៃក៏កាច់មែកទំលាក់មកលើខ្លាឃ្មុំ ៗ នោះត្រូវនឹងមែកជ្រៃជាទម្ងន់ក៏ក្រោកដើរទៅទៀតមិនរួចនឹកខឹងនឹងដើមជ្រៃនោះខ្លាំងណាស់ថា យើអើអាដើមឈើនេះពេញហៅកាប ឯងគ្រាន់តែមកជ្រកដេកសំរាកកំឡាំង

១ ពេលវាវាយឯងត្រូវជាទំងន់រកនឹងទៅទៀតពុំរួបផង ខ្លា ឃ្មុំគិតក្នុងចិត្តតែប៉ុណ្ណោះទឹងខ្លាំងក៏ទំស្មុះក្រោកទៅទាំដើមពង្រ ហើយស្លាប់ទៅ ។

ហេតុមានរឿងព្រេងនិទានយ៉ាងនេះ បានជាសត្វខ្លាឃ្មុំ ស្អប់ដើមពង្រលុះដល់មកសព្វថ្ងៃនេះ ។

រឿងនេះចប់តែប៉ុណ្ណោះ

មានថ្ងៃ ១ សត្វព្រាបតាំងចាប់ជំងឺឈឺជាទំងន់ ហើយចេះតែស្រែកថ្ងូ សត្វទីទុយជាអ្នកស្មុំភិតភ័យខ្លាំងក៏ខំប្រឹងបន់គ្រូអារក្ខទេព្រាក្ខឲ្យព្រាប ប៉ុន្តែជម្ងឺចេះតែរឹតខ្លាំង ១ ថ្ងៃបន្តិចៗឡើង សត្វគ្រលេងគ្រលោងនិយាយទៅនឹងទីទុយថា យើបងអើយ ជាក៏លៀងមិនជាក៏លៀងទៅ ព្រោះជម្ងឺនេះចេះតែរឹតខ្លាំងឡើង ហើយបានប្រហែលជា ៥-៦ ថ្ងៃព្រាបស្លាប់ទៅ ហើយសត្វឯទៀតក៏ផ្តើលឈ្ងួចឡើង គិតគ្នានឹងយកខ្មោចព្រាបទៅព្រៃ ឲ្យសត្វអាអួតទៅរកទូក មាន់ទឹករកប្រវាថៃរ មាន់រកចប ជល់រកបានប្រដាប់សព្វគ្រប់ហើយរៀបចំនឹងយកខ្មោចព្រាបទៅព្រៃ សត្វទាស្រែកសួរសត្វអាអួតថាៈ "ប្រាក់ ១ បាទទុកឯណា" ប្រាក់ ១ បាទទុកឯណា" ខ្លាគ្រួសប្រាប់ទៅវិញថា ប្រាក់ ១ បាទអញទុកក្នុងគ្រួសនៅចុងជើងដំណោកអញនោះ ។

ហេតុមានរឿងព្រេងនិទានយ៉ាងដូច្នេះ បានជាសត្វទាំងនេះឥឡូវយំឡើងមិនខុសពីរឿងព្រេងនាយមក ។

# បញ្ជីរឿង


ទំព័រ

១— សេចក្ដីក្រាបបង្គំទូលព្រះករុណា សូមសាងវត្តកំពង់នៅខែត្រពោធិសត្វជាថ្មីឡើងវិញ. . . . . . . . . . . . . . . . . . . . . . . ៨៧

២— សម្ពោធឆ្លងសាលាបាឡីរង នៅឃុំគគីធំ ស្រុកកៀនស្វាយ ខែត្រកណ្ដាល. ៩៥

៣— រឿងព្រះពេទខទយន (ត) . . . . . . . . . . . . . . . . . . . ១០៣

៤— សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម រៀបរៀង (ត) . . . . . . . . . ១១១

៥— រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយ គឺរឿងក្អែក ១ ជាក្អែក ១០ ... ១១៩


## រូបថតក្រៅរឿង


ប្រាសាទបៅសាយ ដែលសាងឧទ្ទិស្សដល់សាសនាព្រាហ្មណ៍ នៅក្រៅកំផែងអង្គរធំ. . . . . . . . . . . . . . . . . . . . . . . ៨៥

ប្រាសាទតាសោម-នៅជ្រុងពាយព្យនៃគោបុរ ខាងលិច. . . . . . . . . . ១០១

# TABLE DES MATIÈRES


Pages

I. Discours de M. le Résident de France à Pursat à l'occasion de l'inauguration de la Pagode de Kompang.......... 87

II. L'inauguration de l'École élémentaire de Pâli à Koki Thom kandal.................................. 95

III. La légende d'Udayana (suite)...................... 103

IV. Sasanaprayatti ou l'Histoire des Religions par Préas Maha Pitou Krasém (suite)............................. 111

V. Contes populaires cambodgiens inédits: l'Histoire d'un corbeau qui se décuple ................ 119


## ILLUSTRATIONS:


I. Hors texte: monument brahmanique de Chau-Say...... 85

II. Tasom-Angle Nord Ouest du Gopura Ouest .......... 101



ប្រាសាទចៅសាយ ប្រាសាទនេះនៅក្រៅកំផែងអង្គរធំ ឧទ្ទិស្សដល់ព្រាហ្មណសាសនា
នៅលើប្រាសាទនេះមានក្បាច់យ៉ាងល្អ ៗ ណាស់

សូមក្រាបបង្គំទូលព្រះករុណា សូមទ្រង់ជ្រាប

សូមលោករេស៊ីដង់ត៍ស៊ុប៉េរីយ៉េរ

សូមអស់ លោក / អ្នក ស្រី

សូមអស់ លោក / អ្នក ប្រុស ជ្រាប

ឥឡូវនេះទ្រង់ទតហើយ យើងរាល់គ្នាឃើញវត្តកំប៉ាងកើតឡើង បើយើងនឹងឋាវត្តនេះអន្តរាយបាត់បង់ហើយរស់ឡើងវិញក៏បាន ។

ពីព្រោះនៅទីកន្លែងនេះ ដែលកាលពីដើមប្ដីប្ដើងរុងរឿងសប្បាយ គេបានឃើញហោជាងវត្តចាស់ភ្លឺរន្ទាលប្រាលឆ្ពោះនៅលើដីទួលដដែលនេះ មានភូមិស្រុកដាះច្រើននៅជុំវិញវត្តចាស់ លើដីជិត ៗ នេះដែលមានផលល្អ ។

ប៉ុន្តែកាលពី ១០២ ឆ្នាំមុននេះ មានរាជសេនាសៀមមកដល់បំផ្លាញកំទេចកំទីភូមិអស់ ប្លន់ដណ្ដើមរបស់ទ្រព្យក្នុងវត្តចាស់ ដុតវត្តចោល ហើយចាប់អ្នកស្រុកអ្នកស្រែជាបណ្ដាជនឧស្សាហ៍ធ្វើការស្លូតត្រង់ នាំយកទៅឲ្យនៅឯអាត់ទន្លេម៉ែណាម

អស់ទៅ ទីកន្លែងនេះក៏ធ្លាក់ចុះក្នុងសេចក្ដីក្រីក្រលំបាកហិន ហោចតាំងពីគ្រានោះមក ហើយមានព្រៃផ្សៃដុះក្រាស់ក្រៃល ពាសពេញលើស្រែដែលឥតម្ចាស់ថែទាំរក្សាហើយនៅទីកន្លែង នេះក៏ស្ងាត់ឈឹងសូន្យរៀងរាបដរាបមក ឮតែសូរដំរីព្រៃយំ ម្ដងៗ ។

ស្រុកស្រែទាំងអស់នេះវិនាសអន្តរាយអស់ដូច្នេះហើយមាន វត្តជាច្រើនដែលពួកខ្មាំងសត្រូវបានបំផ្លាញឲ្យខូចខ្ទីដូចវត្តកំ-ប៉ង់នេះដែរ ក្រោយនោះមកគេឃើញនៅមានសល់របស់ខ្លះ ដួនកាលសីមានៅទីកន្លែងដដែល ដួនកាលដីខ្ពស់ប៉ោងបន្តិច ដួនកាលឥដ្ឋក្បឿងបន្តិចបន្តួចសល់នៅដីឲ្យល្មមសម្គាល់ជាទី កន្លែងវត្តចាស់បុរាណក្នុងស្មសានឋានស្ងាត់នេះ ។

តាមសេចក្ដីសំគាល់នេះ អ្នកស្រុកក៏បានឃើញកន្លែង វត្តចាស់ ៧ នៅតាមមាត់ស្ទឹងស្វាយដូនកែវ ដែលគេទុកជា ព្រំប្រទល់ក្រុងកម្ពុជាធិបតីនឹងនគរសៀមពីយូរអង្វែងណាស់ ហើយ:

គឺ វត្ត កំប៉ាង ១

" វត្ត ឫស្សីគ្រៃ ១

" វត្ត គ្រួស ១

ដែលនៅពីខាងជើងថ្នល់ក្រូឡូនីញ៉ាល់លេខ ១ ពីភ្នំពេញ ទៅបាត់ដំបងៈ

ហើយនឹងវត្ត យាង ១

វត្ត ក្រសាស ១

វត្ត ស្រុង ១

វត្ត ដង្កោរមាស ១

ដែលនៅខាងត្បូងផ្លូវនេះដែរ ។

ក្នុងខែមេ៉ឆ្នាំ ១៩៣៤ ចៅហ្វាយខេត្រពោធិសត្វនឹង ទូលព្រះបង្គំ/ខ្ញុំ បានដើរទៀតខេត្រ ស្រាប់តែមកដល់ជិតដីទួល ដំបូកដែលមានព្រឹក្សាដុះរុំជុំព័ទ្ធបែកមែកសាខានេះ អ្នកស្រុក បានប្រាប់ចៅហ្វាយខេត្រនឹង ទូលព្រះបង្គំ/ខ្ញុំ ថាដីទួលនេះហើយជា ទីវត្តកំប៉ាងចាស់បូរាណ ហើយសូមខ្លួនយកកាំបិតទៅកាប់

ព្រឹក្សានាំហៅហ្វាយខែត្រនឹង ទូលព្រះបង្គំ / ខ្ញុំ មកដល់ទីវត្តកំប៉ុង ចាស់បូរាណនេះ, ទូលព្រះបង្គំ / ខ្ញុំ ក៏បានដើរចូលទៅក្រោមប្រក លហាកព្រៃផ្សៃទាបតូចមានដើមផ្តៅដើមបន្លា នឹងដើមវល្លិជុះ ប្រទាក់ស្រែះជាប់គ្នាជាអស្ចារ្យ ហើយយើងខ្ញុំបានទៅដល់ សីមាកិលនៅប្រហារបំកន្លែងព្រះវិហារដែលបាត់បង់ទៅ បាន មើលឃើញទីកន្លែងនេះកាលណាហើយក៏ ទូលព្រះបង្គំ / ខ្ញុំ មានចិត្ត សទ្ធាជ្រះថ្លាប្រាថ្នាចង់កសាងវត្តកំប៉ុងនេះឡើងវិញ ពីព្រោះ វត្តនេះដូចជាប្រផ្នូល ១ យ៉ាងសំខាន់ នាំឲ្យឃើញជាជាក់ស្តែង ថា តែសៀមមកកាលណាស្រុកភូមិនេះស្ងាត់អស់ ដល់វេលា ក្រុងបារាំងសែសមកជួយការពារទំនុកបំរុងក្រុងកម្ពុជា ឲ្យមាន កំឡាំងពលាំងឡើងវិញកាលណាកន្លែងនេះដូចជាប្រស់ឲ្យរួប រស់ជីវិត ហើយប្តីប្តើងក្បេមក្បាគ្គឡើងវិញដែរ ហើយកើត នៅលើទីដីចាស់ដដែល គឺនៅលើកន្លែងដែលអន្តរាយសូន្យអស់ ទៅកាលមុន ។

នៅក្រុងកម្ពុជាវត្តអារាម គឺដូចជាទង់ជ័យឬជាទីប្រជុំ ១ ដែលបណ្ដាជនទាំងឡាយរីករាយស្មោះស្ម័គ្រប្រជុំគ្នា និយាយអំពីធម៌អាថ៌ក្បួនច្បាប់ផ្សេង ៗ ហើយជំនុំការប្រយោជន៍ដល់អ្នកទាំងពួងក្នុងស្រុកផង ឯវត្តនេះយើងបានកសាងសំរាប់ខ្មែរដែលមកអំពីស្រុកបាសាក់ខេត្តព្រះត្រពាំងមកតាំងទីលំនៅ ៗ ទីនេះ ។

នៅក្នុងវាលធំនេះគេធ្លាប់ដាំដំណាំបន្តិចម្ដង ៗ ឡើងវិញ ហើយយូរបន្តិចទៅទៀតនឹងបានច្រូតកាត់ផលាហារនានាបរិបូណ៌ដូចគ្រាពីដើមឡើងវិញ ពួកអ្នកបាសាក់ព្រះត្រពាំងនឹងបានអាស្រ័យទឹកដីខ្យល់អាកាសរបស់ខ្មែរសុទ្ធឡើង នឹងបានជ្រកកោនក្រោមម្លប់គុណបុណ្យព្រះវិហារនេះ ដើម្បីនឹងទុកទំនៀមទំលាប់បូរាណនឹងកិរិយាប្រសើរយ៉ាងសំខាន់របស់ខេមរៈជាតិឲ្យគង់តទៅ ។

ប៉ុន្តែការកសាងវត្តនេះ ក៏បានសំរេចដោយសាព្រះករុណាជាអម្ចាស់ទ្រង់ព្រះមេត្តាប្រោសនឹងពួកឧបាសកឧបាសិកាជួយទំនុកបំរុងជាយ៉ាងម៉ាំមួនណាស់ បើឧបាសកឧបាសិកាទាំង

អស់គ្នាគ្មានសេចក្ដីសទ្ធាជ្រះថ្លានឹងព្រះពុទ្ធសាសនាយ៉ាងមាំមួន ហើយគ្មានសេចក្ដីឧស្សាហ៍ព្យាយាមរួសរាន់ ហើយការធំបំផុត បើព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស ទ្រង់ពុំមេត្តាប្រោសជាមែនទែន ហើយបើទ្រង់មិនបានព្រះរាជទានប្រាក់ព្រះរាជទ្រព្យយ៉ាងក្រាស់ក្រែល ឲ្យល្មមប្រើការបានដូចសេចក្ដីប្រាថ្នាទេ ទូលព្រះបង្គំយើងខ្ញុំក៏ធ្វើការនេះពុំបានឡើយ ។

សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោសទទួលសេចក្ដីអំណរព្រះគុណធ្ងន់ ពីទូលព្រះបង្គំយើងរាល់គ្នា ដែលមកសន្និបាតប្រជុំក្នុងទីនេះ ដោយសាព្រះរាជហ្ឫទ័យជ្រះថ្លារបស់ព្រះករុណាជាម្ចាស់ផែនដី ដែលអាណាប្រជាជនទាំងអស់គោរពប្រតិបត្តិកោតខ្លាចស្រឡាញ់ ថ្ងៃនេះក្រុងកម្ពុជាបានឃើញចំរើនកើនចំនួនវត្ត គួរឲ្យបណ្ដាភ្ញៀវបរទេសលោកសង្ឃ ដែលជាដំណាងតាងព្រះសង្ឃសាវក ពួកពុទ្ធបរិសទ្យព្រះជាម្ចាស់ ហើយដែលជាគ្រូប្រដៅបង្ហាត់បង្ហាញក្បួនច្បាប់ ក្នុងនាលោក

នេះនឹងបរលោកនាយនាំឲ្យខ្មែរជាតិបានជាសាស្ន ១ ដែលគេគួរឲ្យស្រឡាញ់មេត្តាករុណាជាងជាតិទាំងអស់ នៅក្នុងប្រទេសឥណ្ឌូចិនក្នុងឱវាទក្រុងបារាំងសែស ។

២១ មិនា ១៩៣៥

សម្ពោធន៍សាលាចាឡីង

# នៅឃុំគគីធំ ស្រុកកៀនស្វាយ ខេត្រកណ្ដាល

នៅថ្ងៃ ១ យូរាំង ១៩៣៥

### សម្ពោធឆ្លងសាលាបាលីរង

## នៅឃុំគគីធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

នៅថ្ងៃ ១៥ កើត ខែពិសាខ ឆ្នាំកុរ សប្តស័ក ព.ស. ២៤៧៨ (១ យូវាំង ១៩៣៥)

ពីថ្ងៃមុនមក ពួកអ្នកស្រុកគគីធំមានសទ្ធាជ្រះថ្លានឹងទំនុកបម្រុងការបរិយត្តិធម៌ក្នុងព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងឡើង ទើបស្រុះស្រួលបបួលគ្នាសាងសាលាបាលីរង ១ នៅក្នុងស្រុកនោះ[១] ដល់មកថ្ងៃ ១ ខែយូវាំង ឆ្នាំ ១៩៣៥ ជាវេលាដែលត្រូវធ្វើពិធីសម្ពោធឆ្លងសាលាបាលីនោះ វេលាម៉ោង ៩ ព្រឹកជួបជុំព្រះសង្ឃគ្រហស្ថប្រមាណជា ២០០ នាក់ ។ ក្នុងឱកាសនេះ លោកស្រីជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ នឹងលោកចៅហ្វាយស្រុកកៀនស្វាយបានអញ្ជើញទៅពីមង្គល នឹងជាកិត្តិយសដល់ការប្រជុំនេះដែរ គ្រានោះមេឃុំ ជា បានសូត្រសុន្ទរកថាកណ្ដាលទីជុំនុំថា៖

សូមក្រាបប្រណិបត្តិលោកស្រីជាអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ នឹងសូមក្រាបប្រណិបត្តិលោកចៅហ្វាយម្ចាស់

(១) សាលានេះធ្វើក្នុងស្រុក មិនមែនធ្វើក្នុងវត្ត ។

ខ្ញុំប្របាទម្ចាស់ព្រមទាំងពពួកឧបាសកឧបាសិកាទាំងអស់ មានសេចក្តីអរគុណ នឹងសេចក្តីត្រេកអររាប់ពុំបាន បំពោះលោកស្រីនឹងលោកចៅហ្វាយម្ចាស់ ដែលបានអញ្ជើញមកជាមង្គលក្នុងឱកាសបុណ្យសម្ពោធសាលាបាលីនេះ ។

ខ្ញុំប្របាទសូមថ្លែងសេចក្តីយ៉ាងសង្ខេប ពីកំប្លុកសាងសាលានេះ ជំរាបលោកស្រីនឹងប្របាទម្ចាស់ជាចៅហ្វាយ យើងខ្ញុំទាំងអស់គ្នាមានសេចក្តីជ្រះថ្លានឹងព្រះពុទ្ធសាសនា ជាយូរមកហើយបង់ស្វែងរកផ្លូវបដិបត្តិក្នុងព្រះពុទ្ធសាសនា នឹងយកមកបដិបត្តិធ្វើតាមឲ្យត្រឹមត្រូវតាមគន្លងព្រះពុទ្ធដីកា តែរកបានដោយលំបាក ព្រោះកាលពីដើមសៀវភៅធម៌អាថ៌ពុំសូវមានលោកអ្នកចេះដឹងក៏មានតិច តាំងពីរាជការប្រតិកគូរាត់បារាំងសែស ព្រមនឹងរាជការព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបានបង្កើតឲ្យមានសាលាបាឡីជាន់ខ្ពស់, ព្រះរាជបណ្ណាល័យ, ពុទ្ធសាសនបណ្ឌិត្យ, យើងខ្ញុំរាល់គ្នា ក៏បានធូរបិត្តធូរគំនិតបានភ្លឺស្វាងក្នុងព្រះពុទ្ធសាសនាឡើងដោយច្រើន ព្រោះលោកអ្នកចេះដឹងក៏មានច្រើន សៀវភៅធម៌អាថ៌ក៏សម្បូណ៌ឡើង ។

ដល់មកគ្រាក្រោយនេះរាជការបានអនុញ្ញាតឲ្យអ្នកស្រុកដែលមានសទ្ធាមានអំណាចនឹងបង្កើតសាលារៀនបាលី ខាងព្រះពុទ្ធសាសនាថែមទៀត យើងរាល់គ្នារឹងរិតតែមានសេចក្ដីត្រេកអរថែមឡើងទៀត ទើបនាំគ្នាកសាងសាលាបាឡីនេះ ដោយបរិច្ចាគធនធានបន្តិច ៗ ម្នាក់ ខំប្រឹងធ្វើក្នុងសម័យកំពុងក្រីក្រលំបាកដរាបដល់បានស្រេចហើយ បានទាំងសុំអាចារ្យពីរាជការធំ ៗ ក៏បានអនុញ្ញាតឲ្យតាមសុំ លោកចៅហ្វាយម្ចាស់ក៏បានជួយទំនុកបំរុងដរាបដល់បានសម្រេច ។

ថ្ងៃនេះជាថ្ងៃសម្ពោធឆ្លងសាលាបាលីនេះ យើងខ្ញុំសូមឧទ្ទិស្សផលដែលកើតអំពីការសាងនេះ ជូនលោកស្រី ជូនលោកចៅហ្វាយសូមឲ្យបានសេចក្ដីសុខចំរើនរៀងទៅ ។

លំដាប់នោះលោកស្រី ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ មានប្រសាសន៍ថា ខ្ញុំមានសេចក្ដីអំណរក្នុងការដែលអ្នកទាំងឡាយ បានអញ្ជើញខ្ញុំមកជាកិត្តិយសក្នុងការសម្ពោធសាលាបាឡីនេះមកបានឃើញសេចក្ដីសទ្ធានឹងឧស្សាហ៍ខំប្រឹងប្រែងកបង្កើតឲ្យបានជាសាលាបាលី ១ ខ្នងក្នុងដំបន់ស្រុកនេះ

ដោយបំនួនគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ គួរឲ្យសរសើរណាស់ ខ្ញុំមានសេចក្ដីសង្ឃឹមថា គង់ជានឹងបានរុងរឿងទៅថ្ងៃមុខ ដោយអំណាចសេចក្ដីខ្មាស់ខ្មែររបស់អ្នកទាំងឡាយ ។

ប៉ុណ្ណោះហើយក៏លើកលែងប្រជុំ ។



ប្រាសាទតាសោម - ជ្រុងខាងពាយព្យ នៃគោបុរខាងលិច ១

រឿងព្រះបាទឧទេយនមានសម្តែង ក្នុងឧទេយនវត្ថុរាជបរិប្ចា ថាជាអ្នកល្អក្នុងធម៌អាថ៌ដែរ ។ រឿងនេះមានដល់ទៅ ៣ កន្លែង ក្នុងព្រះត្រៃបិដកចិន ។ ទំនងវែងក៏វិតរបស់រឿងគឺខ្ញុំយកមក អំពី មាគន្ទិក-អវទាន ។

ខ្ញុំត្រូវពិនិត្យរឿងលេខ ៣៨ ក្នុង នញ្ជោ សិន ។ ក្នុង វេលាដែលព្រះបាទឧទេយនទ្រង់គង់នៅកោសម្ពីនោះ មាន មនុស្សប្រុសម្នាក់ឈ្មោះមាគន្ទិក មានកូនក្រមុំ ១ មានរូបឆោម ល្អឥតឧបមា ឈ្មោះថាអនុបមា ។ មានស្តេចជាច្រើនទាំង មន្ត្រីជាច្រើនមានប្រាថ្នាចង់បាន ប៉ុន្តែ មាគន្ទិក បានឃើញ ព្រះសម្មាសម្ពុទ្ធប្រកបដោយលក្ខណៈទាំង ៣២ យ៉ាង ក៏ត្រូវ ការតែលើកថ្វាយព្រះអង្គ ហើយក៏នាំនាងអនុបមាទៅថ្វាយ ភរិយានិយាយឃាត់ដូចម្តេចក៏មិនព្រមស្តាប់ ។ ព្រះបរមគ្រូ មិនព្រមទទួល ហើយទ្រង់សម្តែងធម្មទេសនា ត្រង់នេះឃើញ ដូចគ្នានឹងរឿងដែលយើងបានពោលមកហើយ ។ មាគន្ទិក ទូលសួរព្រះបរមគ្រូថា គួរថ្វាយនាងអនុបមាទៅព្រះបាទ ឧទេយនឬទេ តែព្រះអង្គទ្រង់ស្ងៀម ហើយ មាគន្ទិក ក៏ថ្វាយ

នាងអនុបមាទៅព្រះបាទឧទយនទៅ ។ ព្រះមហាក្សត្រក៏ទ្រង់ទទួលដោយព្រះទ័យសោមនស្ស ហើយទ្រង់បាត់ឲ្យសាងដំណាក់ ១ ព្រះរាជទាន ។ ឯព្រះមហេសីទី ១ នោះទ្រង់ប្រកបដោយសីលបរិសុទ្ធល្អ ជឿជ្រាស់ក្នុងគុណព្រះពុទ្ធ ។ នាងអនុបមាមានសេចក្តីព្យាបាទក៏ទូលបង្កាច់ថា ព្រះនាងស្យាមាវតីសហាយស្មន់នឹងព្រះសម្មាសម្ពុទ្ធ ។ ព្រះមហាក្សត្រទ្រង់ព្រះក្រោធបង់ប្រហារនូវព្រះនាងដោយព្រួញ ។ ត្រង់បាញ់នេះមានសេចក្តីដូចរឿងមុន ។ ព្រះបាទឧទយន ព្រមដោយសេនាយោធាមាត្យ យាងទៅឯព្រះសម្មាសម្ពុទ្ធដើម្បីសូមខមាទោសនឹងព្រះអង្គថា: ខ្ញុំព្រះអង្គជាមនុស្សពាលសាហាវខឹងឥតបើគិត ។ ជាមនុស្សគិតតែអធ្យាស្រ័យខ្លួនឥតគិតដល់អធ្យាស្រ័យអ្នកដទៃ ។ លុះក្នុងអំណាចថ្នាំពិសទាំង ៣ យ៉ាង គឺ តណ្ហា ក្រោធ នឹងមោហ ខ្ញុំត្រេកត្រអាលដោយអំពើជាអកុសល ។ ខ្ញុំស្តាប់ដំបូន្មានដែលប្រកបដោយពិសពុលរបស់ស្រ្តី ហើយក៏មិនអាចសំគាល់បាននូវសេចក្តីល្អនឹងសេចក្តីអាក្រក់ ។ ហេតុនេះកជារបស់ខ្ញុំនៅវេលាក្រោយដែលខ្ញុំ

ស្លាប់ទៅ ។ សូមព្រះអង្គទ្រង់មេត្តាដល់ខ្ញុំព្រះអង្គ ព្រះអង្គប្រកបដោយពន្លឺ សូមទ្រង់មេត្តាពន្យល់ដល់ខ្ញុំព្រះអង្គអំពីបែបភាពរបស់មាយាដែលពួននៅក្នុងរូបស្ត្រី ព្រះសម្មាសម្ពុទ្ធបរមៈ-គ្រូទ្រង់សម្ដែងថា វេលាតែបុរសណាមួយតាំងត្រេកត្រអាលដោយសាប់ វេលានោះហើយនឹងបានសោយទុក្ខព្រោះមាយារបស់ស្ត្រី ។ ធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធមានបែកយ៉ាងវែងទៅជា ៤ បំណែកដូច្នេះ គឺៈ មនុស្សដែលត្រេកត្រអាលដោយកាមគុណ គិតតែស្រីតែ ១ មុខ ដើរគេចចេញពីផ្លូវត្រង់ លែងជឿសេចក្ដីពិត ឥតមានសំគាល់សេចក្ដីបរិសុទ្ធនឹងសេចក្ដីសៅហ្មងឡើយ ភ្លេចអាពុកម្ដាយ ភ្លេចកិច្ចដែលត្រូវជាប់បំពាក់ដល់អាពុកម្ដាយព្រោះតែស្រី ។ លែងកាន់ចិត្តសុចរិត លែងតាំងនៅក្នុងសីល លែងកោតខ្លាចសមណ លែងធ្វើទាន លែងគិតទៅអនាគតសោះ ។ ខំសន្សំទ្រព្យសម្បត្តិមកមិនមែនប្រយោជន៍ធ្វើការកុសលឡើយ គឺប្រយោជន៍តែត្រេកត្រអាលក្នុងផ្លូវកាមគុណ ។ល។ រួចពីនេះព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងជាបទព្រះគាថាយ៉ាងវែង អំពីទុក្ខដែលបណ្ដាលមកពីសមាគម

ពួកស្ត្រី ។ ក្នុងវេលានោះព្រះបាទឧទយនបានឃើញនូវសេចក្ដីត្រូវ ក្នុងព្រះធម្មទេសនានេះហើយក៏តាំងប្ដេជ្ញាថា លែងប្រព្រឹត្តិបំពានលើលក្ខណបញ្ញត្តិរបស់ព្រះពុទ្ធសាសនាហើយ ហើយក៏យាងត្រឡប់ទៅកាន់ព្រះដំណាក់វិញ ដោយមានព្រះទ័យខ្ជាប់ក្នុងសីល ។

ឯរឿងលេខ ៣៨៨ នៃនញ្ញោនោះ មានរឿងជាមួយគ្នា ហើយមានសម្ដែងធម៌ដូចគ្នា ប៉ុន្តែដូចជាគ្រប់គ្រាន់ជាង ។ ព្រះសម្មាសម្ពុទ្ធទ្រង់គង់ក្នុងក្រុងកោសម្ពី ក្នុងសួនឃោសិតារាម ឬឃោសិល មួយអន្លើដោយភិក្ខុបំនួន ៥០០ អង្គ ។ ក្នុងវេលានោះ នាងអនុបមាជាបុត្រីមាកន្ទិក មានសេចក្ដីព្យាបាទព្រះនាងស្យាមាវតីជាអគ្គមហេសី ហើយរករឿងបង់ធ្វើព្រះនាងឲ្យវិនាសបេញ ។ នាងទូលព្រះបាទឧទយនថា ព្រះនាងស្យាមាវតីនឹងបរិវារទាំង ៥០០ ស្មន់អន្តរាយនឹងព្រះសម្មាសម្ពុទ្ធព្រមទាំងភិក្ខុទាំង ៥០០ អង្គ ។ តពីនេះមកដល់ត្រង់ស្ដេចក្រោធ ដល់ត្រង់បាញ់ រួបតមកទៀតដល់សេចក្ដីសួរនឹងឆ្លើយរបស់ស្ដេចឧទយននឹងនាងស្យាមាវតី ដូចក្នុងមាកន្ទិកអវទាន

ដូច្នោះដែរ ធម៌ទេស្នារបស់នាងស្យាមាវតី ជាបទព្រះគាថា នោះមានអធិប្បាយដោយវែង ។ សល់ពីនេះទាំងប៉ុន្មាន ដូចគ្នានឹងរឿងលេខ ៣៨ ទាំងអស់ ប៉ុន្តែមានសព្ទគ្រប់ជាង បន្តិច ធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធក៏ជាបទព្រះគាថា ទាំងអស់ ។

រឿងលេខ ២៣ នៃនញ្ញោនោះ ជាសេចក្តីប្រែថ្មីអំពីរឿង លេខ ៣៨មក ប៉ុន្តែឯការរៀបចំទំនងនោះត្រូវគ្នានឹងរឿងលេខ ៣៨៨ គឺរឿងនេះកើតនៅក្នុងសួនឃោសិតដែលព្រះសម្មា-សម្ពុទ្ធទ្រង់គង់មួយអន្លើដោយភិក្ខុសង្ឃចំនួន ១២៥០ អង្គ ឯ នាងដែលមានសេចក្តីព្យាបាទនោះឈ្មោះហា ទេវកន្យា (គឺជា ឈ្មោះដែលមានសេចក្តីដូចគ្នានឹងអនុបមាដែរ)[១] ។

---

(១) នៅមានរឿង លេខ ១៣៥០នៃនញ្ញោទៀត គឺ ធ្យាន-និស្ពា-សមាធិ-សូត្រ ដែលសម្តែង អំពីទុភិក្ខិត ហើយសម្តែងតទៅទៀត អំពីត្រង់ព្រះបាទឧទេយនទ្រង់ច.ប់ព្រួញទាំង ៥០០ មកបាញ់តពីនេះ សម្តែងរឿងយ៉ាងវិញ អំពីនាងស្យាមាវតីនឹងអនុបមា ។ ច្បាប់ដើមរឿងនេះ ៣.នមកអំពីសង្ស្ក្រឹត ដែលជាអ្នកធ្វើរាជការក្នុងព្រះបាទកនិស្គ សេចក្តីប្រែរបស់ កុមារជីវពី ឆ្នាំ ៤០២ នឹង ៤០៧ ។

បើនឹងពោលដោយពិតនោះ រឿងរ៉ាវនោះគេទុកជាក់ជារឿងផ្ទាល់ព្រះអង្គរបស់ស្ដេចឧទេន ។ ដែលគេស្រង់យករឿងនេះមកបញ្ចូលក្នុងរឿងព្រះពុទ្ធសាសនា ត្រង់ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាអំពីស្រីនោះ ដោយហេតុរឿងនេះមានជាប់សេចក្ដីវង្វេងដែលកាមគុណអាចនាំមហាក្សត្រឲ្យវិលវល់ផង ហើយដោយហេតុមានអ្នកដែលប្រព្រឹត្តកន្លងច្បាប់ចូលលន់តួទោសខ្លួនផង ។ ឯរឿងកាប់ចាក់របស់ស្ដេចឧទយនក៏ស្រាលបិយទៅ ដោយព្រះអង្គត្រឡប់ទៅជាអ្នកជឿសាសនាស្ទើរតែនឹងដល់ទីព្រះអរហត្ត ។

ខ្ញុំយល់ឃើញថា កាលដាន់ដើមនៅក្នុងក្រុងកោសម្ពី នោះមានរឿងសម្រាប់ស្រុកនិយាយអំពីស្ដេច ១ អង្គ ឈ្មោះឧទយនរឿងនោះមានជាបារិកឬមានជាសំដីនិយាយតៗគ្នាមក ដែលច្បាស់លាស់ជាងដែលមាននិទានក្នុងគម្ពីរផ្សេងៗរបស់ព្រះពុទ្ធសាសនា ។ រឿងឧទយនចរិតនេះច្បាស់ជាសម្ដែងនូវជ័យជំនះរបស់ស្ដេចនេះ ។ មានសេចក្ដីអាថ៌កំបាំងមួយនៅជុំវិញរឿងប្រសូតិរបស់ព្រះអង្គ មានឫទ្ធិវេទ្យមន្តនាំឲ្យទ្រង់បាននូវ

រាជសម្បត្តិរបស់ព្រះវររាជបិតាវិញ គឺទ្រង់បេះមគ្គផ្សាំងដំរី ហើយព្រះហស្តទ្រង់មិនដែលបោះបង់ពិណដែលតាបសឬនាគបានថ្វាយឡើយ ។ ទ្រង់មានព្រះរាជវរបំបោះបាន ហើយធបគ្នានឹងពួកទេព្វរក្ស ។ ខ្ញុំយល់ឃើញថា ហេតុអ្វីបានជាយើងមិនពិនិត្យតាមសំអាងរបស់គុណាពរ្យ អំពីសេចក្តីផ្សេង ៗ ដែលត្រូវគ្នានឹងរឿងរ៉ាវនេះ ។ គឺព្រះអង្គជាក្សត្រ ១ ព្រះអង្គយ៉ាងក្លាហាន ជាទីស្រឡាញ់របស់ស្ត្រី, ទ្រង់ត្រេកត្រអាលក្នុងផ្លូវកាមគុណ, គង់ក្នុងរាជសម្បត្តិយ៉ាងបរិបូណ៌ ទ្រង់ជាប់ក្តី ព្រះបាទប្រទ្យោតហើយរត់រួច នាំបំរត់ទាំងព្រះរាជបុត្រីស្តេចនេះមកផង ។ ក្នុង ១ ជាតិព្រះអង្គ សុទ្ធតែប្រកបទៅដោយការសប្បាយក្នុងរូបស្ត្រីនឹងរឿងរ៉ាវចាក់កាប់ក្នុងការស្រឡាញ់ស្ត្រី ទ្រង់មានមហេសី ១ ដែលមានសេចក្តីព្យាបាទមហេសីដើមហើយដុតដំណាក់ឲ្យឆេះស្លាប់ ។ តែព្រះបាទឧទយននេះទ្រង់មានព្រះទ័យជឿបុណ្យ ហើយទ្រង់ជាមិត្រនឹងពួកអ្នកបួស ។

ព្រះពុទ្ធសាសនាបានយករឿងនេះមកបញ្ចូលហើយលើកស្ដេចនេះមកបញ្ចូលក្នុងពួក ស្ដេចទាំងប៉ុន្មានដែលមាននៅក្នុងពុទ្ធសម័យ ។

ចប់

សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម រៀបរៀង

(៣)

១០ គោបរិនិព្វាន ធ្វើជាព្រះពុទ្ធរូបផ្ទំជាអនុដ្ឋានសេយ្យាសន៍ ព្រះសិរកើយលើព្រះហស្តខាងស្តាំ ព្រះហស្តឆ្វេងសណ្ដូកតាមព្រះកាយ ជួនកាលគេធ្វើជាព្រះរូបរុំសំពត់ស្នបតាមក្នុងរឿងបឋមសម្ពោធិកថា គ្រឿងប្រកបធ្វើជារូបព្រះស្តូបនៅខាងក្រោយព្រះបរមសព ឬជួនកាលគេធ្វើទាំងរូបព្រះភិក្ខុសង្ឃ និងរូបទេវតាផង ។ ធ្វើដំណាលកាលព្រះបរមគ្រូរំលត់ខន្ធចូលកាន់ព្រះបរមនិព្វាន នាសួនសាលវនោទ្យាន ទៀបនគរកុសិនារា ។

ព្រះពុទ្ធរូប ១០ គោនេះ ពួកឥណ្ឌៀលើបានប្រឌិតសាងឡើងជាដំបូងមុនប្រទេសដទៃៗទាំងអស់ ។

១១ ព្រះត្រៃកាយ ធ្វើជាព្រះពុទ្ធរូប ៣ អង្គគង់ទន្ទឹមគ្នា តែអង្គកណ្ដាលធ្វើទ្រើសបន្តិច ព្រះពុទ្ធរូបបែបនេះ ពួកមហាយានិកនិកាយសាងឡើងដោយចូលចិត្តថា ព្រះពុទ្ធមានព្រះកាយ ៣ ដូចមានអធិប្បាយហើយក្នុងបរិច្ឆេទទី ៣ ។

១២ ព្រះភេសជ្ជគុរុ ធ្វើជាព្រះពុទ្ធរូបគង់ពត់ព្រះភ្នែន ព្រះហស្តស្តាំលាតផ្ងារ លើព្រះជង្ឃ ព្រះហស្តឆ្វេងកាន់គិលានភេសជ្ជ គឺផ្លែរក្សារោគឯណានីមួយមានផ្លែសម៉ជាដើម ដែលគេ

សាងព្រះពុទ្ធរូបបែបនេះឡើង ដោយមានគតិជឿក្លាយទៅថា ព្រះពុទ្ធជាទេវរូបវិសេស ១ បំណែកខាងពួកទក្ខិណនិកាយគ្មានសាងសោះ ។

នៅមានព្រះពុទ្ធរូប១បែបទៀតធ្វើអំពីសម្រិទ្ធ អង្គតូច ៗ ប្រមាណប៉ុនមេដៃ ខាងក្នុងអង្គព្រះមានគ្រាប់ អង្រួនទៅឮក្រិងៗ គេទើបហៅថា "ព្រះក្រិង" ឬ"ព្រះក្រឹក" បំពោះមានសាងតែក្នុងប្រទេសកម្ពុជា គឺសាងក្នុងរជ្ជកាលព្រះបទុមសុរិយវង្ស តែសម្តេចក្រុមព្រះយាំដាំរុងរាជានុភាពថា ឃើញមាននៅប្រទេសបិនខ្លះដែរ តែមិនដឹងជាអ្នកណាយកបែបអ្នកណាទៅសាង ព្រះនេះគេរាប់អានទៅក្នុងផ្លូវពូកែសក្តិសិទ្ធ ។

ប៉ែកព្រះនៅក្នុងឋានសួគ៌

១៣ ព្រះអាទិពុទ្ធ ធ្វើជាព្រះពុទ្ធរូបទ្រង់គ្រឿងបែបស្តេចចក្រពត្តិ ដែលអ្នកខ្លះហៅថា "ព្រះទ្រង់គ្រឿង" សម្រាប់ប្រទេសកម្ពុជាយើង ឃើញមានសាងតាំងអំពីរវាងព.ស. ១០០០ មកដោយឃើញមាននៅក្រុងមហិន្ទ្របុរី នឹងស្រុកស្រីសលរោជាដើមដែលជាស្រុកដំណែលចាស់របស់ខ្មែរ តែសម័យក្រោយមក

កាលកើតមានរឿងមហាជម្ពូបតិ ផ្សាយមកដល់ប្រទេសកម្ពុជា ខ្មែរយើងក៏នាំគ្នាចូលចិត្តឋាជា ព្រះពុទ្ធរូបគ្រាផ្ចាញ់មហាជម្ពូបតិ ទៅវិញ ។

ព្រះធ្យានីពុទ្ធ៥អង្គ

១៤ ព្រះវៃរោចន ធ្វើដូចគ្រាចក្រមុទ្រ

១៥ ព្រះអក្សោភ្យ " គ្រាភូមិស្បរ្សមុទ្រ

១៦ ព្រះរត្នសម្ភវ " គ្រាវរមុទ្រ

១៧ ព្រះអមិតាភ " គ្រាធ្យានមុទ្រ

នៅមានព្រះពុទ្ធរូប ១ បែបទៀត ធ្វើជាព្រះសមាធិមាន នាគប្រក់ហើយមានរូបព្រះលោកេស្វរ នឹងរូបនាងប្រជ្ញាបារមិតា ឈរអមសងខាង នេះក៏ជាព្រះអមិតាភដែរ ។

១៨ ព្រះអមោឃសិទ្ធ ធ្វើដូចគ្រាអភយមុទ្រ ។

ព្រះធ្យានីពោធិសត្វ៥អង្គ

១៩ ព្រះសមន្តភទ្រ ធ្វើជារូបពោធិសត្វ កាន់ចិន្តាមណី

២០ ព្រះវជ្របាណី ធ្វើជារូបពោធិសត្វ កាន់វជិរ

២១ ព្រះរត្នបាណី " " កាន់ចិន្តាមណីឬផ្កាឈូក

២២ ព្រះលោកេស្វរ ធ្វើជារូបពោធិសត្វ កាន់ផ្កាឈូក

២៣ ព្រះវិស្វបាណី " " កាន់វជិរ ២ ។

ក៏ឯវត្ថុដែលព្រះពោធិសត្វអំបាលនេះតែងកាន់ មិនមែនមានតែប៉ុណ្ណោះ បើធ្វើជារូបមានព្រះហស្ត ៤ ឬព្រហស្តច្រើនជាងនេះក៏តោងមានរបស់ផ្សេង ៗ ទៀតកាន់ ដូចយ៉ាងរូបព្រះលោកេស្វរព្រះហស្ត ៤ ព្រះហស្តលើពីរ ១ កាន់ផ្កាំ ១ ទៀតកាន់ក្រាំង ព្រះហស្តក្រោមពីរ ១ កាន់ផ្កាឈូក ១ ទៀតកាន់កន្ធីទឹក ។ នៅមានគ្រឿងសំគាល់ម្យ៉ាងទៀតជាសំខាន់ដែលត្រូវចាំទុក គឺរូបព្រះពោធិសត្វអំបាលនេះសុទ្ធតែមានព្រះពុទ្ធរូបតូច ៗ នៅត្រង់ឧណ្ហិស (ផើងសក់ពីខាងមុខ) ជាសំគាល់ ឬជួនកាលគេធ្វើនៅទីដទៃទៀតក៏មាន បើគ្មានព្រះពុទ្ធរូបទេគាប្បីប្ចូលចិត្តថា មិនមែនរូបព្រះពោធិសត្វអំបាលនេះ ។

២៤ នាងប្រជ្ញាបារមិតា ធ្វើជារូបស្ត្រីទ្រង់គ្រឿង កាន់ក្រាំងនៅដៃ ដោយច្រើនបំណាំតែធ្វើជារូបគូគ្នា នឹងរូបព្រះលោកេស្វរ ។

# មនុស្សពោធិសត្វ

## គឺព្រះពោធិសត្វនៅក្នុងមនុស្សលោក

២៥ អារ្យមៃត្រេយ ធ្វើជារូបប្រុសទ្រង់គ្រឿង ព្រះហស្ត ២ ក៏មាន ព្រះហស្ត ៤ ក៏មាន ព្រះហស្ត ៨ ក៏មាន ហើយមានរូបព្រះស្តូបនៅត្រង់ឧណ្ហិសជាសំគាល់ ។ រូបមនុស្សពោធិសត្វឃើញគេសាងតែរូបព្រះអរិយមេត្រេយ ១ អង្គប៉ុណ្ណោះ ។ រូបព្រះអារ្យមៃត្រេយ ព្រះហស្ត ៨ មាននៅសាលាព្រះរាជបណ្ណាល័យកម្ពុជា ១ អង្គធ្វើដោយសម្រឹទ្ធ ជារបស់ខ្មែរបុរាណ អ្នកប្រាថ្នាចង់ឃើញច្បូរទៅមើលនៅទីនោះចុះ ។

# រឿងព្រេងខ្មែរ

## ១- រឿងក្អែក ១ ជាក្អែក ១០

រឿងពាក្យព្រេងថា ក្អែក១ជាក្អែក ១០ រកស៊ីទុច្ចរិតពេករលាយខ្លួន ដើមនិទានអំពីឈ្មោះអាខឹលអាខ្វប នៅស្រុកទីទៃពីគ្នា គំនិតតែដោយខ្លួន ។ ឯអាខ្វបនោះជុះអាចម៍ដាក់ពាងច្រើនថ្ងៃទៅពេញពាង ហើយយកអាចម៍លាក់បិទភ្ជិតយ៉ាងល្អមិនឲ្យក្លិនចេញក្រៅបាន ។ ឯអាខឹលនោះធ្វើកាំបិត ១ផ្លែប៉ុនបង្កើះអកកំបោរ ដងប៉ុនកដៃ ស្រោមធំវែង១ លុក អាខឹលនោះក៏ស្ពាយកាំបិតដើរទៅលក់ អាខ្វបនោះក៏ពុនពាងអាចម៍ដើរទៅលក់ អាខិលទៅអំពីនេះ អាខ្វបមកអំពីនោះ ជួបគ្នាកណ្ដាលផ្លូវ អាខ្វបពពាយឆាយថា អ្នកកើយទិញផ្អកយកទៅពីសារផ្អកបារយ៉ាងល្អស្លក៏បានចំហុយក៏បានឆ្ងាញ់របស់ខ្ញុំណាស់ ។ អាខិលឆ្លើយថា ទាស់នឹងលក់ដាវនេះមិនទាន់ដាច់គ្មានលុយទិញ បើខ្ញុំសុំដូរជាដាវនេះព្រមដូរឬទេ ។ អាខ្វបឃើញដាវនោះវែងក៏ឆ្លើយថា ដូរក៏ដូរ ។ អាខិលប្រគល់ដាវឲ្យអាខ្វបហើយភូតអួតថា ដាវខ្ញុំនេះមុតបំផុតបិត្ត មេដែករបស់ខ្ញុំ

ផង បើត្រូវការម្តង ៗ សុំហូតកាប់ អ្នកឯងកុំប្រញាប់ហូតមើល កុំហូតលរព្រើល ៗ សិកទៅវិញមិនបុះទេ ដាវខ្ញុំពូកែខ្ញុំស្តាយរបស់ផងខ្ញុំ បើកុំតែខែនេះវាក្រមួបណាស់ នោះខ្ញុំមិនដូរទេ ។ ឯអាខ្ទូបនោះក៏ប្រគល់ពាងអាចម៍ឲ្យអាខិលហើយហាមថា ផ្អកខ្ញុំហ្នឹងក៏ដែរ ដល់ពេលស៊ីសុំបើកយកបំហុយកុំអាលបើកមើលក្រែងវាស្អុយសត្វរុយវាបែង ក្រែងវាធុំខ្មោះស៊ីមិនទាន់អស់វាទៅជាខារឆ្ងាញ់ផឹកឃើញជីដូនជីតាបានតែខារស៊ីឆៅ អាទាំងពីរបែកគ្នាទៅដល់ផ្ទះរាល់ខ្លួន ហើយទៀនប្រពន្ធកូនថា ដណ្តាំបាយទៅអញបានផ្អក ហើយប្រពន្ធកូនថា បានផ្អកពីណា អាខិលថា ដូរដាវគេថាផ្អកបាវស៊ីទាំងឆៅឆ្ងាញ់ណាស់ ប្រពន្ធកូនស្រាប់តែអរពេញចិត្តនឹកថា ប្តីបេះធ្វើកាំបិតទៅដូរផ្អកស្ទុះភ្លែតទៅលាងចានដួសបាយ ៗ ហើយកាន់កាំបិតចាស់យ៉ាងកំរិលកកិលទៅជិតពាងផ្អក យកកាំបិតគាស់អាចម៍លាក់នោះរបើកឡើងហើយលូកខារបាន ១ ក្តាប់ដាក់ឆ្លាប់ទៅក្នុងចានសល់នៅដៃប៉ុន្មានក៏លិតផ្លប់ភ្លក់មើល ងើយមុខឡើងលើថា យើផ្អកបាវអីក៏ស្អុយដូចអាចម៍ គ្មានផ្អឹងនឹងសាប់កខ្វេបកខ្វក់ហ្មត់ឈឹង

យ៉ាងហ្នឹងតើផ្អកត្រីអ្វី ប្ដីថា ក្រែងត្រីពោ ប្រពន្ធក៏លូកក្លួរវាវិរក ក្បាល លូកបានពាក់កណ្ដាលក្អួតបង្អោរជាង ២០ វ៉ក ដឹង ជាក់ជាអាចម៍មិនមែនផ្អកបកបន្ទោសទៅម្ចាស់ដើមផ្ដើមលេប បាយមិនរួច និយាយអំពីអាខ្វបត្រែកអរណាស់ដើរទៅផ្ទះក៏អួត ប្រាប់ប្រពន្ធថា អាចម៍ ១ ពាងដូរបានជារី ១ ដែរ ទទួលទឹង នឹងផ្ដៅ ៗ នោះវានោមប្រាស់សង្ក្រៃ កន្ទ្រាក់លោតទៅដល់ដីបំរុង នឹងកាប់ផ្ដៅសម្លាប់ ក៏ចាប់ជង់ជារីហូតខ្វិច ឃើញផ្លែជារី នោះខ្លីប្រប៉ុបគេបឡើងទៅលើផ្ទះបង្ហាញឲ្យប្រពន្ធមើលហើយ សើចទាំងពីរនាក់សើចហើយប្រាប់ប្រពន្ធថា ប្រាជ្ញាអានោះ ស្មើនឹងអញ ៗ ទៅបបួលធ្វើសំឡាញ់នឹងរកស៊ីពីរនាក់ នឹង បានមាសប្រាក់ដោយងាយ ដើរទៅប្រទះនឹងអាខ្វិលដើរមក អំពីឯនាយសើចពព្រាយនិយាយសួរគ្នាថា ឯងទៅណា ឆ្លើយ ថា អញមកស៊ុំឯងធ្វើសំឡាញ់ អា ១ ក៏ថា អញមកស៊ុំឯង ធ្វើខ្លីដែរ ហើយក៏សុខចិត្តដើរពីរនាក់ទៅដល់ផ្ទះមហាសេដ្ឋី ១ ចាស់ជរាឈឺស្លាប់ ដាក់ក្នុងក្ដារមឈ្ឈូសបំរុងបូជាថ្ងៃស្អែក បំណែកកូនចៅនឹងប្រពន្ធយំសោកគ្រប់គ្នា វេលានោះអាទាំង

ពីរស៊ើបសួរអ្នកដើរខាងក្រៅថា អ្នកណាស្លាប់ក៏មានគេយំ គេប្រាប់ថា មហាសេដ្ឋីស្លាប់ ស្រាប់តែអាទាំងពីរនាក់គិតគ្នាថា ឯងគិតក្លែងសំបុត្រ១ច្បាប់ទៅប្រាប់គេថា សំបុត្រលោកឲ្យមកយកទ្រព្យរបស់ អញបន្ទិលបដេកក្នុងម្លូសអំពីលើខ្មោចសេដ្ឋីអញចាំស្ដីតនឹងឯងថា ស្រេចអាមួយក៏ទៅបន្ទំដេកដូចគំនិត អ្នកនៅជិតមិនបានឃើញមិនបានដឹង ដ្បិតភ្នែកខំសំឡឹងប្រឹងពេញ្ញាកមើលក្រាំងសូត្រព្រះធម្ម កូនចៅតូចធំរវល់តែយំសោក អាខ្ចូបដើររកក្រដាសបានធ្វើសំបុត្រក្លែងកាន់ទៅសំដែងសូត្រឲ្យគេស្ដាប់ថា សំបុត្រអំពីមហាសេដ្ឋីប្រាប់មកចៅខ្ចូបកំសត់តាំងពីតូចទុកជាកូនធម៌ ឥឡូវអាពុកជរាហើយកូនឡើយចូរទៅយករបស់ទ្រព្យទុកបាយឲ្យសប្បាយចិត្តចុះ កូនចៅស្រីប្រុសគេមិនសុខចិត្ត ព្រោះដ្បិតគ្មានត្រាឬស៊ីញ៉េឈ្មោះសេដ្ឋី អាខ្ចូបឆ្លើយថា ខ្ញុំសូមសន្យានឹងអស់អ្នកកូនចៅ អញ្ជើញទៅហៅហើយសួរលោក បើលោកស្ដីនោះខ្ញុំត្រង់ពិត បើខ្ញុំមកក្លែងបញ្ឆោតនោះឲ្យលោកស្ងៀម កូនសេដ្ឋីចូលភ្លាមក្រាបផ្ទឹបស្រែកហៅលោកឪពុក អាទិលឆ្លើយថា ហៅអី កូនសួរ

ថា លោកឪពុកបានឲ្យសំបុត្រទៅកូនធម៌មកយករបស់ទ្រព្យ
មែនឬអ្វី អាខិលស្តីថា អើកូនអញឈ្មោះអាខ្វប តឡូផ្ទះវាមក
ហើយឬអ្វី កូនឆ្លើយថា ទាន់ប្រោសមកហើយ អាខិលបង្គាប់
ថា អើមើលយករទេះ ១ ធំហើយយកក្របីម្នីមទឹមរទេះនោះហើយ
យកមាសប្រាក់កែវកងសំពត់អាវវាល់ផ្ទុកក្នុងរទេះនោះឲ្យល្មមតែ
ក្របីនោះវាអូសរួចបានប៉ុន្មានឲ្យវាយកទៅចុះ កូនចៅស្រីប្រុសក៏
ចាញ់ឧបាយកលអាខិលអាខ្វបក៏ខឹងនឹងខ្មោចសេដ្ឋីស្លាប់ហើយ
បេះស្តីហៅអស្ចារ្យតឡូវនឹងបើកភ្នែកមើលឲ្យច្បាស់ ពាក្យ
ចាស់ហាមប្រាមថា មើលខ្មោចមិនបាន ពាក្យបូរាណថា ខ្លាប
ដេកយប់ទៅមមាល ម្ល៉ោះហើយក៏ជឿជាក់យកមាសនឹងប្រាក់
សំពត់អាវស្លៀកពាក់នឹងកន្ទេលពូកខ្នល់ខ្នើយ ហើយថែមតុក
ថាសចានល្អ ៗ អំបិលប្រហុក ៤ ក្រឡរ អង្ករ ៥ ការុងដាក់ផ្លុង
ទៅឲ្យ អា ខ្វប ខិល បង្ហិលរទេះយ៉ាងធំ ទឹកភ្នែកដំដែកយំហើយឲ្យ
ដោយខឹងដោយបញ្ឆោះទាំងស្រីទាំងប្រុសស្រែះគ្នាហើយ ក៏
ដឹកក្របី ១ នឹមទឹមរទេះប្រគល់ឲ្យអាខ្វប អានោះស្រាប់តែអរ
ឡើងបររទេះចេញទៅ អ្នកទាំងអស់ដែលនៅបេះតែជ្រួលមិន

ស្រួលចិត្តព្រោះដ្បិតខឹងហើយស្ដាយ   អាវិលល្បួចមើលនាយ
អាយក៏លបចេញប្រិបរត់តាមទៅបន្តិចក៏ទាន់រទេះ   ហើយនិ-
យាយគ្នាថា  យើងបានទ្រព្យរបស់តែទាស់នឹងឃ្លានបាយ នឹង
ឈប់ដណ្ដាំបាយនៅរៀងអាយក្រែងមិនស្ងាត់ ខ្លាចចោរវាតាម
មកវាប្លន់យកទ្រព្យ ១ រទេះ បើដូច្នេះឯងបញ្ឈប់ចាំអញ ៗ ទៅ
សុំបាយគេស៊ីខ្លះយកខ្លះមកឲ្យឯង  អា ១ ក៏ព្រមហើយអាមួយ
ក៏ដើរទៅ   គិតរកថ្នាំតាមផ្លូវនឹងលាយនឹងបាយឲ្យពុលស្លាប់
អន្តរាយយកទ្រព្យរបស់ទាំងអស់នោះតែម្នាក់ឯង ។ ឯអា ១
ដែលនៅចាំរទេះក៏បេះធ្វើខ្នារដាក់ស្នាក់ផ្លូវបម្រុងឲ្យត្រូវអានោះ
ស្លាប់នឹងយកទ្រព្យតែឯង គំនិតខែងស្មើគ្នា  វេលានោះអា ១
សុំបាយគេស៊ី ៗ រួចហើយថា សុំ ១ ចានផ្ញើសំឡាញ់  គេក៏មិន
កំណាញ់ គេក៏រកស្លឹកចេកខ្ចប់ឲ្យហើយមានត្រីអាំង អានោះក៏
តាំងលាគេដើរចេញមកហើយក៏យកថ្នាំប្រលាក់បាយ មកដល់
ខាងអាយក៏ត្រូវនឹងខ្នារនោះស្លាប់  អា ១ ដើរប្រញាប់ចាប់បាយ
ស៊ីទាល់តែស្អំ  អាសិរពិសថ្នាំពុលស្លាប់បន្ទាប់គ្នា  ឯក្របីនោះ
អួសរទេះបួលព្រៃរតែករគោកជ្រកក្នុងទឹកត្រពាំង  ប្រទាញឆាំង

ដាប់ខ្សែទាមដេកត្រាំទឹក ស្រាប់តែដល់វេលាព្រឹកមានបុរសម្នាក់ ដើរទៅឃើញទ្រព្យរបស់ទាំងអស់នៅក្នុងព្រៃ នឹកម្តងភ័យនឹកម្តងអរថា ឯងអ្នកក្រមិនដែលប្រទះទ្រព្យនេះច្រើនណាស់ ក្របើនឹងលៃលកនឹងយកទៅជារបស់ខ្លួនក្រែងពុំសុខ ក៏រុញរទេះសំរុកទៅទុកក្នុងព្រៃ បង្ក្របីយ៉ាងជាប់ត្រឡប់ទៅផ្ទះវិញ ហើយក៏តាំងពីសោត្តមារយាទប្រពន្ធ គិតថាបើប្រពន្ធមារយាទល្អនឹងយកទ្រព្យនោះទុកជារបស់ខ្លួន បើនិយាយអ្វីទៅមិនបេះលាក់នឹងយករបស់ទាំងអស់ជូនរាជការផែនដី ប្រយោជន៍ដើម្បីឲ្យតែសុខខ្លួន គិតហើយដើរទៅដល់ផ្ទះក៏តាំងពោលពាក្យកុហកប្រពន្ធថា អញផុះអាចម៍ពីថ្ងៃមិញមានសត្វក្អែក ១ ហើរចេញអំពីក្តិត តែឯងអាណិតបិទមាត់ឲ្យឈឹងកុំឲ្យនរណាគេដឹង ១ ជាពីរ តែបួលត្រចៀកគេបែកអាក្រក់ណាស់ កើតមានជំនុំជំរះសួរទៅសួរមក ហើយគ្មានទាំងសាក្សីបានដឹងនឹងអាង ក្រែងគេយកអញទៅឆ្កាងឬយកទៅដាក់គុក ឯប្រពន្ធនោះវាមិនទុកដើរប្រាប់គេថា មានក្អែកពីរហើរចេញពីក្តិតប្តីអញតែឯងកុំមាត់មេ ១ ទៀតមិនអត់ទៅប្រាប់ថែមថា ក្អែក ៥ ប្រាប់ ១ លើស ៗ

តគ្នាដរាបដល់ក្អែក ១០ ស្រាប់តែជ្រួតជ្រាបដរាបទៅដល់មហាក្សត្រទ្រង់ចាត់ប្រើរាជអាមាត្យឲ្យមកហៅបុរសនោះ ក៏ទៅថ្វាយបង្គំគាល់ស្តេចទ្រង់ឆ្ងល់ ក៏ត្រាស់មានបន្ទូលថា មែនឬមិនមែន ។ ឯបុរសនោះក៏ទូលឆ្លើយថា ទូលបង្គំជាខ្ញុំកុហកប្រពន្ធបង់ដឹងចិត្ត ព្រោះដ្បិតឃើញទ្រព្យហើយបុរសនោះរៀបរាប់ដូចមានខាងលើរៀងមកនេះ បង្គំលាទៅទឹមរទេះយកមកថ្វាយស្តេចទ្រង់បែកចាយឲ្យបុរសនោះពាក់កណ្តាល ដំណើរដំណាលក្អែក ១ ជាក្អែក ១០ ក៏ចប់អស់តែប៉ុណ្ណឹង អាទាំងពីរស្លាប់ចោលឆ្អឹង ត្នាតក្អែកហ្សូរហែកស៊ី ក្នុងទីព្រៃស្ងាត់អសារឥតការ ។

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| អក្កោសកថា........................ | ១ សៀវភៅថ្លៃ | ០រ, ០៥ |
| អត្តានុសាសនី........................ | — | ០, ១០ |
| អនត្តលក្ខណសុត្ត........................ | — | ០, ១០ |
| អនុត្តរិយសុត្ត........................ | — | ០, ០២ |
| អភិធម្មត្ថសង្គហ........................ | — | ០, ៩០ |
| អរិយសច្ចកថា........................ | — | ០, ៥០ |
| អំពីព្រះនិព្វាន........................ | — | ០, ៦០ |
| អំពីព្រះពុទ្ធសាសនា........................ | — | ១, ៥០ |
| អំពីប្រាសាទនៅអង្គរ........................ | — | ០, ៣៥ |
| កច្ចាយនូបត្ថម្ភកខ្សែ ១........................ | — | ១, ៣០ |
| " " ខ្សែ ២........................ | — | ១, ៤០ |
| កាលាមសុត្តនិងបរាភវសុត្ត........................ | — | ០, ១៥ |
| គតិលោកខ្សែ ១........................ | — | ០, ១៥ |
| គិរិមានន្ទសុត្ត........................ | — | ០, ០៧ |
| គិហិបដិបត្តិ........................ | — | ០, ៤៥ |
| ច្បាប់ថ្មី........................ | — | ០, ១៥ |
| ជយវរ្ម័ន ទី ៧ ( អក្សរខ្មែរ ) ក្រដាសស្តើង........ | — | ០, ២០ |
| " " ( " )ក្រដាសក្រាស........ | — | ០, ២៥ |
| ជយវរ្ម័ន ទី ៧ ( អក្សរបារាំង )............... | — | ០, ៤៥ |
| ញាណកថា........................ | — | ០, ១២ |
| ដំណាលពុទ្ធចេតិយ........................ | — | ១, ៨០ |
| ទសបារមីកថា........................ | — | ០, ៣០ |
| ទស្សនាវដ្តី........................ | — | ៤, ០០ |
| ធម្មបទដ្ឋកថា........................ | — | ០, ៦៥ |
| ធម្មប្រទីប........................ | — | ០, ៤០ |

| | | |
|---|---|---|
| ឆគោបមាទិកថា. . . . . . . . . . . . . . . . . . . . . | ១ សៀវភៅ ថ្លៃ | ០៛, ០៨ |
| បញ្ញាសជាតក. . . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| ជាដិមោក្ខសង្ខេប. . . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| ជាយាសិភជញ្ញសុត្ត. . . . . . . . . . . . . . . . . . . . | — | ០, ០៤ |
| បុណ្ណោវាទសុត្តៈ . . . . . . . . . . . . . . . . . . . . | — | ០, ០២ |
| ព្រះត្រៃបិដក (បាឡីនឹងប្រែ) ១ ចប់ចំនួន ១០០ សៀវភៅ. . . . | — | ២៥០,១០ |
| ព្រះបង្គុមកែវ. . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| ពុទ្ធប្រវត្តិ . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| ពុទ្ធោវាទានុសាសនី. . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ពាក្យកាព្យក្រមអ្វ. . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| ពាក្យសក្រាវ ទី ១ . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ″ ″ ២ . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ″ ″ ៣ . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| មនោបុព្វកថា . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| មរណានុស្សតិ. . . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| មាតាបិតុឧបដ្ឋាន. . . . . . . . . . . . . . . . . . . . . | — | ០, ៣៥ |
| មិលិន្ទបញ្ហាវគ្គ ១. . . . . . . . . . . . . . . . . . . . | — | ០, ៩០ |
| ″ ″ ២ . . . . . . . . . . . . . . . . . . . . | — | ០, ៧០ |
| ១០០ គាថា. . . . . . . . . . . . . . . . . . . . . | — | ០, ២០ |
| រឿង ១ ពាន់ ១ យប់. . . . . . . . . . . . . . . . . . . | — | ០, ០៤ |
| ល្បើកទូន្មានកូនចៅបិន . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| វិជ្ជាចរណកថា . . . . . . . . . . . . . . . . . . . . | — | ០, ៣៥ |
| វុត្តោទយ. . . . . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| សប្បុរិសធម៌. . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| សត្តបរិត្តនិងទ្វាទសបរិត្ត. . . . . . . . . . . . . . . . . . | — | ០, ៣៥ |
| សតិបដ្ឋានសុត្ត. . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| សាមណេរវិន័យ. . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សារទេសនា. . . . . . . . . . . . . . . . . . . . | — | ០, ០៣ |

| | | |
|---|---|---|
| សាសនកិច្ចានុក្រម ១២ ខ្សែ . . . . . . . . . . . . . . . . . | ១ សៀវភៅថ្លៃ | ០៛, ៥០ |
| សិង្គាលោវាទសុត្ត. . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សីមាវិនិច្ឆ័យ. . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| សុភទោសកថា. . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| សុរិយាត្រឡើងស័ក. . . . . . . . . . . . . . . . . . . | — | ០, ៦០ |
| សុភាសិតប្បកាសិនី . . . . . . . . . . . . . . . . . . | — | ០, ៤០ |
| សេកសោមបណ្ឌិត. . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សេចក្តីដាស់តឿន. . . . . . . . . . . . . . . . . . . . | — | ០, ០៦ |
| សំវេជនីយធម៌. . . . . . . . . . . . . . . . . . . . . | — | ០, ១២ |
| គិហិបដិបត្តិសង្ខេប . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| បក្ខគណនាវិធី និងបក្ខសម្រេច . . . . . . . . . . . . . | — | ០, ៥០ |
| សម្ពុទ្ធមាលា . . . . . . . . . . . . . . . . . . . . . | — | ០, |
| សីលនិទ្ទេស . . . . . . . . . . . . . . . . . . . . . | — | ០, |

សៀវភៅនៅកំពុងតែបោះពុម្ពហើយនឹងចេញនៅថ្ងៃក្រោយៈ

ព្រះត្រៃបិដកទី ១០, ១១ និង ១២ ។

វេយ្យាករណ៍បាឡីបោះពុម្ពលើក ២ ទី ២ ។

ធម្មបទដ្ឋកថាបោះពុម្ពទី ២ ។

## រូបបដិតពុម្ពផ្សេង ៗ

| | | |
|---|---|---|
| ព្រះពុទ្ធរូបមានអគ្គសាវកអម (របនាគការ). . . . . . . . . . . . | — | ០៧, ០៥ |
| ព្រះពុទ្ធរូប និព្វាន . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ៣ ព្រះអង្គ . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ៩ ព្រះអង្គ. . . . . . . . . . . . . . . . . . | — | ០, ០៥ |
| ព្រះពុទ្ធរូបជាយ័ន ១៣ សន្លឹក ១ សន្លឹក. . . . . . . . . . . . | — | ០, ០២ |
| ព្រះពុទ្ធរូបមានព្រះឥន្ទ្រនឹងព្រះព្រហ្មឈរអម . . . . . . . . . . | — | ០, ០៥ |
| ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀង). . . . . . . . . . . . | — | ១, ០៣ |
| ព្រះរូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . . | — | ០, ២៥ |
| " " ក្រដាសទន់ . . . . . . . | — | ០, ០៦ |
| " ព្រះស៊ីសុវត្ថិ. . . . . . . . . . . . . . . . | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . . . . . | — | ០, ១០ |
| រូបព្រះពុទ្ធបាទ ១ សន្លឹក. . . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបព្រះឥន្ទ្រលាសំពត់រឿងពុទ្ធបរិវត្ត . . . . . . . . . . . | — | ០, ០៣ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក ១ សន្លឹក. . . . . . . . . . . . . | — | ០, ០៦ |
| រូបតំនូរ តេមិយជាតក ១៣ សន្លឹក. . . . . . . . . . . . . . | — | ០, ១៥ |
| " មហាជនកជាតក ១៣ សន្លឹក . . . . . . . . . . | — | ០, ១៥ |
| " សុវណ្ណសាមជាតក ១៣ " . . . . . . . . . . . . | — | ០, ១៥ |
| រូបសម្តេចព្រះវររាជជននី. . . . . . . . . . . . . . . . . . | — | ០, ០២ |
| ប្រក្រតិទិនឆ្នាំថ្មី. . . . . . . . . . . . . . . . . . . . | — | ០, ១៥ |

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'E... ...NT

IMPRIMERIE ROYALE